ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

CADA
Cambodia Anti-Doping Agency

# វិធានរបស់គណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជា

## Cambodia Anti-Doping Committee Rules

# អារម្ភកថា

ក្រសួងអប់រំ យុវជន និងកីឡាសូមសម្តែងការអបអរសាទរ និងស្វាគមន៍យ៉ាងកក់ក្តៅបំផុតចំពោះសហព័ន្ធកីឡាជាតិ គណៈកម្មាធិការជាតិអូឡាំពិកកម្ពុជា គណៈកម្មាធិការជាតិប៉ារ៉ាឡាំពិកកម្ពុជា និងស្ថាប័នកីឡាពាក់ព័ន្ធទាំងអស់ ដែលបានសហការ និងខិតខំប្រឹងប្រែងជំរុញវិស័យកីឡាក្នុងព្រះរាជាណាចក្រកម្ពុជាឲ្យមានការរីកចម្រើនជាគួរឲ្យកត់សម្គាល់ ក្រោមការដឹកនាំដ៏ឈ្លាសវៃរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**។ ក្រសួងអប់រំ យុវជន និងកីឡាសូមថ្លែងអំណរគុណដល់ គ្រូបង្វឹក អត្តពលិក ជម្រើសជាតិកម្ពុជាទាំងអស់ ដែលបានខិតខំប្រឹងប្រែងហ្វឹកហាត់ និងដណ្តើមមេដាយជូនជាតិក្នុងការប្រកួតកម្រិតពិភពលោក កម្រិតអាស៊ី កម្រិតអាស៊ាន និងការប្រកួតលក្ខណៈអន្តរជាតិផ្សេងៗនានា ដោយមិនមានការប្រើប្រាស់សារធាតុ ឬ វិធីសាស្រ្តហាមឃាត់ក្នុងវិស័យកីឡា ដែលនាំមកនូវកិត្តិយសដ៏ឧត្តុង្គឧត្តមជូនមាតុភូមិ។

ដោយសារព្រះរាជាណាចក្រកម្ពុជា ជារដ្ឋភាគីនៃអនុសញ្ញាអន្តរជាតិប្រឆាំងដូប៉ាក្នុងវិស័យកីឡា ហើយក៏ជាសមាជិករបស់ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក (WADA) និងអង្គការប្រឆាំងដូប៉ាតំបន់អាស៊ីអាគ្នេយ៍ (SEARADO) កម្ពុជាមានកាតព្វកិច្ចគោរពអនុសញ្ញាអន្តរជាតិប្រឆាំងដូប៉ា និងអនុវត្តតាមក្រមទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក។ ក្នុងន័យនេះ ក្រសួងអប់រំ យុវជន និងកីឡាចូលរួមចំណែកយ៉ាងសកម្មប្រយុទ្ធប្រឆាំងសារធាតុ និងវិធីសាស្រ្តហាមឃាត់ក្នុងវិស័យកីឡា តាមរយៈគណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជា ដើម្បីធានាសុវត្ថិភាព និងសុខុមាលភាពអត្តពលិក ព្រមទាំងផ្តល់ភាពស្អាតស្អំ (Clean Athletes) ជូនអត្តពលិក និងនាំឲ្យមានកីឡាស្អាតស្អំ (Clean Sports) នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ក្រសួងអប់រំ យុវជន និងកីឡាប្តេជ្ញាចិត្តខ្ពស់ក្នុងការលើកទឹកចិត្ត និងបន្តគាំទ្រសកម្មភាពប្រឆាំងដូប៉ារបស់គណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជា ដែលបានបង្កើត **វិធានប្រឆាំងដូប៉ា** អនុលោមទៅតាមក្រមប្រឆាំងដូប៉ាពិភពលោកឆ្នាំ២០២១ (WADA Code 2021) ដើម្បីដាក់ឲ្យសហព័ន្ធកីឡាជាតិ និងស្ថាប័នកីឡាពាក់ព័ន្ធទាំងអស់គោរព និងអនុវត្ត។ គោលបំណងនៃការបង្កើត និងដាក់ឲ្យអនុវត្ត **វិធានប្រឆាំងដូប៉ា** នេះ គឺដើម្បីធានាការប្រកួតកីឡាទាំងអស់ប្រព្រឹត្តទៅប្រកបដោយ យុត្តិធម៌ តម្លាភាព សុចរិត ហើយលទ្ធផលទទួលបាន គឺគ្មានការប្រើប្រាស់សារធាតុ ឬវិធីសាស្រ្តហាមឃាត់ ដើម្បីបង្កើនសមត្ថភាព អត្តពលិក ឬគុណផលកីឡា។

ក្រសួងអប់រំ យុវជន និងកីឡាសង្ឃឹមយ៉ាងមុតមាំថា សហព័ន្ធកីឡាជាតិ គណៈកម្មាធិការជាតិអូឡាំពិកកម្ពុជា គណៈកម្មាធិការជាតិប៉ារ៉ាឡាំពិកកម្ពុជា គ្រូបង្វឹក អត្តពលិក បុគ្គលគាំពារអត្តពលិក និងស្ថាប័នកីឡាពាក់ព័ន្ធទាំងអស់ នឹងចូលរួមអនុវត្តតាមខ្លឹមសារនៃវិធានប្រឆាំងដូប៉ានេះ ប្រកបដោយប្រសិទ្ធភាពខ្ពស់បំផុត។

ថ្ងៃ [illegible] ខែ ស្រាពណ៍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ សីហា ឆ្នាំ២០២១

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

# មាតិកា


ប្រការ ១៖ និយមន័យដូប៉ា ........................................................................ ៧

ប្រការ២៖ ការប្រព្រឹត្តបំពាននឹងវិធានប្រឆាំងដូប៉ា ........................................................................ ៧

ប្រការ ៣៖ ការបង្ហាញភស្តុតាងដូប៉ា ........................................................................ ១០

ប្រការ ៤៖ បញ្ជីហាមឃាត់ ........................................................................ ១២

ប្រការ ៥៖ ការធ្វើតេស្ត និងការស៊ើបអង្កេត ........................................................................ ១៨

ប្រការ ៦៖ ការវិភាគសំណាក ........................................................................ ២២

ប្រការ ៧៖ ការដោះស្រាយវិវាទដូប៉ា ការទទួលខុសត្រូវ ការត្រួតពិនិត្យបឋម ការជូនដំណឹង និងការព្យួរសិទ្ធិបណ្តោះអាសន្ន ........................................................................ ២៤

ប្រការ ៨៖ ការដោះស្រាយវិវាទដូប៉ា៖ សិទ្ធិទទួលបានសវនាការយុត្តិធម៌ និងការជូនដំណឹងអំពីសេចក្តីសម្រេចរបស់សវនាការ ........................................................................ ២៨

ប្រការ៩៖ ការបដិសេធលទ្ធផលប្រកួតដោយស្វ័យប្រវត្តិ ........................................................................ ៣១

ប្រការ១០៖ ការដាក់ទណ្ឌកម្មលើបុគ្គល ........................................................................ ៣១

ប្រការ១១៖ ទណ្ឌកម្មសម្រាប់ក្រុម ........................................................................ ៤៣

ប្រការ១២៖ ការដាក់ទណ្ឌកម្មដោយគណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជាលើស្ថាប័នកីឡាផ្សេងទៀត ....... ៤៣

ប្រការ១៣៖ ការដោះស្រាយវិវាទដូប៉ា៖ការប្តឹងជំទាស់ ........................................................................ ៤៤

ប្រការ១៤៖ ការរក្សាការសម្ងាត់ និងការរាយការណ៍ ........................................................................ ៥១

ប្រការ១៥៖ ការអនុវត្តសេចក្តីសម្រេច ........................................................................ ៥៥

ប្រការ១៦៖ អាជ្ញាយុកាល ........................................................................ ៥៧

ប្រការ១៧៖ ការអប់រំ ........................................................................ ៥៧

ប្រការ១៨៖ មុខងារ និងការទទួលខុសត្រូវបន្ថែមរបស់សហព័ន្ធកីឡាជាតិ ........................................................................ ៥៧

ប្រការ១៩៖ មុខងារ និងការទទួលខុសត្រូវបន្ថែមរបស់គណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជា ........................ ៥៨

ប្រការ ២០៖ តួនាទី និងការទទួលខុសបន្ថែមត្រូវរបស់អត្តពលិក ........................................................................ ៥៩

ប្រការ២១៖ តួនាទី និងការទទួលខុសត្រូវបន្ថែមរបស់បុគ្គលិកគាំពារអត្តពលិក ........................................................................ ៥៩

ប្រការ ២២៖ មុខងារ និងការទទួលខុសត្រូវបន្ថែមរបស់បុគ្គលផ្សេងទៀត ដែលស្ថិតក្រោមវិធានប្រឆាំងដូប៉ាទាំងនេះ ........................................................................ ៦០

ប្រការ២៣៖ ការបកស្រាយក្រុម ........................................................................ ៦០

ប្រការ២៤៖ អវសានប្បញ្ញត្តិ ........................................................................ ៦១

ឧបសម្ព័ន្ធ ៖ និយមន័យ ........................................................................ ៦៤

វិធានរបស់គណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជា

សេចក្តីផ្តើម

វិធានប្រឆាំងដូប៉ានេះត្រូវបានអនុម័ត និងអនុវត្តដោយអនុលោមតាមការទទួលខុសត្រូវ របស់គណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជា អនុលោមតាមក្រម និងក្នុងក្របខ័ណ្ឌនៃកិច្ចខិតខំប្រឹងប្រែងបន្តអនុវត្តការលុបបំបាត់ដូប៉ាក្នុងវិស័យកីឡានៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ទាំងនេះគឺជាវិធានកីឡាដែលគ្រប់គ្រងលក្ខខណ្ឌនៃការលេងកីឡា។ ដោយផ្តោតលើការអនុវត្តវិធានប្រឆាំងដូប៉ាក្នុងលក្ខណៈសកល និងសុខដុមនីយកម្មជាមួយគ្នា វាមានលក្ខណៈដោយឡែកក្នុងទិដ្ឋភាពច្បាប់ព្រហ្មទណ្ឌ និងរដ្ឋប្បវេណី។ វាមិនមែនសម្រាប់ជាកម្មវត្ថុ ឬត្រូវបានកំហិតដោយលក្ខខណ្ឌតម្រូវ និងបទដ្ឋានគតិយុត្តរបស់ជាតិដែលត្រូវដាក់ឱ្យបានអនុវត្តចំពោះនីតិវិធីព្រហ្មទណ្ឌ ឬរដ្ឋប្បវេណីទេ ទោះបីជាគោលបំណងរបស់វាគឺដើម្បីអនុវត្តតាមរបៀបដែលគោរពគោលការណ៍សមាមាត្រ និងសិទ្ធិមនុស្សក៏ដោយ។ នៅពេលដែលធ្វើការពិនិត្យអង្គហេតុ និងអង្គច្បាប់នៃករណីជាក់លាក់ណាមួយ គ្រប់តុលាការ ស្ថាប័នមជ្ឈតកម្ម និងស្ថាប័នវិនិច្ឆ័យផ្សេងទៀតត្រូវយល់ដឹង និងគោរពលក្ខណៈពិសេសដោយឡែកនៃវិធានប្រឆាំងដូប៉ានេះ ដែលអនុវត្តក្រមព្រមទាំងការពិតដែលថា វិធានទាំងនេះតំណាងឱ្យការព្រមព្រៀងទាំងអស់គ្នារបស់ភាគីពាក់ព័ន្ធ នៅទូទាំងពិភពលោក លើអ្វីដែលជាតម្រូវការចាំបាច់ ដើម្បីឱ្យមានការគោរព និងធានាបាននូវការលេងកីឡាដោយយុត្តិធម៌។

ដូចអ្វីដែលមានចែងក្នុងក្រម គណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជា ត្រូវទទួលខុសត្រូវលើគ្រប់ទិដ្ឋភាព នៃការត្រួតពិនិត្យដូប៉ា។ រាល់ទិដ្ឋភាពនៃការត្រួតពិនិត្យសារជាតុដូប៉ា ឬការអប់រំស្តីពីការប្រឆាំង ដូប៉ាអាចត្រូវបានធ្វើប្រតិភូកម្ម ដោយគណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជា ទៅឱ្យតតិយជនណាមួយ។ តែទោះជាយ៉ាងណាក៏ដោយ គណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជា មានកាតព្វកិច្ចតម្រូវឱ្យតតិយជនទាំងអស់អនុវត្តនូវទិដ្ឋភាពទាំងនោះដោយអនុលោមតាមក្រម ស្តង់ដារអន្តរជាតិ និងវិធានប្រឆាំងដូប៉ានេះ។ គណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជា នៅតែមានទំនួលខុសត្រូវទាំងស្រុងចំពោះការធានា ថាគ្រប់ទិដ្ឋភាពនៃការងារដែលត្រូវបានធ្វើប្រតិភូកម្មត្រូវបានអនុវត្តដោយអនុលោមតាមក្រម ។

មូលដ្ឋានគ្រឹះនៃក្រម និងវិធានប្រឆាំងដូប៉ារបស់គណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជា

កម្មវិធីប្រឆាំងដូប៉ាត្រូវបានបង្កើតឡើងជាគុណតម្លៃភ្ជាប់នឹងកីឡា។ គុណតម្លៃនេះត្រូវ បានហៅថា "ស្មារតីកីឡា"៖ ការខិតខំប្រឹងប្រែងប្រកបដោយវិជ្ជាជីវៈ ដើម្បីសម្រេចបាននូវឧត្តមភាពរបស់មនុស្ស តាមរយៈភាពឥតខ្ចោះនៃទេពកោសល្យធម្មជាតិរបស់អត្តពលិកនីមួយៗ។

កម្មវិធីប្រឆាំងដូប៉ាមានបំណងការពារសុខភាពរបស់អត្តពលិក និងផ្តល់ឱកាសដល់អត្តពលិកឱ្យសម្រេចបាននូវឧត្តមភាពរបស់មនុស្ស ដោយគ្មានការប្រើប្រាស់សារជាតុ និងវិធីសាស្ត្រដែលត្រូវបានហាមឃាត់។

កម្មវិធីប្រឆាំងដូប៉ាក៏មានបំណងការពារសុចរិតភាពកីឡា តាមរយៈការគោរពច្បាប់ ការគោរពគូប្រកួតផ្សេងទៀត ការប្រកួតដោយយុត្តិធម៌ ក្នុងមូលដ្ឋានស្មើគ្នា និងគុណតម្លៃនៃកីឡាដែលមានភាពស្អាតស្អំសម្រាប់ពិភពលោក។

ស្មារតីកីឡាគឺជាការសាទរស្មារតី រាងកាយ និងសតិបញ្ញារបស់មនុស្សជាតិ។ វាជាស្នូលនៃកីឡាអូឡាំពិក ហើយដែលត្រូវបានឆ្លុះបញ្ចាំងក្នុងគុណតម្លៃដែលយើងឃើញនៅក្នុង និងតាមរយៈកីឡា ដូចមានរៀបរាប់ខាងក្រោម៖

- សុខភាព
- សីលធម៌ ការប្រកួតដោយយុត្តិធម៌ និងភាពស្មោះត្រង់
- សិទ្ធិរបស់អត្តពលិកដូចបានកំណត់ក្នុងក្រម
- ឧត្តមភាពនៃសមត្ថភាព
- ចរិតលក្ខណៈ និងការអប់រំ
- ភាពសប្បាយរីករាយ និងសេចក្តីត្រេកអរ
- ការងារជាក្រុម
- ការលះបង់ និងការប្តេជ្ញាចិត្ត
- ការគោរពច្បាប់ និងបទប្បញ្ញត្តិ
- ការគោរពចំពោះខ្លួនឯង និង អ្នកចូលរួមដទៃទៀត
- ភាពក្លាហាន
- សហគម និងសាមគ្គីភាព

ស្មារតីកីឡាត្រូវបានបង្ហាញនៅក្នុងរបៀបនៃការប្រកួតកីឡាដោយត្រឹមត្រូវ។

ដូប៉ាគឺផ្ទុយទាំងស្រុងទៅនឹងស្មារតីកីឡា។

កម្មវិធីថ្នាក់ជាតិប្រឆាំងដូប៉ា

គណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជា ត្រូវបានបង្កើតឡើងដោយរាជរដ្ឋាភិបាលកម្ពុជា ដើម្បីដើរតួនាទីជាអង្គការជាតិប្រឆាំងដូប៉ាសម្រាប់ប្រទេសកម្ពុជា។ ដូច្នេះយោងតាមប្រការ ២០.៥.១ នៃក្រម គណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជា មានសិទ្ធិអំណាច និងការទទួលខុសត្រូវឯករាជ្យពីស្ថាប័នកីឡា និងរដ្ឋាភិបាល ក្នុងការសម្រេចធ្វើប្រតិបត្តិការរបស់ខ្លួន។ ឯករាជ្យភាពនេះរួមបញ្ចូលទាំងការហាមឃាត់ការជ្រៀតជ្រែក ក្នុងកិច្ចការគ្រប់គ្រង ឬប្រតិបត្តិការពីសហព័ន្ធកីឡាអន្តរជាតិ សហព័ន្ធកីឡាជាតិ ស្ថាប័នរៀបចំព្រឹត្តិការណ៍កីឡាធំៗ គណៈកម្មធិការជាតិអូឡាំពិក គណៈកម្មាធិការជាតិប៉ារ៉ាឡាំពិក ឬស្ថាប័នរដ្ឋដែលទទួលខុសត្រូវផ្នែកកីឡា ឬទទួលខុសត្រូវលើការប្រឆាំងដូប៉ា។

វិសាលភាពនៃវិធានប្រឆាំងដូប៉ា

វិធានប្រឆាំងដូប៉ានេះត្រូវអនុវត្តចំពោះ ៖

(ក) គណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជា រួមបញ្ចូលទាំងសមាជិកក្រុមប្រឹក្សាភិបាល ប្រធាន មន្ត្រី បុគ្គលិក និងប្រតិភូកម្មទៅភាគីទី៣ ព្រមទាំងបុគ្គលិករបស់ខ្លួនដែលជាប់ពាក់ព័ន្ធនឹងទិដ្ឋភាពណាមួយនៃការត្រួតពិនិត្យសារធាតុដូប៉ា។

(ខ) សហព័ន្ធកីឡាជាតិកម្ពុជា រួមបញ្ចូលទាំងក្រុមប្រឹក្សាភិបាល ប្រធាន មន្ត្រី បុគ្គលិក និងប្រតិភូកម្មទៅភាគីទី៣ ព្រមទាំងបុគ្គលិករបស់ស្ថាប័នទាំងនេះដែលជាប់ពាក់ព័ន្ធនឹងទិដ្ឋភាពណាមួយនៃការត្រួតពិនិត្យសារធាតុដូប៉ា។

(គ) អត្តពលិក អ្នកគាំពារអត្តពលិក និងបុគ្គលផ្សេងទៀតដូចខាងក្រោម (រួមទាំងអ្នកដែលត្រូវបានការពារ) ក្នុងករណីនីមួយៗ ទោះបីជាបុគ្គលនោះជាជនជាតិខ្មែរ ឬមានលំនៅដ្ឋានក្នុងប្រទេសកម្ពុជា ឬអត់ក៏ដោយ។

    (i) គ្រប់អត្តពលិក និងអ្នកគាំពារអត្តពលិក ដែលជាសមាជិក ឬអ្នកមានអាជ្ញាប័ណ្ណសហព័ន្ធកីឡាជាតិណាមួយនៅក្នុងប្រទេសកម្ពុជា ឬជាសមាជិក ឬ អង្គការសម្របសម្រួលនៃសហព័ន្ធកីឡាជាតិក្នុងប្រទេសកម្ពុជា (រួមទាំងក្លឹប ក្រុម សមាគម និងលីគ)។

(ii) គ្រប់អត្តពលិក និងអ្នកគាំពារអត្តពលិកដែលបានចូលរួមព្រឹត្តិការណ៍ដូចជា ការប្រកួត និងសកម្មភាពផ្សេងទៀត រៀបចំដោយសហព័ន្ធកីឡាជាតិណាមួយនៅក្នុងប្រទេសកម្ពុជា ឬជាសមាជិកនៃអង្គការសម្របសម្រួល នៃសហព័ន្ធកីឡាជាតិណាមួយទោះជានៅកន្លែងណាមួយនៃប្រទេសកម្ពុជា (រួមទាំងក្លឹប ក្រុម សមាគម និងលីគ)។

(iii) អត្តពលិកណាម្នាក់ អ្នកគាំពារអត្តពលិក ឬបុគ្គលណាម្នាក់ តាមរយៈការទទួលស្គាល់ អាជ្ញាប័ណ្ណ ឬកិច្ចសន្យាផ្សេងទៀត ដែលស្ថិតនៅក្រោមអំណាចនៃសហព័ន្ធកីឡាជាតិក្នុងប្រទេសកម្ពុជា ឬជាសមាជិកនៃអង្គការសម្របសម្រួលរបស់សហព័ន្ធកីឡាជាតិណាមួយនៅក្នុងប្រទេសកម្ពុជា (រួមទាំងក្លឹប ក្រុម សមាគម និងលីគ) ក្នុងបុព្វហេតុប្រឆាំងដូប៉ា។

(iv) គ្រប់អត្តពលិក និងអ្នកគាំពារអត្តពលិកដែលចូលរួមក្នុងសមាសភាពណាក៏ដោយ ក្នុងសកម្មភាពណាមួយដែលរៀបចំប្រារព្ធឡើង ប្រព្រឹត្តទៅ ឬអនុញ្ញាតដោយស្ថាប័នរៀបចំព្រឹត្តិការណ៍កីឡាជាតិ ឬដោយក្រុមកីឡាជាតិដែលមិនមានការពាក់ព័ន្ធសហព័ន្ធកីឡាជាតិ។

(v) អត្តពលិកកម្សាន្តដូចជាបុគ្គលណាម្នាក់ដែលពាក់ព័ន្ធ ឬចូលរួមក្នុងសកម្មភាពកីឡា ឬក្នុងគោលបំណងកម្សាន្តប៉ុន្តែមិនមែនជាអ្នកចូលរួមក្នុងការប្រកួត ឬក្នុងព្រឹត្តិការណ៍កីឡាណាមួយដែលត្រូវបានរៀបចំទទួលស្គាល់ ឬធ្វើជាម្ចាស់ផ្ទះដោយសហព័ន្ធកីឡាជាតិ ឬដោយសមាគម អង្គការ ក្លឹប ក្រុម ឬលីគដែលពាក់ព័ន្ធ ឬមិនពាក់ព័ន្ធក្តី និងដែលក្នុងរយៈពេល ០៥(ប្រាំ)ឆ្នាំ មុនពេលប្រព្រឹត្តបំពានវិធានប្រឆាំងដូប៉ា ដែលមិនមែនជាអត្តពលិកកម្រិតអន្តរជាតិ (ដូចដែលបានកំណត់ដោយសហព័ន្ធកីឡាអន្តរជាតិ ស្របនឹងស្តង់ដារអន្តរជាតិស្តីពីការធ្វើតេស្ត និងការស៊ើបអង្កេត) ឬមិនមែនជាអត្តពលិកកម្រិតថ្នាក់ជាតិ (ដូចដែលបានកំណត់ដោយគណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជា ឬអង្គការជាតិប្រឆាំងដូប៉ា ស្របនឹងស្តង់ដារអន្តរជាតិស្តីពីការធ្វើតេស្ត និងការស៊ើបអង្កេត) ដែលមិនតំណាងឱ្យប្រទេសកម្ពុជា ឬប្រទេសណាមួយក្នុងកម្រិតនៃព្រឹត្តិការណ៍អន្តរជាតិចំពោះប្រភេទព្រឹត្តិការណ៍កីឡាបើកចំហ ឬមិនធ្លាប់បានជាប់ឈ្មោះក្នុងបញ្ជីឈ្មោះធ្វើតេស្ត ឬក្នុងបញ្ជីព័ត៌មានអំពីទីសំចត ដែលត្រូវបានរក្សាទុកដោយសហព័ន្ធកីឡាអន្តរជាតិ គណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជា ឬដោយអង្គការជាតិប្រឆាំងដូប៉ា។

(ឃ) គ្រប់បុគ្គលដែលក្រម ផ្តល់សិទ្ធិអំណាចដល់ គណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជា រួមបញ្ចូលគ្រប់អត្តពលិកដែលមានសញ្ជាតិខ្មែរ និងមានទីលំនៅក្នុងប្រទេសកម្ពុជា និងគ្រប់បុគ្គលិកទាំងអស់ដែលមានវត្តមាននៅក្នុងប្រទេសកម្ពុជា ទោះក្នុងបំណងប្រកួតប្រជែង ឬហ្វឹកហាត់ ឬបំណងផ្សេងទៀតក៏ដោយ។

ក្រោមលក្ខខណ្ឌនៃការចូលរួមរបស់ពួកគេក្នុងវិស័យកីឡាក្នុងប្រទេសកម្ពុជា គ្រប់បុគ្គលទាំងអស់ដូចបានរៀបរាប់ខាងលើត្រូវបានចាត់ទុកថាបានយល់ព្រម និងចងកាតព្វកិច្ចក្រោមវិធានប្រឆាំងដូប៉ានេះ និងយល់ព្រមគោរពតាមសិទ្ធិអំណាចរបស់គណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជារួមបញ្ចូលទាំងទណ្ឌកម្មណាមួយចំពោះការបំពាន និងយុត្តាធិការរបស់ក្រុមប្រឹក្សាជំនុំជម្រះ ដូចដែលបានចែងក្នុងប្រការ ៨ និងប្រការ ១៣ ដើម្បីស្តាប់ និងកំណត់ករណី និងបណ្តឹងជំទាស់នានា ដែលបានធ្វើឡើងក្រោមវិធានប្រឆាំងដូប៉ានេះ។

នៅក្នុងបញ្ជីរួមនៃអត្តពលិក ដូចដែលបានលើកឡើងខាងលើ ដែលត្រូវបានចងភ្ជាប់កាតព្វកិច្ច និងតម្រូវឱ្យអនុវត្តតាមវិធានប្រឆាំងដូប៉ានេះ អត្តពលិកខាងក្រោមត្រូវបានចាត់ទុកជាអត្តពលិកថ្នាក់ជាតិសម្រាប់គោលបំណងនៃវិធានប្រឆាំងដូប៉ានេះ ដូច្នេះបញ្ញត្តិជាក់លាក់នៃវិធានប្រឆាំងដូប៉ានេះនឹងត្រូវអនុវត្តចំពោះអត្តពលិកថ្នាក់ជាតិ ដូចជាការ (ការធ្វើតេស្ត ការលើកលែងឱ្យប្រើប្រាស់ថ្នាំព្យាបាល ព័ត៌មានអំពីទីសំចត និងការដោះស្រាយវិវាទដូប៉ា) ត្រូវអនុវត្តចំពោះអត្តពលិកដូចខាងក្រោម ៖

(ក) អត្តពលិកទាំងឡាយណាដែលជាសមាជិក ឬមានកាតសហព័ន្ធកីឡាជាតិណាមួយនៅក្នុងប្រទេសកម្ពុជា ឬអង្គការផ្សេងទៀតណាមួយដែលពាក់ព័ន្ធនឹងសហព័ន្ធកីឡាជាតិ រួមទាំងសមាគម ក្លឹប ក្រុម និងលីគ។

(ខ) អត្តពលិកណាមួយដែលបានចូលរួមក្នុងការប្រកួត ព្រឹត្តការណ៍កីឡា ឬសកម្មភាពដែលបានរៀបចំឡើង ទទួលស្គាល់ ឬធ្វើជាម្ចាស់ផ្ទះដោយសហព័ន្ធកីឡាជាតិ ឬសមាគម អង្គការ ក្លឹប ក្រុម លីគណាមួយ ឬដោយរដ្ឋាភិបាលកម្ពុជា។

(គ) អត្តពលិកដែលមានការទទួលស្គាល់ អាជ្ញាប័ណ្ណ ឬមានកិច្ចសន្យាផ្សេងទៀតដែលស្ថិតក្នុងសមត្ថភាពរបស់សហព័ន្ធកីឡាជាតិនៅកម្ពុជា ឬសមាគម អង្គការ ក្រុម ឬលីគណាមួយនៅក្នុងប្រទេសកម្ពុជា គោលបំណងប្រយុទ្ធប្រឆាំងដូប៉ានៅក្នុងវិស័យកីឡាក្នុងប្រទេសកម្ពុជា។

(ឃ) អត្តពលិកដែលចូលរួមក្នុងសកម្មភាពណាមួយ ដែលរៀបចំឡើងដោយស្ថាប័នរៀបចំព្រឹត្តិការណ៍កីឡាជាតិណាមួយ ឬក្រុមដែលមិនមានទំនាក់ទំនងជាមួយសហព័ន្ធកីឡាជាតិ។

ទោះជាយ៉ាងណាក៏ដោយ ប្រសិនបើអត្តពលិកណាម្នាក់ត្រូវបានសហព័ន្ធកីឡាអន្តរជាតិ ក្នុងប្រទេសរៀងៗខ្លួនចាត់ថ្នាក់ថាជាអត្តពលិកកម្រិតអន្តរជាតិនោះ ពួកគេនឹងត្រូវបានចាត់ទុកថាជាអត្តពលិកកម្រិតអន្តរជាតិ (មិនមែនអត្តពលិកកម្រិតជាតិទេ) សម្រាប់គោលបំណងនៃវិធានប្រឆាំងដូប៉ានេះ។

ប្រការ១៖ និយមន័យដូប៉ា

បដូប៉ាត្រូវបានផ្តល់និយមន័យថាជាការប្រព្រឹត្តិបំពានវិធានប្រឆាំងដូប៉ាមួយ ឬច្រើន ដូចដែលបានចែងក្នុងប្រការ ២.១ រហូតដល់ប្រការ ២.១១ នៃវិធានប្រឆាំងដូប៉ានេះ។

ប្រការ២៖ ការប្រព្រឹត្តបំពាននឹងវិធានប្រឆាំងដូប៉ា

គោលបំណងនៃប្រការ ២ គឺដើម្បីកំណត់ស្ថានភាព និងការអនុវត្តដែលត្រូវបានចាត់ទុកថាការប្រព្រឹត្តិបំពានវិធានប្រឆាំងដូប៉ា។ សវនាការក្នុងសំណុំរឿងសារធាតុដូប៉ាត្រូវផ្អែកទៅលើការបង្ហាញថាមានការប្រព្រឹត្តិបំពានវិធានជាក់លាក់មួយ ឬច្រើន។

អត្តពលិក និងបុគ្គលផ្សេងទៀត ត្រូវទទួលខុសត្រូវស្វែងយល់អំពីថាតើអ្វីដែលត្រូវបានចាត់ទុកថាជាសកម្មភាពបំពានវិធានប្រឆាំងដូប៉ានេះ ព្រមទាំងស្វែងយល់ពីសារធាតុ ឬវិធីសាស្ត្រហាមឃាត់ដូចដែលមានចែងក្នុងបញ្ជីសារធាតុហាមឃាត់។

លក្ខខណ្ឌខាងក្រោមត្រូវបានចាត់ទុកថាជាការប្រព្រឹត្តិបំពាននឹងវិធានប្រឆាំងដូប៉ា៖

២.១ វត្តមាននៃសារធាតុហាមឃាត់ ឬសារធាតុមេតាបូលីស ឬសារធាតុបិទបាំងនៅក្នុងសំណាករបស់អត្តពលិក

២.១.១ វាជាភារកិច្ចផ្ទាល់ខ្លួនរបស់អត្តពលិកម្នាក់ៗ ដែលត្រូវធានាថាក្នុងខ្លួនរបស់គេម្នាក់ៗ មិនមានសារធាតុហាមឃាត់។ អត្តពលិកម្នាក់ៗ ត្រូវទទួលខុសត្រូវលើសារធាតុហាមឃាត់ ឬសារធាតុមេតាបូលីស ឬសារធាតុបិទបាំងនៅក្នុងសំណាករបស់ខ្លួន។ ដូច្នេះ វាមិនសំខាន់ថាតើ វាជាការប្រព្រឹត្តិដោយចេតនាជាកំហុស ឬការធ្វេសប្រហែសនោះទេ ឱ្យតែរកឃើញថាមានសារធាតុហាមឃាត់នៅក្នុងសំណាករបស់អត្តពលិកនោះ វានឹងត្រូវបានចាត់ទុកថាជាការប្រព្រឹត្តិបំពានក្រោមប្រការ ២.១ នៃវិធានប្រឆាំងដូប៉ា។

២.១.២ ភស្តុតាងគ្រប់គ្រាន់បញ្ជាក់ពីការប្រព្រឹត្តិបំពានវិធានប្រឆាំងដូប៉ាក្រោមប្រការ ២.១ នេះ ត្រូវបានកំណត់ដោយលក្ខខណ្ឌណាមួយខាងក្រោម ៖ មានវត្តមាននៃសារធាតុហាមឃាត់ ឬសារធាតុមេតាបូលីស ឬសារធាតុ

បិទបាំងនៅក្នុងសំណាក (ក) របស់អត្តពលិក ក្នុងករណីដែលអត្តពលិកបោះបង់ការវិភាគសំណាក (ខ) ហើយសំណាក (ខ) មិនត្រូវបានវិភាគ ឬក្នុងករណីដែលសំណាក (ខ) របស់អត្តពលិកត្រូវបានវិភាគ ហើយលទ្ធផលនៃសំណាក (ខ) នោះបញ្ជាក់ពីវត្តមានសារធាតុហាមឃាត់ សារធាតុមេតាបូលីស ឬសារធាតុបិទបាំងដែលបានរកឃើញនៅក្នុងសំណាក (ក) របស់អត្តពលិក ឬក្នុងករណីដែលសំណាក (ក) និងសំណាក (ខ) របស់អត្តពលិកត្រូវបានបែងចែកជាពីរផ្នែក ហើយលទ្ធផលនៃការវិភាគបំណែកណាមួយបញ្ជាក់ថាមានវត្តមាននៃសារធាតុហាមឃាត់ សារធាតុមេតាបូលីស ឬសារធាតុបិទបាំង ត្រូវបានរកឃើញនៅក្នុងបំណែកទី១ ឬអត្តពលិកបោះបង់ការវិភាគបំណែកដែលបញ្ជាក់ថាមានសារធាតុហាមឃាត់។

២.១.៣ ការលើកលែងចំពោះសារធាតុ ដែលត្រូវបានកំពុងកម្រិតនៃសេចក្តីសម្រេចក្នុងបញ្ជីហាមឃាត់ ឬឯកសារបច្ចេកទេស វត្តមាននៃសារធាតុហាមឃាត់ ឬសារធាតុមេតាបូលីស ឬសារធាតុបិទបាំងក្នុងសំណាករបស់អត្តលិកដែលចាត់ទុកថាជាការប្រព្រឹត្តិបំពានវិធានប្រឆាំងដូប៉ា។

២.១.៤ ជាការលើកលែងចំពោះវិធានទូទៅនៃប្រការ ២.១ បញ្ជីហាមឃាត់ ស្តង់ដារអន្តរជាតិ ឬឯកសារបច្ចេកទេសអាចបង្កើត លក្ខខណ្ឌវិនិច្ឆ័យពិសេសសម្រាប់ការរាយការណ៍ ឬការវាយតម្លៃលើសារធាតុហាមឃាត់ជាក់លាក់។

២.២ ការប្រើប្រាស់ ឬការប៉ុនប៉ងប្រើប្រាស់សារធាតុហាមឃាត់ ឬវិធីសាស្ត្រហាមឃាត់ដោយអត្តពលិក

២.២.១ វាជាភារកិច្ចផ្ទាល់ខ្លួនរបស់អត្តពលិកម្នាក់ៗ ដែលត្រូវធ្វើឱ្យប្រាកដថាគ្មានសារធាតុហាមឃាត់នៅក្នុងខ្លួន និងគ្មានវិធីសាស្ត្រហាមឃាត់ណាមួយ ដែលខ្លួនបានប្រើប្រាស់ឡើយ។ ដូច្នេះ វាមិនសំខាន់ទេថាតើវាជាចេតនាកំហុស ការធ្វេសប្រហែសឬជាការប្រើប្រាស់ដោយដឹងមុនរបស់អត្តពលិក ដរាបណាមានការបង្ហាញថាមានការប្រព្រឹត្តិបំពានវិធានប្រឆាំងដូប៉ា ចំពោះការប្រើប្រាស់សារធាតុហាមឃាត់ ឬវិធីសាស្ត្រហាមឃាត់។

២.២.២ វាមិនសំខាន់ទេថាតើ ការប្រើប្រាស់ ឬការប៉ុនប៉ងប្រើប្រាស់សារធាតុហាមឃាត់ ឬវិធីសាស្ត្រហាមឃាត់ទទួលបានជោគជ័យ ឬមិនជោគជ័យនោះ។ វាមានភាពគ្រប់គ្រាន់ហើយដែលសារធាតុហាមឃាត់ ឬវិធីសាស្ត្រហាមឃាត់ត្រូវបានប្រើប្រាស់ ឬប៉ុនប៉ងប្រើប្រាស់សម្រាប់កំណត់ថាមានការបំពានវិធានប្រឆាំងដូប៉ា។

២.៣ ការគេចវេស ការបដិសេធ ឬការខកខានក្នុងការផ្តល់សំណាករបស់អត្តពលិក

ការគេចវេសពីការប្រមូលសំណាក ឬការបដិសេធ ឬការខកខានមិនបានផ្តល់សំណាករបស់អត្តពលិកដោយមិនបានបញ្ជាក់ពីមូលហេតុច្បាស់លាស់ បន្ទាប់ពីការជូនដំណឹងដោយបុគ្គលដែលមានសមត្ថកិច្ចក្នុងការប្រមូលសំណាក។

២.៤ ការខកខានមិនបានផ្តល់ព័ត៌មានអំពីទីសំចតដោយអត្តពលិក

កត្តារួមផ្សំណាមួយនៃការខកខានមិនបានធ្វើតេស្ត និង/ឬមិនបានបំពេញព័ត៌មានត្រឹមត្រូវ ចំនួន ៣(បី)ដងដូចដែលបានកំណត់ក្នុងស្តង់ដារអន្តរជាតិស្តីពីការដោះស្រាយវិវាទដូប៉ាក្នុងរយៈពេល ១២(ដប់ពីរ)ខែដោយអត្តពលិកដែលមានឈ្មោះក្នុងបញ្ជីឈ្មោះធ្វើតេស្ត។

២.៥ ការរំខានធ្វើឱ្យខូចដំណើរការ ឬប៉ុនប៉ងរំខានទៅលើផ្នែកណាមួយនៃដំណើរការត្រួតពិនិត្យសារធាតុដូប៉ាដោយអត្តពលិក ឬពីបុគ្គលផ្សេងទៀត

២.៦ ការកាន់កាប់សារធាតុហាមឃាត់ និងវិធីសាស្ត្រហាមឃាត់ដោយអត្តពលិក ឬអ្នកគាំពារអត្តពលិក

២.៦.១ ការកាន់កាប់សារធាតុហាមឃាត់ ឬប្រើវិធីសាស្ត្រហាមឃាត់ណាមួយ ដោយអត្តពលិក នៅក្នុងការប្រកួត និងនៅក្រៅការប្រកួត លើកលែងតែអត្តពលិកនោះបង្ហាញថាការកាន់កាប់នោះ ស្របតាមការលើកលែងឱ្យប្រើប្រាស់ថ្នាំព្យាបាល ដែលអនុញ្ញាតដោយប្រការ ៤.៤ ឬហេតុផលផ្សេងទៀតដែលអាចទទួលយកបាន។

២.៦.២ ការកាន់កាប់សារធាតុហាមឃាត់ ឬប្រើវិធីសាស្ត្រហាមឃាត់ណាមួយដោយ អ្នកគាំពារអត្តពលិនៅក្នុងការប្រកួត និងនៅក្រៅការប្រកួត ដែលត្រូវបានហាមឃាត់នៅក្រៅការប្រកួត ពាក់ព័ន្ធនឹងអត្តពលិក ការប្រកួត ឬការហ្វឹកហាត់ លើកលែងតែអ្នកគាំពារអត្តពលិកបង្ហាញថាការកាន់កាប់នោះ ស្របតាមការលើកលែងឱ្យប្រើប្រាស់ថ្នាំព្យាបាល ដែលអនុញ្ញាតសម្រាប់អត្តពលិកស្របតាម ប្រការ ៤.៤ ឬហេតុផលផ្សេងទៀតដែលអាចទទួលយកបាន ។

២.៧ ការជួញដូរ ឬការប៉ុនប៉ងជួញដូរសារធាតុហាមឃាត់ ឬវិធីសាស្ត្រហាមឃាត់ណាមួយ ដោយអត្តពលិក ឬបុគ្គលផ្សេងទៀត

២.៨ ការផ្តល់ ឬការប៉ុនប៉ងផ្តល់សារធាតុហាមឃាត់ ឬវិធីសាស្ត្រហាមឃាត់ ដោយអត្តពលិក ឬបុគ្គលផ្សេងទៀត ទៅឱ្យអត្តពលិកក្នុងការប្រកួត និងក្រៅការប្រកួត ដែលត្រូវបានហាមឃាត់នៅក្រៅការប្រកួត។

២.៩ ការរួមគំនិត ឬការប៉ុនប៉ងរួមគំនិតដោយអត្តពលិក ឬបុគ្គលផ្សេងទៀត

ការជ្រោមជ្រែង ការលើកទឹកចិត្ត ការគាំទ្រ ការញុះញង់ ការរួមគំនិត ការបិតបាំង ឬការរួមគំនិតដោយចេតនា ឬការប៉ុនប៉ងរួមគំនិត ទាក់ទងនឹងការប្រព្រឹត្តិបំពានវិធានប្រឆាំងដូប៉ា ការប៉ុនប៉ងប្រព្រឹត្តិបំពានវិធានប្រឆាំងដូប៉ា ឬការប្រព្រឹត្តិបំពាននឹងប្រការ ១០.១៤.១ ដោយបុគ្គលណាមួយផ្សេងទៀត។

២.១០ ការហាមឃាត់ ការចូលរួមពាក់ព័ន្ធរបស់អត្តពលិក ឬបុគ្គលផ្សេងទៀត

២.១០.១ ក្នុងក្របខ័ណ្ឌ វិជ្ជាជីវៈ ឬក្របខ័ណ្ឌកីឡា ទំនាក់ទំនងរបស់អត្តពលិក ឬបុគ្គលផ្សេងទៀត ត្រូវស្ថិតក្រោមសិទ្ធិអំណាចរបស់អង្គការប្រឆាំងដូប៉ា សម្រាប់ទំនាក់ទំនងរបស់ពួកគេជាមួយនឹងអ្នកគាំពារអត្តពលិកដែល៖

២.១០.១.១ ប្រសិនបើស្ថិតក្រោមសិទ្ធិអំណាចរបស់អង្គការប្រឆាំងដូប៉ា កំពុងអនុវត្តការព្យួរសិទ្ធិ។ ឬ

២.១០.១.២ ប្រសិនបើវាមិនស្ថិតក្រោមសិទ្ធិអំណាចរបស់អង្គការប្រឆាំងដូប៉ា ហើយបើការព្យួរសិទ្ធិមិនត្រូវបានដោះស្រាយក្នុងដំណើរការដោះស្រាយវិវាទដូប៉ា ស្របតាមក្រមទេនោះ ឬបើត្រូវបានកាត់ឱ្យជាប់ទោសព្រហ្មទណ្ឌ ឬត្រូវបានរកឃើញក្នុងនីតិវិធីព្រហ្មទណ្ឌវិន័យ ឬវិជ្ជាជីវៈ ថាមានជាប់ពាក់ព័ន្ធនឹងការប្រព្រឹត្តិបំពានវិធានប្រឆាំងដូប៉ា ប្រសិនបើវិធានដែលអនុលោមតាមក្រមត្រូវបានអនុវត្តចំពោះបុគ្គលនោះ។ ស្ថានភាពនៃការដកសិទ្ធិលើបុគ្គលបែបនេះនឹងត្រូវមានសុពលភាពសម្រាប់រយៈពេលរហូតដល់ ៦(ប្រាំមួយ)ឆ្នាំ ចាប់ពីពេលដែលមានសេចក្តីសម្រេចស្តីពី នីតិវិធីព្រហ្មទណ្ឌ នីតិវិធីវិន័យ ឬវិជ្ជាជីវៈនោះ ឬសម្រាប់រយៈពេលអនុវត្តទោសព្រហ្មទណ្ឌ ទណ្ឌកម្មវិន័យ ឬវិជ្ជាជីវៈនោះ ។ ឬ

២.១០.១.៣ ដើរតួជាបុគ្គលជួរមុខ ឬអន្តរការីសម្រាប់បុគ្គល ដូចដែលមានចែងក្នុងប្រការ ២.១០.១.១ ឬប្រការ ២.១០.១.២ ។

២.១០.២ ដើម្បីកំណត់ពីការប្រព្រឹត្តិបំពានប្រការ ២.១០ អង្គការប្រឆាំងដូប៉ាត្រូវកំណត់ថា អត្តពលិក ឬបុគ្គលផ្សេងទៀត យល់ដឹងពីស្ថានភាពនៃការដកសិទ្ធិរបស់អ្នកគាំពារអត្តពលិកនោះ។

បន្ទុកត្រូវស្ថិតនៅលើអត្តពលិក និងបុគ្គលផ្សេងទៀតដែលត្រូវកំណត់ថាទំនាក់ទំនងណាមួយជាមួយអ្នកគាំពារអត្តពលិក ដែលមានចែងក្នុងប្រការ ២.១០.១.១ ឬប្រការ ២.១០.១.២ គឺមិនមែនក្នុងក្របខ័ណ្ឌអាជីព ឬទាក់ទងនឹងកីឡា និង/ឬទំនាក់ទំនងបែបនោះជាទំនាក់ទំនងមិនអាចចៀសបាន ដោយហេតុផលសមរម្យ។

អង្គការប្រឆាំងដូប៉ាដែលបានមានព័ត៌មានអំពីអ្នកគាំពារអត្តពលិក ដូចដែលបានរៀបរាប់នៅក្នុងប្រការ

២.១០.១.១ ប្រការ ២.១០.១.២ ឬប្រការ ២.១០.១.៣ ត្រូវផ្តល់ព័ត៌មាននោះទៅទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក។

២.១១ សកម្មភាពរបស់អត្តពលិក ឬបុគ្គលផ្សេងទៀតក្នុងការរារាំង ឬសងសឹកចំពោះការរាយការណ៍ទៅអាជ្ញាធរ

ក្នុងករណីដែលការប្រព្រឹត្តនោះមិនត្រូវបានចាត់ទុកថាជាបទបំពានប្រឆាំងដូប៉ា ក្នុងប្រការ ២.៥ ៖

២.១១.១ អំពើដែលគំរាមគំហែង ឬព្យាយាមបំភិតបំភ័យដល់បុគ្គលណាម្នាក់ ក្នុងបំណងរារាំង បុគ្គលនោះមិនឱ្យរាយការណ៍ដោយស្មោះត្រង់ នូវព័ត៌មានដែលជាប់ទាក់ទងនៃការបំពានវិធានប្រឆាំងដូប៉ា ឬការចោទប្រកាន់ថាមិនបានគោរពតាមក្រម ទៅទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក ឬអង្គការប្រឆាំងដូប៉ា មន្ត្រីអនុវត្តច្បាប់ ស្ថាប័នច្បាប់ វិជ្ជាជីវៈ ឬវិន័យ ក្រុមប្រឹក្សាសវនាការ ឬបុគ្គលដែលធ្វើការស៊ើបអង្កេតរបស់ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក ឬអង្គការប្រឆាំងដូប៉ា។

២.១១.២ ការសងសឹកប្រឆាំងបុគ្គលណាម្នាក់ដែល ក្នុងបំណងសុចរិត បានផ្តល់នូវភស្តុតាង ឬព័ត៌មាន ទាក់ទងទៅនឹងការចោទប្រកាន់ថាមានការបំពានវិធានប្រឆាំងដូប៉ា ឬការចោទប្រកាន់ថាមានការមិនអនុវត្តតាមក្រម ទៅឱ្យទៅអង្គការប្រឆាំងដូប៉ាពិភពលោក អង្គការប្រឆាំងដូប៉ាជាតិ មន្ត្រីអនុវត្តច្បាប់ ស្ថាប័នច្បាប់ វិជ្ជាជីវៈ ឬវិន័យ ក្រុមប្រឹក្សាសវនាការ ឬបុគ្គលដែលធ្វើការស៊ើបអង្កេតរបស់ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក ឬអង្គការប្រឆាំងដូប៉ាជាតិ។

សម្រាប់គោលបំណងនៃប្រការ ២.១១ ការសងសឹក ការគំរាមគំហែង ឬការបំភិតបំភ័យ រួមបញ្ចូលទាំងសកម្មភាពដែលធ្វើឡើងប្រឆាំងបុគ្គលណាម្នាក់ ទោះដោយមូលហេតុដែលថាការរាយការណ៍នោះខ្វះមូលដ្ឋាននៃភាពសុចរិត ឬជាការឆ្លើយតបដែលមិនសមាមាត្រ។

ប្រការ៣៖ ការបង្ហាញភស្តុតាងដូប៉ា

៣.១ បន្ទុក និងស្តង់ដារនៃការបង្ហាញភស្តុតាង

គណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជា ត្រូវមានកាតព្វកិច្ចបង្ហាញថា ការប្រព្រឹត្តិបំពានវិធានប្រឆាំងដូប៉ាបានកើតឡើង។ ស្តង់ដារនៃការបង្ហាញភស្តុតាងនេះ គឺអាចថាគណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជា ត្រូវបង្ហាញថាមានការប្រព្រឹត្តិបំពានកើតឡើងដែល ក្រុមប្រឹក្សាជំនុំជម្រះអាចជឿជាក់បាន ដោយផ្អែកលើភាពធ្ងន់ធ្ងរនៃការចោទប្រកាន់។ ស្តង់ដារនៃការបង្ហាញភស្តុតាង នៅក្នុងគ្រប់សំណុំរឿងប្រសើរជាងការដែលគ្រាន់តែបង្ហាញតុល្យការនៃលទ្ធភាពដែលអាចកើតមាន ប៉ុន្តែនៅមានទម្ងន់តិចជាង ភស្តុតាងលើសពីសេចក្តីសង្ស័យ។ ក្នុងករណីដែលវិធានប្រឆាំងដូប៉ា ដាក់បន្ទុកនៃការបង្ហាញភស្តុតាងលើអត្តពលិក ឬបុគ្គលផ្សេងទៀតដែលត្រូវបានចោទប្រកាន់ថា បានប្រព្រឹត្តបំពានវិធានប្រឆាំងដូប៉ា ដើម្បីបដិសេធការសន្មតជាមុន ឬបង្កើតអង្គហេតុ ឬកាលៈទេសៈជាក់លាក់ លើកលែងតែដូចអ្វីដែលមានចែងក្នុងប្រការ ៣.៣.៣ និង ៣.២.៣ ស្តង់ដារនៃការបង្ហាញភស្តុតាងត្រូវផ្អែកលើតុល្យការនៃភាពដែលអាចកើតឡើង។

៣.២ វិធីសាស្ត្រនៃការបង្កើតអង្គហេតុ និងការសន្មតទុកជាមុន

អង្គហេតុដែលទាក់ទងការបំពានវិធានប្រឆាំងដូប៉ា អាចត្រូវបានបង្កើតឡើង ដោយមធ្យោបាយដែលគួរឱ្យជឿជាក់ណាមួយ ព្រមទាំងការសារភាព។ ខាងក្រោមនេះជាវិធានបង្ហាញភស្តុតាងដែលត្រូវអនុវត្តចំពោះសំណុំរឿងដូប៉ា ៖

៣.២.១ វិធីសាស្ត្រនៃការវិភាគ ឬកំពុងកម្រិតនៃសេចក្តីសម្រេច ដែលអនុម័តដោយទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក បន្ទាប់ពីការប្រឹក្សាយោបល់នៅក្នុងសហគមន៍វិទ្យាសាស្ត្រពាក់ព័ន្ធ ឬដែលជាកម្មវត្ថុនៃការពិនិត្យឡើងវិញដោយសហការីក្នុងវិស័យ ត្រូវបានសន្មតទុកជាមុន ថាត្រឹមត្រូវតាមបែបវិទ្យាសាស្ត្រ។ អត្តពលិក ឬបុគ្គលផ្សេងទៀតដែលជំទាស់នឹងលក្ខខណ្ឌ នៃការសន្មតទុកជាមុននេះ ឬបដិសេធសុពលភាពបែបវិទ្យាសាស្ត្រនៃការសន្មតទុកជាមុននេះ តាមលក្ខខណ្ឌ តម្រូវជាមុនសម្រាប់ការមិនសុខចិត្តបែបនេះ ត្រូវជូនដំណឹងទៅទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោកជាមុនអំពីការមិនសុខចិត្ត និងមូលដ្ឋាននៃការជំទាស់នោះ។ ស្ថាប័នសវនាការបឋម ស្ថាប័នបណ្តឹងជំទាស ឬមជ្ឈតកម្មកីឡា ក្រោមគំនិតផ្តួចផ្តើមរបស់ខ្លួន អាចផ្តល់ព័ត៌មានទៅទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក អំពីការជំទាស់ណាមួយ។ នៅក្នុងរយៈពេល ១០(ដប់)ថ្ងៃ បន្ទាប់ពីទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោកទទួលការជូនដំណឹង និងសំណុំរឿងពាក់ព័ន្ធនឹងការជំទាស់នេះ ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក នឹងមានសិទ្ធិធ្វើអន្តរាគមន៍ក្នុងនាមជាភាគីមួយ ដោយដើរតួនាទីជាអ្នកជូនយោបល់ក្រុមប្រឹក្សាមជ្ឈតកម្មកីឡា ឬក៏ផ្តល់ភស្តុតាងផ្សេងក្នុងនីតិវិធីមជ្ឈតកម្មកីឡា។ ក្នុងសំណុំរឿងនៅចំពោះមុខមជ្ឈតកម្មកីឡាតាមការស្នើសុំរបស់ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក មជ្ឈតកម្មកីឡាដែលត្រូវបានតែងតាំងអ្នកជំនាញវិទ្យាសាស្ត្រសមស្រប ដើម្បីជាជំនួយដល់ក្រុមប្រឹក្សាក្នុងការវាយតម្លៃនៃសំណុំរឿងរបស់ខ្លួនចំពោះការជំទាស់នោះ។

៣.២.២ មន្ទីរពិសោធន៍ដែលទទួលស្គាល់គុណភាពដោយទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក ឬមន្ទីរពិសោធន៍ផ្សេងទៀតដែលអនុម័តដោយទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក ត្រូវបានសន្មតថាបានធ្វើវិភាគសំណាក និងអនុវត្តនីតិវិធីចាំបាច់ ដោយអនុលោមតាមស្តង់ដារស្តីពីមន្ទីរពិសោធន៍។ អត្តពលិក ឬបុគ្គលផ្សេងទៀត អាចបដិសេធការសន្មតជាមុននេះ ដោយបង្ហាញថាមានការអនុវត្តប្រាសចាកពីស្តង់ដារអន្តរជាតិស្តីពីមន្ទីរពិសោធន៍បានកើតឡើងដែលអាចបណ្តាលឱ្យមានលទ្ធផលវិភាគវិជ្ជមាន។

ប្រសិនបើអត្តពលិក ឬបុគ្គលដទៃទៀតបដិសេធការសន្មតជាមុន ដោយបង្ហាញថា មានការអនុវត្តប្រាសចាកពីស្តង់ដារអន្តរជាតិស្តីពីមន្ទីរពិសោធន៍បានកើតឡើងដែលអាចបណ្តាលឱ្យមានលទ្ធផលវិភាគវិជ្ជមាននោះ គណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជា មានភារកិច្ចទទួលបន្ទុកបង្ហាញថាការប្រាសចាកនោះមិនបង្កឱ្យមានលទ្ធផលវិភាគវិជ្ជមានទេ។

៣.២.៣ ការប្រាសចាកពីស្តង់ដារអន្តរជាតិណាមួយ ឬវិធានប្រឆាំងដូប៉ា ឬគោលនយោបាយ ដូចដែលមានចែងនៅក្នុងក្រម ឬវិធានប្រឆាំងដូប៉ាទាំងនេះ នឹងមិនមោឃភាពលើលទ្ធផលវិភាគ ឬភស្តុតាងផ្សេងទៀតនៃការបំពានវិធានប្រឆាំងដូប៉ាទេ និងមិនត្រូវបានយកជាសំអាងហេតុ ចំពោះការប្រព្រឹត្តិលបំពានវិធានប្រឆាំងដូប៉ានេះឡើយ ទោះបីក្នុងករណីដែលថាអត្តពលិក ឬអ្នកគាំពារអត្តពលិកបង្ហាញថាមានការប្រាសចាកពីបទប្បញ្ញត្តិនៃស្តង់ដារអន្តរជាតិជាក់លាក់ណាមួយខាងក្រោមក្នុងហេតុផលសមស្រប បានបង្កឱ្យមានការបំពានវិធានប្រឆាំងដូប៉ាដោយផ្អែកលើលទ្ធផលវិភាគវិជ្ជមាន ឬការខកខានមិនបានផ្តល់ព័ត៌មានអំពីទីសំចតនោះគណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជា ត្រូវទទួលបន្ទុកបង្ហាញថាការប្រាសចាកពីស្តង់ដារនោះមិនបង្កជាមូលហេតុនៃលទ្ធផលវិភាគវិជ្ជមាន ឬខកខានក្នុងការផ្តល់ព័ត៌មានអំពីទីសំចតទេ៖

(i) ការប្រាសចាកពីស្តង់ដារអន្តរជាតិស្តីពីការធ្វើតេស្ត និងការស៊ើបអង្កេត ដែលទាក់ទងនឹងការប្រមូលសំណាក ឬការគ្រប់គ្រងសំណាក ដែលអាចជាមូលហេតុបង្កឱ្យមានការបំពានវិធានប្រឆាំងដូប៉ាផ្អែកលើលទ្ធផលវិភាគវិជ្ជមាន ដែលក្នុងករណីនេះ គណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជា ត្រូវទទួលបង្ហាញថាការប្រាសចាកពីស្តង់ដារនោះ មិនបង្កជាមូលហេតុនៃលទ្ធផលវិភាគវិជ្ជមានទេ។

(ii) ការប្រាសចាកពីស្តង់ដារអន្តរជាតិស្តីពីការដោះស្រាយវិវាទដូប៉ា ឬស្តង់ដារអន្តរជាតិស្តីពីការធ្វើតេស្ត និងការស៊ើបអង្កេត ដែលទាក់ទងនឹងការរកឃើញនៃប្រវត្តិជីវសាស្ត្រមិនល្អ ដែលជាមូលហេតុបង្ក

ឱ្យមានលើការបំពានវិធានប្រឆាំងដូប៉ា ដែលក្នុងករណីនេះ ត្រូវទទួលបន្ទុកបង្ហាញថាការប្រាសចាកពីស្តង់ដារនោះ មិនបង្កឱ្យមានការបំពានវិធានប្រឆាំងដូប៉ាទេ។

(iii) ការប្រាសចាកពីស្តង់ដារអន្តរជាតិស្តីពីការដោះស្រាយវិវាទដូប៉ា ដែលទាក់ទងនឹងលក្ខខណ្ឌតម្រូវនៃការផ្តល់ការជូនដំណឹងទៅអត្តពលិកអំពីការបើកសំណាក (ខ) ដែលក្នុងហេតុផលសមស្របបង្កឱ្យមានការបំពានវិធានប្រឆាំងដូប៉ា ដោយផ្អែកលើលទ្ធផលវិភាគវិជ្ជមានដែលក្នុងករណីនេះ គណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជា ត្រូវទទួលបន្ទុកបង្ហាញថាការប្រាសចាកពីស្តង់ដារនោះ មិនបង្កជាមូលហេតុនៃលទ្ធផលវិភាគវិជ្ជមាននោះទេ។

(iv) ការប្រាសចាកពីស្តង់ដារអន្តរជាតិស្តីពីការដោះស្រាយវិវាទដូប៉ាដែលក្នុងហេតុផលសមស្រប អាចបង្កឱ្យមានការបំពានវិធានប្រឆាំងដូប៉ា ដោយផ្អែកលើការខកខាន មិនបានផ្តល់ព័ត៌មានអំពីទីសំចតរបស់អត្តពលិក ដែលក្នុងករណីនេះ គណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជាត្រូវទទួលបន្ទុកបង្ហាញថាការប្រាសចាកនោះ មិនបង្កឱ្យមានការខកខានក្នុងការផ្តល់ព័ត៌មានអំពីទីសំចតរបស់អត្តពលិកទេ។

៣.២.៤ អង្គហេតុដែលបង្កើតឡើងដោយសេចក្តីសម្រេចរបស់តុលាការ ឬសាលាវិនិច្ឆ័យដែលសមត្ថកិច្ច ដែលមិនមែនជាកម្មវត្ថុនៃបណ្តឹងជំទាស់ដែលកំពុងដំណើរការ គឺជាភស្តុតាងមិនអាចបដិសេធបានប្រឆាំងនឹងអត្តពលិក ឬបុគ្គលដទៃទៀត សម្រាប់អ្នកដែលមានសេចក្តីសម្រេចពាក់ព័ន្ធនឹងអង្គហេតុនោះ លើកលែងតែអត្តពលិក ឬបុគ្គលដទៃទៀតបង្ហាញថាសេចក្តីសម្រេចនោះបានបំពានលើគោលការណ៍យុត្តិធម៌។

៣.២.៥ ក្រុមប្រឹក្សាជំនុំជម្រះនៅក្នុងពេលសវនាការ លើករណីបំពានវិធានប្រឆាំងដូប៉ា អាចទាញសេចក្តីសន្និដ្ឋានអវិជ្ជមានចំពោះអត្តពលិក ឬបុគ្គលដទៃទៀត ដែលត្រូវបានអះអាងថា បានបំពានវិធានប្រឆាំងដូប៉ា ដោយផ្អែកលើការបដិសេធរបស់អត្តពលិក ឬបុគ្គលដទៃទៀត បន្ទាប់ពីទទួលបានសំណើក្នុងរយៈពេលសមស្របមុនពេលសវនាការ ដើម្បីបង្ហាញខ្លួននៅក្នុងសវនាការនោះ (ទាំងបង្ហាញខ្លួនដោយផ្ទាល់ ឬតាមទូរស័ព្ទតាមការបង្គាប់ដោយក្រុមប្រឹក្សាជំនុំជម្រះ) ព្រមទាំងឆ្លើយសំនួររបស់ក្រុមប្រឹក្សាជំនុំជម្រះ ឬគណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជា។

## ប្រការ៤៖ បញ្ជីហាមឃាត់

### ៤.១ ការបញ្ចូលក្នុងបញ្ជីហាមឃាត់

វិធានប្រឆាំងដូប៉ានេះរួមបញ្ចូលបញ្ជីហាមឃាត់ដែលត្រូវបានផ្សព្វផ្សាយ និងកែសម្រួលដោយទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក ដូចបានរៀបរាប់នៅក្នុងប្រការ ៤.១ នៃក្រម។

លុះត្រាតែមានការចែងផ្សេងពីនេះក្នុងបញ្ជីហាមឃាត់ ឬការកែសម្រួលបញ្ជីហាមឃាត់ និងការកែសម្រួលរបស់វាត្រូវប្រើប្រាស់ក្រោមវិធានប្រឆាំងដូប៉ារយៈពេល ៣(បី)ខែ បន្ទាប់ពីការផ្សព្វផ្សាយដោយទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក ដោយមិនតម្រូវឱ្យធ្វើសកម្មភាពបន្ថែមណាមួយដោយ គណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជាឡើយ។ អត្តពលិក ឬបុគ្គលផ្សេងទៀតទាំងអស់ត្រូវបានចងកាតព្វកិច្ចក្រោមបញ្ជីហាមឃាត់ និងការកែសម្រួលជាបន្តបន្ទាប់របស់វា ចាប់ពីកាលបរិច្ឆេទមានសុពលភាពទៅ ដោយគ្មានទម្រង់អ្វីត្រូវបន្ថែមទេ។ វាជាការទទួលខុសត្រូវរបស់អត្តពលិក និងបុគ្គលផ្សេងៗទៀតដែលត្រូវយល់ដឹងដោយខ្លួនឯងពីកំណែចុងក្រោយនៃបញ្ជីហាមឃាត់ និងការកែសម្រួលផ្សេងៗ។

### ៤.២ សារធាតុហាមឃាត់ និងវិធីសាស្ត្រហាមឃាត់ដែលត្រូវបានកំណត់នៅក្នុងបញ្ជីហាមឃាត់

#### ៤.២.១ សារធាតុហាមឃាត់ និងវិធីសាស្ត្រហាមឃាត់

សារធាតុហាមឃាត់ ឬបញ្ជីហាមឃាត់ត្រូវកំណត់អត្តសញ្ញាណនៃសារធាតុហាមឃាត់ ឬវិធីសាស្ត្រហាមឃាត់ ដែលត្រូវបានហាមឃាត់ថាជាសារធាតុដូប៉ាគ្រប់ពេលវេលា (ទាំងក្នុងការប្រកួត និងក្រៅការប្រកួត) ដោយសារឥទ្ធិពលរបស់វាក្នុងការបង្កើនកម្លាំងរបស់អត្តពលិក ក្នុងការប្រកួតនាពេលអនាគត ឬឥទ្ធិពលបិទបាំងរបស់វា ព្រមទាំងសារធាតុ និងវិធីសាស្ត្រ ដែលត្រូវបានហាមឃាត់សម្រាប់តែក្នុងការប្រកួតប៉ុណ្ណោះ។ បញ្ជីហាមឃាត់អាចត្រូវបាន កែសម្រួលដោយទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក សម្រាប់ប្រភេទកីឡាជាក់លាក់។ សារធាតុហាមឃាត់ និងវិធីសាស្ត្រហាមឃាត់អាចត្រូវបានបញ្ចូលក្នុងបញ្ជីហាមឃាត់ តាមប្រភេទទូទៅ (ឧទាហរណ៍ ៖ សារធាតុអាណាបូលីស) ឬសម្រាប់សារធាតុជាក់លាក់ និងវិធីសាស្ត្រជាក់លាក់ណាមួយ។

៤.២.២ សារធាតុជាក់លាក់ ឬវិធីសាស្ត្រជាក់លាក់

សម្រាប់គោលបំណងនៃការអនុវត្តប្រការ ១០ រាល់សារធាតុហាមឃាត់ទាំងអស់ ត្រូវជាសារធាតុជាក់លាក់ លើកលែងដូចអ្វីដែលត្រូវបានកំណត់នៅក្នុងបញ្ជីហាមឃាត់។ គ្មានវិធីសាស្ត្រហាមឃាត់ណាជាវិធីសាស្ត្រជាក់លាក់ទេ លើកលែងតែមានការកំណត់ច្បាស់លាស់ថាវាជាវិធីសាស្ត្រជាក់លាក់នៅក្នុងបញ្ជីហាមឃាត់។

៤.២.៣ សារធាតុបំពាន

សម្រាប់គោលបំណងនៃការអនុវត្តប្រការ ១០ រាល់សារធាតុបំពានទាំងអស់ត្រូវរាប់បញ្ចូល ទាំងសារធាតុហាមឃាត់ដែលត្រូវបានកំណត់ជាក់លាក់ថា ជាសារធាតុបំពាននៅក្នុងបញ្ជីហាមឃាត់ ព្រោះសារធាតុបែបនេះជាញឹកញាប់ត្រូវបានប្រើដោយបំពាននៅក្នុងសង្គម ក្រៅពីបរិបទរបស់កីឡា។

៤.៣ ការកំណត់បញ្ជីហាមឃាត់របស់ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក

ការកំណត់សារធាតុហាមឃាត់ និងវិធីសាស្ត្រហាមឃាត់ ដែលនឹងត្រូវដាក់បញ្ចូលទៅក្នុងបញ្ជីហាមឃាត់របស់ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក ការកំណត់ចំណាត់ថ្នាក់សារធាតុនៅក្នុងបញ្ជីហាមឃាត់ការកំណត់ចំណាត់ថ្នាក់សារធាតុមួយថាជាសារធាតុហាមឃាត់គ្រប់ពេលវេលា ឬសារធាតុហាមឃាត់សម្រាប់តែក្នុងការប្រកួត ការកំណត់ចំណាត់ថ្នាក់នៃសារធាតុ ឬវិធីសាស្ត្រ ថាជាសារធាតុជាក់លាក់ វិធីសាស្ត្រជាក់លាក់ ឬសារធាតុបំពាន គឺជាការសម្រេច/កំណត់ចុងក្រោយ និងមិនអាចត្រូវបានជំទាស់ដោយអត្តពលិក ឬបុគ្គលផ្សេងទៀតណាម្នាក់ឡើយ រួមបញ្ចូលទាំងការជំទាស់ផ្អែកលើទឡ្ហីករណ៍ដែលថាសារធាតុ ឬវិធីសាស្ត្រនោះមិនមែនជាសារធាតុបិទបាំង ឬមិនមានសក្តានុពលបង្កើនកម្លាំងអត្តពលិក នាំឱ្យមានហានិភ័យសុខភាព ឬបំពានលើស្មារតីកីឡាបានទេ។

៤.៤ ការលើកលែងឱ្យប្រើប្រាស់ថ្នាំព្យាបាល

៤.៤.១ វត្តមាននៃសារធាតុហាមឃាត់ ឬសារធាតុមេតាបូលីស ឬសារធាតុបិទបាំង និង/ឬការប្រើប្រាស់ ឬការប៉ុនប៉ងប្រើប្រាស់ ការកាន់កាប់ ឬការផ្តល់ ឬការប៉ុនប៉ងផ្តល់សារធាតុហាមឃាត់ ឬវិធីសាស្ត្រហាមឃាត់ មិនត្រូវបានចាត់ទុកថាជាការបំពានវិធានប្រឆាំងដូប៉ាឡើយ ប្រសិនបើវាស្របនឹងបទបញ្ញត្តិនៃការលើកលែងឱ្យប្រើប្រាស់ថ្នាំព្យាបាល ដែលអនុលោមតាមស្តង់ដារអន្តរជាតិស្តីពីការលើកលែងឱ្យប្រើប្រាស់ថ្នាំព្យាបាល។

៤.៤.២ ដំណើរការដាក់ពាក្យសុំការលើកលែងឱ្យប្រើប្រាស់ថ្នាំព្យាបាល

៤.៤.២.១ អត្តពលិកដែលមិនមែនជាអត្តពលិកកម្រិតអន្តរជាតិ ត្រូវដាក់ពាក្យស្នើសុំការលើកលែងឱ្យប្រើប្រាស់ថ្នាំព្យាបាលមកគណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជា ឱ្យបានលឿនតាមដែលអាចធ្វើទៅបាន ដូចដែលបានចែងក្នុងប្រការ ៤.១ និងប្រការ ៤.៣ នៃស្តង់ដារអន្តរជាតិស្តីពីការលើកលែងឱ្យប្រើប្រាស់ថ្នាំព្យាបាល។ ការដាក់ពាក្យស្នើសុំត្រូវអនុលោមតាមប្រការ ៦

នៃស្តង់ដារអន្តរជាតិស្តីពីការលើកលែងឱ្យប្រើប្រាស់ថ្នាំព្យាបាល ដែលត្រូវបានផ្សាយក្នុងគេហទំព័រ និងទំព័រហ្វេសបុករបស់គណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជា។

៤.៤.២.២ គណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជា ត្រូវបង្កើតអនុគណៈកម្មាធិការលើកលែងឱ្យប្រើប្រាស់ថ្នាំព្យាបាល ដើម្បីពិនិត្យពាក្យស្នើសុំ ការលើកលែងឱ្យប្រើប្រាស់ថ្នាំព្យាបាលដោយយោងតាមប្រការ ៤.៤.២.២ (ក) ដល់ (ឃ) ខាងក្រោម៖

ក. អនុគណៈកម្មាធិការលើកលែងឱ្យប្រើប្រាស់ថ្នាំព្យាបាល ត្រូវមានប្រធាន ១(មួយ)រូប និងសមាជិក ២(ពីរ)រូប ដែលមានបទពិសោធន៍ក្នុងការថែទាំ និងព្យាបាលអត្តពលិក និងមានចំណេះដឹងផ្នែកវេជ្ជសាស្ត្រកីឡា និងឱសថលំហាត់ប្រាណ។

ខ. មុននឹងបំពេញការងារជាសមាជិក របស់អនុគណៈកម្មាធិការលើកលែងឱ្យប្រើប្រាស់ថ្នាំព្យាបាលសមាជិកម្នាក់ៗ ត្រូវចុះហត្ថលេខាលើ សេចក្តីប្រកាសពីទំនាស់ផលប្រយោជន៍ និងការរក្សាការសម្ងាត់។ សមាជិកដែលត្រូវបានតែងតាំងមិនត្រូវជាបុគ្គលិករបស់គណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជានោះទេ។

គ. នៅពេលពាក្យស្នើសុំត្រូវបានដាក់ជូនទៅ គណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជាដើម្បីស្នើសុំការលើកលែងឱ្យប្រើប្រាស់ថ្នាំព្យាបាល ហើយប្រធានអនុគណៈកម្មាធិការលើកលែងឱ្យប្រើប្រាស់ថ្នាំព្យាបាល ត្រូវចាត់តាំងសមាជិក ៣(បី)នាក់ (ដែលអាចរាប់បញ្ចូលទាំងប្រធាន) ដើម្បីពិនិត្យលើពាក្យស្នើសុំនោះ។

ឃ. មុនពេលពិចារណាលើពាក្យស្នើសុំ ការលើកលែងឱ្យប្រើប្រាស់ថ្នាំព្យាបាល សមាជិកម្នាក់ៗ ត្រូវបង្ហាញព័ត៌មានដល់ប្រធានអំពីគ្រប់កាលៈទេសៈទាំងអស់ ដែលអាចបង្កឱ្យមានភាពលម្អៀង ទាក់ទងនឹងអត្តពលិកដែលដាក់ពាក្យស្នើសុំការលើកលែងឱ្យប្រើប្រាស់ថ្នាំព្យាបាលនោះ។ ប្រសិនបើសមាជិកណាម្នាក់ដែលត្រូវបានតែងតាំងដោយប្រធានឱ្យពិចារណាលើ ពាក្យស្នើសុំមិនមានឆន្ទៈ ឬមិនអាចវាយតម្លៃពាក្យស្នើសុំ ការលើកលែងឱ្យប្រើប្រាស់ថ្នាំព្យាបាល នោះតែទោះក្នុងហេតុផលណាក៏ដោយប្រធានអាចចាត់តាំងសមាជិកជំនួស ឬតែងតាំងគណៈកម្មាការថ្មីមួយ (ដោយជ្រើសរើស ចេញពីបញ្ជីបេក្ខជនដែលត្រូវបានកំណត់ទុកជាមុន)។ ប្រធានមិនអាចដើរតួជាសមាជិកនៃអនុគណៈកម្មាធិការលើកលែងឱ្យប្រើប្រាស់ថ្នាំព្យាបាលបានទេ ប្រសិនបើមានកាលៈទេសៈណាមួយ ដែលទំនងជាបង្កឱ្យមានភាពលម្អៀង ដល់ការសម្រេចចិត្តក្នុងការផ្តល់ការលើកលែងឱ្យប្រើប្រាស់ថ្នាំព្យាបាលនោះ។

៤.៤.២.៣ អនុគណៈកម្មាធិការលើកលែងឱ្យប្រើប្រាស់ថ្នាំព្យាបាលត្រូវវាយតម្លៃ និងធ្វើសេចក្តីសម្រេចភ្លាមៗ លើពាក្យស្នើសុំ ដោយយោងទៅតាមបទប្បញ្ញតិនៃស្តង់ដារអន្តរជាតិស្តីពីការលើកលែងឱ្យប្រើប្រាស់ថ្នាំប្រាស់ព្យាបាល ហើយជាទូទៅមិនឱ្យលើសពី ២១(ម្ភៃមួយ)ថ្ងៃ (លុះត្រាតែក្នុងករណីលើកលែង) បន្ទាប់ពីទទួលបានពាក្យស្នើសុំពេញលេញ។ នៅពេលពាក្យស្នើសុំ ត្រូវបានដាក់ជូនក្នុងរយៈពេលសមស្រប មុននឹងការរៀបចំព្រឹត្តិការណ៍ អនុគណៈកម្មាធិការលើកលែងឱ្យប្រើប្រាស់ថ្នាំព្យាបាល ត្រូវព្យាយាមចេញសេចក្តីសម្រេចរបស់ខ្លួនឱ្យបានមុនថ្ងៃចាប់ផ្តើមនៃព្រឹត្តិការណ៍នោះ។

៤.៤.២.៤ សេចក្តីសម្រេចរបស់អនុគណៈកម្មាធិការលើកលែងឱ្យប្រើប្រាស់ថ្នាំព្យាបាល គឺជាសេចក្តីសម្រេចចុងក្រោយរបស់គណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជា ដោយអនុលោមតាមប្រការ ៤.៤.៦។ សេចក្តីសម្រេចរបស់អនុគណៈកម្មាធិការលើកលែងឱ្យប្រើប្រាស់ថ្នាំព្យាបាល របស់គណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជា ត្រូវផ្តល់ជូនជាលាយលក្ខណ៍អក្សរដល់អត្តពលិក និង

ដល់ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក និងអង្គការប្រឆាំង ដូប៉ាផ្សេងទៀតស្របតាមស្តង់ដារអន្តរជាតិស្តីពីការលើកលែងឱ្យប្រើប្រាស់ថ្នាំព្យាបាល សេចក្តីសម្រេចនេះ ក៏ត្រូវតែបានដាក់បញ្ចូលទៅក្នុងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលប្រឆាំងដូប៉ាផងដែរ។

៤.៤.៣ ប្រតិសកម្មនៃការស្នើសុំការលើកលែងឱ្យប្រើប្រាស់ថ្នាំព្យាបាល

ប្រសិនបើគណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជាជ្រើសរើសធ្វើតេស្តលើអត្តពលិក ដែលមិនមែនជាអត្តពលិកកម្រិតអន្តរជាតិ ឬអត្តពលិកកម្រិតជាតិ គណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជា ត្រូវតែអនុញ្ញាតឱ្យអត្តពលិកនោះ ដាក់ពាក្យស្នើសុំប្រតិសកម្មនៃការលើកលែងឱ្យប្រើប្រាស់ថ្នាំព្យាបាល សម្រាប់សារធាតុហាមឃាត់ ឬវិធីសាស្ត្រហាមឃាត់ណាមួយ ដែលអត្តពលិកនោះកំពុងប្រើប្រាស់ជាថ្នាំព្យាបាល។

៤.៤.៤ ការទទួលស្គាល់ការលើកលែងឱ្យប្រើប្រាស់ថ្នាំព្យាបាល

ការលើកលែងឱ្យប្រើប្រាស់ថ្នាំព្យាបាលដែលផ្តល់ដោយ គណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជា មានសុពលភាពនៅកម្រិតថ្នាក់ជាតិ នៃគ្រប់ប្រទេស និងមិនតម្រូវឱ្យ មានការទទួលស្គាល់ជាផ្លូវការដោយអង្គការជាតិប្រឆាំងដូប៉ាផ្សេងទៀតទេ។

ទោះបីជាយ៉ាងណាក៏ដោយ វាមិនមានសុពលភាពដោយស្វ័យប្រវត្តិនោះទេ ប្រសិនបើអត្តពលិកក្លាយជាអត្តពលិកកម្រិតអន្តរជាតិ ឬចូលរួមប្រកួតក្នុងព្រឹត្តការណ៍កម្រិតអន្តរជាតិ លើកលែងតែវាត្រូវបានទទួលស្គាល់ ដោយសហព័ន្ធកីឡាអន្តរជាតិដែលពាក់ព័ន្ធ ឬស្ថាប័នរៀបចំព្រឹត្តិការណ៍កីឡាធំៗ ដោយអនុលោមតាមស្តង់ដារអន្តរជាតិស្តីពីការលើកលែងឱ្យប្រើប្រាស់ថ្នាំព្យាបាល ដូចខាងក្រោម៖

៤.៤.៤.១ ក្នុងករណីដែលអត្តពលិក ទទួលបានការអនុញ្ញាតលើការលើកលែងឱ្យប្រើប្រាស់ថ្នាំព្យាបាលជាស្រេច ដែលផ្តល់ដោយគណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជា សម្រាប់សារធាតុជាក់លាក់ ឬវិធីសាស្ត្រជាក់លាក់នោះ លុះត្រាតែការលើកលែងឱ្យប្រើប្រាស់ថ្នាំព្យាបាលរបស់ពួកគេ ត្រូវទទួលស្គាល់ដោយស្វ័យប្រវត្តិពីសហព័ន្ធកីឡាអន្តរជាតិ ឬស្ថាប័នរៀបចំព្រឹត្តិការណ៍កីឡាធំៗ អត្តពលិកនោះត្រូវដាក់ពាក្យស្នើសុំការទទួលស្គាល់ ការលើកលែងឱ្យប្រើប្រាស់ថ្នាំព្យាបាលនោះទៅសហព័ន្ធកីឡាអន្តរជាតិ ឬស្ថាប័នរៀបចំព្រឹត្តិការណ៍កីឡាធំៗ។ ប្រសិនបើការលើកលែងឱ្យប្រើប្រាស់ថ្នាំព្យាបាលនោះ មានភាពសមស្រប តាមគោលការណ៍ស្តង់ដារអន្តរជាតិស្តីពីការលើកលែងឱ្យប្រើប្រាស់ថ្នាំព្យាបាល នោះសហព័ន្ធកីឡាអន្តរជាតិ ឬស្ថាប័នរៀបចំព្រឹត្តិការណ៍កីឡាធំៗ ត្រូវទទួលស្គាល់ការអនុញ្ញាតនោះ។

ប្រសិនបើសហព័ន្ធកីឡាអន្តរជាតិ ឬស្ថាប័នរៀបចំព្រឹត្តិការណ៍កីឡាធំៗ យល់ឃើញថាការលើកលែងឱ្យប្រើប្រាស់ថ្នាំព្យាបាល ដោយគណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជា មិនសមតាមលក្ខខណ្ឌវិនិច្ឆ័យទាំងនោះទេ ហើយបដិសេធមិនព្រមទទួលស្គាល់ការអនុញ្ញតនោះ សហព័ន្ធកីឡាអន្តរជាតិត្រូវជូនដំណឹងភ្លាមទៅដល់អត្តពលិក និងគណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជា ដោយផ្តល់ហេតុផលច្បាស់លាស់។ អត្តពលិក និង/ឬគណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជា មានរយៈពេល ២១(ម្ភៃមួយ)ថ្ងៃ បន្ទាប់ពីថ្ងៃចេញសេចក្តីជូនដំណឹង ក្នុងការបញ្ជូនបញ្ហានេះទៅទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក ដើម្បីធ្វើការពិនិត្យឡើងវិញ ដោយយោងទៅតាមប្រការ ៤.៤.៦។

ក្នុងករណីបញ្ហាត្រូវបានបញ្ជូនទៅទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក ដើម្បីធ្វើការពិនិត្យឡើងវិញ ស្របតាមប្រការ ៤.៤.៦ ការលើកលែងឱ្យប្រើប្រាស់ថ្នាំព្យាបាល ដែលផ្តល់ជូនដោយ

គណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជា ត្រូវបន្តមានសុពលភាពសម្រាប់ការធ្វើតេស្តការប្រកួត និងការធ្វើតេស្តក្រៅការប្រកួតកម្រិតជាតិ (ប៉ុន្តែមិនមានសុពលភាពសម្រាប់ការប្រកួតកម្រិតអន្តរជាតិទេ) ដោយរង់ចាំសេចក្តីសម្រេចរបស់ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក។

ក្នុងករណីបញ្ហាមិនត្រូវបានបញ្ជូន ទៅទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក ដើម្បីពិនិត្យឡើងវិញក្នុងរយៈពេលកំណត់ ២១(ម្ភៃមួយ)ថ្ងៃទេនោះ គណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជា ត្រូវកំណត់ថា ការលើកលែងឱ្យប្រើប្រាស់ថ្នាំព្យាបាលដើម ដែលខ្លួនបានផ្តល់គួរបន្តមានសុពលភាពសម្រាប់ការធ្វើតេស្តការប្រកួត និងការធ្វើតេស្តក្រៅការប្រកួតកម្រិតជាតិ ឬមិនគួរ (ក្នុងលក្ខខណ្ឌដែលថា អត្តពលិកទាំងនោះលែងជាអត្តពលិកកម្រិតអន្តរជាតិ និងមិនចូលរួមក្នុងការប្រកួតកម្រិតអន្តរជាតិទេ)។ ដោយរង់ចាំសេចក្តីសម្រេចរបស់គណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជា ការលើកលែងឱ្យប្រើប្រាស់ថ្នាំព្យាបាល នោះត្រូវបន្តសុពលភាព សម្រាប់ការធ្វើតេស្តការប្រកួត និងការធ្វើតេស្តក្រៅការប្រកួតកម្រិតជាតិ (ប៉ុន្តែមិនមានសុពលភាពសម្រាប់ការប្រកួតកម្រិតអន្តរជាតិទេ)។

៤.៤.៤.២ ប្រសិនបើអត្តពលិកមិនទាន់ទទួលបាន ការលើកលែងឱ្យប្រើប្រាស់ថ្នាំព្យាបាល ពីគណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជាសម្រាប់សារធាតុជាក់លាក់ ឬវិធីសាស្ត្រជាក់លាក់នោះទេ អត្តពលិកត្រូវតែដាក់ពាក្យផ្ទាល់ទៅសហព័ន្ធកីឡាអន្តរជាតិ លើការលើកលែងឱ្យប្រើប្រាស់ថ្នាំព្យាបាលស្របតាមនីតិវិធីដែលបានចែង ក្នុងស្តង់ដារអន្តរជាតិស្តីពីការលើកលែងឱ្យប្រើប្រាស់ថ្នាំព្យាបាលឱ្យបានឆាប់តាមតម្រូវការ។

ប្រសិនបើសហព័ន្ធកីឡាអន្តរជាតិបដិសេធពាក្យស្នើសុំរបស់អត្តពលិក សហព័ន្ធត្រូវជូនដំណឹងដល់អត្តពលិកនោះឱ្យបានឆាប់រហ័ស ដោយផ្តល់មូលហេតុ។

ប្រសិនបើសហព័ន្ធកីឡាអន្តរជាតិ ផ្តល់ការលើកលែងតាមការស្នើសុំរបស់អត្តពលិក សហព័ន្ធត្រូវធ្វើការជូនដំណឹងដល់អត្តពលិក និងគណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជា។ ប្រសិនបើគណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជា យល់ឃើញថាការផ្តល់ការលើកលែងឱ្យប្រើប្រាស់ថ្នាំព្យាបាល ដោយសហព័ន្ធកីឡាអន្តរជាតិ មិនគ្រប់លក្ខណៈវិនិច្ឆ័យ ដូចដែលមានចែងក្នុងស្តង់ដារអន្តរជាតិស្តីពីការលើកលែងឱ្យប្រើប្រាស់ថ្នាំព្យាបាល គណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជា មានរយៈពេល ២១(ម្ភៃមួយ)ថ្ងៃ ចាប់ពីថ្ងៃជូនដំណឹង ក្នុងការបញ្ជូនបញ្ហានោះ ទៅទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក ដើម្បីធ្វើការពិនិត្យឡើងវិញ។

ប្រសិនបើគណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជា បញ្ជូនបញ្ហានេះទៅទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក ឱ្យពិនិត្យវិញ ការលើកលែងឱ្យប្រើប្រាស់ថ្នាំព្យាបាល ដែលផ្តល់ដោយសហព័ន្ធកីឡាអន្តរជាតិ នៅតែមានសុពលភាពសម្រាប់ការធ្វើតេស្តការប្រកួតកម្រិតអន្តរជាតិ និងការធ្វើតេស្តក្រៅការប្រកួត (ប៉ុន្តែមិនមានសុពលភាពសម្រាប់ការប្រកួតថ្នាក់ជាតិទេ) ដោយរង់ចាំសេចក្តីសម្រេចរបស់ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក។

ប្រសិនបើគណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជា មិនបញ្ជូនបញ្ហានេះទៅទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោកឱ្យពិនិត្យឡើងវិញទេនោះ ការលើកលែងឱ្យប្រើប្រាស់ថ្នាំព្យាបាល ដែលផ្តល់ដោយសហព័ន្ធកីឡាអន្តរជាតិនោះក៏នៅមានសុពលភាពសម្រាប់ការប្រកួតថ្នាក់ជាតិដែរ នៅពេលការពិនិត្យឡើងវិញរយៈពេល ២១(ម្ភៃមួយ)ថ្ងៃ ត្រូវបានផុតកំណត់។

៤.៤.៥ ការផុតកំណត់ ការដក ឬការបញ្ចប់ការលើកលែងឱ្យប្រើប្រាស់ថ្នាំព្យាបាល

៤.៤.៥.១ ការលើកលែងឱ្យប្រើប្រាស់ថ្នាំព្យាបាល ដែលផ្តល់ដោយអនុលោមតាមវិធានប្រឆាំងដូប៉ា៖

(ក) នឹងផុតកំណត់ដោយស្វ័យប្រវត្តិនៅចុងកាលបរិច្ឆេទកំណត់ ដោយមិនចាំបាច់មានការជូនដំណឹងបន្ថែមណាមួយ ឬនីតិវិធីផ្សេងទៀតនោះទេ។ ត្រូវដកហូតប្រសិនបើអត្តពលិកមិនគោរពតាមលក្ខខណ្ឌតម្រូវ ឬលក្ខខណ្ឌដែលកំណត់ដោយ អនុគណៈកម្មាធិការលើកលែងឱ្យប្រើប្រាស់ថ្នាំព្យាបាល ក្រោយទទួលបានការលើកលែងឱ្យប្រើប្រាស់ប្រាស់ថ្នាំព្យាបាលហើយ។

(ខ) នឹងត្រូវបានដកហូត ដោយអនុគណៈកម្មាធិការលើកលែងឱ្យប្រើប្រាស់ថ្នាំព្យាបាល ប្រសិនបើអនុគណៈកម្មាធិការនេះ យល់ថាលក្ខណៈតម្រូវសម្រាប់ការផ្តល់ ការលើកលែងនេះមិនត្រូវបានអនុវត្ត។ ឬ

(គ) អាចត្រូវបានបញ្ចប់ ដោយការពិនិត្យរបស់ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក ឬដោយបណ្តឹងជំទាស់។

៤.៤.៥.២ ក្នុងករណីបែបនោះ អត្តពលិកមិនត្រូវប្រឈមនឹងទណ្ឌកម្មណាមួយដោយសារតែការប្រើប្រាស់ ការកាន់កាប់ ការដំណើរការសារធាតុហាមឃាត់ ឬវិធីសាស្ត្រហាមឃាត់ ដោយអនុលោមតាមការលើកលែងឱ្យប្រើប្រាស់ថ្នាំព្យាបាលទេ មុនពេលនៃកាលបរិច្ឆេទផុតកំណត់ ការដកហូត ឬបដិសេធចំពោះការលើកលែងឱ្យប្រើប្រាស់ថ្នាំព្យាបាល។ ការពិនិត្យឡើងវិញ យោងតាមប្រការ ៥.១.១.១ នៃស្តង់ដារអន្តរជាតិស្តីពីការដោះស្រាយវិវាទដូប៉ា ក្នុងករណីលទ្ធផលវិភាគវិជ្ជមានដែលត្រូវរាយការណ៍ភ្លាមៗ បន្ទាប់ពីកាលបរិច្ឆេទផុតកំណត់ ការដកហូត ឬការបដិសេធការលើកលែងនោះ ត្រូវបង្ហាញហេតុផល ថាតើលទ្ធផលនោះស្របតាមគោលការណ៍ប្រើប្រាស់សារធាតុហាមឃាត់ ឬវិធីសាស្ត្រហាមឃាត់ មុនកាលបរិច្ឆេទនោះ ឬយ៉ាងណា ដែលក្នុងករណីនោះ គ្មានការបំពានវិធានប្រឆាំងដូប៉ានឹងត្រូវបានធ្វើឡើងទេ។

៤.៤.៦ ការពិនិត្យឡើងវិញ និងបណ្តឹងជំទាស់សេចក្តីសម្រេចនៃការលើកលែងឱ្យប្រើប្រាស់ថ្នាំព្យាបាល

៤.៤.៦.១ ប្រសិនបើគណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជា បដិសេធលើពាក្យស្នើសុំការលើកលែងឱ្យប្រើប្រាស់ថ្នាំព្យាបាល អត្តពលិកអាចប្តឹងជំទាស់ទៅស្ថាប័ន ដោះស្រាយបណ្តឹងជំទាស់ថ្នាក់ជាតិ ដូចដែលមានចែងក្នុងប្រការ ១៣.២.២។

៤.៤.៦.២ ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក ត្រូវធ្វើការពិនិត្យឡើងវិញលើសេចក្តីសម្រេចរបស់សហព័ន្ធកីឡាអន្តរជាតិ ដែលមិនទទួលស្គាល់ការលើកលែងឱ្យប្រើប្រាស់ថ្នាំព្យាបាលរបស់គណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជា ដែលអត្តពលិក ឬដោយគណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជាបានបញ្ជូនទៅទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោកនោះ។ លើសពីនេះទៀតទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោកត្រូវពិនិត្យឡើងវិញ លើសេចក្តីសម្រេចផ្តល់ការលើកលែងឱ្យប្រើប្រាស់ថ្នាំព្យាបាលរបស់សហព័ន្ធអន្តរជាតិ ដែលបានបញ្ជូនទៅទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក ដោយគណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជា។ ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក អាចធ្វើការពិនិត្យឡើងវិញលើសេចក្តីសម្រេច ផ្តល់ការលើកលែងឱ្យប្រើប្រាស់ថ្នាំព្យាបាលណាមួយផ្សេងទៀត គ្រប់ពេលវេលាទោះជាតាមការស្នើសុំដោយអ្នក/ស្ថាប័ន ដែលរងផលប៉ះពាល់ ឬតាមការផ្តួចផ្តើមដោយខ្លួនឯង។ ប្រសិនបើសេចក្តីសម្រេចការលើកលែងឱ្យប្រើប្រាស់ថ្នាំព្យាបាល ដែលកំពុងត្រូវបានពិនិត្យឡើងវិញនោះ បំពេញតាមលក្ខខណ្ឌតម្រូវ ដូចមានចែងក្នុងស្តង់ដារអន្តរជាតិស្តីពីការលើកលែងការប្រើប្រាស់ថ្នាំព្យាបាលហើយ ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោកនឹងមិនជ្រៀតជ្រែកសេចក្តីសម្រេចនោះទេ។ ប្រសិនបើសេចក្តីសម្រេចការលើកលែងឱ្យ

ប្រើប្រាស់ថ្នាំព្យាបាល ដែលកំពុងត្រូវបានពិនិត្យឡើងវិញនោះ មិនបំពេញតាមលក្ខខណ្ឌតម្រូវទេ ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក នឹងបដិសេធសេចក្តីសម្រេចនោះទេ។

៤.៤.៦.៣ រាល់សេចក្តីសម្រេចផ្តល់ការលើកលែងឱ្យប្រើប្រាស់ថ្នាំព្យាបាល ដែលចេញដោយសហព័ន្ធកីឡាអន្តរជាតិ (ឬដោយគណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជា ប្រសិនបើយល់ព្រមទទួលយកពាក្យស្នើសុំក្នុងនាមជាសហព័ន្ធកីឡាអន្តរជាតិ) ដែលមិនត្រូវបានត្រួតពិនិត្យឡើងវិញដោយទីភ្នាក់ងារប្រឆាំងពិភពលោក ឬដែលត្រូវបានពិនិត្យឡើងវិញដោយទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក តែមិនត្រូវបានបដិសេធក្រោយការពិនិត្យឡើងវិញនោះ អាចត្រូវបានជំទាស់ដោយអត្តពលិក និង/ឬ គណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជា ទៅមជ្ឈតកម្មកីឡា។

៤.៤.៦.៤ សេចក្តីសម្រេចរបស់ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក ក្នុងការបដិសេធសេចក្តីសម្រេចលើកលែងឱ្យប្រើប្រាស់ថ្នាំព្យាបាល អាចត្រូវបានប្តឹងជំទាស់ទៅមជ្ឈតកម្មកីឡាដោយអត្តពលិក គណៈកម្មាធិការប្រឆាំងដូបាកម្ពុជា និង/ឬសហព័ន្ធកីឡាអន្តរជាតិ។

៤.៤.៦.៥ ការខកខានក្នុងការអនុវត្តសេចក្តីសម្រេចតាមកាលកំណត់ សមស្របទៅលើពាក្យសុំដែលបានបញ្ជូនត្រឹមត្រូវ ដើម្បីស្នើសុំការផ្តល់/ការទទួលស្គាល់នៃការលើកលែងឱ្យប្រើប្រាស់ថ្នាំព្យាបាល ឬដើម្បីពិនិត្យឡើងវិញ នូវសេចក្តីសម្រេចការលើកលែងឱ្យប្រើប្រាស់ថ្នាំព្យាបាល នឹងត្រូវបានចាត់ទុកថាជាការបដិសេធលើការស្នើសុំនោះ ដែលនឹងនាំឱ្យមានការអនុវត្តសិទ្ធិពិនិត្យឡើងវិញ/ប្តឹងជំទាស់។

## ប្រការ៥៖ ការធ្វើតេស្ត និងការស៊ើបអង្កេត

### ៥.១ គោលបំណងនៃការធ្វើតេស្ត និងការស៊ើបអង្កេត

៥.១.១ ការធ្វើតេស្ត និងការស៊ើបអង្កេតអាចត្រូវធ្វើឡើងក្នុងគោលបំណងប្រឆាំងដូប៉ា។ វាអាចនឹងត្រូវធ្វើឡើងដោយអនុលោមតាមស្តង់ដាអន្តរជាតិស្តីពីការធ្វើតេស្ត និងការស៊ើបអង្កេត។

៥.១.២ ការធ្វើតេស្ត ត្រូវធ្វើឡើង ដើម្បីទទួលបានភស្តុតាងវិភាគដើម្បីកំណត់ថាតើ អត្តពលិកបានបំពានលើប្រការ ២.១ (វត្តមាននៃសារធាតុហាមឃាត់ ឬសារធាតុមេតាប៉ូលីស ឬសារធាតុបិតបាំងក្នុងសំណាករបស់អត្តពលិក) ឬប្រការ ២.២ (ការប្រើប្រាស់ ឬការប៉ុនប៉ងប្រើប្រាស់សារធាតុហាមឃាត់ ឬវិធីសាស្ត្រហាមឃាត់ដោយអត្តពលិក) ឬយ៉ាងណា។

### ៥.២ អាជ្ញាធរធ្វើតេស្ត

៥.២.១ ផ្អែកតាមដែនកំណត់នៃការធ្វើតេស្តសម្រាប់ព្រឹត្តិការណ៍កីឡា ដូចដែលមានចែងក្នុងប្រការ ៥.៣ គណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជា មានសិទ្ធិធ្វើតេស្តទាំងនៅក្នុងការប្រកួត និងក្រៅការប្រកួត លើគ្រប់អត្តពលិកទាំងអស់ ដូចដែលត្រូវបានបញ្ជាក់នៅក្នុងសេចក្តីផ្តើមនៃវិធានប្រឆាំងដូប៉ានេះ (ផ្នែកស្តីពី "ដែនវិសាលភាពនៃវិធានប្រឆាំងដូប៉ា")។

៥.២.២ គណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជា អាចស្នើសុំអត្តពលិកណាម្នាក់ ដែលខ្លួនមានសិទ្ធិអំណាចក្នុងការធ្វើតេស្ត (រួមទាំងអត្តពលិក ដែលស្ថិតក្នុងរយៈពេលព្យួរសិទ្ធិ) ដើម្បីឱ្យផ្តល់សំណាកនៅគ្រប់ពេល និងគ្រប់ទីកន្លែង។

៥.២.៣ ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក មានសិទ្ធិធ្វើតេស្តទាំងក្នុងការប្រកួត និងក្រៅការប្រកួត ដូចដែលបានចែងក្នុងប្រការ ២០.៧.១០ នៃក្រម។

៥.២.៤ ប្រសិនបើសហព័ន្ធកីឡាអន្តរជាតិ ឬស្ថាប័នរៀបចំព្រឹត្តិការណ៍កីឡាធំៗណាមួយ ផ្តល់សិទ្ធិ ឬផ្តល់កិច្ចសន្យា

ផ្នែកណាមួយនៃការធ្វើតេស្ត ទៅឱ្យគណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជាដោយផ្ទាល់ ឬតាមរយៈសហព័ន្ធកីឡាជាតិ គណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជា អាចប្រមូលសំណាកបន្ថែម ឬឱ្យមន្ទីរពិសោធន៍ធ្វើការវិភាគប្រភេទផ្សេងទៀត ក្រោមការចំណាយរបស់គណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជា។ ប្រសិនបើសំណាកបន្ថែមត្រូវបានប្រមូលយក ឬប្រភេទនៃការវិភាគបន្ថែមត្រូវបានអនុវត្ត សហព័ន្ធកីឡាអន្តរជាតិ ឬស្ថាប័នរៀបចំព្រឹត្តិការណ៍កីឡាធំៗ ត្រូវទទួលបានការជូនដំណឹងពីបញ្ហានោះ។

៥.៣ ការធ្វើតេស្តសម្រាប់ព្រឹត្តិការណ៍កីឡា

៥.៣.១ លើកលែងដូចករណីដែលបានកំណត់ខាងក្រោម មានតែស្ថាប័នមួយគត់ដែលមានសិទ្ធិធ្វើតេស្តនៅទីលានក្នុងអំឡុងពេលនៃព្រឹត្តការណ៍ការប្រកួតកីឡានោះ។ នៅក្នុងព្រឹត្តិការណ៍ប្រកួតកីឡាអន្តរជាតិដែលរៀបចំនៅក្នុងប្រទេសកម្ពុជា អង្គការអន្តរជាតិដែលជាស្ថាប័នគ្រប់គ្រងព្រឹត្តិការណ៍ប្រកួតកីឡានោះ មានសិទ្ធិក្នុងការធ្វើតេស្ត។ ក្នុងព្រឹត្តការណ៍ប្រកួតកីឡាថ្នាក់ជាតិដែលធ្វើនៅក្នុងប្រទេសកម្ពុជា គណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជាមានសិទ្ធិធ្វើតេស្ត។ តាមការស្នើរបស់ស្ថាប័នមានសិទ្ធិសម្រាប់ព្រឹត្តិការណ៍កីឡាមួយ រាល់ការធ្វើតេស្តក្នុងអំឡុងពេលនៃការប្រកួតនៅខាងក្រៅទីលាន ត្រូវសម្របស្រួលជាមួយស្ថាប័នមានសិទ្ធិសម្រាប់ព្រឹត្តិការណ៍នោះ។

៥.៣.២ ប្រសិនបើអង្គការប្រឆាំងដូប៉ា ដែលមានសិទ្ធិក្នុងការធ្វើតេស្ត តែពុំមានការទទួលខុសត្រូវក្នុងការផ្តួចផ្តើម និងគ្រប់គ្រងការធ្វើតេស្តនៅក្នុងព្រឹត្តិការណ៍ប្រកួតកីឡា មានបំណងធ្វើតេស្តលើអត្តពលិកនៅទីលានក្នុងអំឡុងពេលនៃព្រឹត្តិការណ៍ប្រកួតកីឡា អង្គការប្រឆាំងដូប៉ានោះត្រូវពិភាក្សាជាមួយស្ថាប័នគ្រប់គ្រងព្រឹត្តិការណ៍ប្រកួតកីឡា ដើម្បីទទួលបាននូវការអនុញ្ញាតឱ្យអនុវត្ត និងសម្របសម្រួលក្នុងការធ្វើតេស្ត។ ប្រសិនបើអង្គការប្រឆាំងដូប៉ាមិនពេញចិត្តនឹងការឆ្លើយតបរបស់ស្ថាប័នគ្រប់គ្រងព្រឹត្តិការណ៍ប្រកួតកីឡាទេ អង្គការប្រឆាំងដូប៉ានោះ អាចយោងតាមនីតិវិធីដែលបានពិពណ៌នាក្នុងស្តង់ដារអន្តរជាតិស្តីពីការធ្វើតេស្ត និងការស៊ើបអង្កេត ស្នើទៅទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក ដើម្បីសុំការអនុញ្ញាតការធ្វើតេស្ត និងកំណត់វិធីសម្របសម្រួលក្នុងការធ្វើតេស្តនោះ។ ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក មិនត្រូវផ្តល់ការអនុញ្ញាតឱ្យធ្វើតេស្តមុនពេលប្រឹក្សា និងជូនដំណឹងដល់ស្ថាប័នគ្រប់គ្រងព្រឹត្តិការណ៍ប្រកួតកីឡាឡើយ។ សេចក្តីសម្រេចរបស់ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក ជាសេចក្តីសម្រេចចុងក្រោយ និងមិនអាចត្រូវបានជំទាស់ទេ។ លើកលែងតែមានការបញ្ជាក់ក្នុងការផ្ទេរសិទ្ធិឱ្យធ្វើតេស្ត ការធ្វើតេស្តនឹងត្រូវបានចាត់ទុកថាជាការធ្វើតេស្តក្រៅការប្រកួត។ ការដោះស្រាយវិវាទដូប៉ាចំពោះការធ្វើតេស្តណាមួយ គឺជាទំនួលខុសត្រូវរបស់អង្គការប្រឆាំងដូប៉ា ដែលផ្តួចផ្តើមក្នុងការធ្វើតេស្តនេះលើកលែងតែមានការបញ្ជាក់ផ្សេងពីនេះ នៅក្នុងវិធានរបស់ស្ថាប័នគ្រប់គ្រងព្រឹត្តិការណ៍ប្រកួតកីឡា។

៥.៤ លក្ខខណ្ឌតម្រូវនៃការធ្វើតេស្ត

៥.៤.១ គណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជា ត្រូវរៀបចំផែនការបែងចែកការធ្វើតេស្ត និងអនុវត្តការធ្វើតេស្តឱ្យស្របតាមស្តង់ដារអន្តរជាតិស្តីពីការធ្វើតេស្ត និងការស៊ើបអង្កេត។

៥.៤.២ ប្រសិនបើអាចធ្វើបាន ការធ្វើតេស្តត្រូវសម្របស្រួលសមស្របតាមវិធានស្តង់ដារអន្តរជាតិ ដោយប្រព័ន្ធគ្រប់គ្រងរដ្ឋបាលប្រឆាំងដូប៉ា ដើម្បីទទួលបានប្រសិទ្ធិភាពខ្ពស់បំផុតនៃការខិតខំរួមគ្នានៃការធ្វើតេស្ត និងដើម្បីជៀសវាងការធ្វើតេស្តដដែលៗ ដែលមិនចាំបាច់។

៥.៥ ព័ត៌មានអំពីទីសំចតរបស់អត្តពលិក

៥.៥.១ គណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជា បានបង្កើតបញ្ជីឈ្មោះធ្វើតេស្តសម្រាប់អត្តពលិក ដែលតម្រូវឱ្យផ្តល់

ព័ត៌មានអំពីទីសំចតជាក់លាក់ ដូចដែលបានបញ្ជាក់ក្នុងស្តង់ដារអន្តរជាតិស្តីពីការធ្វើតេស្ត និងការស៊ើបអង្កេត និងដែលអាចរងទណ្ឌកម្មណាមួយចំពោះការប្រព្រឹត្តបំពាននឹងប្រការ ២.៤ ដូចដែលមានចែងក្នុងប្រការ ១០.៣.២។ គណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជា ត្រូវសម្របសម្រួលជាមួយសហព័ន្ធកីឡាអន្តរជាតិ ដើម្បីកំណត់អត្តសញ្ញាណអត្តពលិក និងប្រមូលព័ត៌មានទីសំចតរបស់ពួកគេ។

៥.៥.២ គណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជា តាមរយៈប្រព័ន្ធគ្រប់គ្រងរដ្ឋបាលប្រឆាំងដូប៉ា ត្រូវផ្តល់បញ្ជីដែលកំណត់អត្តសញ្ញាណអត្តពលិកទាំងនោះ ដោយរួមបញ្ចូលទៅក្នុងបញ្ជីឈ្មោះធ្វើតេស្ត តាមឈ្មោះនីមួយៗ។ គណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជាត្រូវត្រួតពិនិត្យ និងធ្វើបច្ចុប្បន្នភាព ជាទៀងទាត់តាមការចាំបាច់នូវលក្ខខណ្ឌវិនិច្ឆ័យសម្រាប់បញ្ចូលឈ្មោះអត្តពលិកក្នុងបញ្ជីឈ្មោះធ្វើតេស្តរបស់ខ្លួន ហើយត្រូវពិនិត្យឱ្យបានទៀងទាត់ (ប៉ុន្តែមិនឱ្យតិចជាងម្តងក្នុងមួយត្រីមាសឡើយ) នូវបញ្ជីឈ្មោះអត្តពលិកដែលមាននៅក្នុងបញ្ជីឈ្មោះធ្វើតេស្តដើម្បីឱ្យប្រាកដថា អត្តពលិកនីមួយៗ ដែលមានឈ្មោះក្នុងបញ្ជី នៅបំពេញតាមលក្ខខណ្ឌពាក់ព័ន្ធ។ អត្តពលិកត្រូវទទួលបានការជូនដំណឹងមុនពេលពួកគេត្រូវបានបញ្ចូលឈ្មោះទៅក្នុងបញ្ជី និងនៅពេលពួកគេត្រូវបានដកចេញពីបញ្ជី។ ការជូនដំណឹងនេះត្រូវមានព័ត៌មានដូចបានកំណត់ក្នុងស្តង់ដារអន្តរជាតិស្តីពីការធ្វើតេស្ត និងការស៊ើបអង្កេត។

៥.៥.៣ ពេលដែលអត្តពលិកម្នាក់ត្រូវបានបញ្ចូលឈ្មោះទៅក្នុងបញ្ជីឈ្មោះធ្វើតេស្តអន្តរជាតិ ដោយសហព័ន្ធកីឡាអន្តរជាតិរបស់ពួកគេ និងនៅក្នុងបញ្ជីឈ្មោះធ្វើតេស្តជាតិដោយគណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជា និងសហព័ន្ធកីឡាអន្តរជាតិ ត្រូវព្រមព្រៀងគ្នាថាតើស្ថាប័នណាក្នុងចំណោមស្ថាប័នទាំងពីរដែលត្រូវទទួលស្គាល់ឯកសារស្តីពីព័ត៌មានអំពីទីសំចតរបស់អត្តពលិកនោះ។ គ្មានករណីណាដែលអត្តពលិកត្រូវបានតម្រូវឱ្យផ្តល់ព័ត៌មានអំពីទីសំចត របស់ខ្លួនលើសមួយស្ថាប័ននោះទេ។

៥.៥.៤ យោងតាមស្តង់ដារអន្តរជាតិស្តីពីការធ្វើតេស្ត និងការស៊ើបអង្កេត អត្តពលិកម្នាក់ៗដែលមានឈ្មោះក្នុងបញ្ជីឈ្មោះធ្វើតេស្តត្រូវអនុវត្តដូចខាងក្រោម៖

ក. ជូនដំណឹងដល់គណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជាអំពីទីសំចតរបស់ខ្លួន ប្រចាំត្រីមាស។

ខ. ធ្វើបច្ចុប្បន្នភាពនូវព័ត៌មានដែលចាំបាច់ និងសំខាន់ដើម្បីឱ្យមានភាពច្បាស់លាស់ និងត្រឹមត្រូវគ្រប់ពេល។

គ. ត្រូវមានវត្តមានដើម្បីធ្វើតេស្តនៅទីសំចតរបស់ខ្លួន។

៥.៥.៥ សម្រាប់គោលបំណងនៃប្រការ ២.៤ ការខកខានអត្តពលិកក្នុងការអនុវត្តតាមលក្ខខណ្ឌតម្រូវនៃស្តង់ដារអន្តរជាតិស្តីពីការធ្វើតេស្ត និងការស៊ើបអង្កេត នឹងត្រូវបានចាត់ទុកថាជាការខកខានមិនបានបំពេញឯកសារ ឬការខកខានមិនបានធ្វើតេស្ត ដូចមានចែងក្នុងឧបសម្ព័ន្ធ នៃស្តង់ដារអន្តរជាតិស្តីពីការដោះស្រាយវិវាទដូប៉ា ក្នុងករណីដែលលក្ខខណ្ឌក្នុង ឧបសម្ព័ន្ធ ត្រូវបានបំពេញ។

៥.៥.៦ អត្តពលិកដែលមានឈ្មោះក្នុងបញ្ជីឈ្មោះធ្វើតេស្តរបស់គណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជា នឹងត្រូវបន្តស្ថិតក្រោមកាតព្វកិច្ចក្នុងការអនុវត្តតាមលក្ខខណ្ឌតម្រូវស្តីពីព័ត៌មានអំពីទីសំចត ដែលបានកំណត់នៅក្នុងស្តង់ដារអន្តរជាតិស្តីពីការធ្វើតេស្ត និងការស៊ើបអង្កេត លែកលែងតែ ឬរហូតដល់៖

ក. អត្តពលិកនោះផ្តល់សេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរដល់ គណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជា ថាខ្លួនបានចូលនិវត្តន៍ហើយ ឬ

ខ. គណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជា បានជូនដំណឹងទៅអត្តពលិកនោះថាគាត់លែងបំពេញតាមលក្ខខណ្ឌវិនិច្ឆ័យ សម្រាប់ការដាក់បញ្ចូលក្នុងបញ្ជីឈ្មោះធ្វើតេស្តរបស់គណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជាទៀតហើយ។

៥.៥.៧ ព័ត៌មានអំពីទីសំចតក្នុងបញ្ជីឈ្មោះធ្វើតេស្ត ដែលអត្តពលិកផ្តល់ទៅទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក និង

អង្គការប្រឆាំងដូប៉ាផ្សេងៗទៀតដែលមានសិទ្ធិធ្វើតេស្តលើអត្តពលិក ដូចដែលមានចែងក្នុងប្រការ ៥.២ នឹងអាចរកបាននៅប្រព័ន្ធគ្រប់គ្រងរដ្ឋបាលប្រឆាំងដូប៉ា។ ព័ត៌មានអំពីទីសំចតរបស់អត្តពលិកនឹងត្រូវបានរក្សាជាសម្ងាត់គ្រប់ពេល ហើយព័ត៌មាននេះនឹងត្រូវបានប្រើប្រាស់សម្រាប់តែក្នុងគោលបំណងធ្វើផែនការការសម្របសម្រួល ឬដំណើរការគ្រប់គ្រងសារធាតុដូប៉ា ដោយផ្តល់ព័ត៌មានដែលទាក់ទងទៅនឹងប្រវត្តិជីវសាស្ត្រអត្តពលិក ឬលទ្ធផលវិភាគផ្សេងទៀត ដើម្បីជាប្រយោជន៍ ដល់ការស៊ើបអង្កេតករណីបំពានវិធានប្រឆាំងដូប៉ាសក្តានុពល ឬដើម្បីគាំទ្រដល់នីតិវិធីចោទប្រកាន់ពីបទបំពានវិធានប្រឆាំងដូប៉ា ហើយវានឹងត្រូវបានកម្ទេចចោល បន្ទាប់ពីវាលែងមានពាក់ព័ន្ធនឹងគោលបំណងទាំងនេះ ដោយយោងទៅតាមស្តង់ដារអន្តរជាតិស្តីពីរក្សាការសម្ងាត់ និងព័ត៌មានបុគ្គល។

៥.៥.៨ យោងតាមស្តង់ដាអន្តរជាតិស្តីពីការធ្វើតេស្ត និងការស៊ើបអង្កេត គណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជា បានបង្កើតបញ្ជីឈ្មោះធ្វើតេស្តដែលរួមបញ្ចូលអត្តពលិក ដែលជាប់លក្ខខណ្ឌតម្រូវនៃការផ្តល់ព័ត៌មានអំពីទីសំចតតិចជាងអត្តពលិក នៅក្នុងបញ្ជីឈ្មោះធ្វើតេស្ត របស់គណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជា។

៥.៥.៩ គណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជា ត្រូវជូនដំណឹងទៅអត្តពលិកម្នាក់ៗ មុនពេលដាក់បញ្ចូលឈ្មោះពួកគេក្នុងបញ្ជីឈ្មោះធ្វើតេស្ត និងនៅពេលដកពួកគេចេញពីបញ្ជីឈ្មោះធ្វើតេស្ត។ ការជូនដំណឹងនោះត្រូវបញ្ចូលទាំងលក្ខខណ្ឌតម្រូវនៃការរាយការណ៍ពីទីសំចត និងទណ្ឌកម្មដែលត្រូវអនុវត្ត ក្នុងករណីមិនគោរពវិធានដូចដែលមានចែងក្នុងប្រការ ៥.៥.១០ និងប្រការ ៥.៥.១១។

៥.៥.១០ អត្តពលិកដែលមានឈ្មោះក្នុងបញ្ជីឈ្មោះធ្វើតេស្ត ត្រូវផ្តល់ឱ្យគណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជានូវព័ត៌មានទាក់ទង ព័ត៌មានអំពីទីសំចតដូចខាងក្រោមដើម្បីងាយស្វែងរក និងធ្វើតេស្ត៖

ក. អាសយដ្ឋានស្នាក់នៅពេលយប់

ខ. កាលវិភាគប្រកួត និងព្រឹត្តការណ៍ប្រកួតកីឡា និង

គ. សកម្មភាពហ្វឹកហាត់ជាប្រចាំ ព័ត៌មានអំពីទីសំចតទាំងអស់នេះ នឹងត្រូវដាក់បញ្ចូលទៅក្នុងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលប្រឆាំងដូប៉ា ដើម្បីមានភាពងាយស្រួល ក្នុងការសហការធ្វើតេស្ត ជាមួយអង្គការប្រឆាំងដូប៉ាផ្សេងៗទៀត។

៥.៥.១១ ការខកខានរបស់អត្តពលិកក្នុងការផ្តល់ព័ត៌មានអំពីទីសំចតឱ្យបានទាន់ពេល ឬមុនពេលកំណត់របស់គណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជា ឬការខកខានរបស់អត្តពលិកក្នុងការផ្តល់ព័ត៌មានអំពីទីសំចតត្រឹមត្រូវ នឹងអាចឱ្យគណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជាដាក់ឈ្មោះអត្តពលិកនោះទៅ ក្នុងបញ្ជីឈ្មោះធ្វើតេស្តរបស់គណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជា។

៥.៥.១២ យោងតាមស្តង់ដារអន្តរជាតិស្តីពីការធ្វើតេស្ត និងការស៊ើបអង្កេត គណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជា អាចប្រមូលព័ត៌មានអំពីទីសំចត របស់អត្តពលិកដែលមិនមានឈ្មោះនៅក្នុងបញ្ជីឈ្មោះធ្វើតេស្តអន្តរជាតិ ឬបញ្ជីឈ្មោះធ្វើតេស្តជាតិ។ ប្រសិនបើអត្តពលិកខកខានក្នុងការផ្តល់ព័ត៌មានអំពីទីស៊ំចតទាន់ពេល ឬពុំទាន់ថ្ងៃដែលគណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជាកំណត់ ឬអត្តពលិកខកខានផ្តល់ព័ត៌មានទីសំចតស្នាក់ត្រឹមត្រូវ នឹងត្រូវបានគណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជា ដាក់បញ្ចូលអត្តពលិកនោះក្នុងបញ្ជីឈ្មោះធ្វើតេស្តរបស់គណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជា។

៥.៦ អត្តពលិកចូលនិវត្តន៍ដែលត្រឡប់មកប្រកួតវិញ

៥.៦.១ ប្រសិនបើអត្តពលិកកម្រិតអន្តរជាតិ និងអត្តពលិកកម្រិតជាតិ ដែលមានឈ្មោះក្នុងបញ្ជីឈ្មោះធ្វើតេស្តរបស់គណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជាដែលចូលនិវត្តន៍ ហើយមានបំណងចង់ចូលរួមប្រកួតកីឡាវិញ អត្តពលិក

នោះមិនអាចចូលរួមព្រឹត្តិការណ៍ប្រកួតកីឡាកម្រិតអន្តរជាតិ ឬព្រឹត្តិការណ៍ប្រកួតកីឡាកម្រិតជាតិបានទេ លុះត្រាណាតែអត្តពលិករូបនោះអនុញ្ញាតឱ្យគេធ្វើតេស្ត ដោយជូនដំណឹងជាលាយលក្ខណ៍អក្សរជាមុនរយៈពេល ៦(ប្រាំមួយ)ខែ ទៅសហព័ន្ធអន្តរជាតិ និងគណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជា។

ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក ដោយពិភាក្សាជាមួយគណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជា និងសហព័ន្ធកីឡាអន្តរជាតិរបស់អត្តពលិក អាចផ្តល់ការលើកលែងចំពោះការជូនដំណឹងជាលាយលក្ខណ៍អក្សរជាមុនរយៈពេល ៦(ប្រាំមួយ)ខែ នេះ ប្រសិនបើការអនុវត្តតឹងរឹងលើវិធាននោះនឹងនាំឱ្យមានភាពអយុត្តិធម៌ចំពោះអត្តពលិក។ សេចក្តីសម្រេចនេះ អាចត្រូវបានជំទាស់ ដោយយោងតាមប្រការ ១៣។

លទ្ធផលទទួលបានដែលមានលក្ខខណៈប្រកួតប្រជែង ដែលបំពានប្រការ ៥.៦.១ នឹងត្រូវបាន "ដកសិទ្ធិ" លុះត្រាតែអត្តពលិកអាចបង្ហាញថា ខ្លួនមិនអាចដឹង តាមហេតុផលសមស្រប ថាវាជាព្រឹត្តិការណ៍ប្រកួតកីឡាកម្រិតអន្តរជាតិ ឬព្រឹត្តិការណ៍ប្រកួតកីឡាកម្រិតជាតិ។

៥.៦.២ ប្រសិនបើអត្តពលិកណាម្នាក់ចូលនិវត្តន៍ក្នុងរយៈពេលនៃការ "ព្យួរសិទ្ធិ" អត្តពលិកនោះត្រូវជូនដំណឹងទៅអង្គការប្រឆាំងដូប៉ា ដែលដាក់ពិន័យដោយការព្យួរសិទ្ធិនោះជាលាយលក្ខណ៍អក្សរអំពីការចូលនិវត្តន៍របស់ខ្លួន។ ប្រសិនបើអត្តពលិកមានបំណងចង់ចូលរួមក្នុងការប្រកួតវិញ អត្តពលិកនោះមិនអាចចូលរួមក្នុងព្រឹត្តិការណ៍ប្រកួតកីឡាកម្រិតអន្តរជាតិ ឬព្រឹត្តិការណ៍ប្រកួតកីឡាកម្រិតជាតិឡើយ លុះត្រាតែអត្តពលិកនោះទទួលយកការធ្វើតេស្តក្នុងអំឡុងពេល ៦(ប្រាំមួយ)ខែ ចាប់ពីថ្ងៃទទួលដំណឹងជាលាយលក្ខណ៍អក្សរ (ឬការជូនដំណឹងត្រូវសមមូលស្មើនឹងរយៈពេលនៃការ "ព្យួរសិទ្ធិ" ដែលនៅសល់ គិតត្រឹមថ្ងៃដែលអត្តពលិកនោះចូលនិវត្តន៍ ប្រសិនបើអំឡុងនោះមិនយូរជាង ៦(ប្រាំមួយ)ខែ ទៅគណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជា និងសហព័ន្ធកីឡាអន្តរជាតិ។

៥.៧ កម្មវិធីអ្នកសង្កេតការណ៍ឯករាជ្យ

គណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជា និងគណៈកម្មការរៀបចំការប្រកួតកីឡាសម្រាប់ការប្រកួតកីឡាកម្រិតជាតិក្នុងប្រទេសកម្ពុជាត្រូវផ្តល់សិទ្ធិ និងសម្របសម្រួលឱ្យមានកម្មវិធីអ្នកសង្កេតការណ៍ឯករាជ្យក្នុងព្រឹត្តិការណ៍ប្រកួតកីឡា។

## ប្រការ៦៖ ការវិភាគសំណាក

សំណាកនឹងត្រូវបានវិភាគដោយយោងទៅតាមគោលការណ៍ដូចខាងក្រោម៖

៦.១ ការប្រើប្រាស់មន្ទីរពិសោធន៍ដែលត្រូវបានទទួលស្គាល់ និងទទួលសិទ្ធិ និងមន្ទីរពិសោធន៍ផ្សេងទៀត

៦.១.១ ក្នុងគោលបំណងនៃការស្វែងរកដោយផ្ទាល់នូវលទ្ធផលវិភាគវិជ្ជមាន ដូចមានចែងក្នុងប្រការ ២.១ សំណាកនឹងត្រូវបានវិភាគ តែនៅក្នុងមន្ទីរពិសោធន៍ដែលទទួលស្គាល់ដោយទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក ឬមន្ទីរពិសោធន៍ផ្សេងទៀត ដែលត្រូវបានផ្តល់សិទ្ធិពីទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោកតែប៉ុណ្ណោះ។ ការជ្រើសរើសមន្ទីរពិសោធន៍ដែលទទួល ឬដែលផ្តល់សិទ្ធិដោយទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោកដើម្បីប្រើប្រាស់ក្នុងការធ្វើការវិភាគសំណាក គឺជាសិទ្ធិសម្រេចផ្តាច់មុខរបស់គណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជា។

៦.១.២ ដូចដែលមានក្នុងប្រការ ៣.២ អង្គហេតុទាក់ទងនឹងការបំពានវិធានប្រឆាំងដូប៉ា អាចត្រូវបានបង្ហាញតាមមធ្យោបាយដែលអាចជឿជាក់បាន។ ឧទាហរណ៍៖ វារួមបញ្ចូលទាំងមន្ទីរពិសោធន៍ដែលអាចជឿទុកចិត្តបាន ឬការធ្វើកោសល្យវិច្ឆ័យផ្សេងទៀត ដែលធ្វើឡើងនៅខាងក្រោមន្ទីរពិសោធន៍ដែលទទួលស្គាល់ ឬផ្តល់សិទ្ធិ

ដោយទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក។

៦.២ គោលបំណងនៃការវិភាគសំណាក និងទិន្នន័យ

៦.២.១ សំណាក និងទិន្នន័យវិភាគដែលពាក់ព័ន្ធ ឬព័ត៌មាននៃការត្រួតពិនិត្យសារធាតុដូប៉ា នឹងត្រូវបានវិភាគរកសារធាតុហាមឃាត់ និងវិធីសាស្ត្រហាមឃាត់ដូចបានកំណត់នៅក្នុងបញ្ជីហាមឃាត់ និងសារធាតុផ្សេងទៀតដែលការងារនេះអាចត្រូវបានដឹកនាំដោយទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក ដោយអនុលោមតាមកម្មវិធីត្រួតពិនិត្យ ដូចបានបញ្ជាក់ក្នុងប្រការ ៤.៥ នៃក្រម ឬដើម្បីជួយគណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជាក្នុងការបញ្ជាក់ឱ្យបានច្បាស់នូវប៉ារ៉ាម៉ែត្រដែលពាក់ព័ន្ធនៅក្នុង ទឹកនោម ឈាម ឬម៉ាទ្រីសផ្សេងទៀតរបស់អត្តពលិករាប់បញ្ចូលទាំងឌីអិនអេ (DNA) ឬទំរង់ពន្ធុវិទ្យា ឬសម្រាប់គោលបំណងប្រឆាំងដូប៉ាផ្សេងទៀត។

៦.៣ ការស្រាវជ្រាវលើសំណាក និងទិន្នន័យ

សំណាក ទិន្នន័យវិភាគពាក់ព័ន្ធ និងព័ត៌មានត្រួតពិនិត្យសារធាតុដូប៉ា អាចត្រូវបានប្រើសម្រាប់គោលបំណងស្រាវជ្រាវប្រឆាំងដូប៉ា ទោះបីជាគ្មាន សំណាក ណាមួយអាចត្រូវបានប្រើសម្រាប់ការស្រាវជ្រាវ ដោយគ្មានការយល់ព្រមជាលាយលក្ខណ៍អក្សររបស់អត្តពលិកក៏ដោយ។ សំណាក និងទិន្នន័យវិភាគដែលពាក់ព័ន្ធ ឬព័ត៌មានត្រួតពិនិត្យដូប៉ា ដែលត្រូវបានប្រើប្រាស់សម្រាប់គោលបំណងស្រាវជ្រាវ នឹងត្រូវបានដំណើរការជាមុនក្នុងលក្ខណៈមួយដើម្បីបង្ការការប្រើប្រាស់សំណាក និងទិន្នន័យវិភាគដែលពាក់ព័ន្ធ ឬព័ត៌មានត្រួតពិនិត្យដូប៉ាពីការស្វែងរកអត្តពលិកជាក់លាក់ណាមួយបាន។ ការស្រាវជ្រាវណាមួយដែលពាក់ព័ន្ធនឹងសំណាក និងទិន្នន័យវិភាគពាក់ព័ន្ធ ឬព័ត៌មានត្រួតពិនិត្យដូប៉ា ត្រូវប្រកាន់ខ្ជាប់នូវគោលការណ៍ ដូចដែលមានចែងក្នុងប្រការ ១៩ នៃក្រម ។

៦.៤ ស្តង់ដារស្តីពីការវិភាគសំណាក និងការរាយការណ៍

ដោយអនុលោមតាមប្រការ ៦.៤ គណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជាត្រូវស្នើសុំឱ្យមន្ទីរពិសោធន៍វិភាគសំណាកដោយអនុលោមទៅតាម ស្តង់ដារអន្តរជាតិស្តីពីមន្ទីរពិសោធន៍ និងប្រការ ៤.៧ នៃស្តង់ដារអន្តរជាតិស្តីការធ្វើតេស្ត និងការស៊ើបអង្កេត។

តាមគំនិតផ្តួចផ្តើម និងក្រោមការចំណាយរបស់ខ្លួន មន្ទីរពិសោធន៍អាចវិភាគសំណាក រកសារធាតុហាមឃាត់ ឬវិធីសាស្ត្រហាមឃាត់ដែលមិនមាននៅក្នុងបញ្ជី វិភាគសំណាកស្តង់ដារ ឬតាមការស្នើសុំពីគណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជា។ ត្រូវរាយការណ៍លទ្ធផលដែលបានមកពីការវិភាគនេះ ទៅគណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជា ហើយវាមានសុពលភាព និងផលវិបាកដូចគ្នា នឹងលទ្ធផលនៃពីការវិភាគដទៃទៀតដែរ។

៦.៥ ការវិភាគបន្ថែមទៀតលើសំណាក មុនពេល ឬក្នុងអំឡុងពេលនៃការដោះស្រាយវិវាទដូប៉ា

មិនមានដែនកំណត់លើសិទ្ធិអំណាចរបស់មន្ទីរពិសោធន៍ ក្នុងការធ្វើការវិភាគឡើងវិញ ឬការវិភាគបន្ថែមលើសំណាកមុនពេលដែលគណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជា ជូនដំណឹងដល់ អត្តពលិកថាសំណាកនោះគឺជាមូលដ្ឋានសម្រាប់ការចោទប្រកាន់ពីបទបំពានវិធានប្រឆាំងដូប៉ា។ ប្រសិនបើបន្ទាប់ពីមានការជូនដំណឹងបែបនេះ គណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជាចង់ធ្វើការវិភាគបន្ថែមលើសំណាកនោះអាចធ្វើបានដោយមានការយល់ព្រមពីអត្តពលិក ឬការយល់ព្រមពីក្រុមប្រឹក្សាសវនាការ។

៦.៦ ការវិភាគបន្ថែមលើសំណាកណាមួយ បន្ទាប់ពីវាត្រូវបានគេរាយការណ៍ថាអវិជ្ជមាន ឬមិនមានលទ្ធផលក្នុងការចោទប្រកាន់ពីបទបំពានវិធានប្រឆាំងដូប៉ា។

បន្ទាប់ពីមន្ទីរពិសោធន៍បានរាយការណ៍ពីសំណាកនោះថាអវិជ្ជមាន ឬសំណាក នោះមិននាំឱ្យមានការចោទប្រកាន់ពីបទបំពានវិធានប្រឆាំងដូប៉ាទេនោះ សំណាកនោះអាចត្រូវបានរក្សាទុក និងធ្វើការវិភាគបន្ថែមសម្រាប់គោលបំណងនៃប្រការ ៦.២ នៅគ្រប់ពេលវេលា តាមការសម្រេចផ្តាច់មុខរបស់អង្គការប្រឆាំងដូប៉ាដែលផ្តួចផ្តើម និងដឹកនាំការប្រមូលសំណាក ឬទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក។ អង្គការប្រឆាំងដូប៉ាណាមួយផ្សេងទៀតដែលមានសិទ្ធិធ្វើតេស្តអត្តពលិក និងដែលមានបំណងធ្វើការវិភាគបន្ថែមលើសំណាកដែលត្រូវបានរក្សាទុក អាចធ្វើវាបាន ដោយមានការអនុញ្ញាតពីអង្គការប្រឆាំងដូប៉ាដែលផ្តួចផ្តើម និងដឹកនាំការប្រមូលសំណាក ឬទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក ហើយត្រូវទទួលខុសត្រូវចំពោះការតាមដានការដោះស្រាយវិវាទដូប៉ា។ ការរក្សាទុកសំណាកណាមួយ ឬការវិភាគបន្ថែមដែលបានផ្តួចផ្តើមដោយទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក ឬអង្គការប្រឆាំងដូប៉ាផ្សេងទៀត ត្រូវស្ថិតក្រោមការចំណាយរបស់ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក ឬការចំណាយរបស់អង្គការប្រឆាំងដូប៉ានោះ។ ការវិភាគបន្ថែមទៀតលើសំណាក នឹងត្រូវអនុវត្តតាមលក្ខខណ្ឌតម្រូវនៃស្តង់ដារអន្តរជាតិស្តីពីមន្ទីរពិសោធន៍។

៦.៧ ការបែងចែកសំណាក (ក) ឬសំណាក (ខ)

ក្នុងករណីដែលទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក អង្គការប្រឆាំងដូប៉ាដែលមានសិទ្ធិដោះស្រាយវិវាទ និង/ឬមន្ទីរពិសោធន៍ដែលទទួលស្គាល់ដោយទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក (ផ្តល់សិទ្ធិដោយអង្គការ ឬទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក)មានបំណងញែកសំណាក (ក) ឬសំណាក (ខ) សម្រាប់គោលបំណងនៃការប្រើផ្នែកទី១ សម្រាប់ការវិភាគសំណាក (ក) និងផ្នែកទីពីរនៃសំណាក (ខ) ដែលបានញែកសម្រាប់ការបញ្ជាក់ត្រូវអនុវត្តតាមនីតិវិធីដែលមានចែងនៅក្នុងស្តង់ដារអន្តរជាតិស្តីពីមន្ទីរពិសោធន៍។

៦.៨ សិទ្ធិរបស់ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក ក្នុងការកាន់កាប់សំណាក និងទិន្នន័យ

ក្រោមការសម្រេចផ្តាច់មុខរបស់ខ្លួន នៅពេលណាក៏បាន ដោយមាន ឬគ្មានការជូនដំណឹងជាមុនទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក អាចទាមទារជាកម្មសិទ្ធិនូវសំណាក និងទិន្នន័យវិភាគ ឬព័ត៌មានដែលកាន់កាប់ដោយមន្ទីរពិសោធន៍ ឬអង្គការប្រឆាំងដូប៉ា ។ តាមការស្នើសុំដោយទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក មន្ទីរពិសោធន៍ ឬអង្គការប្រឆាំងដូប៉ាដែលកាន់កាប់សំណាក ឬទិន្នន័យ ត្រូវផ្តល់សិទ្ធិឱ្យចូលដំណើរការ និងអនុញ្ញាតឱ្យទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក កាប់កាប់ជាម្ចាស់កម្មសិទ្ធិនូវសំណាក ឬទិន្នន័យនោះ។

ប្រសិនបើ ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក មិនបានផ្តល់សេចក្តីជូនដំណឹងជាមុនដល់មន្ទីរពិសោធន៍ ឬអង្គការប្រឆាំងដូប៉ា មុនពេលចូលកាន់កាប់ជាកម្មសិទ្ធិនូវសំណាក ឬទិន្នន័យនោះទេ ទីភ្នាក់ងារនេះត្រូវជូនដំណឹងដល់មន្ទីរពិសោធន៍ និងអង្គការប្រឆាំងដូប៉ានីមួយៗដែលសំណាក ឬទិន្នន័យរបស់ខ្លួនត្រូវបានទាញយកជាកម្មសិទ្ធិ ដោយទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក ក្នុងរយៈពេលសមស្រប បន្ទាប់ពីការយកជាកម្មសិទ្ធិនោះ។ បន្ទាប់ពីការវិភាគ និងការស៊ើបអង្កេតណាមួយលើសំណាក ឬទិន្នន័យដែលរឹបអូសហើយ ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក អាចចាត់តាំងឱ្យអង្គការប្រឆាំងដូប៉ាមួយផ្សេងទៀតដែលមានសិទ្ធិក្នុងការធ្វើតេស្តលើអត្តពលិក ដើម្បីទទួលខុស ត្រូវលើការដោះស្រាយវិវាទដូប៉ាសម្រាប់សំណាក ឬទិន្នន័យនោះក្នុងករណីមានការបំពានវិធានប្រឆាំងដូប៉ា។

ប្រការ៧៖ ការដោះស្រាយវិវាទដូប៉ា ការទទួលខុសត្រូវ ការត្រួតពិនិត្យបឋម ការជូនដំណឹង និងការព្យួរសិទ្ធិបណ្តោះអាសន្ន

ការដោះស្រាយវិវាទដូប៉ា ក្រោមវិធានប្រឆាំងដូប៉ាបង្កើតជាដំណើរការមួយ ដែលត្រូវបានរៀបចំឡើង ដើម្បីដោះស្រាយបញ្ហាបំពានវិធានប្រឆាំងដូប៉ាប្រកបដោយភាពយុត្តិធម៌ រហ័ស និងមានប្រសិទ្ធភាព។

៧.១ ទំនួលខុសត្រូវក្នុងការអនុវត្តការដោះស្រាយវិវាទដូប៉ា

៧.១.១ លើកលែងតែដូចអ្វីដែលមានចែងក្នុងប្រការ ៦.៦ ប្រការ ៦.៨ និងប្រការ ៧.១ នៃក្រម ការដោះស្រាយវិវាទដូប៉ានឹងត្រូវជាទំនួលខុសត្រូវ និងត្រូវបានគ្រប់គ្រងដោយវិធាននីតិវិធីរបស់អង្គការប្រឆាំងដូប៉ាដែលបានផ្តួចផ្តើម និងដឹកនាំការប្រមូលសំណាក (ឬបើមិនមានការប្រមូលសំណាកទេ អង្គការប្រឆាំងដូប៉ា ដែលផ្តល់ការជូនដំណឹងបឋមដល់អត្តពលិក ឬបុគ្គលផ្សេងទៀតអំពីការបំពានវិធានប្រឆាំងដូប៉ា ហើយបន្ទាប់មកបន្តអនុវត្តយ៉ាងម៉ឺងម៉ាត់ចំពោះការបំពានវិធានប្រឆាំងដូប៉ានោះ)។

៧.១.២ ក្នុងករណីដែលវិធានរបស់អង្គការជាតិប្រឆាំងដូប៉ា មិនផ្តល់ដល់អង្គការជាតិប្រឆាំងដូប៉ា នូវសិទ្ធិអំណាចលើអត្តពលិក ឬបុគ្គលផ្សេងទៀតដែលមិនមានសញ្ជាតិ ឬមិនមែនជានិវាសនជន អ្នកកាន់អាជ្ញាប័ណ្ណ ឬសមាជិកនៃអង្គការកីឡានៃប្រទេសនោះ ឬក្នុងករណីដែលអង្គការជាតិប្រឆាំងដូប៉ា បដិសេធមិនអនុវត្តអំណាចបែបនោះ ការដោះស្រាយវិវាទដូប៉ា ត្រូវអនុវត្តដោយសហព័ន្ធកីឡាអន្តរជាតិដែលមានសិទ្ធិ ឬដោយតតិយជនដែលមានសិទ្ធិអំណាចលើអត្តពលិក ឬបុគ្គលផ្សេងទៀត ស្របតាមវិធានរបស់សហព័ន្ធកីឡាអន្តរជាតិដែលមានសិទ្ធិនោះ។

៧.១.៣ ការដោះស្រាយវិវាទដូប៉ាទាក់ទងទៅនឹងការខកខានផ្តល់ព័ត៌មានអំពីទីសំចត (ការខកខានក្នុងការដាក់ឯកសារ ឬមិនបានធ្វើតេស្ត) នឹងត្រូវគ្រប់គ្រងដោយសហព័ន្ធកីឡាអន្តរជាតិ ឬគណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជា ដែលអត្តពលិកនោះត្រូវដាក់ឯកសារជូនដូចមានចែងក្នុងស្តង់ដារអន្តរជាតិស្តីពីការដោះស្រាយវិវាទដូប៉ា។ ប្រសិនបើគណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជាកំណត់ថាជាការខកខានមិនបានបំពេញឯកសារ ឬការខកខានក្នុងការធ្វើតេស្ត ខ្លួននឹងបញ្ជូនព័ត៌មាននោះទៅទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោកតាមរយៈប្រព័ន្ធគ្រប់គ្រងរដ្ឋបាលប្រឆាំងដូប៉ា ដែលជាកន្លែងដែលព័ត៌មាននេះនឹងត្រូវបានផ្តល់ជូនទៅដល់ អង្គការប្រឆាំងដូប៉ាដែលពាក់ព័ន្ធផ្សេងៗទៀត។

៧.១.៤ ស្ថានភាពផ្សេងទៀតដែលគណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជា ត្រូវទទួលខុសត្រូវក្នុងការដោះស្រាយវិវាទដូប៉ា ទាក់ទងនឹងការបំពានវិធានប្រឆាំងដូប៉ាដែលពាក់ព័ន្ធនឹង អត្តពលិក និងបុគ្គល ដទៃទៀតដែលស្ថិតនៅក្រោមអំណាចរបស់ខ្លួនត្រូវបានកំណត់ និងយោងតាមប្រការ ៧ នៃក្រម។

៧.១.៥ ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក អាចចាត់តាំងឱ្យគណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជា ដោះស្រាយវិវាទដូប៉ាក្នុងកាលៈទេសៈជាក់លាក់ណាមួយ។ ប្រសិនបើគណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជាបដិសេធមិនអនុវត្តការដោះស្រាយវិវាទដូប៉ា ក្នុងរយៈពេលសមហេតុផល តាមកាលកំណត់របស់ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោកទេ ការបដិសេធបែបនេះនឹងត្រូវបានចាត់ទុកថាជាការមិនអនុវត្តមតាម ហើយទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក អាចចាត់តាំងឱ្យអង្គការប្រឆាំងដូប៉ាមួយផ្សេងទៀត ដែលមានអំណាចលើអត្តពលិក ឬបុគ្គលផ្សេងទៀត ដែលមានឆន្ទៈក្នុងការធ្វើដូច្នេះដើម្បីទទួលអនុវត្តការងារ ការដោះស្រាយវិវាទដូប៉ាជំនួសឱ្យគណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជា ឬក្នុងករណីដែលមិនមានអង្គការប្រឆាំងដូប៉ាបែបនោះទេ អង្គការប្រឆាំងដូប៉ាណាមួយផ្សេងទៀត ដែលមានបំណងទទួលយកការងារនេះ។ ក្នុងករណីបែបនេះ គណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជាត្រូវសងថ្លៃចំណាយ និងថ្លៃសេវា មេធាវី ក្នុងការអនុវត្តការដោះស្រាយវិវាទដូប៉ា ទៅឱ្យអង្គភាពប្រឆាំងដូប៉ាផ្សេងទៀតដែលកំណត់ដោយ ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក ហើយការខកខានក្នុងការទូទាត់សំណងនិងថ្លៃសេវាមេធាវីនឹងត្រូវចាត់ទុកថាជាការមិនគោរពច្បាប់។

៧.២ ការពិនិត្យឡើងវិញ និងការជូនដំណឹងទាក់ទងនឹងការបំពានវិធានប្រឆាំងដូប៉ា

គណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជាត្រូវអនុវត្តការត្រួតពិនិត្យ និងការជូនដំណឹងទាក់ទងនឹងការបំពានវិធាន

ប្រឆាំងដូប៉ាណាមួយដែលមានសក្ដានុពល ស្របតាមស្តង់ដារអន្តរជាតិស្តីពីការដោះស្រាយវិវាទដូប៉ា។

៧.៣ ការកំណត់អត្តសញ្ញាណនៃការបំពានវិធានប្រឆាំងដូប៉ា

មុនពេលផ្ដល់ការជូនដំណឹងដល់អត្តពលិក ឬបុគ្គលផ្សេងទៀតអំពីការបំពានវិធានប្រឆាំងដូប៉ា ដូចមានចែងខាងលើ គណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជា ត្រូវយោងលើប្រព័ន្ធគ្រប់គ្រងរដ្ឋបាលប្រឆាំងដូប៉ា និងទាក់ទងទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក និងអង្គការប្រឆាំងដូប៉ាដទៃទៀត ដើម្បីកំណត់ថាតើមានការបំពានវិធានប្រឆាំងដូប៉ាណាមួយ ឬអត់ពីមុនមក។

៧.៤ ការព្យួរសិទ្ធិបណ្ដោះអាសន្ន

៧.៤.១ ការព្យួរសិទ្ធិបណ្ដោះអាសន្នដែលចាំបាច់បន្ទាប់ពីការរកឃើញលទ្ធផលវិភាគវិជ្ជមាន ឬលទ្ធផលប្រវត្តិជីវសាស្ត្រមិនល្អ

ប្រសិនបើគណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជាទទួលបានលទ្ធផលវិភាគវិជ្ជមាន ឬលទ្ធផលប្រវត្តិជីវសាស្ត្រមិនល្អ (នៅពេលបញ្ចប់ដំណើរការពិនិត្យលទ្ធផលប្រវត្តិជីវសាស្ត្រមិនល្អនោះ) សម្រាប់សារធាតុហាមឃាត់ ឬវិធីសាស្ត្រហាមឃាត់ ដែលមិនមែនជាសារធាតុជាក់លាក់ ឬវិធីសាស្ត្រជាក់លាក់ ស្ថាប័ននេះត្រូវសម្រេចព្យួរសិទ្ធិបណ្ដោះអាសន្ន លើអត្តពលិកនោះភ្លាមៗ ឬបន្ទាប់ពីការពិនិត្យឡើងវិញ និងការជូនដំណឹងដែលតម្រូវដោយប្រការ ៧.២ ។

ការព្យួរសិទ្ធិបណ្ដោះអាសន្ន អាចត្រូវបានលុបចោល ប្រសិនបើ៖

(i) អត្តពលិកបង្ហាញដល់ក្រុមប្រឹក្សាជំនុំជម្រះ នៃគណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជាថាការបំពាននោះទំនងជាពាក់ព័ន្ធនឹងផលិតផលមិនស្មោះត្រង់ ឬ
(ii) ការបំពាននោះពាក់ព័ន្ធនឹងសារធាតុបំពាន ហើយអត្តពលិក អាចបង្ហាញពីសិទ្ធិប្រើប្រាស់សម្រាប់រយៈពេលខ្លីនៃការព្យួរសិទ្ធិ តាមប្រការ ១០.២.៤.១។

សេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាជំនុំជម្រះរបស់គណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជា ក្នុងការមិនលុបការព្យួរសិទ្ធិបណ្ដោះអាសន្នចាំបាច់ តាមការអះអាងរបស់អត្តពលិកទាក់ទងនឹងផលិតផលដែលមានផ្ទុកសារធាតុដូប៉ាមិនត្រូវបានយកមកអនុវត្តទេ។

៧.៤.២ ការព្យួរសិទ្ធិបណ្ដោះអាសន្ន ជាជម្រើសផ្អែកលើលទ្ធផលវិភាគវិជ្ជមានសម្រាប់សារធាតុជាក់លាក់ វិធីសាស្ត្រជាក់លាក់ ផលិតផលមិនស្មោះត្រង់ ឬការបំពានវិធានប្រឆាំងដូប៉ាផ្សេងទៀត។

គណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជាអាចដាក់ពិន័យដោយ ការព្យួរសិទ្ធិបណ្ដោះអាសន្ន ចំពោះការបំពានវិធានប្រឆាំងដូប៉ាដែលមិនមានចែងក្នុងប្រការ ៧.៤.១ មុនការវិភាគសំណាក (ខ) របស់អត្តពលិក ឬសវនាការចុងក្រោយ ដូចដែលបានកំណត់នៅក្នុងប្រការ ៨ ។

ការព្យួរសិទ្ធិបណ្ដោះអាសន្នដែលមិនតម្រូវ អាចត្រូវបានលើកលែងវិញ តាមសេចក្ដីសម្រេចរបស់គណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជា នៅពេលណាមួយ មុនពេលនៃការចេញសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាជំនុំជម្រះនៃគណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជាក្រោមប្រការ ៨ លុះត្រាតែមានការចែងផ្សេងពីនេះនៅក្នុងស្តង់ដារអន្តរជាតិស្តីពីការដោះស្រាយវិវាទដូប៉ា។

៧.៤.៣ ឱកាសទទួលបានសវនាការ ឬបណ្ដឹងជំទាស់

ទោះដូចមានចែងក្នុងប្រការ ៧.៤.១ និងប្រការ ៧.៤.២ ក៏ដោយ ការព្យួរសិទ្ធិបណ្ដោះអាសន្ន មិនអាចត្រូវបានអនុវត្តទេ លុះត្រាតែ អត្តពលិក ឬបុគ្គលផ្សេងទៀតនោះបានទទួលៈ

ក. ឱកាសសម្រាប់ សវនាការបណ្ដោះអាសន្ន ទោះមុនពេល ឬនៅពេលសមស្របបន្ទាប់ពីការដាក់ពិន័យព្យួរសិទ្ធិបណ្ដោះអាសន្ននោះ ឬ

ខ. ឱកាសសម្រាប់សវនាការបន្ទាន់មួយ ស្របតាមប្រការ ៨ ដោយឈរលើមូលដ្ឋានពេលវេលាសមស្របបន្ទាប់ពីការដាក់ពិន័យព្យួរសិទ្ធិបណ្ដោះអាសន្ននោះ។

ការដាក់ពិន័យ ព្យួរសិទ្ធិបណ្ដោះអាសន្ន ឬសេចក្ដីសម្រេចមិនដាក់ពិន័យ ព្យួរសិទ្ធិបណ្ដោះអាសន្ន អាចត្រូវបានប្ដឹងជំទាស់ក្នុងដំណើរការបន្ទាន់មួយ ស្របតាមប្រការ ១៣.២ ។

៧.៤.៤ ការទទួលយកដោយស្ម័គ្រចិត្តនៃការព្យួរសិទ្ធិបណ្ដោះអាសន្ន

តាមគំនិតផ្ដួចផ្ដើមផ្ទាល់ខ្លួន អត្តពលិក អាចទទួលយកការព្យួរសិទ្ធិបណ្ដោះអាសន្នដោយស្ម័គ្រចិត្ត ប្រសិនបើពួកគេធ្វើដូច្នេះ មុនរយៈពេលចុងក្រោយនេះ

(i) ការផុតកំណត់រយៈពេល ១០(ដប់)ថ្ងៃ បន្ទាប់ពីរបាយការណ៍ សំណាក (ខ) (ឬ ការបោះបង់សិទ្ធិលើសំណាក (ខ) ឬ ១០(ដប់)ថ្ងៃ បន្ទាប់ពីការជូនដំណឹងអំពីការបំពានវិធានប្រឆាំងដូប៉ាផ្សេងទៀត។ ឬ

(ii) កាលបរិច្ឆេទដែល អត្តពលិក ចូលរួមប្រកួតដំបូង បន្ទាប់ពីមានរបាយការណ៍ ឬការជូនដំណឹងបែបនេះ។

ក្រោមគំនិតផ្ដួចផ្ដើមដោយខ្លួនឯង បុគ្គលផ្សេងទៀតអាចទទួលយកការព្យួរសិទ្ធិបណ្ដោះអាសន្នដោយស្ម័គ្រចិត្ត ប្រសិនបើធ្វើដូច្នេះក្នុងរយៈពេល ១០(ដប់)ថ្ងៃ ចាប់ពីការជូនដំណឹងអំពីការបំពានវិធានប្រឆាំងដូប៉ាតទៅ។

ក្រោយការទទួលយកដោយស្ម័គ្រចិត្តបែបនេះ ការព្យួរសិទ្ធិបណ្ដោះអាសន្ន នឹងមានប្រសិទ្ធិភាពពេញលេញ និងត្រូវបានអនុវត្តដូចគ្នានឹង ការព្យួរសិទ្ធិបណ្ដោះអាសន្ន ដូចដែលត្រូវបានកំណត់ក្នុងប្រការ ៧.៤.១ ឬប្រការ ៧.៤.២ ក្នុងលក្ខខណ្ឌដែលថានៅពេលណាមួយបន្ទាប់ពីទទួលយកការព្យួរសិទ្ធិបណ្ដោះអាសន្នដោយស្ម័គ្រចិត្តនេះ អត្តពលិក ឬបុគ្គលផ្សេងទៀតអាចដកការទទួលយកការព្យួរសិទ្ធិនេះវិញ បានដែលក្នុងករណីនេះ អត្តពលិក ឬបុគ្គលផ្សេងទៀតនឹងមិនទទួលបានការលើកលែងណាមួយចំពោះការអនុវត្តពីមុនក្នុងកំឡុងពេលនៃការព្យួរសិទ្ធិបណ្ដោះអាសន្ននោះទេ។

៧.៤.៥ ប្រសិនបើការព្យួរសិទ្ធិបណ្ដោះអាសន្ននោះផ្អែកលើលទ្ធផលវិភាគវិជ្ជមាននៃសំណាក (ក) ហើយបន្ទាប់មកការវិភាគសំណាក (ខ) (ប្រសិនបើស្នើសុំដោយអត្តពលិក ឬគណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជា) មិនបានបញ្ជាក់សុពលភាពនៃការវិភាគសំណាក (ក) ទេនោះ អត្តពលិក នឹងមិនត្រូវទទួលរងការព្យួរសិទ្ធិបណ្ដោះអាសន្នបន្ថែម លើការបំពានប្រការ ២.១ ទេ។ ក្នុងកាលៈទេសៈដែលអត្តពលិក ឬក្រុមរបស់អត្តពលិក ត្រូវបានដកចេញពីព្រឹត្តិការណ៍កីឡាណាមួយ ដោយផ្អែកលើការបំពានប្រការ ២.១ ហើយបន្ទាប់មកការវិភាគសំណាក (ខ) មិនបញ្ជាក់សុពលភាពលទ្ធផល សំណាក (ក) នោះ ប្រសិនបើវានៅតែអាចឱ្យអត្តពលិក ឬក្រុមនោះ អាចបន្តចូលរួមក្នុងព្រឹត្តិការណ៍នោះបាន។ ឬក្រុមរបស់អត្តពលិក ចូលរួមព្រឹត្តិការណ៍នោះឡើងវិញ ដោយមិនមានការប៉ះពាល់ដល់ព្រឹត្តិការណ៍ អត្តពលិក។

៧.៥ សេចក្ដីសម្រេចស្ដីពីការដោះស្រាយវិវាទដូប៉ា

សេចក្ដីសម្រេចលើការដោះស្រាយវិវាទដូប៉ា ឬសេចក្ដីសម្រេចរបស់គណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជា មិន

ត្រូវបង្ហាញថា កំណត់ត្រឹមតែចំពោះតំបន់ភូមិសាស្ត្រ ឬកីឡាជាក់លាក់ណាមួយឡើយ ហើយដោយគ្មានដែនកំណត់ ត្រូវដោះស្រាយ និងកំណត់បញ្ហាដូចខាងក្រោម៖

(i) កំណត់ថាតើមានការបំពានវិធានប្រឆាំងដូប៉ាឬទេ ឬថាតើគួរធ្វើការព្យួរសិទ្ធិបណ្តោះអាសន្ន ឬទេ កំណត់ មូលដ្ឋានសម្រាប់ធ្វើសេចក្តីសម្រេច និងកំណត់ប្រការជាក់លាក់ដែលត្រូវបានបំពាន។ និង

(ii) រាល់ទណ្ឌកម្ម ទាំងអស់ដែលកើតចេញពីការបំពានវិធានប្រឆាំងដូប៉ា រួមទាំងការដកសិទ្ធិ តាមប្រការ ៩ និង ១០.១០ ការដកមេដាយ ឬរង្វាន់មកវិញ រយៈពេលព្យួរសិទ្ធិ (និងកាលបរិច្ឆេទចាប់ផ្តើមដំណើរការ) និងទណ្ឌកម្មហិរញ្ញវត្ថុណាមួយ។

៧.៦ ការជូនដំណឹងអំពីសេចក្តីសម្រេចលើការដោះស្រាយវិវាទដូប៉ា

គណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជាត្រូវជូនដំណឹងដល់ អត្តពលិក បុគ្គលផ្សេងទៀត ស្ថាប័នហត្ថលេខី និងទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក អំពីសេចក្តីសម្រេចលើការដោះស្រាយវិវាទដូប៉ា ដូចមានចែងក្នុងប្រការ ១៤.២ និងក្នុងស្តង់ដារអន្តរជាតិស្តីពីការដោះស្រាយវិវាទដូប៉ា។

៧.៧ ការចូលនិវត្តន៍ពីកីឡា

ប្រសិនបើអត្តពលិក ឬបុគ្គលផ្សេងទៀតចូលនិវត្តន៍នៅពេលដែលគណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជាកំពុងដំណើរការដោះស្រាយវិវាទដូប៉ា គណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជារក្សាសិទ្ធិក្នុងការបញ្ចប់ដំណើរការការដោះស្រាយវិវាទដូប៉ារបស់ខ្លួន។ ប្រសិនបើអត្តពលិក ឬបុគ្គលផ្សេងទៀតចូលនិវត្តន៍មុនពេលនៃការចាប់ផ្តើមដំណើរការដោះស្រាយវិវាទដូប៉ា ហើយប្រសិនបើគណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជាអាចមានសិទ្ធិលើការគ្រប់គ្រងលើអត្តពលិក ឬបុគ្គលផ្សេងទៀតនោះ នៅពេលដែលអត្តពលិក ឬបុគ្គលផ្សេងទៀតនោះ បានប្រព្រឹត្តបំពានវិធានប្រឆាំងដូប៉ា គណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជាមានសិទ្ធិក្នុងការអនុវត្តការដោះស្រាយវិវាទដូប៉ា។

ប្រការ៨៖ ការដោះស្រាយវិវាទដូប៉ា៖ សិទ្ធិទទួលបានសវនាការយុត្តិធម៌ និងការជូនដំណឹងអំពីសេចក្តីសម្រេចរបស់សវនាការ

ចំពោះបុគ្គលណាដែលត្រូវបានអះអាងថា បានប្រព្រឹត្តការបំពានវិធានប្រឆាំងដូប៉ា គណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជាត្រូវផ្តល់សវនាការដោយយុត្តិធម៌ក្នុងរយៈពេលសមហេតុផល តាមរយៈក្រុមប្រឹក្សាជំនុំជម្រះដែលយុត្តិធម៌ មិនលម្អៀង និងឯករាជ្យក្នុងប្រតិបត្តិការ ដោយអនុលោមតាមក្រម និងស្តង់ដារអន្តរជាតិស្តីពីការដោះស្រាយវិវាទដូប៉ា។

៨.១ សវនាការយុត្តិធម៌

៨.១.១ ក្រុមប្រឹក្សាជំនុំជម្រះដែល យុត្តិធម៌ មិនលម្អៀង និងឯករាជ្យក្នុងប្រតិបត្តិការ

៨.១.១.១ គណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជាត្រូវបង្កើតក្រុមប្រឹក្សាជំនុំជម្រះ ដែលមានយុត្តាធិការក្នុងការធ្វើសវនាការ និងកំណត់ ថាតើអត្តពលិក ឬបុគ្គលផ្សេងទៀតដែលស្ថិតក្រោមវិធានប្រឆាំងដូប៉ា បានប្រព្រឹត្តនូវការបំពានវិធានប្រឆាំងដូប៉ាឬទេ ហើយបើអាចត្រូវដាក់ទណ្ឌកម្មដែលពាក់ព័ន្ធ។

៨.១.១.២ គណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជា ត្រូវធានាថាក្រុមប្រឹក្សាសវនាការ របស់គណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជាមិនមានទំនាស់ផលប្រយោជន៍ ហើយធានាថាសមាសភាព អាណត្តិ

បទពិសោធន៍វិជ្ជាជីវៈ ឯករាជ្យភាពនៃប្រតិបត្តិការ និងការផ្ដល់ហិរញ្ញប្បទានគ្រប់គ្រាន់ស្រប តាមលក្ខខណ្ឌតម្រូវនៃស្តង់ដារអន្តរជាតិស្តីពីការដោះស្រាយវិវាទដូប៉ា ។

៨.១.១.៣ សមាជិកក្រុមប្រឹក្សា បុគ្គលិក សមាជិកគណៈកម្មការ ទីប្រឹក្សា និងមន្ត្រីនៃគណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជា ឬស្ថាប័នរបស់ខ្លួន ក៏ដូចជា បុគ្គលដែលពាក់ព័ន្ធនឹងការស៊ើបអង្កេត និងការធ្វើបុរេវិនិច្ឆ័យលើបញ្ហានោះ មិនអាចត្រូវបានតែងតាំងជាសមាជិក និង/ឬស្មៀន (ក្នុងកម្រិតវិសាលភាពដែលថាមន្ត្រី ឬស្មៀននោះចូលរួមនៅក្នុងដំណើរការពិភាក្សា និង/ឬការធ្វើសេចក្តីព្រាងនៃសេចក្តីសម្រេចណាមួយ) នៃក្រុមប្រឹក្សាជំនុំជម្រះរបស់ទីគណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជាឡើយ។ ជាពិសេសគ្មានសមាជិកណាម្នាក់គួរពិចារណាលើពាក្យស្នើសុំការលើកលែងឱ្យប្រើប្រាស់ថ្នាំព្យាបាល សេចក្ដីសម្រេចលើការដោះស្រាយវិវាទដូប៉ា ឬបណ្ដឹងជំទាស់ក្នុងករណីដូចគ្នានេះទេ។

៨.១.១.៤ ក្រុមប្រឹក្សាជំនុំជម្រះរបស់គណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជាមានប្រធានឯករាជ្យ និងសមាជិកឯករាជ្យ ២(ពីរ)នាក់ ផ្សេងទៀត។

៨.១.១.៥ សមាជិកម្នាក់ៗត្រូវបានតែងតាំង ដោយផ្អែកលើបទពិសោធប្រឆាំងដូប៉ា រួមទាំងជំនាញច្បាប់ កីឡា វេជ្ជសាស្ត្រ និង/ឬវិទ្យាសាស្ត្ររបស់ពួកគេ។ សមាជិកនីមួយៗនឹងត្រូវបានតែងតាំងសម្រាប់អណត្តិ ៣(បី)ឆ្នាំ ដែលបន្តទៀតបាន។

៨.១.១.៦ ក្រុមប្រឹក្សាជំនុំជម្រះរបស់គណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជា ត្រូវមានតួនាទីអនុវត្តដំណើរការសវនាការ និងការធ្វើសេចក្តីសម្រេច ដោយមិនមានការជ្រៀតជ្រែកពីគណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជា ឬភាគីទី៣ ណាមួយឡើយ។

## ៨.១.២ ដំណើរការនៃសវនាការ

៨.១.២.១ នៅពេលគណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជាផ្ញើសេចក្តីជូនដំណឹងទៅអត្តពលិក ឬបុគ្គលផ្សេងទៀតជូនដំណឹងដល់ពួកគេអំពីការបំពានវិធានប្រឆាំងដូប៉ាហើយ អត្តពលិក ឬបុគ្គលដទៃទៀតមិនបោះបង់សិទ្ធិទទួលបានសវនាការទេ ដោយអនុលោមតាមប្រការ ៨.៣.១ ឬប្រការ ៨.៣.២ នោះករណីនឹងត្រូវបានបញ្ជូនទៅក្រុមប្រឹក្សាជំនុំជម្រះ របស់គណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជាសម្រាប់សវនាការ និងការជំរះក្តីដែលនឹងត្រូវធ្វើឡើងដោយអនុលោមតាមគោលការណ៍ដែលបានចែងក្នុងប្រការ ៨ និងប្រការ ៩ នៃស្តង់ដារអន្តរជាតិស្តីពីការដោះស្រាយវិវាទដូប៉ា។

៨.១.២.២ ប្រធានត្រូវតែងតាំងសមាជិក ៣(បី)នាក់ (ដែលអាចរួមបញ្ចូលទាំងប្រធាន) ដើម្បីចូលសវនាការនោះ។ នៅក្នុងពេលសវនាការ ត្រូវតែមានសមាជិក ១(មួយ)រូប ជាមេធាវីមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដែលមានបទពិសោធន៍ផ្នែកច្បាប់មិនតិចជាង ៣(បី)ឆ្នាំ និងសមាជិកគណៈកម្មាធិការ ១(មួយ)រូប ជាអ្នកជំនាញខាងវេជ្ជសាស្ត្រដែលមានបទពិសោធន៍វេជ្ជសាស្ត្រពាក់ព័ន្ធមិនតិចជាង ៣(បី)ឆ្នាំ។

៨.១.២.៣ ក្រោយពេលប្រធានតែងតាំងជាសមាជិកនៃក្រុមប្រឹក្សាជំនុំជម្រះ របស់គណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជា ហើយសមាជិកត្រូវតែចុះហត្ថលេខាលើសេចក្តីប្រកាសមួយដែលថា មិនមានហេតុការណ៍ ឬកាលៈទេសៈដែលខ្លួនបានដឹងណាមួយ ដែលអាចធ្វើឱ្យមានការសង្ស័យចំពោះភាពមិនលម្អៀងរបស់ខ្លួន នៅក្នុងក្រសែភ្នែករបស់ភាគីណាមួយ ក្រៅតែពីស្ថានភាពដែលត្រូវបានបង្ហាញនៅក្នុងសេចក្តីប្រកាសនោះឡើយ។

៨.១.២.៤ សវនាការដែលធ្វើឡើងទាក់ទងនឹងព្រឹត្តិការណ៍ដែលពាក់ព័ន្ធនឹងអត្តពលិក និងបុគ្គលផ្សេងទៀត ដែលស្ថិតក្រោមវិធានប្រឆាំងដូប៉ាទាំងនេះ អាចត្រូវបានធ្វើឡើងតាមដំណើរការរហ័ស

ក្នុងករណីដែលបានអនុញ្ញាតដោយក្រុមប្រឹក្សាសវនាការ របស់គណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជា។

៨.១.២.៥ ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក សហព័ន្ធអន្តរជាតិ និងសហព័ន្ធកីឡាជាតិ ឬបុគ្គលផ្សេងទៀត អាចចូលរួមសវនាការជាអ្នកសង្កេតការណ៍។ ក្នុងករណីណាក៏ដោយគណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជា ត្រូវមានព័ត៌មានបច្ចុប្បន្នភាពពេញលេញ ទាក់ទងនឹងស្ថានភាពនៃបណ្តឹងដែលមិនទាន់សម្រេច និងលទ្ធផលនៃសវនាការទាំងអស់។

៨.២ ការជូនដំណឹងស្តីពីការសេចក្តីសម្រេច

៨.២.១ នៅចុងបញ្ចប់នៃសវនាការ ឬភ្លាមៗបន្ទាប់ពីនោះ ក្រុមប្រឹក្សាជំនុំជម្រះរបស់ គណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជា ត្រូវចេញសេចក្តីសម្រេចជាលាយលក្ខណ៍អក្សរ ដោយអនុលោមតាមប្រការ ៩ នៃស្តង់ដារអន្តរជាតិស្តីពីការដោះស្រាយវិវាទដូប៉ា ហើយដែលរួមបញ្ចូលហេតុផលពេញលេញសម្រាប់សេចក្តីសម្រេចនោះ រយៈពេលនៃការព្យួរសិទ្ធិ ការបដិសេធលទ្ធផលប្រកួតក្រោមប្រការ ១០.១០ ហើយប្រសិនបើអាចការពន្យល់ថាតើហេតុអ្វីមិនដាក់ទណ្ឌកម្មធ្ងន់បំផុត។

៨.២.២ គណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជា ត្រូវជូនដំណឹងពីសេចក្តីសម្រេចនោះដល់ អត្តពលិក ឬបុគ្គល និងអង្គការប្រឆាំងដូប៉ាផ្សេងទៀត ដែលមានសិទ្ធិប្តឹងជំទាស់តាមប្រការ ១៣.២.៣ ហើយត្រូវរាយការណ៍ទៅប្រព័ន្ធគ្រប់គ្រងរដ្ឋបាលប្រឆាំងដូប៉ាជាបន្ទាន់។ សេចក្តីសម្រេចនោះអាចត្រូវបានប្តឹងជំទាស់ ដូចមានចែងក្នុងប្រការ ១៣ ។

៨.៣ ការបោះបង់សិទ្ធិទទួលបានសវនាការ

៨.៣.១ អត្តពលិក ឬបុគ្គលផ្សេងទៀតដែលត្រូវបានចោទពីបទបំពានលើវិធានប្រឆាំងដូប៉ាអាចសារភាព អំពីការបំពាននោះ បានគ្រប់ពេលវេលា លះបង់សិទ្ធិទទួបានសវនាការ និងទទួលយកទណ្ឌកម្មដែលដាក់ដោយគណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជា។

៨.៣.២ ទោះជាយ៉ាងណាក៏ដោយ ប្រសិនបើអត្តពលិក ឬបុគ្គលផ្សេងទៀតដែលត្រូវបានចោទពីបទបំពាវិធានប្រឆាំងដូប៉ា មិនបានជំទាស់នឹងការចោទនេះ ក្នុងរយៈពេល ២០(ម្ភៃ)ថ្ងៃ ឬមុនថ្ងៃផុតកំណត់ដែលបានបញ្ជាក់នៅក្នុងសេចក្តីជូនដំណឹង ដែលបានផ្ញើដោយគណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជា ដែលបញ្ជាក់ពីការបំពាននោះទេ ពួកគេនឹងត្រូវបានសន្មតថាបានសារភាពចំពោះការបំពាននោះ និងថាបានបោះបង់សិទ្ធិទទួលបានសវនាការ និងទទួលយកទណ្ឌកម្មដែលបានស្នើឡើង។

៨.៣.៣ ក្នុងករណីដែលប្រការ ៨.៣.១ ឬប្រការ ៨.៣.២ ត្រូវបានអនុវត្តមិនតម្រូវឱ្យមានសវនាការនៅចំពោះមុខក្រុមប្រឹក្សាសវនាការរបស់គណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជាទេ។ ប៉ុន្តែគណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជាត្រូវចេញសេចក្តីសម្រេចជាលាយលក្ខណ៍អក្សរដែលអនុលោមតាមប្រការ ៩ នៃស្តង់ដារអន្តរជាតិស្តីពីការដោះស្រាយវិវាទដូប៉ា ហើយដែលរួមបញ្ចូលទាំងហេតុផលពេញលេញ សម្រាប់សេចក្តីសម្រេចនោះ រយៈពេលនៃការព្យួរសិទ្ធិ ការបដិសេធលទ្ធផលប្រកួត តាមប្រការ ១០.១០ ហើយបើអាចហេតុផលថាតើហេតុអ្វីមិនដាក់ទណ្ឌកម្មធ្ងន់បំផុត។

៨.៣.៤ គណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជាត្រូវជូនដំណឹង ពីសេចក្តីសម្រេចនោះដល់អត្តពលិក ឬបុគ្គល និងអង្គការប្រឆាំងដូប៉ាផ្សេងទៀត ដែលមានសិទ្ធិប្តឹងជំទាស់តាមប្រការ ១៣.២.៣ ហើយត្រូវរាយការណ៍ទៅប្រព័ន្ធគ្រប់គ្រងរដ្ឋបាលប្រឆាំងដូប៉ាជាបន្ទាន់។ គណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជា ត្រូវបង្ហាញជាសាធារណៈនូវសេចក្តីសម្រេចនោះស្របតាមប្រការ ១៤.៣.២។

៨.៤ សវនាការតែមួយនៅចំពោះមុខមជ្ឈតកម្មកីឡា

ការបំពានវិធានប្រឆាំងដូប៉ាដែលត្រូវបានចោទប្រឆាំងនឹងអត្តពលិកកម្រិតអន្តរជាតិ អត្តពលិកកម្រិតជាតិ ឬបុគ្គលដទៃទៀត ដោយមានការយល់ព្រមពីអត្តពលិក ឬបុគ្គលផ្សេងទៀតគណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជា (ក្នុងករណីទទួលខុសត្រូវក្នុងការដោះស្រាយវិវាទដូប៉ាស្របតាមប្រការ ៧) និងទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក អាចត្រូវបានធ្វើសវនាការរួមដោយផ្ទាល់នៅមជ្ឈតកម្មកីឡា។

ប្រការ៩៖ ការបដិសេធលទ្ធផលប្រកួតដោយស្វ័យប្រវត្តិ

ការបំពានវិធានប្រឆាំងដូប៉ានៅក្នុងកីឡានីមួយៗ ពាក់ព័ន្ធនឹងការធ្វើតេស្តសម្រាប់ការប្រកួតនាំឱ្យមានការបដិសេធលទ្ធផលប្រកួតដោយស្វ័យប្រវត្តិ ព្រមទាំងទណ្ឌកម្មទាំងអស់ រួមទាំងការដកមេដាយ ពិន្ទុ និងរង្វាន់មកវិញ។

ប្រការ១០៖ ការដាក់ទណ្ឌកម្មលើបុគ្គល

១០.១ ការបដិសេធលទ្ធផលនៅក្នុងការប្រកួត ដែលមានការបំពានវិធានប្រឆាំងដូប៉ា

១០.១.១ ការបំពានវិធានប្រឆាំងដូប៉ាដែលកើតឡើងក្នុងអំឡុងពេល ឬពាក់ព័ន្ធនឹងព្រឹត្តិការណ៍កីឡាមួយ តាមសេចក្តីសម្រេចរបស់ស្ថាប័នគ្រប់គ្រងព្រឹត្តិការណ៍នោះ អាចនាំឱ្យមានការបដិសេធលទ្ធផលប្រកួតទាំងអស់របស់អត្តពលិកដែលទទួលបានក្នុងព្រឹត្តិការណ៍កីឡានោះ ជាមួយទណ្ឌកម្មទាំងអស់ ដែលរួមទាំងការដកមេដាយ ពិន្ទុ និងរង្វាន់ទាំងអស់មកវិញ លើកលែងតែករណីដូចមានចែងក្នុងប្រការ ១០.១.២។

កត្តាអង្គដែលត្រូវបានរាប់បញ្ចូលក្នុងការពិចារណាថា តើត្រូវបដិសេធលទ្ធផលប្រកួតផ្សេងទៀតនៅក្នុងព្រឹត្តិការណ៍មួយ អាចរួមបញ្ចូល ឧទាហរណ៍ ភាពធ្ងន់ធ្ងរនៃការបំពានលើវិធានប្រឆាំងដូប៉ារបស់ អត្តពលិក និងថាតើអត្តពលិក មានលទ្ធផលតេស្តអវិជ្ជមាននៅក្នុងការប្រកួតដទៃទៀត ឬទេ។

១០.១.២ ប្រសិនបើអត្តពលិកអាចបញ្ជាក់ថាខ្លួនមិនមានកំហុស ឬការធ្វេសប្រហែស ចំពោះការបំពានបំពាននោះ លទ្ធផលប្រកួតរបស់អត្តពលិក ក្នុងការប្រកួតផ្សេងទៀតនឹងមិនត្រូវបានបដិសេធឡើយ លើកលែងតែលទ្ធផលរបស់អត្តពលិកក្នុងការប្រកួត ដែលកើតមានការបំពានវិធានប្រឆាំងដូប៉ានោះផ្ទាល់ ហើយវាទំនងជាប៉ះពាល់ដល់លទ្ធផលប្រកួតរបស់អត្តពលិក។

១០.២ ការព្យួរសិទ្ធិ ចំពោះវត្តមាន ការប្រើប្រាស់ ឬប៉ុនប៉ងប្រើប្រាស់ ឬការកាន់កាប់ សារធាតុហាមឃាត់ ឬវិធីសាស្ត្រហាមឃាត់

រយៈពេលនៃការព្យួរសិទ្ធិចំពោះការបំពានលើប្រការ ២.១ ប្រការ ២.២ ឬប្រការ ២.៦ នឹងមានដូចខាងក្រោម អាស្រ័យតាមការបន្ធូរបន្ថយ ឬការព្យួរសក្ដានុពល ស្របតាមប្រការ ១០.៥ ប្រការ ១០.៦ ឬប្រការ ១០.៧៖

១០.២.១ រយៈពេលនៃការព្យួរសិទ្ធិ អាស្រ័យតាមប្រការ ១០.២.៤ នឹងមានរយៈពេល ៤(បួន)ឆ្នាំ ក្នុងករណីដែល៖

១០.២.១.១ ការបំពានវិធានប្រឆាំងដូប៉ាមិនពាក់ព័ន្ធនឹងសារធាតុជាក់លាក់ លើកលែងតែអត្តពលិក ឬបុគ្គលផ្សេងទៀត អាចបញ្ជាក់ថាការបំពានវិធានប្រឆាំងដូប៉ាកើតឡើងដោយមិនមានចេតនា។

១០.២.១.២ ការបំពានលើវិធានប្រឆាំងដូប៉ាពាក់ព័ន្ធនឹងសារធាតុជាក់លាក់ ហើយគណៈកម្មាធិការប្រឆាំង

ដូប៉ាកម្ពុជា អាចបញ្ជាក់ថាការបំពានវិធានប្រឆាំងដូប៉ាកើតឡើងដោយមានចេតនា។

១០.២.២ ប្រសិនបើប្រការ ១០.២.១ មិនត្រូវបានអនុវត្តទេ អាស្រ័យតាមប្រការ ១០.២.៤.១ រយៈពេលនៃការព្យួរសិទ្ធិគឺ ២(ពីរ)ឆ្នាំ។

១០.២.៣ ដូចដែលបានប្រើក្នុងប្រការ ១០.២ ពាក្យ "មានចេតនា" ត្រូវបានប្រើដើម្បីកំណត់ អត្តពលិក ឬបុគ្គលផ្សេងទៀតដែលពាក់ព័ន្ធក្នុងការប្រព្រឹត្ត ដែលពួកគេបានដឹងថាជាការបំពានវិធានប្រឆាំងដូប៉ា ឬដឹងថាមានហានិភ័យធ្ងន់ធ្ងរ ដែលការប្រព្រឹត្តនោះអាចជា ឬបណ្តាលឱ្យមាន ការបំពានវិធានប្រឆាំងដូប៉ា និងការមិនអើពើចំពោះហានិភ័យនោះ។ ការបំពានវិធានប្រឆាំងដូប៉ាដែលកើតចេញពីលទ្ធផលវិភាគវិជ្ជមាន ដែលបានរកឃើញសារធាតុហាមឃាត់តែនៅក្នុងការប្រកួត នឹងត្រូវបានសន្មតថា "មិនមានចេតនា" ប្រសិនបើសារធាតុនោះជាសារធាតុជាក់លាក់ ហើយអត្តពលិកអាចបង្ហាញថា សារធាតុហាមឃាត់នោះត្រូវបានគេប្រើប្រាស់នៅក្រៅការប្រកួត។ ការបំពានវិធានប្រឆាំងដូប៉ាដែលបណ្តាលមកពីលទ្ធផលវិភាគវិជ្ជមានសម្រាប់ការស្វែងរកសារធាតុហាមឃាត់ ក្នុងការប្រកួត នឹងមិនត្រូវបានចាត់ទុកថា "មានចេតនា" ទេ ប្រសិនបើសារធាតុនោះមិនមែនជាសារធាតុជាក់លាក់ ហើយអត្តពលិក អាចបញ្ជាក់ថា សារធាតុហាមឃាត់នោះត្រូវបាន គេប្រើប្រាស់នៅក្រៅការប្រកួត នៅក្នុងបរិបទដែលមិនទាក់ទងទៅនឹងការប្រកួតកីឡា។

១០.២.៤ មិនមានបទប្បញ្ញត្តិផ្សេងទៀតនៅក្នុងប្រការ ១០.២ ដែលការបំពានវិធានប្រឆាំងដូប៉ាទាក់ទងនឹងសារធាតុបំពាន៖

១០.២.៤.១ ប្រសិនបើអត្តពលិកអាចបង្ហាញថាការលេបចូល ឬប្រើប្រាស់នៅក្រៅការប្រកួត និងមិនទាក់ទងនឹងការប្រកួតកីឡា នោះរយៈពេលនៃការព្យួរសិទ្ធិគឺ ៣(បី)ខែ។

លើសពីនេះទៀត រយៈពេលនៃការព្យួរសិទ្ធិ ដែលកំណត់ក្រោមប្រការ ១០.២.៤.១ អាចនឹងត្រូវបន្ថយមកនៅត្រឹម ១(មួយ)ខែ ប្រសិនបើ អត្តពលិក ឬបុគ្គលផ្សេងទៀតបានពេញចិត្ត និងទទួលស្គាល់ការបំពានសារធាតុហាមឃាត់ ដែលអនុម័តដោយគណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជា។ រយៈពេលនៃការព្យួរសិទ្ធិដូចដែលបានកំណត់ក្នុងប្រការ ១០.២.៤.១ នេះមិនត្រូវបានបន្ថយដោយផ្អែកលើបទប្បញ្ញត្តិណាមួយនៅក្នុងប្រការ ១០.៦ ទេ។

១០.២.៤.២ ប្រសិនបើការលេបចូល ការប្រើប្រាស់ ឬការកាន់កាប់ កើតឡើងនៅក្នុងអំឡុងពេលនៃការប្រកួត ហើយអត្តពលិក អាចបញ្ជាក់ថាបរិបទនៃការលេបចូល ការប្រើប្រាស់ ឬការកាន់កាប់នោះ មិនទាក់ទងទៅនឹងសមត្ថភាពប្រកួតកីឡាទេនោះ ការលេបចូល ការប្រើប្រាស់ ឬការកាន់កាប់នោះ មិនត្រូវចាត់ទុកថាជាចេតនាឡើយ ដោយយោងតាមប្រការ ១០.២.១ និងមិនត្រូវបានយកធ្វើជាមូលដ្ឋានសម្រាប់ការស្វែងរកស្ថានការណ៍ ដែលមានស្ថានទម្ងន់ទោសក្រោមប្រការ ១០.៤ ឡើយ។

១០.៣ ការព្យួរសិទ្ធិ សម្រាប់ការបំពានវិធានប្រឆាំងដូប៉ាផ្សេងទៀត

រយៈពេលនៃការព្យួរសិទ្ធិ សម្រាប់ការបំពានវិធានប្រឆាំងដូប៉ា ក្រៅពីអ្វីដែលមានចែងក្នុងប្រការ ១០.២ នឹងមានដូចខាងក្រោម លើកលែងតែប្រការ ១០.៦ ឬប្រការ ១០.៧ ត្រូវបានអនុវត្ត៖

១០.៣.១ ចំពោះការបំពានប្រការ ២.៣ ឬ ប្រការ ២.៥ រយៈពេលនៃការព្យួរសិទ្ធិគឺ ៤(បួន) ឆ្នាំ លើកលែងតែ៖

(i) ក្នុងករណីខកខានមិនបានបញ្ជូនទៅការប្រមូលសំណាក ប្រសិនបើអត្តពលិកអាចបង្ហាញថាការប្រព្រឹត្តិបំពានវិធានប្រឆាំងដូប៉ានោះធ្វើឡើងដោយគ្មានចេតនា នោះរយៈពេលនៃការព្យួរសិទ្ធិគឺ ២(ពីរ)ឆ្នាំ។

(ii) ក្នុងករណីផ្សេងទៀតទាំងអស់ប្រសិនបើអត្តពលិក ឬបុគ្គលផ្សេងទៀតអាចបង្ហាញកាលៈទេសៈពិសេស

ដែលអាចផ្តល់ហេតុផលសម្រាប់ការបន្ធូរបន្ថយរយៈពេលនៃការព្យួរសិទ្ធិ នោះរយៈពេលនៃការព្យួរសិទ្ធិ គឺចន្លោះពី ២(ពីរ)ឆ្នាំ ទៅ៤(បួន)ឆ្នាំ អាស្រ័យលើកម្រិតកំហុសរបស់អត្តពលិក ឬផ្សេងទៀតនោះ។

(iii) ក្នុងករណីដែលពាក់ព័ន្ធនឹងបុគ្គល ដែលត្រូវបានការពារ ឬអត្តពលិកកម្សាន្ត រយៈពេលនៃការព្យួរសិទ្ធិ គឺចន្លោះពីអតិប្បរមា ២(ពីរ)ឆ្នាំ និងការស្តីបន្ទោសដោយគ្មានការព្យួរសិទ្ធិ អាស្រ័យលើកម្រិតកំហុសរបស់បុគ្គលដែលត្រូវបានការពារ ឬអត្តពលិកកម្សាន្តនោះ។

១០.៣.២ ចំពោះការបំពានប្រការ ២.៤ រយៈពេលនៃការព្យួរសិទ្ធិគឺ ២(ពីរ)ឆ្នាំ និងអាចត្រូវបានបន្ធូរបន្ថយមកនៅត្រឹមកម្រិតអប្បបរមា ១(មួយ)ឆ្នាំ អាស្រ័យលើកម្រិតកំហុសរបស់អត្តពលិក។ ភាពបត់បែនរវាង ២(ពីរ) ឆ្នាំ និង ១(មួយ)ឆ្នាំ នៃការព្យួរសិទ្ធិ នៅក្នុងប្រការនេះគឺ មិនអាចយកទៅប្រើសម្រាប់អត្តពលិកបានទេ ក្នុងករណីដែលទម្រង់នៃព័ត៌មានអំពីទីសំចតរបស់អត្តពលិកចុងក្រោយ ឬការប្រព្រឹត្តផ្សេងទៀតបង្កឱ្យមានការសង្ស័យធ្ងន់ធ្ងរ ថាអត្តពលិកព្យាយាមគេចវេសពីការធ្វើតេស្ត។

១០.៣.៣ ចំពោះការបំពានប្រការ ២.៧ ឬប្រការ ២.៨ រយៈពេលនៃការព្យួរសិទ្ធិគឺអប្បបរមា ៤(បួន ឆ្នាំ រហូតដល់ការព្យួរសិទ្ធិមួយជីវិត អាស្រ័យលើភាពធ្ងន់ធ្ងរនៃការបំពាននោះ។ ការបំពានប្រការ ២.៧ ឬប្រការ ២.៨ ដែលពាក់ព័ន្ធនឹងបុគ្គលដែលត្រូវបានការពារ នឹងត្រូវចាត់ទុកជាការបំពានបំពានធ្ងន់ធ្ងរ ហើយប្រសិនបើប្រព្រឹត្តដោយអ្នកគាំពារអត្តពលិក ចំពោះការបំពានក្រៅពីសារធាតុដែលបានកំណត់នោះនឹងនាំឱ្យមានការព្យួរសិទ្ធិមួយជីវិតចំពោះអ្នកគាំពារអត្តពលិក។ លើសពីនេះទៀត ការបំពានសំខាន់ៗលើប្រការ ២.៧ ឬប្រការ ២.៨ ដែលអាចជាការបំពានវិធាន និងបទប្បញ្ញត្តិមិនទាក់ទងនឹងកីឡា នឹងត្រូវបានរាយការណ៍ទៅអាជ្ញាធរមានសមត្ថកិច្ចរដ្ឋបាលវិជ្ជាជីវៈ ឬតុលាការ។

១០.៣.៤ ចំពោះការបំពានប្រការ ២.៩ រយៈពេលនៃការព្យួរសិទ្ធិ គឺយ៉ាងតិច ២(ពីរ)ឆ្នាំ រហូតដល់ការព្យួរសិទ្ធិពេញមួយជីវិត អាស្រ័យលើភាពធ្ងន់ធ្ងរនៃការបំពាននោះ។

១០.៣.៥ ចំពោះការបំពានប្រការ ២.១០ រយៈពេលដែល ការព្យួរសិទ្ធិគឺ ២(ពីរ)ឆ្នាំ និងអាចត្រូវបានបន្ធូរបន្ថយមកនៅត្រឹមកម្រិតអប្បបរមា ១(មួយ)ឆ្នាំ អាស្រ័យលើកម្រិតកំហុសរបស់អត្តពលិក ឬបុគ្គលផ្សេងទៀត និងលើកាលៈទេសៈផ្សេងទៀតនៃករណីនោះ។

១០.៣.៦ ចំពោះការបំពានប្រការ ២.១១ រយៈពេលនៃការព្យួរសិទ្ធិ គឺអប្បបរមា ២(ពីរ)ឆ្នាំ រហូតដល់ការព្យួរសិទ្ធិពេញមួយជីវិត អាស្រ័យលើភាពធ្ងន់ធ្ងរនៃការបំពានរបស់ អត្តពលិក ឬបុគ្គលផ្សេងទៀត។

១០.៤ ស្ថានទម្ងន់ទោសដែលអាចបង្កើនរយៈពេលនៃការព្យួរសិទ្ធិ

ប្រសិនបើគណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជាអាចបង្ហាញ ក្នុងករណីដោយឡែក ដែលពាក់ព័ន្ធនឹងការបំពានវិធានប្រឆាំងដូប៉ាក្រោមប្រការ ២.៧ (ការជួញដូរ ឬការប៉ុនប៉ងជួញដូរ) ប្រការ ២.៨ (ការផ្តល់ឱ្យ ឬការប៉ុនប៉ងផ្តល់ឱ្យ) ប្រការ ២.៩ (ការសមគំនិត) ឬប្រការ ២.១១ (ការប្រព្រឹត្តិរបស់អត្តពលិក ឬបុគ្គលផ្សេងទៀត ដើម្បីរារាំង ឬសងសឹកប្រឆាំងនឹងការរាយការណ៍) ថាមានស្ថានទម្ងន់ទោស ដែលផ្តល់ហេតុផលអំពីការព្យួរសិទ្ធិមិនត្រឹមត្រូវ លើសពីទណ្ឌកម្មស្តង់ដារ នោះរយៈពេលនៃការព្យួរសិទ្ធិ ត្រូវកើនឡើងបន្ថែមហូតដល់ទៅ ២(ពីរ)ឆ្នាំ អាស្រ័យលើភាពធ្ងន់ធ្ងរនៃការបំពាន និងលក្ខណៈនៃស្ថានទម្ងន់ទោសនោះលើកលែងតែអត្តពលិក ឬបុគ្គលផ្សេងទៀតអាចបញ្ជាក់ថាខ្លួនមិនបានប្រព្រឹត្តិការបំពានវិធានប្រឆាំងដូប៉ា។

១០.៥ ការដករយៈពេលនៃការព្យួរសិទ្ធិ ក្នុងករណីដែលគ្មានកំហុស ឬការធ្វេសប្រហែស

ប្រសិនបើអត្តពលិក ឬបុគ្គលផ្សេងទៀត បង្ហាញនៅក្នុងករណីដោយឡែកថា គាត់គ្មានកំហុសធ្ងន់ធ្ងរ ឬ

ការធ្វេសប្រហែសនោះរយៈពេលនៃការព្យួរសិទ្ធិនឹងត្រូវបានលុបចេញ។

១០.៦ ការកាត់បន្ថយរយៈពេលនៃការព្យួរសិទ្ធិ ផ្អែកលើការគ្មានកំហុស ឬការធ្វេសប្រហែស

១០.៦.១ ការកាត់បន្ថយទណ្ឌកម្មក្នុងកាលៈទេសៈពិសេសសម្រាប់ការបំពានប្រការ ២.១, ប្រការ ២.២ ឬប្រការ ២.៦ ។

ការកាត់បន្ថយទាំងអស់ក្រោមប្រការ ១០.៦.១ គឺមិនអាចអនុវត្តទន្ទឹមគ្នា។

១០.៦.១.១ សារធាតុជាក់លាក់ ឬវិធីសាស្ត្រជាក់លាក់

ក្នុងករណីដែលការបំពានវិធានប្រឆាំងដូប៉ា ពាក់ព័ន្ធនឹងសារធាតុជាក់លាក់ (ក្រៅពីសារធាតុបំពាន) ឬវិធីដែលបានកំណត់ ហើយអត្តពលិក ឬបុគ្គលផ្សេងទៀត អាចបង្ហាញថាគ្មានកំហុសធ្ងន់ធ្ងរ ឬការធ្វេសប្រហែស នោះការដាក់ពិន័យ អប្បបរមាគឺការស្តីបន្ទោសដោយគ្មានការព្យួរសិទ្ធិ ហើយការដាក់ពិន័យអតិប្បរមាគឺការព្យួរសិទ្ធិរយៈពេល ២(ពីរ)ឆ្នាំ ដោយផ្អែកលើកម្រិតកំហុសរបស់អត្តពលិក ឬបុគ្គលផ្សេងទៀតនោះ ។

១០.៦.១.២ ផលិតផលមិនស្មោះត្រង់

ក្នុងករណីដែលអត្តពលិក ឬបុគ្គលផ្សេងទៀតអាចបង្ហាញថា គ្មានទាំងកំហុសធ្ងន់ធ្ងរ ឬការធ្វេសប្រហែស ហើយថាសារធាតុហាមឃាត់ដែលត្រូវបានរកឃើញ (ក្រៅពីសារធាតុបំពាន) បានមកពីផលិតផលមិនស្មោះត្រង់ នោះការពិន័យអប្បបរមាគឺការស្តីបន្ទោសដោយគ្មានការព្យួរសិទ្ធិ និងអតិប្បរមានគឺការព្យួរសិទ្ធិរយៈពេល ២(ពីរ)ឆ្នាំ អាស្រ័យលើកម្រិតកំហុសរបស់អត្តពលិក ឬបុគ្គលផ្សេងទៀតនោះ។

១០.៦.១.៣ បុគ្គលដែលត្រូវបានការពារ ឬអត្តពលិកកម្សាន្ត

ក្នុងករណីការបំពានវិធានប្រឆាំងដូប៉ា ដែលមិនពាក់ព័ន្ធនឹងសារធាតុបំពានត្រូវបានប្រព្រឹត្តិដោយបុគ្គលដែលត្រូវបានការពារ ឬអត្តពលិកកម្សាន្ត និងក្នុងករណីដែលបុគ្គលដែលត្រូវបានការពារ ឬអត្តពលិកកម្សាន្តអាចបង្ហាញថាគ្មានកំហុសធ្ងន់ ឬជាការធ្វេសប្រហែសនោះរយៈពេលនៃការព្យួរសិទ្ធិនឹងមានក្នុងកម្រិតអប្បបរមា ត្រឹមការស្តីបន្ទោសដោយគ្មានការព្យួរសិទ្ធិ ហើយអតិប្បរមាគឺការព្យួរសិទ្ធិរយៈពេល ២(ពីរ)ឆ្នាំ អាស្រ័យលើកម្រិតកំហុសរបស់បុគ្គលដែលត្រូវបានការពារ ឬអត្តពលិកកម្សាន្តនោះ។

១០.៦.២ ការដាក់ពាក្យសុំ គ្មានកំហុស ឬការធ្វេសប្រហែស លើសការអនុវត្តប្រការ ១០.៦.១

ប្រសិនបើអត្តពលិក ឬបុគ្គលផ្សេងទៀតក្នុងករណីដោយឡែកដែលប្រការ ១០.៦.១ មិនត្រូវបានអនុវត្តអាចបង្ហាញថាគាត់មិនមានកំហុស ឬជាការធ្វេសប្រហែសនោះ អាស្រ័យលើការកាត់បន្ថយ ឬការដកចេញ ដូចមានចែងក្នុងប្រការ ១០.៧ រយៈពេលនៃការព្យួរសិទ្ធិដែលអាចអនុវត្តបានផ្សេងទៀតអាចត្រូវបានកាត់បន្ថយដោយផ្អែកលើកម្រិតកំហុសរបស់អត្តពលិក ឬផ្សេងទៀត ប៉ុន្តែការកាត់បន្ថយរយៈពេលនៃការព្យួរសិទ្ធិនោះនឹងមិនអាចដល់កម្រិតតិចជាងពាក់កណ្តាល នៃរយៈពេលនៃការព្យួរសិទ្ធិដែលអាចអនុវត្តបាននោះទេ។ ប្រសិនបើរយៈពេលនៃការព្យួរសិទ្ធិដែលអាចអនុវត្តបាន គឺជាការព្យួរសិទ្ធិពេញមួយជីវិត នោះរយៈពេលកាត់បន្ថយនៅក្រោមប្រការនេះមិនអាចតិចជាង ៨(ប្រាំបី)ឆ្នាំ ទេ។

១០.៧ ការដក ការកាត់បន្ថយ ឬការព្យួររយៈពេលនៃការព្យួរសិទ្ធិ ឬទណ្ឌកម្មផ្សេងទៀតសម្រាប់ហេតុផលផ្សេងក្រៅពីកំហុស

១០.៧.១ ជំនួយសំខាន់ៗក្នុងការស្វែងរក ឬការបង្ហាញការបំពានក្រុម

១០.៧.១.១ គណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជា មុនការសម្រេចលើការប្ដឹងជំទាស់តាមប្រការ ១៣ ឬ មុនផុតកំណត់នៃរយៈពេលប្ដឹងជំទាស់ អាចផ្អាកផ្នែកណាមួយនៃទណ្ឌកម្ម (ក្រៅពីការដកសិទ្ធិ និងកាតព្វកិច្ចផ្សព្វផ្សាយជាសាធារណៈ)ដែលបានកំណត់ក្នុងករណីដោយឡែកដែលអត្តពលិក ឬបុគ្គលផ្សេងទៀត បានផ្ដល់ជំនួយសំខាន់ៗដល់អង្គការប្រឆាំងដូប៉ា អាជ្ញាធរព្រហ្មទណ្ឌ ឬស្ថាប័នវិន័យវិជ្ជាជីវៈ ដែលនាំឱ្យ៖

(i) អង្គការប្រឆាំងដូប៉ា ដែលរកឃើញ ឬដែលចោទថាមានការបំពានវិធានប្រឆាំងដូប៉ា ដោយបុគ្គលម្នាក់ ផ្សេងទៀត ឬ

(ii) ដែលនាំឱ្យស្ថាប័នព្រហ្មទណ្ឌ ឬវិន័យរកឃើញ ឬចោទថាមានបទបំពានព្រហ្មទណ្ឌ ឬការបំពានវិធានវិជ្ជាជីវៈដែលបានប្រព្រឹត្តដោយបុគ្គលម្នាក់ទៀត និងព័ត៌មានដែលផ្ដល់ដោយ បុគ្គលដែលផ្ដល់ជំនួយសំខាន់ៗ ត្រូវបានផ្ដល់ជូនគណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជា ឬភ្នាក់ងារដទៃទៀតដែលទទួលខុសត្រូវក្នុងការដោះស្រាយវិវាទដូប៉ា ឬ

(iii) ដែលនាំឱ្យទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក ចាប់ផ្ដើមនីតិវិធីប្រឆាំងនឹងស្ថាប័នហត្ថលេខី មន្ទីរពិសោធន៍ដែលទទួលស្គាល់ដោយទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក ឬអង្គភាពគ្រប់គ្រងប្រវត្តិជីវសាស្ត្រអត្តពលិក (ដូចបានកំណត់នៅក្នុងស្តង់ដាអន្តរជាតិស្ដីពីការធ្វើតេស្ត និងការស៊ើបអង្កេត) សម្រាប់ការមិនអនុលោមតាមក្រមស្តង់ដារអន្តរជាតិ ឬឯកសារបច្ចេកទេស ឬ

(iv) ដោយការអនុម័តពីទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក ដែលនាំឱ្យស្ថាប័នព្រហ្មទណ្ឌ ឬវិន័យដាក់ពាក្យបណ្ដឹងពីបទល្មើសព្រហ្មទណ្ឌ ឬការបំពានលើវិធានអាជីព ឬកីឡា ដែលកើតឡើងពីការបំពានលើសុចរិតភាពកីឡា ក្រៅពីការប្រើប្រាស់សារធាតុដូប៉ា។ បន្ទាប់ពីចេញសេចក្ដីសម្រេចលើបណ្ដឹងជំទាស់ ក្រោមប្រការ ១៣ ឬការផុតកំណត់រយៈពេលសម្រាប់ប្ដឹងជំទាស់ហើយគណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជា អាចផ្អាកតែផ្នែកណាមួយនៃទណ្ឌកម្មដែលអាចអនុវត្តបាន ដោយមានការអនុម័តពីទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក និងសហព័ន្ធកីឡាអន្តរជាតិ។

រយៈពេលដែលការព្យួរសិទ្ធិអាចនឹងត្រូវបានផ្អាកនោះ ត្រូវផ្អែកលើភាពធ្ងន់ធ្ងរនៃការបំពានវិធានប្រឆាំងដូប៉ាដោយអត្តពលិក ឬបុគ្គលផ្សេងទៀត និងសារៈសំខាន់នៃការផ្ដល់ជំនួយសក្ដានុពលដោយអត្តពលិក ឬបុគ្គលផ្សេងទៀតក្នុងកិច្ចខិតខំប្រឹងប្រែង ដើម្បីលុបបំបាត់សារធាតុដូប៉ាក្នុងវិស័យកីឡា ការមិនអនុលោមតាមក្រម ការបំពានក្រម និង/ឬការបំពានលើភាពសុចរិតនៃកីឡា។ ការផ្អាករយៈពេលព្យួរសិទ្ធិ មិនត្រូវលើសបីភាគបួននៃរយៈពេលព្យួរសិទ្ធិដែលត្រូវអនុវត្តនោះទេ។ ប្រសិនបើរយៈពេលព្យួរសិទ្ធិដែលត្រូវអនុវត្ត គឺជាការព្យួរសិទ្ធិមួយជីវិតរយៈពេលបានព្យួរសិទ្ធិដែលមិនត្រូវបានផ្អាកក្រោមប្រការនេះមិនត្រូវតិចជាង ៨(ប្រាំបី)ឆ្នាំ ទេ។ សម្រាប់គោលបំណងនៃកថាខណ្ឌនេះ រយៈពេលដែលអាចអនុវត្តបាននៃការព្យួរសិទ្ធិមិនត្រូវរាប់បញ្ចូលរយៈពេលនៃការព្យួរសិទ្ធិណាមួយ ដែលអាចត្រូវបានបន្ថែមក្រោមប្រការ ១០.៩.៣.២ នៃវិធានប្រឆាំងដូប៉ាទាំងនេះឡើយ។

ប្រសិនបើមានការស្នើសុំពីសំណាក់ អត្តពលិក ឬបុគ្គលផ្សេងទៀត ដែលព្យាយាមផ្ដល់ជំនួយសំខាន់ គណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជានឹងអនុញ្ញាតឱ្យអត្តពលិក ឬបុគ្គលផ្សេងទៀតនោះផ្ដល់ព័ត៌មានបានដោយផ្អែកលើកិច្ចព្រមព្រៀងរក្សាសិទ្ធិភាគី។

ប្រសិនបើអត្តពលិក ឬបុគ្គលផ្សេងទៀត ខកខានក្នុងការបន្តសហការ និងផ្ដល់ជំនួយ

ពេញលេញ និងគួរឱ្យទុកចិត្តបានក្នុងអំឡុងពេលនៃការផ្អាកការអនុវត្តទណ្ឌកម្ម គណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជាត្រូវអនុវត្តទណ្ឌកម្មដើមវិញ។ ប្រសិនបើគណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជា សម្រេចអនុវត្តទណ្ឌកម្មដើម ដែលត្រូវបានផ្អាកនោះឡើងវិញ ឬសម្រេចមិនអនុវត្តទណ្ឌកម្មដើមដែលត្រូវបានផ្អាកនោះទេ សេចក្តីសម្រេចនោះអាចត្រូវបានប្តឹងជំទាស់ដោយបុគ្គលណាមួយដែលមានសិទ្ធិប្តឹងជំទាស់តាមប្រការ ១៣ ។

១០.៧.១.២ ដើម្បីលើកទឹកចិត្ត អត្តពលិក និងបុគ្គលដទៃទៀត ឱ្យផ្តល់ជំនួយសំខាន់ដល់អង្គការប្រឆាំងដូប៉ា តាមរយៈសំណើរបស់គណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជា ឬតាមសំណើរបស់អត្តពលិក ឬបុគ្គលផ្សេងទៀតដែលមាន ឬត្រូវបានអះអាងថាបានប្រព្រឹត្តការបំពានវិធានប្រឆាំងដូប៉ា ឬការបំពានផ្សេងទៀតលើក្រម ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោកអាចយល់ព្រមនៅដំណាក់កាលណាមួយនៃដំណើរការដោះស្រាយវិវាទដូប៉ា រួមទាំងបន្ទាប់ពីសេចក្តីសម្រេចនៃបណ្តឹងជំទាស់តាមប្រការ ១៣ ចំពោះអ្វីដែលខ្លួនចាត់ទុកថាជាការផ្អាកសមស្របនៃរយៈពេលព្យួរសិទ្ធិ និងទណ្ឌកម្មផ្សេងទៀតដែលអាចអនុវត្តបាន។ ក្នុងកាលៈទេសៈពិសេស ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោកអាចយល់ព្រមលើការផ្អាករយៈពេលព្យួរសិទ្ធិ និងការពិន័យផ្សេងទៀតសម្រាប់ជំនួយសំខាន់ ដែលធំលើសពីអ្វីដែលបានចែងក្នុងប្រការនេះ ឬសូម្បីតែការមិនព្យួរសិទ្ធិ ការមិនតម្រូវឱ្យបង្ហាញព័ត៌មានជាសាធារណៈ និង/ឬការមិនដកមកវិញនូវប្រាក់រង្វាន់ ឬការបង់ប្រាក់ពិន័យ ឬការចំណាយផ្សេងៗ។ ការអនុម័តរបស់ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោកត្រូវជាកម្មវត្ថុនៃការដាក់ទណ្ឌកម្មឡើងវិញ បើមិនដូច្នេះទេ ត្រូវអនុវត្តដូចដែលមានចែងក្នុងប្រការនេះ។ ទោះដូចមានចែងក្នុងប្រការ ១៣ ក៏ដោយសេចក្តីសម្រេចរបស់ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោកនៅក្នុងបរិបទនៃប្រការ ១០.៧.១.២ នេះមិនអាចត្រូវបានប្តឹងជំទាស់ទេ។

១០.៧.១.៣ ប្រសិនបើគណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជាសម្រេចព្យួរផ្នែកណាមួយនៃការដាក់ទណ្ឌកម្មដែលអាចអនុវត្តបាន ដោយសារតែមានការផ្តល់ជំនួយសំខាន់គណៈកម្មាធិការនេះត្រូវជូនដំណឹងអំពីការផ្តល់យុត្តិកម្មចំពោះការសម្រេចនោះដល់អង្គការប្រឆាំងដូប៉ាផ្សេងទៀត ដែលមានសិទ្ធិប្តឹងជំទាស់តាមប្រការ ១៣.២.៣ ដូចមានចែងក្នុងប្រការ ១៤.២ ។ ក្នុងកាលៈទេសៈជាក់លាក់ដែលទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោកកំណត់ថា វាជាផលប្រយោជន៍ល្អបំផុតក្នុងកិច្ចខិតខំប្រឹងប្រែងប្រឆាំងដូប៉ា ទីភ្នាក់ងារប្រឆាំដូប៉ាពិភពលោកអាចផ្តល់សិទ្ធិដល់គណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជា ឱ្យចុះកិច្ចព្រមព្រៀងរក្សាការសម្ងាត់សមស្របដោយកំណត់ ឬពន្យារពេលការបង្ហាញពីកិច្ចព្រមព្រៀងផ្តល់ជំនួយសំខាន់ ឬលក្ខណៈនៃការផ្តល់ជំនួយសំខាន់ដែលកំពុងត្រូវបានផ្តល់ជូន។

១០.៧.២ ការទទួលយកថា បានបំពានវិធានប្រឆាំងដូប៉ា ដោយអវត្តមាននៃភស្តុតាងផ្សេងទៀត នៅពេលដែលអត្តពលិក ឬបុគ្គលផ្សេងទៀត ពេញចិត្តក្នុងការទទួលស្គាល់ថា បានបំពានវិធានប្រឆាំងដូប៉ា មុនពេលទទួលបានការជូនដំណឹងអំពីការប្រមូលសំណាកដែលអាចបង្កើតជាការបំពានវិធានប្រឆាំងដូប៉ា (ឬក្នុងករណីដែលវិធានប្រឆាំងដូប៉ាក្រៅពីប្រការ ២.១ មុនពេលទទួលបានសេចក្តីជូនដំណឹងដំបូងអំពីការបំពានដែលខ្លួនទទួលយកដោយអនុលោមតាមប្រការ ៧) ហើយដែលថា ការទទួលយកនោះគឺជាភស្តុតាងដែលអាចទុកចិត្តបានតែមួយគត់នៃការបំពាន នោះរយៈពេលនៃការព្យួរសិទ្ធិ អាចត្រូវបានកាត់បន្ថយ ប៉ុន្តែមិនត្រូវទាបជាងពាក់កណ្តាលនៃរយៈពេលនៃការព្យួរសិទ្ធិ ប្រសិនបើរកឃើញថាមានកំហុសនោះទេ។

១០.៧.៣ ការប្រើប្រាស់ហេតុផលច្រើនសម្រាប់កាត់បន្ថយទណ្ឌកម្ម

នៅពេលដែលអត្តពលិក ឬបុគ្គលដទៃទៀតបង្ហាញថាខ្លួនមានសិទ្ធិទទួលបានការបន្ធូរបន្ថយទណ្ឌកម្មក្រោមបទប្បញ្ញត្តិលើសពីមួយនៃប្រការ ១០.៥ ប្រការ ១០.៦ ឬប្រការ ១០.៧ មុនពេលអនុវត្តការបន្ធូរបន្ថយ ឬការព្យួរការអនុវត្តទណ្ឌកម្ម ក្រោមប្រការ ១០.៧ នោះ រយៈពេលនៃការព្យួរសិទ្ធិ ត្រូវកំណត់ស្របតាមប្រការ ១០.២ ប្រការ ១០.៣ ប្រការ ១០.៥ និងប្រការ ១០.៦។ ប្រសិនបើមានអត្តពលិក ឬបុគ្គលផ្សេងទៀតអាចបង្ហាញសិទ្ធិទទួលបានការបន្ធូរបន្ថយ ឬការផ្អាកនៃរយៈពេលនៃការព្យួរសិទ្ធិក្រោមប្រការ ១០.៧ នោះរយៈពេលនៃការព្យួរសិទ្ធិអាចត្រូវបានកាត់បន្ថយ ឬផ្អាក ប៉ុន្តែមិនត្រូវតិចជាងមួយភាគបួននៃរយៈពេលព្យួរសិទ្ធិដែលត្រូវអនុវត្តនោះទេ។

១០.៨ កិច្ចព្រមព្រៀងដោះស្រាយវិវាទដូប៉ា

១០.៨.១ ការបន្ធូរបន្ថយទណ្ឌកម្ម ១(មួយ)ឆ្នាំ ចំពោះការបំពានវិធានប្រឆាំងដូប៉ាដោយផ្អែកលើការសារភាព និងការទទួលយកទណ្ឌកម្មជាមុនក្នុងករណីដែល អត្តពលិក ឬបុគ្គលផ្សេងទៀត បន្ទាប់ពីត្រូវបានជូនដំណឹងដោយគណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជា អំពីការបំពានវិធានប្រឆាំងដូប៉ាសំខាន់ណាមួយ ដែលត្រូវទទួលពិន័យនៃការព្យួរសិទ្ធិរយៈពេល ៤(បួន)ឆ្នាំ ឬច្រើនជាងនេះ (រាប់បញ្ចូលទាំងរយៈពេលនៃការព្យួរសិទ្ធិតាមប្រការ ១០.៤) ទទួលស្គាល់ថាបានបំពាន និងទទួលយករយៈពេលនៃការព្យួរសិទ្ធិ ក្នុងរយៈពេលមិនលើសពី ២០(ម្ភៃ)ថ្ងៃ បន្ទាប់ពីទទួលបានការជូនដំណឹងអំពីការចោទប្រកាន់ថាបានបំពានវិធានប្រឆាំងដូប៉ានោះ អត្តពលិក ឬបុគ្គលផ្សេងទៀត អាចទទួលបានការបន្ធូរបន្ថយរយៈពេល ១(មួយ)ឆ្នាំ ក្នុងរយៈពេលការព្យួរសិទ្ធិដែលកំណត់ដោយគណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជា។ នៅពេលដែល អត្តពលិក ឬបុគ្គលផ្សេងទៀតទទួលបានការបន្ធូរបន្ថយទណ្ឌកម្មរយៈពេល ១(មួយ)ឆ្នាំ ក្នុងរយៈពេលអនុវត្តការព្យួរសិទ្ធិ ក្រោមប្រការ ១០.៨.១ នេះ គ្មានការបន្ធូរបន្ថយរយៈពេលព្យួរសិទ្ធិបន្ថែមទៀតត្រូវបានអនុញ្ញាតក្រោមប្រការណាមួយឡើយ។

១០.៨.២ កិច្ចព្រមព្រៀងដំណោះស្រាយករណី

នៅពេលដែលអត្តពលិក ឬបុគ្គលផ្សេងទៀត ទទួលសារភាពថាបានបំពានវិធានប្រឆាំងដូប៉ា បន្ទាប់ពីត្រូវបានចោទប្រកាន់ថា បានបំពានវិធានប្រឆាំងដូប៉ា ដោយគណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជា ហើយយល់ព្រមនឹងទណ្ឌកម្មដែលបានទទួលយក ដោយគណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជា និងទីភ្នាក់ងារដូប៉ាពិភពលោក តាមសេចក្តីសម្រេចរបស់ស្ថាប័នទាំងនេះ ៖

ក. អត្តពលិក ឬបុគ្គលផ្សេងទៀតអាចទទួលបានការបន្ធូរបន្ថយរយៈពេលនៃការព្យួរសិទ្ធិ ផ្អែកលើការវាយតម្លៃដោយគណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជា និងទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក លើពាក្យស្នើសុំក្រោមប្រការ ១០.១ ដល់ប្រការ ១០.៧ ចំពោះការបំពានវិធានប្រឆាំងដូប៉ា កម្រិតកំហុសរបស់អត្តពលិក ឬបុគ្គលផ្សេងទៀត និងថាតើអត្តពលិក ឬបុគ្គលផ្សេងទៀតទទួលស្គាល់ថាបានបំពានឆាប់រហ័សប៉ុណ្ណា និង

ខ. រយៈពេលនៃការព្យួរសិទ្ធិ អាចចាប់ផ្តើមនៅដើមកាលបរិច្ឆេទនៃការប្រមូលសំណាក ឬកាលបរិច្ឆេទដែលការបំពានវិធានប្រឆាំងដូប៉ាមួយផ្សេងទៀត កើតឡើងចុងក្រោយបំផុត។ ទោះយ៉ាងណាក៏ដោយក្នុងករណីនីមួយៗដែលប្រការនេះត្រូវបានអនុវត្ត អត្តពលិក ឬបុគ្គលដទៃទៀតត្រូវអនុវត្តយ៉ាងតិចមួយពាក់កណ្តាលនៃរយៈពេលព្យួរសិទ្ធិ ដែលបានព្រមព្រៀងគ្នា រាប់ចាប់ពីមុនកាលបរិច្ឆេទដែលអត្តពលិក ឬបុគ្គលផ្សេងទៀតទទួលយកការដាក់ទណ្ឌកម្ម ឬការព្យួរសិទ្ធិបណ្តោះអាសន្ន ដែលត្រូវបានអនុវត្តតាមលំដាប់លំដោយ ដោយអត្តពលិក ឬបុគ្គលផ្សេងទៀត។ សេចក្តីសម្រេចរបស់ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក និងគណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជាក្នុងការចូលរួម ឬមិនចូលរួមក្នុងកិច្ចព្រមព្រៀងផ្តល់ដំណោះស្រាយ និងរយៈពេលនៃការបន្ធូរបន្ថយ និងកាលបរិច្ឆេទចាប់ផ្តើមនៃរយៈពេល

ព្យួរសិទ្ធិនោះ មិនមែនជាបញ្ហាសម្រាប់ការសម្រេចចិត្ត ឬការពិនិត្យឡើងវិញដោយអង្គសវនាការទេ ហើយមិនអាចត្រូវបានប្ដឹងជំទាស់តាមប្រការ ១៣ ឡើយ។

ប្រសិនបើមានការស្នើសុំពីអត្តពលិក ឬបុគ្គលផ្សេងទៀត ដែលព្យាយាមចូលរួមក្នុងកិច្ចព្រមព្រៀងផ្ដល់ដំណោះស្រាយក្រោមប្រការនេះ គណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជាត្រូវអនុញ្ញាតឱ្យអត្តពលិក ឬបុគ្គលផ្សេងទៀតពិភាក្សាអំពីការទទួលយកការបំពានវិធានប្រឆាំងដូប៉ាដោយផ្អែកលើកិច្ចព្រមព្រៀង។

១០.៩ ការបំពានជាច្រើនដង

១០.៩.១ ការបំពានវិធានប្រឆាំងដូប៉ាលើកទី២ ឬទី៣

១០.៩.១.១ សម្រាប់ការបំពានវិធានប្រឆាំងដូប៉ារបស់អត្តពលិក ឬបុគ្គលផ្សេងទៀត ជាលើកទី២ ការបំពានរយៈពេលនៃការព្យួរសិទ្ធិ ត្រូវមានកម្រិតធ្ងន់ជាង៖

ក. រយៈពេលព្យួរសិទ្ធិ ៦(ប្រាំមួយ) ខែ ឬ

ខ. រយៈពេល ព្យួរសិទ្ធិ នៅក្នុងចន្លោះពេលរវាង៖

(i) រយៈពេលសរុបនៃការព្យួរសិទ្ធិ សម្រាប់ការបំពានវិធានប្រឆាំងដូប៉ាលើកទី១ បូកនឹងរយៈពេលនៃការព្យួរសិទ្ធិដែលត្រូវអនុវត្ត ប្រសិនបើមានការបំពានប្រឆាំងដូប៉ាជាលើកទី២ ដែលត្រូវបានចាត់ទុកថាដូចជាការបំពានលើកទី១ ដែរ ហើយ

(ii) ពីរដងនៃរយៈពេលនៃការព្យួរសិទ្ធិ ដែលត្រូវអនុវត្តប្រសិនបើការបំពានវិធានប្រឆាំងដូប៉ាលើកទី២ ត្រូវបានចាត់ទុកដូចការបំពានជាលើកទី១ រយៈពេលនៃការព្យួរសិទ្ធិនៅក្នុងរយៈពេលនេះត្រូវបានកំណត់ដោយផ្អែកលើស្ថានភាពទាំងមូល និងកម្រិតកំហុសរបស់អត្តពលិក ឬបុគ្គលផ្សេងទៀត ទាក់ទងនឹងការបំពានលើកទី២។

១០.៩.១.២ ការបំពានវិធានប្រឆាំងដូប៉ាលើកទី៣ នឹងបណ្ដាលឱ្យមានកាព្យួរសិទ្ធិមួយជីវិត លើកលែងតែការបំពានលើកទី៣នោះ បំពេញលក្ខខណ្ឌសម្រាប់ការលុបចោល ឬការបន្ធូរបន្ថយរយៈពេលនៃការព្យួរសិទ្ធិ តាមប្រការ ១០.៥ ឬប្រការ ១០.៦ ឬពាក់ព័ន្ធនឹងការបំពានប្រការ ២.៤ ។ ក្នុងករណីពិសេសទាំងនេះ រយៈពេលនៃការព្យួរសិទ្ធិគឺពី ៨(ប្រាំបី)ឆ្នាំ ដល់ការព្យួរសិទ្ធិពេញមួយជីវិត។

១០.៩.១.៣ រយៈពេលនៃការព្យួរសិទ្ធិ ដូចត្រូវបានកំណត់ក្នុងប្រការ ១០.៩.១.១ និង ១០.៩.១.២ អាចត្រូវបានបន្ធូរបន្ថយបន្ថែមទៀត ដោយការអនុវត្តប្រការ ១០.៧។

១០.៩.២ ករណីបំពានវិធានប្រឆាំងដូប៉ាដែលអត្តពលិក ឬបុគ្គលដទៃទៀត អាចបង្ហាញថាខ្លួនគ្មានកំហុស ឬការធ្វេសប្រហែស នឹងមិនត្រូវបានចាត់ទុកថាជាការបំពាន សម្រាប់គោលបំណងនៃប្រការ ១០.៩ នេះទេ។ លើសពីនេះទៀត ការបំពានវិធានប្រឆាំងដូប៉ាដែលត្រូវបានដាក់ទណ្ឌកម្មក្រោមប្រការ ១០.២.៤.១ នឹងមិនត្រូវចាត់ទុកជាការបំពានសម្រាប់គោលបំណងនៃប្រការ ១០.៩ ទេ។

១០.៩.៣ វិធានបន្ថែមចំពោះការបំពានធ្ងន់ធ្ងរជាក់លាក់ច្រើនដង

១០.៩.៣.១ សម្រាប់គោលបំណងដាក់ទណ្ឌកម្មក្រោមប្រការ ១០.៩ លើកលែងដូចមានចែងក្នុងប្រការ ១០.៩.៣.២ និងប្រការ ១០.៩.៣.៣ ការបំពានវិធានប្រឆាំងដូប៉ានឹងត្រូវបានចាត់ទុកថាជាការបំពានជាលើកទី២ លុះត្រាតែគណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជាអាចបង្ហាញថាអត្តពលិក ឬបុគ្គលផ្សេងទៀត បានប្រព្រឹត្តបំពានវិធានប្រឆាំងដូប៉ាបន្ថែមបន្ទាប់ពីអត្តពលិក ឬបុគ្គលផ្សេងទៀត បានទទួលសេចក្ដីជូនដំណឹង ដោយអនុលោមតាមប្រការ ៧ ឬបន្ទាប់ពី គណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជា បានខិតខំប្រឹងប្រែងសមហេតុផល ដើម្បីផ្ដល់សេចក្ដីជូនដំណឹង

អំពីការបំពានវិធានប្រឆាំងដូប៉ាលើកទី១ ហើយ។ ប្រសិនបើគណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជា មិនអាចបង្ហាញករណីនោះបានទេ ការបំពានត្រូវបានចាត់ទុកជាការបំពានតែម្តងលើកទី១ ហើយការដាក់ទណ្ឌកម្មត្រូវផ្អែកលើការបំពាន ដែលត្រូវអនុវត្តការដាក់ទណ្ឌកម្មធ្ងន់ធ្ងរ រួមទាំងការអនុវត្តស្ថានទម្ងន់ទោស។ លទ្ធផលប្រកួតទាំងអស់រាប់ចាប់តាំងកាលបរិច្ឆេទដំបូងនៃការបំពានវិធានប្រឆាំងដូប៉ា នឹងត្រូវបានបដិសេធដូចមានចែងក្នុងប្រការ ១០.១០ ។

១០.៩.៣.២ ប្រសិនបើគណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជាបានកំណត់ថាអត្តពលិក ឬបុគ្គលផ្សេងទៀតបានប្រព្រឹត្តបំពានវិធានប្រឆាំងដូប៉ាមុនការជូនដំណឹង ហើយថាការបំពានបន្ថែមបានកើតឡើងក្នុងរយៈពេល ១២(ដប់ពីរ)ខែ ឬច្រើនជាងនេះ មុន ឬក្រោយការបំពានលើកទី១ ដែលត្រូវបានជូនដំណឹងនោះ រយៈពេលនៃការព្យួរសិទ្ធិ ចំពោះការបំពានបន្ថែមនឹងត្រូវបានគណនា ដូចការបំពានបន្ថែមលើកទី១ផ្សេងទៀត ហើយរយៈពេលនៃការព្យួរសិទ្ធិ ត្រូវអនុវត្តបន្តគ្នា ជាជាងទន្ទឹមគ្នា ជាមួយនឹងរយៈពេលនៃការព្យួរសិទ្ធិ សម្រាប់ការបំពានដែលបានជូនដំណឹងពីមុនៗ។ ក្នុងករណីដែលប្រការ ១០.៩.៣.២ នេះត្រូវបានអនុវត្តការបំពានដែលបានកើតឡើងរួមគ្នាត្រូវបានចាត់ទុកថាជាការបំពានតែមួយ សម្រាប់គោលបំណងនៃប្រការ ១០.៩.១។

១០.៩.៣.៣ ប្រសិនបើគណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជា អាចបង្ហាញថា អត្តពលិក ឬបុគ្គលផ្សេងទៀតបានប្រព្រឹត្តិបំពានប្រការ ២.៥ ទាក់ទងនឹងដំណើរគ្រប់គ្រងដូប៉ាសម្រាប់ការបំពានវិធានប្រឆាំងដូប៉ាដែលត្រូវបានចោទ ការបំពានប្រការ ២.៥ នឹងត្រូវបានចាត់ទុកថាជាការបំពានលើកទី១ ដោយឡែក ហើយរយៈពេលនៃការព្យួរសិទ្ធិចំពោះការបំពានបែបនេះនឹងត្រូវបានអនុវត្តបន្តគ្នា ជាជាងទន្ទឹមគ្នា ជាមួយនឹងរយៈពេលនៃការព្យួរសិទ្ធិ បើមានកំណត់សម្រាប់ការបំពានវិធានប្រឆាំងដូប៉ានោះ។ ក្នុងករណីដែលប្រការ ១០.៩.៣.៣ ត្រូវបានអនុវត្តការបំពានដែលបានកើតឡើងរួមគ្នាត្រូវបានចាត់ទុកថាជាការបំពានតែមួយ សម្រាប់គោលបំណងនៃប្រការ ១០.៩.១ ។

១០.៩.៣.៤ ប្រសិនបើគណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជា អាចបង្ហាញថាបុគ្គលម្នាក់ បានប្រព្រឹត្តិបំពានវិធានប្រឆាំងដូប៉ាជាលើកទី២ ឬទី៣ ក្នុងកំឡុងពេលនៃការព្យួរសិទ្ធិ នោះរយៈពេលនៃការព្យួរសិទ្ធិសម្រាប់ការបំពានច្រើនដងនឹងត្រូវអនុវត្តជាបន្តបន្ទាប់គ្នា ជាជាងដំណាលគ្នា។

១០.៩.៤ ការបំពានវិធានប្រឆាំងដូប៉ាច្រើនដងក្នុងអំឡុងពេល ១០(ដប់)ឆ្នាំ

សម្រាប់គោលបំណងនៃប្រការ ១០.៩ រាល់ការបំពានវិធានប្រឆាំងដូប៉ាត្រូវកើតឡើងក្នុងរយៈពេល ១០ (ដប់)ឆ្នាំ ដូចគ្នា ដើម្បីចាត់ទុកជាការបំពានច្រើនដង។

១០.១០ ការបដិសេធលទ្ធផលប្រកួត បន្ទាប់ពីការប្រមូលសំណាក ឬការប្រព្រឹត្តិបំពានវិធានប្រឆាំងដូប៉ា

បន្ថែមលើការបដិសេធលទ្ធផលប្រកួតដោយស្វ័យប្រវត្តិ ដែលបង្កើតសំណាកវិជ្ជមានក្រោមប្រការ ៩ រាល់លទ្ធផល ដែលមានលក្ខណៈប្រកួតប្រជែងដទៃទៀតទាំងអស់របស់អត្តពលិក ដែលទទួលបានចាប់ពីកាលបរិច្ឆេទដែលសំណាកវិជ្ជមានត្រូវបានប្រមូល(មិនថាក្នុងការប្រកួត ឬក្រៅការប្រកួតទេ) ឬការបំពានវិធានប្រឆាំងដូប៉ាផ្សេងទៀតបានកើតឡើង តាមរយៈការចាប់ផ្តើមអនុវត្តការព្យួរសិទ្ធិបណ្តោះអាសន្នណាមួយ ឬអំឡុងពេលព្យួរសិទ្ធិ លុះត្រាតែភាពយុត្តិធម៌តម្រូវឱ្យអនុវត្តផ្សេងពីនោះ នឹងត្រូវបានបដិសេធដោយមានទណ្ឌកម្មពាក់ព័ន្ធទាំងអស់ រួមបញ្ចូលទាំងការដកមេដាយ ពិន្ទុ និងរង្វាន់មកវិញ។

១០.១១ ប្រាក់រង្វាន់ដែលត្រូវបានដកយកវិញ

ប្រសិនបើគណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជាស្តារមកវិញ នូវប្រាក់រង្វាន់ដែលត្រូវដកយកវិញ ដោយសារការបំពានវិធានប្រឆាំងដូប៉ានោះ ខ្លួននឹងចាត់វិធានការសមហេតុផលក្នុងការរំភាជ និងបែងចែកប្រាក់រង្វាន់នោះដល់អត្តពលិក ដែលមានសិទ្ធិទទួលបាន ប្រសិនបើអត្តពលិកដែលត្រូវបានដកសិទ្ធិនោះមិនជំទាស់។

១០.១២ ទណ្ឌកម្មហិរញ្ញវត្ថុ

១០.១២.១ ក្នុងករណីដែល អត្តពលិក ឬបុគ្គលផ្សេងទៀតប្រព្រឹត្តបំពាននឹងវិធានប្រឆាំងដូប៉ាគណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជាក្រោមសិទ្ធិសម្រេចផ្តាច់មុខរបស់ខ្លួន និងយោងតាមគោលការណ៍សមាមាត្រ អាចជ្រើសរើស

(ក) វិធីស្តារចំណាយរបស់ខ្លួនពី អត្តពលិក ឬបុគ្គលផ្សេងទៀត ដែលពាក់ព័ន្ធនឹងការបំពានវិធានប្រឆាំងដូប៉ាដោយមិនគិតពីរយៈពេលនៃការព្យួរសិទ្ធិ និង/ឬ

(ខ) ដាកពិន័យអត្តពលិក ឬបុគ្គលផ្សេងទៀតក្នុងចំនួនទឹកប្រាក់រហូតដល់ ២៥០ (ពីរយហាសិប) ដុល្លារអាមេរិច លុះត្រាតែក្នុងករណីដែលមានការកំណត់រយៈពេលអតិបរមានៃការព្យួរសិទ្ធិរួចហើយ។

១០.១២.២ ការដាក់ទណ្ឌកម្មហិរញ្ញវត្ថុ ឬការស្តារចំណាយឡើងវិញរបស់គណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជា នឹងមិនត្រូវបានចាត់ទុកថាជាមូលដ្ឋានសម្រាប់ការបន្ធូរបន្ថយរយៈពេលព្យួរសិទ្ធិ ឬទណ្ឌកម្មផ្សេងទៀត ដែលត្រូវអនុវត្ត ក្រោមវិធានប្រឆាំងដូប៉ានោះទេ។

១០.១៣ ការចាប់ផ្តើមនៃរយៈពេលព្យួរសិទ្ធិ

ក្នុងករណីដែលអត្តពលិកកំពុងអនុវត្តរយៈពេលព្យួរសិទ្ធិ ចំពោះការបំពានវិធានប្រឆាំងដូប៉ា រយៈពេលព្យួរសិទ្ធិថ្មីណាមួយនឹងចាប់ផ្តើមនៅថ្ងៃដំបូងបន្ទាប់ពីរយៈពេលព្យួរសិទ្ធិបច្ចុប្បន្ន ត្រូវបានអនុវត្តចប់សព្វគ្រប់ហើយ។ បើមិនដូច្នោះទេ លើកលែងដូចអ្វីដែលបានចែងនៅខាងក្រោម រយៈពេលនៃការព្យួរសិទ្ធិ នឹងចាប់ផ្តើមនៅកាលបរិច្ឆេទនៃសេចក្តីសម្រេចសវនាការចុងក្រោយ ដែលកំណត់ការព្យួរសិទ្ធិនោះ ឬប្រសិនបើសវនាការត្រូវបានលើកលែង ឬមិនមានសវនាការ វាត្រូវចាប់ផ្តើមនៅកាលបរិច្ឆេទដែលការព្យួរសិទ្ធិត្រូវបានទទួលយក ឬត្រូវបានដាក់ចេញ។

១០.១៣.១ ការពន្យារពេលមិនពាក់ព័ន្ធនឹង អត្តពលិក ឬ បុគ្គលផ្សេងទៀត

ក្នុងករណីដែលមានការពន្យារពេលសំខាន់ៗក្នុងដំណើរការសវនាការ ឬទិដ្ឋភាពផ្សេងទៀតនៃការត្រួតពិនិត្យដូប៉ា ហើយអត្តពលិក ឬបុគ្គលផ្សេងទៀត អាចបញ្ជាក់ថាការពន្យារពេលបែបនោះមិនមែនបង្កដោយអត្តពលិក ឬបុគ្គលផ្សេងទៀតទេនោះ ក្រុមប្រឹក្សាជំនុំជម្រះរបស់គណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជា បើអាចអនុវត្តបាន អាចចាប់ផ្តើមរយៈពេលនៃការព្យួរសិទ្ធិ នៅកាលបរិច្ឆេទប្រតិសកម្ម រហូតដល់កាលបរិច្ឆេទចាប់ផ្តើមនៃការប្រមូលសំណាក ឬកាលបរិច្ឆេទដែលការបំពានវិធានប្រឆាំងដូប៉ាផ្សេងទៀត បានកើតឡើង។ រាល់លទ្ធផលប្រកួតដែលទទួលបានក្នុងកំឡុងពេលនៃការព្យួរសិទ្ធិ រាប់បញ្ចូលទាំងកាលបរិច្ឆេទប្រតិសកម្មនៃការព្យួរសិទ្ធិនឹងត្រូវបដិសេធ។

១០.១៣.២ ផលប្រយោជន៍ចំពោះការអនុវត្តការព្យួរសិទ្ធិបណ្តោះអាសន្ន ឬការអនុវត្តរយៈពេលព្យួរសិទ្ធិ

១០.១៣.២.១ ប្រសិនបើការព្យួរសិទ្ធិបណ្តោះអាសន្នត្រូវបានគោរពដោយ អត្តពលិក ឬបុគ្គលផ្សេងទៀត នោះអត្តពលិក ឬបុគ្គលផ្សេងទៀតនឹងទទួលបានប្រយោជន៍សម្រាប់ការអនុវត្តរយៈពេលព្យួរបណ្តោះអាសន្ន ដែលនឹងត្រូវបានកាត់ចេញពីរយៈពេល នៃការព្យួរសិទ្ធិ ដែលត្រូវបានដាក់ចេញចុងក្រោយ។ ប្រសិនបើអត្តពលិក ឬបុគ្គលផ្សេងទៀតមិនគោរពការព្យួរសិទ្ធិបណ្តោះអាសន្ន នោះអត្តពលិក ឬបុគ្គលផ្សេងទៀតនឹងមិនទទួលបានផលប្រយោជន៍ពីការអនុវត្តរយៈពេលនៃការព្យួរសិទ្ធិបណ្តោះអាសន្ននោះឡើយ។ ប្រសិនបើរយៈពេលនៃ

ការព្យួរសិទ្ធិ ត្រូវបានអនុវត្តតាមការសម្រេច ដែលក្រោយមកត្រូវបានប្តឹងជំទាស់អត្តពលិក ឬបុគ្គលផ្សេងទៀតនឹងទទួលបានផលប្រយោជន៍ចំពោះរយៈពេលនោះ ដែលនឹងត្រូវបានដកចេញពីរយៈពេលព្យួរសិទ្ធិ ដែលនឹងត្រូវបានដាក់ចេញចុងក្រោយចំពោះបណ្តឹងជំទាស់នោះ។

១០.១៣.២.២ ប្រសិនបើអត្តពលិក ឬបុគ្គលផ្សេងទៀតយល់ព្រមទទួលការព្យួរសិទ្ធិបណ្តោះអាសន្នដោយស្ម័គ្រចិត្ត ជាលាយលក្ខណ៍អក្សរ ពីគណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជា ហើយបន្ទាប់មកគោរពការព្យួរសិទ្ធិបណ្តោះអាសន្ននោះ អត្តពលិក ឬបុគ្គលផ្សេងទៀតនឹងទទួលបានផលប្រយោជន៍សម្រាប់រយៈពេល នៃការព្យួរសិទ្ធិបណ្តោះអាសន្នដោយស្ម័គ្រចិត្តនោះ ដែលនឹងត្រូវបានដកចេញពីរយៈពេលព្យួរសិទ្ធិ នឹងត្រូវដាក់ចេញចុងក្រោយ។ ឯកសារមួយច្បាប់នៃការទទួលយកដោយស្ម័គ្រចិត្តរបស់អត្តពលិក ឬបុគ្គលផ្សេងទៀត ចំពោះការព្យួរសិទ្ធិបណ្តោះអាសន្ន នឹងត្រូវផ្តល់ឱ្យភ្លាមៗដល់ភាគីនីមួយៗដែលមានសិទ្ធិទទួលបានការជូនដំណឹងអំពីការបំពានវិធានប្រឆាំងដូប៉ាក្រោមប្រការ ១៤.១។

១០.១៣.២.៣ គ្មានផលប្រយោជន៍ណាមួយ ដែលនឹងត្រូវផ្តល់ឱ្យដោយដកចេញពីរយៈពេលព្យួរសិទ្ធិទេ មុនកាលបរិច្ឆេទព្យួរសិទ្ធិបណ្តោះអាសន្ន ឬការព្យួរសិទ្ធិបណ្តោះអាសន្នដោយស្ម័គ្រចិត្ត ចូលជាធរមានដោយមិនគិត ថាតើអត្តពលិកត្រូវបានជ្រើសរើសឱ្យចូលប្រកួត ឬត្រូវបានព្យួរសិទ្ធិដោយក្រុមមួយនោះទេ។

១០.១៣.២.៤ នៅក្នុងកីឡាជាក្រុម ប្រសិនបើរយៈពេលនៃការព្យួរសិទ្ធិ ត្រូវបានដាក់លើក្រុម លើកលែងតែការធ្វើដូច្នោះបង្កឱ្យមានភាពអយុត្តិធម៌ បើមិនដូច្នេះទេ រយៈពេលនៃការព្យួរសិទ្ធិនោះ នឹងចាប់ផ្តើមនៅកាលបរិច្ឆេទនៃសេចក្តីសម្រេចសវនាការចុងក្រោយ ដែលកំណត់ការព្យួរសិទ្ធិនោះ ឬប្រសិនបើសវនាការត្រូវបានលើកលែង ត្រូវចាប់ផ្តើមពីកាលបរិច្ឆេទព្យួរសិទ្ធិដែលត្រូវបានទទួលយក ឬត្រូវបានដាក់។ រយៈពេលនៃការព្យួរសិទ្ធិបណ្តោះអាសន្នរបស់ក្រុម (ទោះជាត្រូវបានដាក់ ឬទទួលយកដោយស្ម័គ្រចិត្តក៏ដោយ) នឹងត្រូវផ្តល់ជាប្រយោជន៍ដោយដកចេញពីរយៈពេលនៃការព្យួរសិទ្ធិ ដែលត្រូវអនុវត្តនោះ។

១០.១៤ ស្ថានភាពក្នុងកំឡុងពេលនៃការព្យួរសិទ្ធិ ឬការព្យួរបណ្តោះអាសន្ន

១០.១៤.១ ការហាមឃាត់មិនឱ្យចូលរួមក្នុងកំឡុងពេលនៃការព្យួរសិទ្ធិ ឬការព្យួរសិទ្ធិបណ្តោះអាសន្ន គ្មានអត្តពលិក ឬបុគ្គលផ្សេងទៀតណាមួយ ដែលត្រូវបានប្រកាសថាស្ថិតក្រោមការព្យួរសិទ្ធិ ឬដែលជាកម្មវត្ថុនៃការព្យួរសិទ្ធិបណ្តោះអាសន្ន ក្នុងអំឡុងពេលនៃការព្យួរសិទ្ធិ ឬការព្យួរសិទ្ធិបណ្តោះអាសន្ន អាចចូលរួមនៅក្នុងសមត្ថភាពណាមួយក្នុងការប្រកួត ឬសកម្មភាព (ផ្សេងទៀតក្រៅពីកម្មវិធីអប់រំប្រឆាំងដូប៉ាដែលត្រូវបានអនុញ្ញាត) ដែលត្រូវបានអនុញ្ញាត ឬរៀបចំដោយស្ថាប័នហត្ថលេខី អង្គការដែលជាសមាជិកស្ថាប័នហត្ថលេខី ឬក្លឹប ឬសមាជិកដទៃទៀត នៃអង្គការដែលជាសមាជិករបស់ស្ថាប័នហត្ថលេខីនោះ ឬក្នុងការប្រកួតដែលត្រូវបានអនុញ្ញាត ឬរៀបចំដោយលីគអាជីព ឬអង្គការរៀបចំព្រឹត្តិការណ៍កីឡាថ្នាក់ជាតិ ឬអន្តរជាតិ ឬក្នុងសកម្មភាពកីឡាថ្នាក់ជាតិដែលផ្តល់មូលនិធិដោយទីភ្នាក់ងាររដ្ឋាភិបាល។

អត្តពលិក ឬបុគ្គលផ្សេងទៀតដែលស្ថិតក្នុងរយៈពេលនៃការព្យួរសិទ្ធិលើសពី ៤(បួន)ឆ្នាំ បន្ទាប់ពីបញ្ចប់រយៈពេល ៤(បួន)ឆ្នាំ នៃការព្យួរសិទ្ធិនោះ អាចចូលរួមក្នុងនាមជា អត្តពលិក ក្នុងព្រឹត្តិការណ៍កីឡាថ្នាក់ជាតិដែលមិនស្ថិតក្រោមទណ្ឌកម្ម ឬបើមិនដូច្នេះទេស្ថិតក្រោមសិទ្ធិអំណាចរបស់ស្ថាប័នហត្ថលេខីនៃក្រុម ឬសមាជិកនៃស្ថាប័នហត្ថលេខីនៃក្រុម ប៉ុន្តែមិនអាចចូលរួមក្នុងព្រឹត្តិការណ៍កីឡាថ្នាក់ជាតិណាដែលអាចផ្តល់សិទ្ធិដល់អត្តពលិក ឬបុគ្គលផ្សេងទៀតនោះ ក្នុងការចូលរួមដោយផ្ទាល់ ឬដោយប្រយោល (ឬប្រមូលពិន្ទុ

ឆ្ពោះទៅចូលរួម) ក្នុងការប្រកួតជើងឯកថ្នាក់ជាតិ ឬព្រឹត្តិការណ៍អន្តរជាតិបានទេ ហើយអត្តពលិក ឬបុគ្គលផ្សេងទៀតនោះ មិនអាចពាក់ព័ន្ធក្នុងសមត្ថភាពណាមួយ ជាមួយបុគ្គលដែលត្រូវបានការពារទេ។

អត្តពលិក ឬបុគ្គលផ្សេងទៀត ដែលស្ថិតក្នុងរយៈពេលនៃការព្យួរសិទ្ធិ នឹងនៅតែជាកម្មវត្ថុនៃការធ្វើតេស្ត និងគ្រប់គ្រងខណ្ឌតម្រូវរបស់គណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជាដើម្បីផ្តល់ព័ត៌មានអំពីទីសំចត។

១០.១៤.២ ការត្រឡប់ទៅការហ្វឹកហាត់

ជាករណីលើកលែងចំពោះប្រការ ១០.១៤.១ អត្តពលិកអាចវិលត្រឡប់មកធ្វើការហ្វឹកហាត់ជាមួយនឹងក្រុមវិញ ឬប្រើប្រាស់វិទ្យាក្លឹប ឬស្ថាប័នសមាជិកផ្សេងទៀត របស់គណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជា ឬសមាជិករបស់ស្ថាប័នហត្ថលេខីផ្សេងទៀត ក្នុងកំឡុងពេល៖

(១) ពីរខែចុងក្រោយនៃរយៈពេលព្យួរសិទ្ធិរបស់អត្តពលិក ឬ

(២) មួយភាគបួនចុងក្រោយនៃរយៈពេលព្យួរសិទ្ធិ។

១០.១៤.៣ ការបំពានលើការហាមឃាត់មិនឱ្យចូលរួមក្នុងកំឡុងពេលនៃការព្យួរសិទ្ធិ ឬការព្យួរសិទ្ធិបណ្តោះអាសន្ន ក្នុងករណីដែលអត្តពលិក ឬបុគ្គលផ្សេងទៀត ដែលត្រូវបានប្រកាសថា ស្ថិតក្រោមការព្យួរសិទ្ធិបានបំពានលើការហាមឃាត់មិនឱ្យចូលរួមក្នុងកំឡុងពេលនៃការព្យួរសិទ្ធិដូចដែលបានពិពណ៌នានៅក្នុងប្រការ ១០.១៤.១ លទ្ធផលនៅក្នុងការចូលរួមប្រកួតទាំងនោះនឹងត្រូវបានបដិសេធ ហើយរយៈពេលព្យួរសិទ្ធិថ្មី ស្មើនឹងរយៈពេលព្យួរសិទ្ធិដើម នឹងត្រូវបានបន្ថែម នៅចុងបញ្ចប់នៃរយៈពេលព្យួរសិទ្ធិដើម។ រយៈពេលនៃការព្យួរសិទ្ធិថ្មីរាប់បញ្ចូលទាំងការស្តីបន្ទោសដោយគ្មានការព្យួរសិទ្ធិ អាចត្រូវបានកែប្រែ ដោយផ្អែកលើកម្រិតកំហុសរបស់អត្តពលិក ឬបុគ្គលផ្សេងទៀតនោះ និងកាលៈទេសៈផ្សេងៗ នៃករណីនោះ។ ការប្តេជ្ញាចិត្តថាតើអត្តពលិក ឬបុគ្គលផ្សេងទៀត បានបំពានលើការហាមឃាត់ប្រឆាំងនឹងការចូលរួម និងថាតើការកែតម្រូវសមស្របត្រូវធ្វើឡើងដោយអង្គការប្រឆាំងដូប៉ា ដែលការដោះស្រាយវិវាទដូប៉ា នាំឱ្យមានការព្យួរសិទ្ធិក្នុងរយៈពេលដំបូង។ សេចក្តីសម្រេចនេះ អាចត្រូវបានជំទាស់ ដោយយោងតាមប្រការ ១៣។

អត្តពលិក ឬបុគ្គលផ្សេងទៀត ដែលបំពានលើការហាមឃាត់មិនឱ្យចូលរួម ក្នុងអំឡុងពេលនៃការព្យួរសិទ្ធិបណ្តោះអាសន្ន ដូចដែលមានចែងក្នុងប្រការ ១០.១៤.១ នឹងមិនទទួលបានផលប្រយោជន៍ចំពោះរយៈពេលនៃការព្យួរសិទ្ធិបណ្តោះអាសន្នណាមួយឡើយ ហើយលទ្ធផលនៃការចូលរួមប្រកួតទាំងនោះនឹងត្រូវបានបដិសេធ។

ក្នុងករណីដែលបុគ្គលគាំពារអត្តពលិក ឬបុគ្គលផ្សេងទៀតជួយបុគ្គលណាមួយក្នុងការបំពានលើការហាមឃាត់មិនឱ្យចូលរួមក្នុងអំឡុងពេលនៃការព្យួរសិទ្ធិ ឬការព្យួរសិទ្ធិបណ្តោះអាសន្នគណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជា ត្រូវដាក់ទណ្ឌកម្មចំពោះការបំពានប្រការ ២.៩ សម្រាប់ការជួយបែបនេះ។

១០.១៤.៤ ការដកការគាំទ្រផ្នែកហិរញ្ញវត្ថុក្នុងកំឡុងពេលនៃការព្យួរសិទ្ធិ

លើសពីនេះទៀត ចំពោះការបំពានវិធានប្រឆាំងដូប៉ាណាមួយ ដែលមិនពាក់ព័ន្ធនឹងការបន្ធូរបន្ថយទណ្ឌកម្មដូចមានចែងក្នុងប្រការ ១០.៥ ឬ ប្រការ ១០.៦ ការគាំទ្រផ្នែកហិរញ្ញវត្ថុ អត្ថប្រយោជន៍ទាក់ទងនឹងកីឡាដទៃទៀតមួយចំនួន ឬទាំងអស់ ដែលទទួលបានដោយបុគ្គលនោះ នឹងត្រូវដកហូត ដោយគណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជា រាជរដ្ឋាភិបាលកម្ពុជា គណៈកម្មាធិការជាតិ អូឡាំពិកកម្ពុជា គណៈកម្មាធិការជាតិប៉ារ៉ាឡាំពិកកម្ពុជា និងសហព័ន្ធកីឡាជាតិ។

១០.១៥ ការផ្សព្វផ្សាយទណ្ឌកម្មដោយស្វ័យប្រវត្តិ

ផ្នែកដែលចាំបាច់នៃទណ្ឌកម្មនីមួយៗរួមមានការផ្សព្វផ្សាយ ដោយស្វ័យប្រវត្តិដូចមានចែងក្នុងប្រការ ១៤.៣។

## ប្រការ១១៖ ទណ្ឌកម្មសម្រាប់ក្រុម

១១.១ ការធ្វើតេស្តសម្រាប់កីឡាជាក្រុម

ក្នុងករណីដែលមានសមាជិកច្រើនជាង ១(មួយ)នាក់ នៃក្រុមក្នុងកីឡាជាក្រុម ត្រូវបានជូនដំណឹងអំពីការបំពានវិធានប្រឆាំងដូប៉ាប្រការ ៧ ទាក់ទងនឹងព្រឹត្តិការណ៍កីឡា ស្ថាប័នគ្រប់គ្រងព្រឹត្តិការណ៍នោះ ត្រូវធ្វើតេស្តគោលដៅលើក្រុមកីឡានោះ ក្នុងកំឡុងពេលនៃព្រឹត្តិការណ៍។

១១.២ ទណ្ឌកម្មសម្រាប់កីឡាជាក្រុម

ប្រសិនបើមានសមាជិកច្រើនជាងពីរនាក់នៃក្រុមមួយនៅក្នុងកីឡាជាក្រុម ត្រូវបានគេរកឃើញថាបានប្រព្រឹត្តិបំពានវិធានប្រឆាំងដូប៉ាក្នុងអំឡុងពេលនៃព្រឹត្តិការណ៍នោះ ស្ថាប័នគ្រប់គ្រងព្រឹត្តិការណ៍ នឹងដាក់ទណ្ឌកម្មសមស្របលើក្រុម (ឧទាហរណ៍៖ ការដកពិន្ទុ ការដកសិទ្ធិពីការប្រកួត ឬពីព្រឹត្តិការណ៍ ឬការដាក់ទណ្ឌកម្មផ្សេងទៀត) បន្ថែមលើទណ្ឌកម្មដែលបានដាក់ទៅលើអត្តពលិក ដែលប្រព្រឹត្តបំពាននឹងវិធានប្រឆាំងដូប៉ា។

១១.៣ ស្ថាប័នគ្រប់គ្រងព្រឹត្តិការណ៍អាចដាក់ទណ្ឌកម្មតឹងរ៉ឹងសម្រាប់កីឡាជាក្រុម

ស្ថាប័នគ្រប់គ្រងព្រឹត្តិការណ៍ប្រកួតកីឡា អាចសម្រេចបង្កើតវិធានសម្រាប់គ្រប់គ្រងព្រឹត្តិការណ៍ដែលកំណត់ទណ្ឌកម្មចំពោះកីឡាជាក្រុមធ្ងន់ធ្ងរជាងទណ្ឌកម្មដែលមានចែងក្នុងប្រការ ១១.២ សម្រាប់គោលបំណងនៃព្រឹត្តិការណ៍នោះ។

## ប្រការ១២៖ ការដាក់ទណ្ឌកម្មដោយគណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជាលើស្ថាប័នកីឡាផ្សេងទៀត

នៅពេលដែលគណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជាដឹងថាសហព័ន្ធកីឡាជាតិ មួយនៅក្នុងប្រទេសកម្ពុជា ឬស្ថាប័នកីឡាដទៃទៀត នៅក្នុងប្រទេសកម្ពុជា ក្រោមសិទ្ធិអំណាចរបស់ខ្លួន ខកខានមិនបានអនុលោមតាម គោរពតាម ប្រកាន់យក និងអនុវត្តតាមវិធានប្រឆាំងដូប៉ា ក្រោមសមត្ថកិច្ចរបស់ស្ថាប័ន ឬអង្គភាពនោះ គណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជាអាចសម្រេចស្នើសុំ គណៈកម្មាធិការជាតិអូឡាំពិកកម្ពុជា រាជរដ្ឋាភិបាលកម្ពុជា ឬសហព័ន្ធកីឡាអន្តរជាតិឱ្យចាត់វិធានការវិន័យបន្ថែមដូចខាងក្រោម ឬក្នុងករណីដែលខ្លួនមានសិទ្ធិអំណាច អាចចាត់វិធានការវិន័យបន្ថែមដូចខាងក្រោម៖

១២.១ ដកសមាជិកមួយចំនួន ឬទាំងអស់របស់ស្ថាប័ន ឬអង្គភាពនោះពីព្រឹត្តិការណ៍កីឡាជាក់លាក់នាពេលអនាគត ឬព្រឹត្តិការណ៍ទាំងអស់ក្នុងរយៈពេលដែលបានកំណត់ណាមួយ។

១២.២ អនុវត្តសកម្មភាពវិន័យបន្ថែមចំពោះការទទួលស្គាល់របស់អង្គភាព ឬស្ថាប័ននោះ សិទ្ធិរបស់សមាជិកខ្លួនក្នុងការចូលរួមក្នុងសកម្មភាពរបស់គណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជា និង/ឬ ការពិន័យជាប្រាក់ដែលអង្គភាព ឬស្ថាប័ននោះ ដោយផ្អែកមូលដ្ឋានលើដូចខាងក្រោម៖

១២.២.១ ការបំពានវិធានប្រឆាំងដូប៉ា (ក្រៅពីការបំពានលើប្រការ ២.៤) ចំនួន ៤(បួន) ឬលើសពីនេះ ត្រូវបានប្រព្រឹត្តដោយអត្តពលិក ឬបុគ្គលផ្សេងទៀត ដែលមានទំនាក់ទំនងជាមួយអង្គភាព ឬស្ថាប័ននោះ ក្នុងរយៈពេល ១២(ដប់ពីរ)ខែ។ នៅក្នុងករណីបែបនោះ៖

ក. សមាជិកមួយចំនួន ឬទាំងអស់របស់ក្រុមនៃអង្គភាព ឬស្ថាប័ននោះ អាចត្រូវបានហាមឃាត់មិនឱ្យ

ចូលរួមក្នុងសកម្មភាពរបស់គណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជាក្នុងរយៈពេលរហូតដល់ ២(ពីរ)ឆ្នាំ និង/ឬ

ខ. អង្គភាព ឬស្ថាប័ននោះ អាចនឹងត្រូវពិន័យជាប្រាក់រហូតដល់ ៥០០(ប្រាំរយ) ដុល្លារអាមេរិច។

១២.២.២ ការបំពានវិធានប្រឆាំងដូប៉ា (ក្រៅពីការបំពានលើប្រការ ២.៤) ចំនួន ៤(បួន) ឬលើសពីនេះ ត្រូវបានប្រព្រឹត្តបន្ថែមលើការបំពានដូចដែលមានចែងក្នុងប្រការ ១២.២.១ ដោយអត្តពលិក ឬបុគ្គលដទៃទៀតដែលមានទំនាក់ទំនងជាមួយអង្គភាព ឬស្ថាប័ន នោះ ក្នុងរយៈពេល ១២(ដប់ពីរ)ខែ។ ក្នុងករណីបែបនេះ អង្គភាព ឬស្ថាប័ននោះអាចត្រូវបានព្យួរសិទ្ធិរយៈពេលរហូតដល់ ៤(បួន)ឆ្នាំ។

១២.២.៣ អត្តពលិក ឬបុគ្គលផ្សេងទៀត លើសពីម្នាក់ដែលមានទំនាក់ទំនងជាមួយអង្គភាព ឬស្ថាប័ននោះប្រព្រឹត្តបំពានវិធានប្រឆាំងដូប៉ា ក្នុងអំឡុងពេលនៃព្រឹត្តិការណ៍កីឡាអន្តរជាតិ។ ក្នុងករណីបែបនោះ អង្គភាព ឬស្ថាប័ននោះ អាចនឹងត្រូវពិន័យជាទឹកប្រាក់រហូតដល់ ៥០០(ប្រាំរយ) ដុល្លារអាមេរិច។

១២.២.៤ អង្គភាព ឬស្ថាប័នខកខានក្នុងការខិតខំប្រឹងប្រែងដើម្បីផ្តល់បច្ចុប្បន្នភាពដល់គណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជា ព័ត៌មានអំពីទីសំចតរបស់អត្តពលិក បន្ទាប់ពីទទួលបានការស្នើសុំព័ត៌មានពីគណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជា។ ក្នុងករណីបែបនេះ អង្គភាព ឬស្ថាប័ននោះអាចនឹងត្រូវពិន័យជាទឹកប្រាក់រហូតដល់ ៥០០ (ប្រាំរយ) ដុល្លារអាមេរិច សម្រាប់អត្តពលិកម្នាក់ៗ បន្ថែមលើសំណងចំពោះការចំណាយ របស់គណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជា ទាំងអស់ក្នុងការធ្វើតេស្តអត្តពលិករបស់អង្គភាពនោះ។

១២.៣ ដកហូតមូលនិធិមួយផ្នែក ឬទាំងអស់ ឬដកការគាំទ្រផ្នែកហិរញ្ញវត្ថុ និងមិនមែនហិរញ្ញវត្ថុ ពីអង្គភាព ឬស្ថាប័ននោះ។

១២.៤ ឱ្យអង្គភាព ឬស្ថាប័ននោះ ផ្តល់សំណងដល់គណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជា សម្រាប់រាល់ការចំណាយ (រាប់បញ្ចូលទាំងថ្លៃមន្ទីរពិសោធន៍ ការចំណាយលើសវនាការ និងការធ្វើដំណើរ) ដែលទាក់ទងនឹងការបំពានវិធានប្រឆាំងដូប៉ា ដែលប្រព្រឹត្តដោយអត្តពលិក ឬបុគ្គលផ្សេងទៀត ដែលមានទំនាក់ទំនងជាមួយអង្គភាព ឬស្ថាប័ននោះ។

## ប្រការ១៣៖ ការដោះស្រាយវិវាទដូប៉ា៖ ការប្តឹងជំទាស់

### ១៣.១ សេចក្តីសម្រេចដែលអាចត្រូវប្តឹងជំទាស់

សេចក្តីសម្រេចដែលធ្វើឡើងក្រោមក្រម ឬវិធានប្រឆាំងដូប៉ាអាចត្រូវបានប្តឹងជំទាស់ ដូចមានចែងក្នុងប្រការ ១៣.២ ដល់ប្រការ ១៣.៧ ឬត្រូវបានកំណត់ក្នុងវិធានប្រឆាំងដូប៉ាក្នុងក្រម ឬក្នុងស្តង់ដារអន្តរជាតិ។ សេចក្តីសម្រេចបែបនេះ នឹងនៅតែមានសុពលភាព ទោះបីក្នុងអំឡុងពេលនៃបណ្តឹងជំទាស់ ក៏ដោយលើកលែងតែស្ថាប័នបណ្តឹងជំទាស់សម្រេចផ្សេងពីនេះ។

### ១៣.១.១ វិសាលភាពនៃការពិនិត្យឡើងវិញមិនមានដែនកំណត់

វិសាលភាពនៃការពិនិត្យលើបណ្តឹងជំទាស់ រួមបញ្ចូលបញ្ហាទាំងអស់ដែលទាក់ទងនឹងករណីនោះ ហើយត្រូវបានបង្ហាញយ៉ាងច្បាស់ថាមិនកំណត់ចំពោះតែបញ្ហា ឬវិសាលភាពនៃការពិនិត្យឡើងវិញមុនការផ្តល់សេចក្តីសម្រេចដំបូងឡើយ។ ភាគីណាមួយនៅក្នុងបណ្តឹងជំទាស់អាចដាក់ភស្តុតាង អំណះអំណាងច្បាប់ និងបណ្តឹងទាមទារសំណង ដែលមិនមាននៅក្នុងសវនាការបឋមបាន ដរាបណាវាកើតចេញពីមូលហេតុដូចគ្នានៃសកម្មភាព ឬអង្គហេតុ ឬកាលៈទេសៈទូទៅដូចគ្នា ដែលត្រូវបានលើកឡើង ឬដោះស្រាយនៅក្នុង

សវនាការបឋម។

១៣.១.២ មជ្ឈតកម្មកីឡាមិនត្រូវរង់ចាំលទ្ធផលបណ្ដឹងជំទាស់ដែលកំពុងដំណើរការឡើយ។

ក្នុងការធ្វើសេចក្ដីសម្រេចរបស់ខ្លួន មជ្ឈតកម្មកីឡាមិនត្រូវរង់ចាំសេចក្ដីសម្រេច ដែលនឹងអនុវត្តដោយស្ថាប័នដែលសេចក្ដីសម្រេចរបស់ខ្លួនកំពុងត្រូវបានប្ដឹងជំទាស់ឡើយ។

១៣.១.៣ ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក មិនចាំបាច់ខិតខំស្វែងរកគ្រប់ដំណោះស្រាយផ្ទៃក្នុងរបស់ខ្លួនទេ

ក្នុងករណីដែល ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក មានសិទ្ធិប្ដឹងជំទាស់ តាមប្រការ ១៣ ហើយគ្មានភាគីណាមួយបានប្ដឹងជំទាស់នឹងសេចក្ដីសម្រេចចុងក្រោយ នៅក្នុងដំណើរការរបស់គណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជាទេនោះ ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក អាចប្ដឹងជំទាស់ចំពោះសេចក្ដីសម្រេចបែបនេះដោយផ្ទាល់ទៅមជ្ឈតកម្មកីឡា ដោយមិនចាំបាច់ប្រើគ្រប់លទ្ធភាព នៃដំណោះស្រាយផ្សេងទៀត នៅក្នុងដំណើរការរបស់គណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជាទេ។

១៣.២ ការប្ដឹងជំទាស់សេចក្ដីសម្រេចទាក់ទងនឹង ការបំពានវិធានប្រឆាំងដូប៉ា ទណ្ឌកម្មការព្យួរសិទ្ធិបណ្ដោះអាសន្ន ការអនុវត្តសេចក្ដីសម្រេច និងសិទ្ធិអំណាច

សេចក្ដីសម្រេចថាតើមានការបំពានវិធានប្រឆាំងដូប៉ា សេចក្ដីសម្រេចក្នុងការដាក់ទណ្ឌកម្ម ឬការមិនដាក់ទណ្ឌកម្ម សម្រាប់ការបំពានវិធានប្រឆាំងដូប៉ា ឬសេចក្ដីសម្រេចថាមិនមានការបំពានលើវិធានប្រឆាំងដូប៉ា សេចក្ដីសម្រេចថានីតិវិធីស្ដីពីការបំពានវិធានប្រឆាំងដូប៉ា មិនអាចបន្តទៅមុខបានតាមហេតុផលនីតិវិធី (រួមទាំង ឧទាហរណ៍ ដោយសារវេជ្ជបញ្ញា) សេចក្ដីសម្រេចរបស់ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក មិនឱ្យលើកលែងលក្ខខណ្ឌតម្រូវក្នុងការជូនដំណឹងរយៈពេល ៦(ប្រាំមួយ)ខែ សម្រាប់ឱ្យអត្តពលិក ចូលនិវត្តន៍ត្រលប់ទៅចូលរួមការប្រកួតវិញ ដូចមានចែងក្នុងប្រការ ៥.៦.១ សេចក្ដីសម្រេចរបស់ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក ដែលចាត់តាំងលើការដោះស្រាយវិវាទដូប៉ាតាមប្រការ ៧.១ នៃក្រម សេចក្ដីសម្រេចដោយគណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជា ក្នុងការមិនលើកយកលទ្ធផលវិភាគវិជ្ជមាន ឬលទ្ធផលមិនធម្មតា ជាមូលដ្ឋាននៃការបំពានវិធានប្រឆាំងដូប៉ា ឬសេចក្ដីសម្រេចមិនបន្តនីតិវិធីស្ដីពីការបំពានវិធានប្រឆាំងដូប៉ា បន្ទាប់ពីការស៊ើបអង្កេតស្របតាមស្តង់ដារអន្តរជាតិស្ដីពីដោះស្រាយវិវាទដូប៉ា សេចក្ដីសម្រេចក្នុងការដាក់ ឬដកការព្យួរសិទ្ធិ បណ្ដោះអាសន្ន ដែលជាលទ្ធផលនៃសវនាការបណ្ដោះអាសន្ន ការខកខានរបស់គណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជា ក្នុងការអនុលោមតាមប្រការ ៧.៤ សេចក្ដីសម្រេចដែលថាគណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជា មិនមានសិទ្ធិអំណាចក្នុងការសម្រេចថាតើមាន ឬមិនមានការបំពានវិធានប្រឆាំងដូប៉ា ឬទណ្ឌកម្មនៃការបំពាននោះ សេចក្ដីសម្រេចព្យួរ ឬមិនព្យួរសិទ្ធិ ទណ្ឌកម្ម ឬសេចក្ដីសម្រេចផ្ដល់សិទ្ធិ ឬមិនផ្ដល់សិទ្ធិឡើងវិញ ទណ្ឌកម្មដែលមានចែងក្នុងប្រការ ១០.៧.១ ការមិនអនុលោមតាមប្រការ ៧.១.៤ និងប្រការ ៧.១.៥ នៃក្រម ការមិនអនុលោមតាមប្រការ ១០.៨.១ សេចក្ដីសម្រេចក្រោមប្រការ ១០.១៤.៣ សេចក្ដីសម្រេចរបស់គណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជា មិនឱ្យអនុវត្តសេចក្ដីសម្រេច របស់ស្ថាប័នប្រឆាំងដូប៉ាផ្សេងទៀតក្រោមប្រការ ១៥ និងសេចក្ដីសម្រេចក្រោមប្រការ ២៧.៣ នៃក្រមនេះអាចត្រូវបានប្ដឹងជំទាស់ទាំងស្រុង ដូចមានចែងក្នុងប្រការ ១៣.២ នេះ។

១៣.២.១ ការប្ដឹងជំទាស់ដែលពាក់ព័ន្ធនឹងអត្តពលិកកម្រិតអន្តរជាតិ ឬព្រឹត្តិការណ៍កីឡាអន្តរជាតិ ក្នុងករណីដែលកើតឡើងពីការចូលរួមក្នុងព្រឹត្តិការណ៍កីឡាអន្តរជាតិ ឬក្នុងករណីពាក់ព័ន្ធនឹងអត្តពលិកកម្រិតអន្តរជាតិ សេចក្ដីសម្រេចអាចត្រូវបានប្ដឹងជំទាស់ទាំងស្រុងទៅមជ្ឈតកម្មកីឡា។

១៣.២.២ ការប្ដឹងជំទាស់ដែលពាក់ព័ន្ធនឹងអត្តពលិក ឬបុគ្គលផ្សេងទៀត

ក្នុងករណីដែលប្រការ ១៣.២.១ មិនអាចអនុវត្តបាន សេចក្តីសម្រេចអាចត្រូវបានប្តឹងជំទាស់ទៅ ក្រុមប្រឹក្សាបណ្តឹងជំទាស់របស់គណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជា។ដំណើរការបណ្តឹងជំទាស់នឹងត្រូវអនុវត្តស្របតាមស្តង់ដារអន្តរជាតិស្តីពីការដោះស្រាយវិវាទដូប៉ា ។

១៣.២.២.១ សវនាការនៅចំពោះមុខក្រុមប្រឹក្សាបណ្តឹងជំទាស់ របស់គណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជា។

១៣.២.២.១.១ ក្រុមប្រឹក្សាបណ្តឹងជំទាស់ របស់គណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជាមានប្រធានឯករាជ្យម្នាក់ និងសមាជិក ២(ពីរ)នាក់។

១៣.២.២.១.២ សមាជិកម្នាក់ៗត្រូវបានតែងតាំងដោយផ្អែកលើបទពិសោធប្រឆាំងដូប៉ា រួមទាំងជំនាញផ្នែកច្បាប់ កីឡា វេជ្ជសាស្ត្រ និង/ឬវិទ្យាសាស្ត្ររបស់ពួកគេ។ សមាជិកនីមួយៗ នឹងត្រូវបានតែងតាំងសម្រាប់អាណត្តិ ៣(បី)ឆ្នាំ បន្តទៀតបាន។

១៣.២.២.១.៣ សមាជិកដែលត្រូវបានតែងតាំងត្រូវមានឯករាជភាពផ្នែកប្រតិបត្តិការ និងស្ថាប័ន។ សមាជិកក្រុមប្រឹក្សាភិបាល បុគ្គលិកសមាជិកគណៈកម្មការ ទីប្រឹក្សា និងមន្ត្រីនៃគណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជា ឬស្ថាប័នបុត្រសម្ព័ន្ធរបស់ខ្លួន (ដូចជាភាគីទី៣ ដែលទទួលសិទ្ធិ) ក៏ដូចជាបុគ្គលដែលពាក់ព័ន្ធនឹងការស៊ើបអង្កេតការសម្រេចក្តីជាមុន ឬការដោះស្រាយវិវាទដូប៉ានៃបញ្ហានោះ មិនអាចត្រូវបានតែងតាំងជាសមាជិក និង/ឬស្មៀននៃក្រុមប្រឹក្សាបណ្តឹងជំទាស់ របស់គណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជាបានទេ។ ជាពិសេសគ្មានសមាជិកណាម្នាក់ ដែលធ្លាប់ពិចារណាលើពាក្យស្នើសុំសម្រាប់ការលើកលែងឱ្យប្រើប្រាស់ថ្នាំព្យាបាល សេចក្តីសម្រេចលើការដោះស្រាយវិវាទដូប៉ាករណីដំបូង ឬបណ្តឹងជំទាស់ដែលពាក់ព័ន្ធនឹងអត្តពលិកឬ បុគ្គលផ្សេងទៀត ក្នុងករណីជាក់លាក់នោះទេ។

១៣.២.២.១.៤ ក្រុមប្រឹក្សាបណ្តឹងជំទាស់របស់គណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជា មានមូលដ្ឋានក្នុងការដំណើរការនីតិវិធីសវនាការ និងធ្វើសេចក្តីសម្រេច ដោយគ្មានការជ្រៀតជ្រែកពីគណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជា ឬភាគីទី៣ឡើយ។

១៣.២.២.១.៥ ប្រសិនបើសមាជិកដែលត្រូវបានតែងតាំងដោយប្រធានឱ្យចូលរួមជំនុំជម្រះក្តីមិនចង់ ឬមិនអាចចូលរួមបាន ក្នុងហេតុផលណាមួយ ក្នុងការចូលរួមជំនុំជម្រះក្តីនោះ ប្រធានអាចតែងតាំងអ្នកជំនួស ឬតែងតាំងក្រុមប្រឹក្សាជំនុំជម្រះថ្មី។

១៣.២.២.១.៦ ក្រុមប្រឹក្សាបណ្តឹងជំទាស់ របស់គណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជាមានសិទ្ធិអំណាចក្នុងការសម្រេចលើការតែងតាំងអ្នកជំនាញណាម្នាក់ដើម្បីជួយជឹងឮ ឬផ្តល់ប្រឹក្សាដល់ក្រុមប្រឹក្សានេះ។

១៣.២.២.១.៧ សហព័ន្ធកីឡាអន្តរជាតិ សហព័ន្ធកីឡាជាតិដែលពាក់ព័ន្ធគណៈកម្មាធិការជាតិអូឡាំពិក (ប្រសិនបើមិនមានជាភាគីនៃកិច្ចដំណើរការនីតិវិធី) និងទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោកមានសិទ្ធិក្នុងការចូលរួមសវនាការរបស់ក្រុមប្រឹក្សាបណ្តឹងជំទាស់ នៃគណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជាជាអ្នកសង្កេតការណ៍។

១៣.២.២.១.៨ សវនាការស្របតាមប្រការនេះ គួរត្រូវបានបញ្ចប់ឱ្យបានឆាប់រហ័សតាមដែលអាចធ្វើទៅបាន។ សវនាការដែលធ្វើឡើងទាក់ទងនឹងព្រឹត្តិការណ៍ កីឡានានា គួរត្រូវបានធ្វើឡើងឱ្យមានឆាប់ហើយ។

១៣.២.២.២ កិច្ចដំណើរការនីតិវិធីរបស់ក្រុម ក្រុមប្រឹក្សាបណ្តឹងជំទាស់នៃគណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជា

១៣.២.២.២.១ កិច្ចដំណើរការនីតិវិធីរបស់ក្រុមប្រឹក្សាបណ្ដឹងជំទាស់ នៃគណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជា ត្រូវគោរពគោលការណ៍ ដូចដែលមានចែងក្នុងប្រការ ៨ ប្រការ ៩ និងប្រការ ១០ នៃស្តង់ដារអន្តរជាតិស្តីពីការដោះស្រាយវិវាទដូប៉ា។

១៣.២.២.២.២ ប្រធានត្រូវតែងតាំងសមាជិក ៣(បី)រូប (ដែលអាចរួមបញ្ចូលទាំងប្រធាន) ដើម្បីចូលសវនាការនោះ។ នៅក្នុងពេលសវនាការត្រូវមានសមាជិក ១(មួយ)រូប ជាមេធាវីមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដែលមានបទពិសោធន៍ផ្នែកច្បាប់មិនតិចជាង ៣(បី)ឆ្នាំ និងសមាជិកគណៈកម្មាធិការ ១(មួយ)រូប ជាអ្នកជំនាញខាងវេជ្ជសាស្ត្រ ដែលមានបទពិសោធន៍វេជ្ជសាស្ត្រពាក់ព័ន្ធមិនតិចជាង ៣(បី)ឆ្នាំ។

១៣.២.២.២.៣ ក្រោយពេលប្រធានតែងតាំងជាសមាជិក នៃក្រុមប្រឹក្សាបណ្ដឹងជំទាស់របស់គណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជា ហើយសមាជិកត្រូវតែចុះហត្ថលេខា លើសេចក្តីប្រកាសមួយដែលថា មិនមានហេតុការណ៍ ឬកាលៈទេសៈដែលខ្លួនបានដឹងណាមួយ ដែលអាចធ្វើឱ្យមានការសង្ស័យចំពោះភាពមិនលំអៀង របស់ខ្លួននៅក្នុងក្រសែភ្នែករបស់ភាគីណាមួយក្រៅតែពីស្ថានភាពដែលត្រូវបានបង្ហាញនៅក្នុងសេចក្តីប្រកាសនោះឡើយ។

១៣.២.២.២.៤ អ្នកប្តឹងជំទាស់ត្រូវបង្ហាញអំណះអំណាងរបស់ខ្លួន ហើយភាគីចុងបណ្ដឹងមួយ ឬច្រើនត្រូវបង្ហាញអំណះអំណាងរបស់ខ្លួនជាការឆ្លើយតប។

១៣.២.២.២.៥ ប្រសិនបើភាគី ឬតំណាងរបស់ខ្លួនមិនបានចូលរួមក្នុងសវនាការបន្ទាប់ពីការជូនដំណឹងទេ សវនាការនៅតែអាចបន្តនីតិវិធីទៅមុខទៀតបាន។

១៣.២.២.២.៦ ភាគីនីមួយៗមានសិទ្ធិធ្វើជាតំណាងដោយក្រុមប្រឹក្សាច្បាប់នៅក្នុងសវនាការ ក្រោមការចំណាយផ្ទាល់របស់ភាគីនោះ។

១៣.២.២.២.៧ ភាគីនីមួយៗមានសិទ្ធិប្រើសេវាបកប្រែភាសានៅក្នុងសវនាការក្រោមការចំណាយ របស់ភាគីនោះ។

១៣.២.២.២.៨ ភាគីនីមួយៗនៅក្នុងដំណើរការនីតិវិធីមានសិទ្ធិទទួលបាន និងបង្ហាញភស្តុតាងដែលពាក់ព័ន្ធ សិទ្ធិដាក់សេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរ និងផ្ទាល់មាត់ និងសិទ្ធិកោះ និងពិនិត្យសាក្សី។

១៣.២.២.៣ សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាបណ្ដឹងជំទាស់នៃគណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជា

១៣.២.២.៣.១ នៅចុងបញ្ចប់នៃសវនាការ ឬភ្លាមៗបន្ទាប់ពីនោះ ក្រុមប្រឹក្សា បណ្ដឹងជំទាស់ របស់គណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជា នឹងចេញសេចក្តីសម្រេចជាលាយលក្ខណ៍អក្សរ និងចុះហត្ថលេខាដែលគោរពគោលការណ៍នៃប្រការ ៩ នៃស្តង់ដារអន្តរជាតិស្តីពីការដោះស្រាយវិវាទដូប៉ា។

១៣.២.២.៣.២ សេចក្តីសម្រេចនោះត្រូវរួមបញ្ចូលទាំងហេតុផលពេញលេញ និងរយៈពេលនៃការព្យួរសិទ្ធិរាប់បញ្ចូល (បើមាន) ទាំងមូលហេតុថាហេតុអ្វីការដាក់ទណ្ឌកម្មសក្តានុពលអតិបរមាមិនត្រូវបានអនុវត្ត។

១៣.២.២.៣.៣ គណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជា ត្រូវជូនដំណឹងពីសេចក្តីសម្រេចនោះដល់អត្តពលិក ឬបុគ្គលដទៃទៀត ដល់សហព័ន្ធកីឡាជាតិរបស់គាត់ និងដល់អង្គការប្រឆាំងដូប៉ា ដែលមានសិទ្ធិប្តឹងជំទាស់ តាមប្រការ ១៣. ២.៣ ហើយត្រូវរាយការណ៍ភ្លាមៗ នៅក្នុងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលប្រឆាំងដូប៉ា។

១៣.២.២.៣.៤ សេចក្តីសម្រេចនោះអាចត្រូវបានប្តឹងជំទាស់ ដូចមានចែងក្នុងប្រការ ១៣.២.៣ និងត្រូវបានបង្ហាញជាសាធារណៈ ដូចមានចែងក្នុងប្រការ ១៤.៣ ។

១៣.២.៣ បុគ្គលដែលមានសិទ្ធិប្តឹងជំទាស់

១៣.២.៣.១ ការប្តឹងទាស់ដែលពាក់ព័ន្ធនឹងអត្តពលិកកម្រិតអន្តរជាតិ ឬព្រឹត្តិការណ៍កីឡាអន្តរជាតិ ក្នុងករណី ដូចមានចែងក្នុងប្រការ ១៣.២.១ ភាគីដូចខាងក្រោមមានសិទ្ធិប្តឹងជំទាស់ទៅមជ្ឈតកម្មកីឡា៖

ក. អត្តពលិក ឬបុគ្គលផ្សេងទៀតដែលជាកម្មវត្ថុនៃសេចក្តីសម្រេចដែលកំពុងត្រូវបានប្តឹងជំទាស់។

ខ. ភាគីផ្សេងទៀតក្នុងរឿងក្តី ដែលត្រូវអនុវត្តសេចក្តីសម្រេចនោះ។

គ. សហព័ន្ធកីឡាអន្តរជាតិពាក់ព័ន្ធ។

ឃ. គណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជា និង(បើផ្សេងពី) ស្ថាប័នប្រឆាំងដូប៉ាជាតិនៃប្រទេសបុគ្គលនោះរស់នៅ ឬប្រទេសដែលផ្តល់សញ្ជាតិ ឬអាជ្ញាប័ណ្ណកីឡាដល់បុគ្គលនោះ។

ង. គណៈកម្មាធិការអូឡាំពិកអន្តរជាតិ ឬគណៈកម្មាធិការប៉ារ៉ាឡាំពិកអន្តរជាតិ តាមករណីដែលអាចអនុវត្តបាន ដែលសេចក្តីសម្រេចអាចមានឥទ្ធិពលទាក់ទងនឹងកីឡា អូឡាំពិក ឬប៉ារ៉ាឡាំពិក ដែលរួមបញ្ចូលទាំងសេចក្តីសម្រេចដែលមានឥទ្ធិពលលើសិទ្ធិចូលរួមកីឡាអូឡាំពិក ឬប៉ារ៉ាឡាំពិក។

ច. ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក ។

១៣.២.៣.២ ការប្តឹងជំទាស់ដែលពាក់ព័ន្ធនឹងអត្តពលិក ឬបុគ្គលផ្សេងទៀត
ក្នុងករណី ដូចមានចែងក្នុងប្រការ ១៣.២.២ ភាគីខាងក្រោមនេះមានសិទ្ធិប្តឹងជំទាស់៖

ក. អត្តពលិក ឬបុគ្គលផ្សេងទៀតដែលជាកម្មវត្ថុនៃសេចក្តីសម្រេចដែលកំពុងត្រូវបានប្តឹងជំទាស់។

ខ. ភាគីផ្សេងទៀតក្នុងរឿងក្តី ដែលត្រូវអនុវត្តសេចក្តីសម្រេចនោះ។

គ. សហព័ន្ធកីឡាអន្តរជាតិពាក់ព័ន្ធ។

ឃ. គណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជា និង(បើផ្សេងពី) ស្ថាប័នប្រឆាំងដូប៉ាជាតិនៃប្រទេសដែលបុគ្គលនោះរស់នៅ ឬប្រទេសដែលផ្តល់សញ្ជាតិ ឬអាជ្ញាប័ណ្ណកីឡាដល់បុគ្គលនោះ។

ង. គណៈកម្មាធិការអូឡាំពិកអន្តរជាតិ ឬគណៈកម្មាធិការប៉ារ៉ាឡាំពិកអន្តរជាតិ តាមករណីដែលអាចអនុវត្តបាន ដែលសេចក្តីសម្រេចអាចមានឥទ្ធិពលទាក់ទងនឹងកីឡាអូឡាំពិក ឬប៉ារ៉ាឡាំពិក ដែលរួមបញ្ចូលទាំងសេចក្តីសម្រេចដែលមានឥទ្ធិពលលើសិទ្ធិចូលរួមកីឡាអូឡាំពិក ឬប៉ារ៉ាឡាំពិក និង

ច. ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក។

ចំពោះករណីដែលមានចែងក្នុងប្រការ ១៣.២.២ ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក គណៈកម្មាធិការអូឡាំពិកអន្តរជាតិ គណៈកម្មាធិការជាតិប៉ារ៉ាឡាំពិកអន្តរជាតិ និងសហព័ន្ធកីឡាអន្តរជាតិដែលពាក់ព័ន្ធក៏មានសិទ្ធិប្តឹងជំទាស់ទៅមជ្ឈតកម្មកីឡា ដោយគោរពតាម សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាបណ្តឹងជំទាស់នៃគណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជា។

ភាគីដែលដាក់ពាក្យបណ្តឹងជំទាស់ នឹងមានសិទ្ធិទទួលបានជំនួយពីមជ្ឈតកម្មកីឡា ដើម្បីទទួលបានព័ត៌មានពាក់ព័ន្ធទាំងអស់ពីអង្គការប្រឆាំងដូប៉ា ដែលសេចក្តីសម្រេចប

ស់ខ្លួនកំពុងត្រូវបានប្តឹងជំទាស់ ហើយព័ត៌មាននឹងត្រូវផ្តល់ជូនប្រសិនបើមជ្ឈតកម្មកីឡាកំណត់ដូច្នោះ ។

១៣.២.៣.៣ ភារកិច្ចក្នុងការជូនដំណឹង

គ្រប់ភាគីនៃបណ្តឹងជំទាស់របស់មជ្ឈតកម្មកីឡា ត្រូវធានាថាទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក និងភាគីដទៃទៀតដែលមានសិទ្ធិប្តឹងជំទាស់ ត្រូវបានផ្តល់សេចក្តីជូនដំណឹងអំពីបណ្តឹងជំទាស់ឱ្យបានទាន់ពេលវេលា។

១៣.២.៣.៤ ការប្តឹងជំទាស់ពីការអនុវត្តការព្យួរសិទ្ធិបណ្តោះអាសន្ន

ទោះបីជាមានបទប្បញ្ញត្តិផ្សេងៗ នៅក្នុងវិធាននេះក៏ដោយបុគ្គលតែម្នាក់គត់ដែលអាចប្តឹងជំទាស់នឹងការដាក់ទណ្ឌកម្មដោយការព្យួរសិទ្ធិបណ្តោះអាសន្នគឺ អត្តពលិក ឬបុគ្គលផ្សេងទៀតដែលត្រូវអនុវត្តការព្យួរបណ្តោះអាសន្ននោះ។

១៣.២.៣.៥ ការប្តឹងជំទាស់សេចក្តីសម្រេចតាមប្រការ ១២

សេចក្តីសម្រេចរបស់គណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជា យោងតាមប្រការ ១២ អាចត្រូវបានប្តឹងជំទាស់ទាំងស្រុងទៅមជ្ឈតកម្មកីឡា ដោយសហព័ន្ធកីឡាជាតិ ឬស្ថាប័នផ្សេងទៀត។

១៣.២.៤ ការប្តឹងជំទាស់ទៅវិញទៅមក និងការប្តឹងជំទាស់ជាបន្តបន្ទាប់ផ្សេងទៀតត្រូវបានអនុញ្ញាត

ការប្តឹងជំទាស់ទៅវិញទៅមក និងប្តឹងជំទាស់បន្តបន្ទាប់ផ្សេងទៀតដោយចុងចម្លើយណាម្នាក់ ដែលមានឈ្មោះនៅក្នុងរឿងក្តីដែលត្រូវបានបញ្ជូនទៅ មជ្ឈតកម្មកីឡា ក្រោមក្រមនេះត្រូវបានអនុញ្ញាត ជាពិសេស។ ភាគីណាមួយដែលមានសិទ្ធិប្តឹងជំទាស់តាមប្រការ ១៣ នេះ ត្រូវដាក់ពាក្យប្តឹងជំទាស់ទៅវិញទៅមក ឬបណ្តឹងជំទាស់ជាបន្តបន្ទាប់ យ៉ាងយូរបំផុតជាមួយចម្លើយរបស់ភាគី។

១៣.៣ ការខកខានផ្តល់សេចក្តីសម្រេចឱ្យបានទាន់ពេលវេលាដោយគណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជា

ក្នុងករណីជាក់លាក់ ប្រសិនបើគណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជា ខកខានមិនបានធ្វើសេចក្តីសម្រេចទាក់ទងនឹងថាតើមាន ឬមិនមានការបំពានវិធានប្រឆាំងដូប៉ា ក្នុងពេលវេលាកំណត់សមរម្យដែលកំណត់ដោយទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក នោះទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក អាចសម្រេចប្តឹងជំទាស់ដោយផ្ទាល់ទៅមជ្ឈតកម្មកីឡាដូចជាក្នុងករណីដែលគណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជា ធ្វើសេចក្តីសម្រេចដោយរកឃើញថាមិនមានការបំពានលើវិធានប្រឆាំងដូប៉ានោះ។ ប្រសិនបើក្រុមប្រឹក្សាជំនុំជម្រះរបស់មជ្ឈតកម្មកីឡា កំណត់ថាមានការបំពានវិធានប្រឆាំងដូប៉ា ហើយកំណត់ថា ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក បានអនុវត្តសមហេតុផលក្នុងការសម្រេចប្តឹងជំទាស់ដោយផ្ទាល់ទៅមជ្ឈតកម្មកីឡា នោះការចំណាយ និងថ្លៃមេធាវីរបស់ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក ក្នុងការប្តឹងជំទាស់នោះ នឹងត្រូវទូទាត់សងទៅទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោកវិញដោយគណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជា។

១៣.៤ ការប្តឹងជំទាស់ទាក់ទងនឹងការលើកលែងឱ្យប្រើប្រាស់ថ្នាំព្យាបាល

សេក្តីសម្រេចលើការលើកលែងឱ្យប្រើប្រាស់ថ្នាំព្យាបាល អាចត្រូវបានប្តឹងជំទាស់ទាំងស្រុង ដូចមានចែងក្នុងប្រការ ៤.៤ ។

១៣.៥ ការជូនដំណឹងអំពីសេចក្តីសម្រេចលើបណ្តឹងជំទាស់

គណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជា ត្រូវផ្តល់សេចក្តីសម្រេចលើបណ្តឹងភ្លាមៗទៅអត្តពលិក ឬបុគ្គលផ្សេងទៀត និងអង្គការប្រឆាំងដូប៉ា ផ្សេងទៀតដែលមានសិទ្ធិប្តឹងជំទាស់ តាមប្រការ ១៣.២.៣ ដូចមានចែងក្នុង

ប្រការ ១៤.២ ។

១៣.៦ រយៈពេលសម្រាប់ការប្ដឹងជំទាស់

១៣.៦.១ ការប្ដឹងជំទាស់ទៅមជ្ឈតកម្មកីឡា

រយៈពេលសម្រាប់ដាក់ពាក្យបណ្ដឹងជំទាស់ទៅមជ្ឈតកម្មកីឡាគឺ ២១(ម្ភៃមួយ)ថ្ងៃ គិតចាប់ពីថ្ងៃដែលទទួលបានសេចក្ដីសម្រេចរបស់ភាគីប្ដឹងជំទាស់។ ទោះដូចមានរៀបរាប់ខាងលើក៏ដោយ ចំណុចខាងក្រោមនេះត្រូវអនុវត្តទាក់ទងទៅនឹងបណ្ដឹងជំទាស់របស់ភាគីដែលមានសិទ្ធិប្ដឹងជំទាស់ តែមិនមែនជាភាគីក្នុងដំណើរការនីតិវិធីដែលបង្កើតសេចក្ដីសម្រេចដែលកំពុងត្រូវប្ដឹងជំទាស់នោះ៖

ក. ក្នុងរយៈពេល ១៥(ដប់ប្រាំ)ថ្ងៃ ចាប់ពីការជូនដំណឹងអំពីសេចក្ដីសម្រេចនោះ ភាគីនានាមានសិទ្ធិស្នើសុំឯកសារសំណុំរឿងទាំងស្រុងពាក់ព័ន្ធ នឹងសេចក្ដីសម្រេចរបស់អង្គការប្រឆាំងដូប៉ា ដែលមានសិទ្ធិអំណាចក្នុងការដោះស្រាយវិវាទដូប៉ា។

ខ. ប្រសិនបើការស្នើសុំបែបនេះត្រូវបានធ្វើឡើងក្នុងរយៈពេល ១៥(ដប់ប្រាំ)ថ្ងៃ នោះភាគីដែលធ្វើសំណើបែបនេះមានរយៈពេល ២១(ម្ភៃមួយ)ថ្ងៃ បន្ទាប់ពីការទទួលឯកសារដើម្បីដាក់ពាក្យបណ្ដឹងជំទាស់ទៅមជ្ឈតកម្មកីឡា។

ទោះយ៉ាងណាក៏ដោយ ថ្ងៃផុតកំណត់នៃការដាក់បណ្ដឹងជំទាស់ដោយទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោកនឹងត្រូវធ្វើឡើងនៅកាលបរិច្ឆេទ៖

ក. ក្នុងរយៈពេល ២១(ម្ភៃមួយ)ថ្ងៃ បន្ទាប់ពីថ្ងៃចុងក្រោយដែលភាគីផ្សេងទៀតដែលមានសិទ្ធិប្ដឹងជំទាស់អាចប្ដឹងជំទាស់ ឬ

ខ. ក្នុងរយៈពេល ២១(ម្ភៃមួយ)ថ្ងៃ បន្ទាប់ពីទទួលបានឯកសារពេញលេញដែលទាក់ទងនឹងសេចក្ដីសម្រេចរបស់ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក។

១៣.៦.២ ការប្ដឹងជំទាស់ ក្រោមប្រការ ១៣.២.២

រយៈពេលដែលត្រូវដាក់បណ្ដឹងជំទាស់ ទៅក្រុមប្រឹក្សាបណ្ដឹងជំទាស់របស់គណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជា គឺ ២១(ម្ភៃមួយ)ថ្ងៃ គិតចាប់ពីថ្ងៃនៃការទទួលសេចក្ដីសម្រេចដោយភាគីដាក់បណ្ដឹងជំទាស់នោះ។ ទោះដូចមានរៀបរាប់ខាងលើក៏ដោយ ចំណុចខាងក្រោមនេះត្រូវអនុវត្តទាក់ទងទៅនឹងបណ្ដឹងជំទាស់របស់ភាគីដែលមានសិទ្ធិប្ដឹងជំទាស់ តែមិនមែនជាភាគីក្នុងដំណើរការនីតិវិធី ដែលបង្កើតសេចក្ដីសម្រេចដែលអាចត្រូវប្ដឹងជំទាស់នោះ៖

ក. ក្នុងរយៈពេល ១៥(ដប់ប្រាំ)ថ្ងៃ ចាប់ពីការជូនដំណឹងអំពីសេចក្ដីសម្រេចនោះ ភាគីនានាមានសិទ្ធិស្នើសុំឯកសារសំណុំរឿងទាំងស្រុង ពាក់ព័ន្ធនឹងសេចក្ដីសម្រេចរបស់អង្គការប្រឆាំងដូប៉ា ដែលមានសិទ្ធិអំណាចក្នុងការដោះស្រាយវិវាទដូប៉ា។

ខ. ប្រសិនបើការស្នើសុំបែបនេះត្រូវបានធ្វើឡើងក្នុងរយៈពេល ១៥(ដប់ប្រាំ)ថ្ងៃ នោះភាគីដែលធ្វើសំណើមានរយៈពេល ២១(ម្ភៃមួយ)ថ្ងៃ ក្រោយពីការទទួលឯកសារ ដើម្បីដាក់បណ្ដឹងជំទាស់ទៅក្រុមប្រឹក្សាបណ្ដឹងជំទាស់របស់គណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជា។

ទោះយ៉ាងណាក៏ដោយ ថ្ងៃផុតកំណត់នៃការដាក់បណ្ដឹងជំទាស់ ដោយទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោកនឹងត្រូវធ្វើឡើងនៅកាលបរិច្ឆេទ៖

ក. ក្នុងរយៈពេល ២១(ម្ភៃមួយ)ថ្ងៃ បន្ទាប់ពីថ្ងៃចុងក្រោយដែលភាគីផ្សេងទៀតដែលមានសិទ្ធិប្ដឹងជំទាស់អាចប្ដឹងជំទាស់ ឬ

ខ. ក្នុងរយៈពេល ២១(ម្ភៃមួយ)ថ្ងៃ បន្ទាប់ពីទទួលបានឯកសារពេញលេញដែលទាក់ទងនឹងសេចក្ដី

សម្រេចរបស់ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក។

ប្រការ១៤៖ ការរក្សាការសម្ងាត់ និងការរាយការណ៍

១៤.១ ព័ត៌មានទាក់ទងនឹងលទ្ធផលវិភាគវិជ្ជមាន លទ្ធផលមិនធម្មតា និងការបំពានវិធានប្រឆាំងដូប៉ា

១៤.១.១ ការជូនដំណឹងអំពីការបំពានវិធានប្រឆាំងដូប៉ាដល់អត្តពលិក និងបុគ្គលដទៃទៀត

ការជូនដំណឹងដល់អត្តពលិក ឬបុគ្គលផ្សេងទៀត ស្ដីពីការបំពានវិធានប្រឆាំងដូប៉ាដែលបានចោទប្រឆាំងនឹងពួកគេ ត្រូវធ្វើឡើង ដូចមានចែងក្នុងប្រការ ៧ និងប្រការ ១៤ ។

ប្រសិនបើមានចំណុចណាមួយក្នុងកំឡុងពេលនៃការដោះស្រាយវិវាទដូប៉ារហូតដល់ការចោទប្រកាន់ពីបទបំពានវិធានប្រឆាំងដូប៉ានោះ គណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជាសម្រេចចិត្តមិនបន្តនីតិវិធីទីភ្នាក់ងារនេះ ត្រូវជូនដំណឹងដល់អត្តពលិក ឬបុគ្គលផ្សេងទៀត (ក្នុងករណីដែលថា អត្តពលិក ឬបុគ្គលផ្សេងទៀតបានទទួលការជូនដំណឹងពីការដោះស្រាយវិវាទដូប៉ាដែលកំពុងបន្តដំណើរការនោះរួចទៅហើយ)។

១៤.១.២ ការជូនដំណឹងពីការបំពានវិធានប្រឆាំងដូប៉ា ទៅអង្គការជាតិប្រឆាំងដូប៉ា សហព័ន្ធកីឡាអន្តរជាតិ និងទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក

ការជូនដំណឹងអំពីការចោទប្រកាន់ ពីការបំពានវិធានប្រឆាំងដូប៉ា ទៅអង្គការប្រឆាំងដូប៉ារបស់អត្តពលិក ឬបុគ្គលផ្សេងទៀត បើមិនមែនគណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជា សហព័ន្ធកីឡាអន្តរជាតិ និងទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោកទេនោះ ត្រូវធ្វើឡើងដូចមានចែងក្នុងប្រការ ៧ និងប្រការ ១៤ ក្នុងពេលដំណាលគ្នាជាមួយនឹងការជូនដំណឹងដល់ អត្តពលិក ឬបុគ្គលផ្សេងទៀត។

ប្រសិនបើនៅពេលណាមួយ ក្នុងកំឡុងពេលដោះស្រាយវិវាទដូប៉ា រហូតដល់ការចោទប្រកាន់ពីបទបំពានវិធានប្រឆាំងដូប៉ា គណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជា សម្រេចចិត្តមិនបន្តនីតិវិធីទេ ហើយត្រូវផ្ដល់ការជូនដំណឹង (ព្រមទាំងហេតុផល) ដល់អង្គការប្រឆាំងដូប៉ា ដែលមានសិទ្ធិប្ដឹងជំទាស់ក្រោមប្រការ ១៣.២.៣។

១៤.១.៣ ខ្លឹមសារនៃការជូនដំណឹងស្ដីពីការបំពានវិធានប្រឆាំងដូប៉ា

ការជូនដំណឹងអំពីការបំពានវិធានប្រឆាំងដូប៉ារួមមាន៖ ឈ្មោះអត្តពលិក ឬឈ្មោះបុគ្គលផ្សេងទៀត ប្រភេទកីឡា និងវិញ្ញាសាប្រកួត កម្រិតនៃភាពប្រកួតប្រជែងរបស់អត្តពលិក មិនថាជាការធ្វើតេស្តក្នុងការប្រកួត ឬក្រៅការប្រកួតទេ កាលបរិច្ឆេទនៃការប្រមូលសំណាក លទ្ធផលវិភាគដែលរាយការណ៍ដោយមន្ទីរពិសោធន៍ និងព័ត៌មានផ្សេងទៀតតាមតម្រូវការរបស់ស្តង់ដារអន្តរជាតិស្ដីពីការធ្វើតេស្ត និងការស៊ើបអង្កេត និងស្តង់ដារអន្តរជាតិស្ដីពីការដោះស្រាយវិវាទដូប៉ា។

ការជូនដំណឹងអំពីការបំពានវិធានប្រឆាំងដូប៉ា ក្រៅពីប្រការ ២.១ ក៏ត្រូវរាប់បញ្ចូលទាំងវិធានដែលបានបំពាន និងមូលដ្ឋាននៃការបំពានដែលត្រូវបានចោទនោះផងដែរ។

១៤.១.៤ របាយការណ៍ស្ថានភាព

លើកលែងតែទាក់ទងនឹងការស៊ើបអង្កេតដែលមិនបានបណ្ដាលឱ្យមានការជូនដំណឹងអំពីការបំពានវិធានប្រឆាំងដូប៉ា តាមប្រការ ១៤.១.១ អត្តពលិក ឬអង្គការជាតិប្រឆាំងដូប៉ារបស់អត្តពលិក ឬបុគ្គលផ្សេងទៀត បើមិនមែនគណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជា សហព័ន្ធកីឡាអន្តរជាតិ និងទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក ត្រូវធ្វើបច្ចុប្បន្នភាពជាប្រចាំលើស្ថានភាព និងលទ្ធផលការត្រួតពិនិត្យ ឬដំណើរការណាមួយដែល

ធ្វើឡើងស្របតាមប្រការ ៧.៨ ឬប្រការ ១៣ ហើយត្រូវផ្តល់ការពន្យល់ជាលាយលក្ខណ៍អក្សរដោយបញ្ជាក់ហេតុផល និងធ្វើឡើងភ្លាមៗ ឬផ្តល់សេចក្តីសម្រេចដែលពន្យល់អំពីការដោះស្រាយចំពោះបញ្ហានោះ។

១៤.១.៥ ការរក្សាការសម្ងាត់

ស្ថាប័នទទួលនឹងមិនត្រូវបង្ហាញព័ត៌មាននេះ ទៅបុគ្គលណាក្រៅតែពីបុគ្គលដែលត្រូវដឹង (ដែលរួមបញ្ចូលទាំងបុគ្គលិកសមស្របនៃគណៈកម្មាធិការជាតិអូឡាំពិក សហព័ន្ធកីឡាជាតិ និងសមាជិកក្នុងកីឡាជាក្រុម) ហូតដល់គណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជាបានផ្សព្វផ្សាយវាជាសាធារណៈ ដូចមានចែងក្នុងប្រការ ១៤.៣។

១៤.១.៦ ការការពារព័ត៌មានសម្ងាត់ដោយបុគ្គលិក ឬភ្នាក់ងាររបស់គណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជាគណៈ កម្មាធិការប្រឆាំងដូប៉ាកម្ពុជា ត្រូវធានាថាព័ត៌មានទាក់ទងនឹងលទ្ធផលវិភាគវិជ្ជមាន លទ្ធផលមិនធម្មតា និងការបំពានវិធានប្រឆាំងដូប៉ាផ្សេងទៀត ត្រូវបានរក្សាជាការសម្ងាត់ហូតដល់ព័ត៌មានទាំងនេះ ត្រូវបានផ្សព្វផ្សាយជាសាធារណៈស្របតាមប្រការ ១៤.៣។ គណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជា ត្រូវធានាថាបុគ្គលិករបស់ខ្លួន (មិនថាជាអចិន្ត្រៃយ៍ ឬអត់នោះទេ) អ្នកម៉ៅការ អ្នកតំណាង ភ្នាក់ងារទីប្រឹក្សា និងភាគីទី៣ ត្រូវទទួលកាតព្វកិច្ចតាមកិច្ចសន្យាដែលអាចអនុវត្តបានពេញលេញក្នុងការរក្សាការសម្ងាត់ និងនីតិវិធីដែលអាចអនុវត្តបានពេញលេញសម្រាប់ការស៊ើបអង្កេត និងការដាក់វិន័យចំពោះការបង្ហាញព័ត៌មានសម្ងាត់មិនត្រឹមត្រូវ និង/ឬដោយគ្មានការអនុញ្ញាត។

១៤.២ ការជូនដំណឹងអំពីការបំពានវិធានប្រឆាំងដូប៉ា ឬការបំពានលើសេចក្តីសម្រេចព្យួរសិទ្ធិ ឬសេចក្តីសម្រេចព្យួរសិទ្ធិបណ្តោះអាសន្ន និងការស្នើសុំឯកសារ

១៤.២.១ សេចក្តីសម្រេចស្តីពីការបំពានវិធានប្រឆាំងដូប៉ា ដែលពាក់ព័ន្ធនឹងការបំពានការព្យួរសិទ្ធិ ឬការព្យួរសិទ្ធិបណ្តោះអាសន្ន ត្រូវបានអនុវត្តស្របតាមប្រការ ៧.៦ ប្រការ ៨.២ ប្រការ ១០.៥ ប្រការ ១០.៦ ប្រការ ១០.៦ ប្រការ ១០.៧ ប្រការ ១០.១៤.៣ ឬប្រការ ១៣.៥ ដោយរួមបញ្ចូល បើអាចអនុវត្តបាននូវយុត្តិកម្មថាហេតុអ្វីមិនដាក់ទណ្ឌកម្មសក្តានុពលអតិបរមា។ ក្នុងករណីដែលសេចក្តីសម្រេចនោះមិនមែនជាភាសាអង់គ្លេស ឬបារាំង គណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជាត្រូវផ្តល់សេចក្តីសង្ខេបជាភាសាអង់គ្លេស ឬបារាំងអំពីសេចក្តីសម្រេច និងហេតុផលគាំទ្រ។

១៤.២.២ អង្គការប្រឆាំងដូប៉ា មានសិទ្ធិប្តឹងជំទាស់លើសេចក្តីសម្រេចដែលបានទទួល ដោយអនុលោមតាមប្រការ ១៤.២.១ ក្នុងរយៈពេល ១៥(ដប់ប្រាំ)ថ្ងៃ បន្ទាប់ពីបានទទួលសំណើសុំសំណុំឯកសារទាំងមូលដែលទាក់ទងនឹងសេចក្តីសម្រេចនោះ។

១៤.៣ ការបង្ហាញជាសាធារណៈ

១៤.៣.១ បន្ទាប់ពីផ្តល់ការជូនដំណឹងដល់អត្តពលិក ឬបុគ្គលផ្សេងទៀត ស្របតាមស្តង់ដារអន្តរជាតិស្តីពីការដោះស្រាយវិវាទដូប៉ា និងទៅឱ្យអង្គការប្រឆាំងដូប៉ា ដោយអនុលោមតាមប្រការ ១៤.១.២ ហើយអត្តសញ្ញាណរបស់អត្តពលិក ឬបុគ្គលផ្សេងទៀត ដែលជាត្រូវបានជូនដំណឹងអំពីការបំពានលើវិធានប្រឆាំងដូប៉ាសារធាតុហាមឃាត់ ឬវិធីសាស្ត្រហាមឃាត់ និងលក្ខណៈនៃការបំពានដែលពាក់ព័ន្ធ និងថាតើអត្តពលិក ឬបុគ្គលផ្សេងទៀតនោះ ត្រូវទទួលរងការព្យួរសិទ្ធិបណ្តោះអាសន្ន ឬយ៉ាងណា អាចត្រូវបានបង្ហាញជាសាធារណៈដោយគណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជា។

១៤.៣.២ មិនលើសពីរយៈពេល ២០(ម្ភៃ)ថ្ងៃ បន្ទាប់ពីត្រូវបានកំណត់នៅក្នុងសេចក្តីសម្រេចលើបណ្តឹងជំទាស់តាម

ប្រការ ១៣.២.១ ឬប្រការ ១៣.២.២ ឬប្រសិនបើបណ្តឹងជំទាស់នោះត្រូវបានលើកលែង ឬសវនាការដែលអនុលោមតាមប្រការ ៨ ត្រូវបានលើកលែង ឬការចោទប្រកាន់អំពីការបំពានវិធានប្រឆាំងដូប៉ាមិនត្រូវបានគេជំទាស់ទេ ឬបញ្ហានេះត្រូវបានដោះស្រាយតាមប្រការ ១០.៨ ឬរយៈពេលថ្មីនៃការព្យួរសិទ្ធិ ឬការស្តីបន្ទោសត្រូវបានកំណត់ក្នុងប្រការ ១០.១៤.៣ គណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជា ត្រូវបង្ហាញជាសាធារណៈនូវការសម្រេចស្តីពីបញ្ហានៃការប្រើប្រាស់សារធាតុដូប៉ា រួមទាំងវិធានប្រឆាំងដូប៉ាដែលត្រូវបានបំពាន ឈ្មោះអត្តពលិក ឬបុគ្គលផ្សេងទៀត ដែលបានប្រព្រឹត្តការបំពានសារធាតុហាមឃាត់ ឬវិធីសាស្ត្រហាមឃាត់ដែលពាក់ព័ន្ធ (ប្រសិនបើមាន) និងទណ្ឌកម្មដែលត្រូវបានដាក់។ គណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជា ត្រូវបង្ហាញជាសាធារណៈក្នុងរយៈពេល ២០(ម្ភៃ)ថ្ងៃ ក្រោយលទ្ធផលនៃសេចក្តីសម្រេច ដែលទាក់ទងនឹងការបំពានវិធានប្រឆាំងដូប៉ា រួមទាំងព័ត៌មានដែលបានពិពណ៌នាខាងលើ។

១៤.៣.៣ ក្រោយការបំពានវិធានប្រឆាំងដូប៉ា ត្រូវបានកំណត់ថាបានប្រព្រឹត្តនៅក្នុងសេចក្តីសម្រេចលើបណ្តឹងជំទាស់តាមប្រការ ១៣.២.១ ឬប្រការ ១៣.២.២ ឬបណ្តឹងជំទាស់ត្រូវបានលើកលែង ឬនៅក្នុងសវនាការ ស្របតាមប្រការ ៨ ឬក្នុងករណីដែលសវនាការបែបនេះត្រូវបានលើកលែង គណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជាអាចធ្វើការកំណត់ ឬសម្រេចប្រកាសជាសាធារណៈ ហើយអាចធ្វើអត្ថាធិប្បាយលើបញ្ហានេះជាសាធារណៈបាន។

១៤.៣.៤ ក្នុងករណីណាក៏ដោយ ប្រសិនបើត្រូវបានកំណត់ បន្ទាប់ពីសវនាការ ឬបណ្តឹងជំទាស់ថា អត្តពលិក ឬបុគ្គលផ្សេងទៀត មិនបានប្រព្រឹត្តិបំពានវិធានប្រឆាំងដូប៉ាទេនោះ លទ្ធផលនៃបណ្តឹងជំទាស់ដែលបដិសេធសេចក្តីសម្រេចដំបូងនោះអាចត្រូវបានបង្ហាញជាសាធារណៈ។ ទោះយ៉ាងណាក៏ដោយ សេចក្តីសម្រេចនិងអង្គហេតុសំខាន់ៗរបស់វានឹងមិនអាចត្រូវបាន បង្ហាញជាសាធារណៈទេ លើកលែងតែមានការយល់ព្រមពីអត្តពលិក ឬបុគ្គលផ្សេងទៀត ដែលជាកម្មវត្ថុនៃសេចក្តីសម្រេចនោះ។ គណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជាត្រូវប្រើកិច្ចខិតខំប្រឹងប្រែងសមហេតុផល ដើម្បីទទួលបានការព្រមព្រៀងបែបនេះ ហើយប្រសិនបើទទួលបានការព្រមព្រៀងហើយ ត្រូវបង្ហាញជាសាធារណៈនូវសេចក្តីសម្រេចនេះទាំងស្រុង ឬក្នុងទម្រង់ដែលត្រូវលុបផ្នែកខ្លះតាមការយល់ព្រមរបស់អត្តពលិក ឬបុគ្គលផ្សេងទៀត។

១៤.៣.៥ ការផ្សព្វផ្សាយត្រូវធ្វើឡើងយ៉ាងតិចបំផុត ដោយដាក់ព័ត៌មានចាំបាច់នៅលើគេហទំព័ររបស់គណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជា ហើយត្រូវរក្សាទុកព័ត៌មាននេះឱ្យបានយ៉ាងតិច ១(មួយ)ខែ ឬស្មើរយៈពេលនៃការព្យួរសិទ្ធិ។

១៤.៣.៦ លើកលែងដូចអ្វីដែលបានចែងក្នុងប្រការ ១៤.៣.១ និងប្រការ ១៤.៣.៣ អង្គការប្រឆាំងដូប៉ា សហព័ន្ធកីឡាជាតិ ឬមន្ទីរពិសោធន៍ ដែលទទួលស្គាល់ដោយទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក ឬមន្ត្រីនៃស្ថាប័នបែបនោះ មិនត្រូវធ្វើអត្ថាធិប្បាយជាសាធារណៈលើអង្គហេតុជាក់លាក់នៃករណីដែលកំពុងដំណើរការ (ក្រៅពីការពិពណ៌នាទូទៅនៃដំណើរការ និងវិទ្យាសាស្ត្រ) លើកលែងតែការឆ្លើយតបទៅនឹងមតិសាធារណៈដែលត្រូវបានសន្មត ឬផ្អែកលើព័ត៌មានដែលផ្តល់ដោយអត្តពលិក បុគ្គលផ្សេងទៀត ឬអ្នកអមរបស់ពួកគេ ឬតំណាងផ្សេងទៀតតែប៉ុណ្ណោះ។

១៤.៣.៧ ការបង្ហាញជាសាធារណៈ ដូចដែលមានចែងក្នុងប្រការ ១៤.៣.២ និងមិនចាំបាច់អនុវត្តទេ ក្នុងករណីដែលអត្តពលិក ឬបុគ្គលផ្សេងទៀតដែលត្រូវបានគេរកឃើញថាបានបំពានវិធានប្រឆាំងដូប៉ា គឺជាអនីតិជន បុគ្គលដែលត្រូវបានការពារ ឬអត្តពលិកកំសាន្ត។ រាល់ការបង្ហាញជាសាធារណៈដែលមិនមែនជាលក្ខខណ្ឌតម្រូវក្នុងករណីដែលពាក់ព័ន្ធនឹង អនីតិជន បុគ្គលដែលត្រូវបានការពារ ឬអត្តពលិកកំសាន្ត ត្រូវមានសមាមាត្រទៅនឹងអង្គហេតុ និងកាលៈទេសៈនៃករណីនោះ។

១៤.៤ របាយការណ៍ស្ថិតិ

គណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជា យ៉ាងហោចណាស់ជារៀងរាល់ឆ្នាំ ផ្សព្វផ្សាយរបាយការណ៍ស្ថិតិទូទៅអំពីសកម្មភាពគ្រប់គ្រងដូប៉ារបស់ខ្លួន ដោយផ្ដល់ឯកសារនោះមួយច្បាប់ដល់ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក។ គណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជា ក៏អាចផ្សព្វផ្សាយរបាយការណ៍ដែលបង្ហាញពី ឈ្មោះអត្តពលិកនីមួយៗ ដែលត្រូវបានធ្វើតេស្ត និងកាលបរិច្ឆេទនៃការធ្វើតេស្តនីមួយៗ ផងដែរ។

១៤.៥ មូលដ្ឋានទិន្នន័យនៃការត្រួតពិនិត្យដូប៉ា និងការត្រួតពិនិត្យអនុលោមភាព

ដើម្បីឱ្យទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក អនុវត្តតួនាទីត្រួតពិនិត្យអនុលោមភាពរបស់ខ្លួន និងដើម្បីធានាឱ្យបាននូវការប្រើប្រាស់ប្រកបដោយប្រសិទ្ធិភាពនៃធនធាន និងការចែករំលែកព័ត៌មាននៃការត្រួតពិនិត្យដូប៉ាក្នុងចំណោមអង្គការប្រឆាំងដូប៉ា គណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជាត្រូវរាយការណ៍ទៅទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក តាមរយៈព័ត៌មានទាក់ទងនឹងការត្រួតពិនិត្យដូប៉ានៃប្រព័ន្ធគ្រប់គ្រងរដ្ឋបាលប្រឆាំងដូប៉ារួមទាំង៖

ក. ទិន្នន័យប្រវត្តិជីវសាស្ត្ររបស់អត្តពលិកសម្រាប់អត្តពលិកកម្រិតអន្តរជាតិ និងអត្តពលិកកម្រិតជាតិ។
ខ. ព័ត៌មានអំពីទីសំចតរបស់អត្តពលិក រួមទាំងអ្នកដែលមានឈ្មោះនៅក្នុងបញ្ជីឈ្មោះធ្វើតេស្ត។
គ. សេចក្ដីសម្រេចលើការលើកលែងឱ្យប្រើប្រាស់ថ្នាំព្យាបាល។
ឃ. សេចក្ដីសម្រេចស្ដីពីការដោះស្រាយវិវាទដូប៉ា តាមលក្ខខណ្ឌតម្រូវនៃស្តង់ដារអន្តរជាតិជាធរមាន។

១៤.៥.១ ដើម្បីសហការរៀបចំផែនការបែងចែកការធ្វើតេស្តដែលមានការសម្របសម្រួល ជៀសវាងការធ្វើតេស្តស្ទួនមិនចាំបាច់ ដោយអង្គការប្រឆាំងដូប៉ានានា និងដើម្បីធានាថាប្រវត្តិជីវសាស្ត្រអត្តពលិក ត្រូវបានធ្វើបច្ចុប្បន្នភាព គណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជាត្រូវរាយការណ៍រាល់ការធ្វើតេស្តក្នុងការប្រកួត និងក្រៅការប្រកួតទាំងអស់ទៅទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក ដោយបញ្ចូលទម្រង់គ្រប់គ្រងដូប៉ាទៅក្នុងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលប្រឆាំងដូប៉ាដោយអនុលោមទៅតាមលក្ខខណ្ឌតម្រូវ និងពេលវេលា ដូចបានកំណត់នៅក្នុងស្តង់ដារអន្តរជាតិស្ដីពីការធ្វើតេស្ត និងការស៊ើបអង្កេត។

១៤.៥.២ ដើម្បីសម្របសម្រួលការត្រួតពិនិត្យ និងសិទ្ធិបណ្ដឹងជំទាស់របស់ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោកសម្រាប់ការលើកលែងឱ្យប្រើប្រាស់ថ្នាំព្យាបាល។

គណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជា ត្រូវរាយការណ៍អំពីពាក្យស្នើសុំសេចក្ដីសម្រេច និងឯកសារគាំទ្រការលើកលែងឱ្យប្រើប្រាស់ថ្នាំព្យាបាលទាំងអស់ ដោយប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងរដ្ឋបាលប្រឆាំងដូប៉ា និងដោយអនុលោមតាមលក្ខខណ្ឌតម្រូវ និងពេលវេលាដែលមាននៅក្នុងស្តង់ដារអន្តរជាតិស្ដីពីការលើកលែងឱ្យប្រើប្រាស់ថ្នាំព្យាបាល ។

១៤.៥.៣ ដើម្បីសម្របសម្រួលការត្រួតពិនិត្យ និងសិទ្ធិប្ដឹងជំទាស់របស់ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក សម្រាប់ការដោះស្រាយវិវាទដូប៉ា គណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជា ត្រូវរាយការណ៍ព័ត៌មានដូចខាងក្រោមនៅក្នុងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលប្រឆាំងដូប៉ា ស្របតាមលក្ខខណ្ឌតម្រូវ និងការកំណត់ពេលវេលា ដូចមានចែងក្នុងស្តង់ដារអន្តរជាតិស្ដីពីការដោះស្រាយវិវាទដូប៉ា៖

ក. ការជូនដំណឹងស្ដីពីការបំពានវិធានប្រឆាំងដូប៉ា និងសេចក្ដីសម្រេចពាក់ព័ន្ធសម្រាប់លទ្ធផលវិភាគវិជ្ជមាន។
ខ. ការជូនដំណឹង និងសេចក្ដីសម្រេចពាក់ព័ន្ធចំពោះការបំពានវិធានប្រឆាំងដូប៉ាផ្សេងទៀត ដែលមិនមែនជាលទ្ធផលវិភាគវិជ្ជមាន។

គ. ការខកខានក្នុងការផ្តល់ព័ត៌មានអំពីទីសំចត។
ឃ. សេចក្តីសម្រេចណាមួយដែលដាក់ទណ្ឌកម្ម ឬផ្តល់សិទ្ធិឡើងវិញចំពោះ ការព្យួរសិទ្ធិបណ្តោះអាសន្ន។

១៤.៥.៤ ព័ត៌មានដូចមានចែងក្នុងប្រការនេះនឹងត្រូវបានផ្តល់ជូន នៅពេលដែលសមស្រប និងស្របតាមវិធានជាធរមាន ដល់អត្តពលិក អង្គការប្រឆាំងដូប៉ាជាតិរបស់អត្តពលិក និងសហព័ន្ធកីឡាអន្តរជាតិ និងអង្គការប្រឆាំងដូប៉ាណាមួយផ្សេងទៀត ដែលមានសិទ្ធិធ្វើតេស្តលើអត្តពលិក។

១៤.៦ ភាពឯកជននៃទិន្នន័យ

១៤.៦.១ គណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជាអាចប្រមូល រក្សាទុក ដំណើរការ ឬផ្សព្វផ្សាយព័ត៌មានផ្ទាល់ខ្លួនទាក់ទងនឹង អត្តពលិក និងបុគ្គលផ្សេងទៀត ក្នុងករណីចាំបាច់ និងសមស្រប ដើម្បីធ្វើសកម្មភាពប្រឆាំងដូប៉ារបស់ខ្លួនតាមក្រម ស្តង់ដារអន្តរជាតិ (រួមបញ្ចូលជាពិសេស ស្តង់ដារអន្តរជាតិស្តីពីការការពារភាពឯកជន និងព័ត៌មានផ្ទាល់ខ្លួន) វិធានប្រឆាំងដូប៉ា និងដោយអនុលោមតាមច្បាប់ជាធរមាន។

១៤.៦.២ ដោយមិនកំណត់នូវអ្វីដែលបានរៀបរាប់ខាងលើ គណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជាត្រូវ៖
ក. ដំណើរការព័ត៌មានផ្ទាល់ខ្លួន តែក្នុងករណីដែលស្របតាមមូលដ្ឋានគតិយុត្តត្រឹមត្រូវប៉ុណ្ណោះ។
ខ. ជូនដំណឹងដល់អ្នកចូលរួម ឬបុគ្គលណាដែល ស្ថិតក្រោមវិធានប្រឆាំងដូប៉ាក្នុងលក្ខណៈ និងទំរង់ដែលអនុលោមតាមច្បាប់ជាធរមាន និងស្តង់ដារអន្តរជាតិស្តីពីការការពារភាពឯកជន និងព័ត៌មានផ្ទាល់ខ្លួន ដែលព័ត៌មានផ្ទាល់ខ្លួនរបស់ពួកគេអាចត្រូវបានដំណើរការ ដោយគណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជា និងបុគ្គលផ្សេងទៀត សម្រាប់គោលបំណងនៃការអនុវត្តវិធានប្រឆាំងដូប៉ានេះ។
គ. ធានាថាភ្នាក់ងារណាមួយរបស់ភាគីទី៣ (រួមទាំងភាគីទី៣ ដែលទទួលសិទ្ធិ) ដែលទទួលបានការចែករំលែកព័ត៌មានផ្ទាល់ខ្លួនរបស់ អ្នកចូលរួម ឬបុគ្គលនោះដោយទីភ្នាក់ងារកម្ពុជាប្រឆាំងដូប៉ា ត្រូវស្ថិតក្រោមការគ្រប់គ្រងបច្ចេកទេស និងកិច្ចសន្យាសមស្របដើម្បីឱ្យពួកគេរក្សាព័ត៌មានសម្ងាត់ និងការពារឯកជនភាពនៃព័ត៌មានទាំងនោះ។

## ប្រការ១៥៖ ការអនុវត្តសេចក្តីសម្រេច

១៥.១ ផលប៉ះពាល់នៃសេចក្តីសម្រេចដែលភ្ជាប់កាតព្វកិច្ចដោយស្វ័យប្រវត្តិរបស់អង្គការប្រឆាំងដូប៉ា ដែលជាស្ថាប័នហត្ថលេខី

១៥.១.១ សេចក្តីសម្រេចស្តីពីការបំពានវិធានប្រឆាំងដូប៉ា ដែលធ្វើឡើងដោយស្ថាប័នហត្ថលេខីប្រឆាំងដូប៉ា ស្ថាប័នបណ្តឹងជំទាស់ (ប្រការ ១៣.២.២ នៃក្រម) ឬមជ្ឈតកម្មកីឡា នឹងបន្ទាប់ពីភាគីនៃនីតិវិធីត្រូវបានជូនដំណឹង ត្រូវភ្ជាប់កាតព្វកិច្ចដោយស្វ័យប្រវត្តិក្នុងដំណើរការនីតិវិធីចំពោះគណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជា និងសហព័ន្ធកីឡាជាតិណាមួយនៅក្នុងប្រទេសកម្ពុជា ក៏ដូចជារាល់ ហត្ថលេខី នៃស្ថាប័នកីឡាទាំងអស់ ដោយមានផលដូចបានរៀបរាប់ខាងក្រោម៖
១៥.១.១.១ សេចក្តីសម្រេចរបស់ស្ថាប័នណាមួយដែលបានពិពណ៌នាខាងលើ ដែលដាក់ទណ្ឌកម្មព្យួរសិទ្ធិបណ្តោះអាសន្ន (បន្ទាប់ពីសវនាការបណ្តោះអាសន្នត្រូវបានធ្វើឡើង ឬអត្តពលិក ឬបុគ្គលផ្សេងទៀតបានទទួលយកការព្យួរសិទ្ធិបណ្តោះអាសន្ន ឬបានលះបង់សិទ្ធិទទួលបានសវនាការបណ្តោះអាសន្ន សវនាការបន្ទាន់ ឬការប្តឹងជំទាស់បន្ទាន់ដូចមានចែងក្នុងប្រការ ៧.៤.៣) ហាមឃាត់អត្តពលិក ឬបុគ្គលផ្សេងទៀតពីការចូលរួមដោយស្វ័យប្រវត្តិ (ដូចដែលមានចែងក្នុងប្រការ ១០.១៤.១) នៅក្នុងកីឡាទាំងអស់ ក្រោមសិទ្ធិអំណាច

របស់ស្ថាប័នហត្ថលេខីណាមួយ ក្នុងអំឡុងពេលនៃការព្យួរសិទ្ធិបណ្តោះអាសន្ននោះ។

១៥.១.១.២ សេចក្តីសម្រេចរបស់ស្ថាប័នណាមួយដែលបានពិពណ៌នាខាងលើ ដែលដាក់ទណ្ឌកម្មព្យួរសិទ្ធិ (បន្ទាប់ពីសវនាការត្រូវបានធ្វើឡើង ឬត្រូវបានលើកលែង) ហាមឃាត់ដោយស្វ័យប្រវត្តិចំពោះអត្តពលិក ឬបុគ្គលដទៃទៀត ពីការចូលរួមប្រកួត (ដូចដែលមានចែងក្នុងប្រការ ១០.១៤.១) នៅក្នុងកីឡាទាំងអស់ ក្រោមសិទ្ធិអំណាចរបស់ ស្ថាប័នហត្ថលេខីណាមួយសម្រាប់រយៈពេលនៃការព្យួរសិទ្ធិនោះ។

១៥.១.១.៣ សេចក្តីសម្រេចរបស់ស្ថាប័នណាមួយដែលបានពិពណ៌នាខាងលើ ដែលទទួលយកការបំពានវិធានប្រឆាំងដូប៉ា នឹងភ្ជាប់កាតព្វកិច្ចដោយស្វ័យប្រវត្តិលើស្ថាប័នហត្ថលេខីទាំងអស់។

១៥.១.១.៤ សេចក្តីសម្រេចរបស់ស្ថាប័នណាមួយដែលបានពិពណ៌នាខាងលើក្នុងការ បដិសេធលទ្ធផលប្រកួត តាមប្រការ ១០.១០ សម្រាប់រយៈពេលជាក់លាក់ណាមួយនឹងជាការបដិសេធដោយស្វ័យប្រវត្តិចំពោះលទ្ធផលប្រកួតទាំងអស់ ដែលទទួលបានក្នុងសិទ្ធិអំណាចនៃស្ថាប័នហត្ថលេខីណាមួយក្នុងអំឡុងពេលដែលបានកំណត់។

១៥.១.២ គណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជា និងសហព័ន្ធកីឡាជាតិណាមួយ នៅក្នុងប្រទេសកម្ពុជាត្រូវទទួលស្គាល់ និងអនុវត្តសេចក្តីសម្រេច និងផលប៉ះពាល់របស់វា ដូចដែលបានចែងក្នុងប្រការ ១៥.១.១ ដោយមិនចាំបាច់មានសកម្មភាពអ្វីបន្ថែមទៀតទេ នៅមុនកាលបរិច្ឆេទដែលគណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជាទទួលបានការជូនដំណឹងជាក់ស្តែង អំពីសេចក្តីសម្រេច ឬកាលបរិច្ឆេទដែលសេចក្តីសម្រេចនោះត្រូវបានដាក់ដោយទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក នៅក្នុងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលប្រឆាំងដូប៉ា។

១៥.១.៣ សេចក្តីសម្រេចដោយអង្គការប្រឆាំងដូប៉ា ដោយស្ថាប័នជំទាស់ ឬដោយមជ្ឈតកម្មកីឡា ក្នុងការផ្អាក ឬការលើកលែងទណ្ឌកម្ម នឹងត្រូវមានសុពលភាពចំពោះគណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជា និងសហព័ន្ធកីឡាជាតិណាមួយនៅក្នុងប្រទេសកម្ពុជា ដោយមិនចាំបាច់មានសកម្មភាពបន្ថែមទៀត នៅមុនកាលបរិច្ឆេទដែលគណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជា ទទួលបានការជូនដំណឹងជាក់ស្តែងអំពីសេចក្តីសម្រេច ឬកាលបរិច្ឆេទដែលសេចក្តីសម្រេចនោះត្រូវបានដាក់នៅក្នុងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលប្រឆាំងដូប៉ា។

១៥.១.៤ ទោះបីជាមានបទប្បញ្ញត្តិនៅក្នុងប្រការ ១៥.១.១ យ៉ាងណាក៏ដោយ សេចក្តីសម្រេចស្តីពីការបំពានវិធានប្រឆាំងដូប៉ាដោយស្ថាប័នរៀបចំព្រឹត្តិការណ៍កីឡាធំៗណាមួយ ដែលបានធ្វើឡើងក្នុងដំណើរការបន្ទាន់ ក្នុងអំឡុងពេលព្រឹត្តិការណ៍ នឹងមិនត្រូវមានសុពលភាពលើគណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជា ឬសហព័ន្ធកីឡាជាតិក្នុងប្រទេសកម្ពុជាទេ ប្រសិនបើវិធានរបស់ស្ថាប័នរៀបចំព្រឹត្តិការណ៍សំខាន់នោះមិនផ្តល់ឱកាសដល់អត្តពលិក ឬបុគ្គលផ្សេងទៀតដើម្បីប្តឹងជំទាស់ក្រោមនីតិវិធីដែលមិនបន្ទាន់នោះ។

## ១៥.២ ការអនុវត្តសេចក្តីសម្រេចផ្សេងទៀត ដោយអង្គការប្រឆាំងដូប៉ា

គណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជា និងសហព័ន្ធកីឡាជាតិណាមួយ នៅក្នុងប្រទេសកម្ពុជាអាចសម្រេចអនុវត្តសេចក្តីសម្រេចប្រឆាំងដូប៉ាផ្សេងទៀត ដែលត្រូវបានផ្តល់ដោយអង្គការប្រឆាំងដូប៉ា ដែលមិនមានចែងក្នុងប្រការ ១៥.១.១ ខាងលើ ដូចជា ការព្យួរសិទ្ធិបណ្តោះអាសន្ន មុនពេលសវនាការបណ្តោះអាសន្ន ឬការទទួលយកដោយអត្តពលិក ឬបុគ្គលផ្សេងទៀត។

## ១៥.៣ ការអនុវត្តសេចក្តីសម្រេចដោយស្ថាប័នដែលមិនមែន ស្ថាប័នហត្ថលេខី

សេចក្តីសម្រេចប្រឆាំងដូប៉ាដោយស្ថាប័ន មិនមែនជាស្ថាប័នហត្ថលេខីនៃក្រម នឹងត្រូវអនុវត្តដោយគណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជា និងសហព័ន្ធកីឡាជាតិណាមួយ នៅក្នុងប្រទេសកម្ពុជា ប្រសិនបើគណៈ

កម្មាធិការប្រឆាំងដូប៉ាកម្ពុជា យល់ឃើញថាសេចក្តីសម្រេចនោះ ស្ថិតក្នុងសិទ្ធិអំណាចស្ថាប័ននោះ និងវិធានប្រឆាំងដូប៉ារបស់ស្ថាប័ននោះស្របតាមក្រម។

ប្រការ១៦៖ អាជ្ញាយុកាល

មិនមាននីតិវិធីប្រឆាំងការប្រើប្រាស់សារធាតុហាមឃាត់ណាមួយ អាចត្រូវបានចាប់ផ្តើមឡើងប្រឆាំងនឹងអត្តពលិក ឬបុគ្គលផ្សេងទៀត បានទេលើកលែងតែអត្តពលិក ឬបុគ្គលផ្សេងទៀតនោះ ត្រូវបានជូនដំណឹងអំពីការបំពានវិធានប្រឆាំងដូប៉ា ដូចមានចែងក្នុងប្រការ ៧ ឬការជូនដំណឹងត្រូវបានប៉ុនប៉ងផ្តល់ជូនដោយសមហេតុផលក្នុងរយៈពេល ១០(ដប់)ឆ្នាំ ចាប់ពីកាលបរិច្ឆេទចោទនៃការប្រកាន់ថាបានបំពាន។

ប្រការ១៧៖ ការអប់រំ

គណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជា ត្រូវធ្វើផែនការអនុវត្ត វាយតម្លៃ និងលើកកម្ពស់ ការអប់រំ ស្របតាមលក្ខខណ្ឌតម្រូវការនៃប្រការ ១៨.២ នៃក្រម និងស្តង់ដារអន្តរជាតិស្តីពីការអប់រំ ។

ប្រការ១៨៖ មុខងារ និងការទទួលខុសត្រូវបន្ថែមរបស់សហព័ន្ធកីឡាជាតិ

១៨.១ សហព័ន្ធកីឡាជាតិ ទាំងអស់នៃប្រទេសកម្ពុជា និងសមាជិករបស់ខ្លួនត្រូវគោរពតាមក្រម ស្តង់ដារអន្តរជាតិ និងវិធានប្រឆាំងដូប៉ានេះ។ សហព័ន្ធកីឡាជាតិទាំងអស់របស់ប្រទេសកម្ពុជា និងសមាជិកដទៃទៀតនឹងត្រូវដាក់បញ្ចូលក្នុងគោលនយោបាយ វិធាន និងកម្មវិធីរបស់ខ្លួន នូវបទប្បញ្ញត្តិចាំបាច់ដើម្បីទទួលស្គាល់សិទ្ធិអំណាច និងការទទួលខុសត្រូវរបស់គណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជា សម្រាប់អនុវត្តកម្មវិធីជាតិប្រឆាំងដូប៉ារបស់កម្ពុជា និងអនុវត្តវិធានប្រឆាំងដូប៉ាទាំងនេះ (រួមបញ្ចូលទាំងការធ្វើតេស្ត) ដោយផ្ទាល់ពាក់ព័ន្ធនឹងអត្តពលិក និងបុគ្គលផ្សេងទៀតដែលស្ថិតនៅក្រោមសិទ្ធិអំណាចប្រឆាំងដូប៉ារបស់ពួកគេ ដូចដែលបានបញ្ជាក់នៅក្នុងសេចក្តីណែនាំអំពីវិធានប្រឆាំងដូប៉ា (ផ្នែក "វិសាលភាព នៃវិធានប្រឆាំងដូប៉ា")។

១៨.២ សហព័ន្ធកីឡាជាតិនីមួយៗ ត្រូវទទួលយក និងគោរពតាមស្មារតី និងលក្ខខណ្ឌនៃកម្មវិធីជាតិប្រឆាំងដូប៉ារបស់ប្រទេសកម្ពុជា និងវិធានប្រឆាំងដូប៉ា ថាជាលក្ខខណ្ឌនៃការទទួលបានហិរញ្ញវត្ថុ និង/ឬជំនួយផ្សេងទៀតពីរាជរដ្ឋាភិបាលកម្ពុជា និង/ឬ គណៈកម្មាធិការជាតិអូឡាំពិកកម្ពុជា។

១៨.៣ សហព័ន្ធកីឡាជាតិនីមួយៗ ត្រូវបញ្ចូលវិធានប្រឆាំងដូប៉ានេះ ទោះដោយផ្ទាល់ ឬដោយយោងទៅក្នុងឯកសារគ្រប់គ្រងលក្ខន្តិកៈ និង/ឬវិធានច្បាប់របស់ខ្លួន ដែលជាផ្នែកមួយនៃច្បាប់កីឡាដែលភ្ជាប់កាតព្វកិច្ចសមាជិករបស់ខ្លួន ដើម្បីឱ្យសហព័ន្ធកីឡាជាតិអាចអនុវត្តវាដោយផ្ទាល់ ពាក់ព័ន្ធនឹងអត្តពលិក និងបុគ្គលផ្សេងទៀតដែលស្ថិតនៅក្រោមសិទ្ធិអំណាចប្រឆាំងដូប៉ារបស់ខ្លួន។

១៨.៤ តាមរយៈការទទួលយកវិធានប្រឆាំងដូប៉ា និងការបញ្ចូលវាទៅក្នុងឯកសារគ្រប់គ្រង និងច្បាប់កីឡា សហព័ន្ធកីឡាជាតិត្រូវសហការ និងគាំទ្រគណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជាក្នុងកិច្ចការនេះ។ ពួកគេក៏ត្រូវទទួលស្គាល់ គោរព និងអនុវត្តសេចក្តីសម្រេចដែលបានធ្វើឡើងស្របតាមវិធានប្រឆាំងដូប៉ាទាំងនេះ រួមទាំងសេចក្តីសម្រេចដាក់ទណ្ឌកម្មលើ ជនទាំងឡាយក្រោមសិទ្ធិអំណាចរបស់ពួកគេ។

១៨.៥ សហព័ន្ធកីឡាជាតិកម្ពុជាត្រូវចាត់វិធានការសមស្របដើម្បីពង្រឹងការអនុវត្តតាម ក្រម ស្តង់ដារអន្តរជាតិ និងវិធានប្រឆាំងដូប៉ា ដោយក្នុងចំណោមកិច្ចការផ្សេងទៀត ៖

(i) ធ្វើតេស្ត ក្រោមសិទ្ធិអំណាចដែលមានចែងជាលាយលក្ខណ៍អក្សរ របស់សហព័ន្ធកីឡាអន្តរជាតិ

របស់ខ្លួន និងប្រើប្រាស់គណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជា ឬអាជ្ញាធរប្រមូលសំណាកផ្សេងទៀត ដើម្បីប្រមូលសំណាក ដោយអនុលោមតាមស្តង់ដារអន្តរជាតិស្តីពីការធ្វើតេស្ត និងការស៊ើបអង្កេត។

(ii) ទទួលស្គាល់សិទ្ធិអំណាចរបស់គណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជា យោងតាមប្រការ ៥.២.១ នៃក្រម និងតាមភាពសមស្រប ជួយគណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជា ក្នុងការអនុវត្តកម្មវិធីធ្វើតេស្តជាតិ សម្រាប់វិស័យកីឡារបស់ពួកគេ។

(iii) វិភាគសំណាកទាំងអស់ដែលប្រមូលបាន ដោយប្រើមន្ទីរពិសោធន៍ដែលទទួលស្គាល់ ឬអនុម័ត ដោយទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក ដោយអនុលោមតាមប្រការ ៦.១។

(iv) ធានាថារាល់ករណីបំពានវិធានប្រឆាំងដូប៉ាកម្រិតថ្នាក់ជាតិ ដែលរកឃើញដោយសហព័ន្ធកីឡាជាតិ ត្រូវបានវិនិច្ឆ័យដោយក្រុមប្រឹក្សាជំនុំជម្រះដែលឯករាជ្យផ្នែកប្រតិបត្តិ ដោយអនុលោមទៅតាមប្រការ ៨.១ និងស្តង់ដារអន្តរជាតិស្តីពីការដោះស្រាយវិវាទដូប៉ា។

១៨.៦ សហព័ន្ធកីឡាជាតិ ទាំងអស់ត្រូវបង្កើតវិធានដែលទាមទារឱ្យអត្តពលិក ទាំងអស់ត្រៀម ឬចូលរួមក្នុងការប្រកួត ឬសកម្មភាពដែលអនុញ្ញាត ឬរៀបចំដោយសហព័ន្ធកីឡាជាតិ ឬអង្គភាពសមាជិករបស់ខ្លួន ហើយបុគ្គលិកគាំពារអត្តពលិកទាំងអស់ ដែលជាប់ទាក់ទងនឹងអត្តពលិកទាំងនោះ ត្រូវយល់ព្រមទទួលយកវិធានប្រឆាំងដូប៉ានេះ និងអនុវត្តតាមសិទ្ធិអំណាចក្នុងការដោះស្រាយវិវាទដូប៉ារបស់អង្គភាពប្រឆាំងដូប៉ា ដោយអនុលោមតាមក្រម ដែលជាលក្ខខណ្ឌសម្រាប់ការចូលរួម។

១៨.៧ សហព័ន្ធកីឡាជាតិទាំងអស់ ត្រូវរាយការណ៍អំពីព័ត៌មានដែលស្នើឡើង ឬដែលពាក់ព័ន្ធនឹងវិធានប្រឆាំងដូប៉ាទៅនឹងគណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជា និងសហព័ន្ធកីឡាអន្តរជាតិ ហើយត្រូវសហការក្នុងការស៊ើបអង្កេតដែលធ្វើឡើងដោយអង្គការប្រឆាំងដូប៉ាណាមួយ ដែលមានអំណាចស៊ើបអង្កេត។

១៨.៨ សហព័ន្ធកីឡាជាតិទាំងអស់ ត្រូវមានវិធានវិន័យជាធរមាន ដើម្បីបង្ការបុគ្គលិកគាំពារអត្តពលិក ដែលប្រើប្រាស់សារធាតុហាមឃាត់ ឬវិធីសាស្ត្រហាមឃាត់ ដោយមិនមានហេតុផលត្រឹមត្រូវ ពីការផ្តល់ការគាំពារដល់អត្តពលិកក្រោមសិទ្ធិអំណាចរបស់គណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជា ឬសហព័ន្ធកីឡាជាតិ។

១៨.៩ សហព័ន្ធកីឡាជាតិទាំងអស់ ត្រូវធ្វើការអប់រំប្រឆាំងដូប៉ា ដោយមានការសម្របសម្រួលជាមួយគណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជា ។

## ប្រការ១៩៖ មុខងារ និងការទទួលខុសត្រូវបន្ថែមរបស់គណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជា

១៩.១ បន្ថែមលើតួនាទី និងការទទួលខុសត្រូវដែលមានចែងក្នុងប្រការ ២០.៥ នៃក្រម សម្រាប់អង្គការជាតិប្រឆាំងដូប៉ា គណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជា ត្រូវរាយការណ៍ជូនទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក ស្តីពីអនុលោមភាពរបស់គណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជាទៅនឹងក្រម និងស្តង់ដារអន្តរជាតិ ស្របតាមប្រការ ២៤.១.២ នៃក្រម។

១៩.២ យោងទៅតាមច្បាប់ជាធរមាន និងអនុលោមតាមប្រការ ២០.៥.១០ នៃក្រមសមាជិកក្រុមប្រឹក្សាភិបាល នាយក បុគ្គលិក មន្ត្រី និងភាគីទី៣ ដែលទទួលសិទ្ធិ របស់គណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជា ដែលពាក់ព័ន្ធនឹងផ្នែកណាមួយនៃការត្រួតពិនិត្យដូប៉ា នឹងត្រូវចុះហត្ថលេខាលើឯកសារដែលផ្តល់ដោយគណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជា ដោយយល់ព្រមគោរពតាមវិធានប្រឆាំងដូប៉ា ក្នុងនាមជាបុគ្គលដោយអនុលោមតាមក្រម សម្រាប់ការប្រព្រឹត្តិខុសដោយផ្ទាល់ និងដោយចេតនា។

១៩.៣ យោងទៅតាមច្បាប់ជាធរមាន និងអនុលោមតាមប្រការ ២០.៥.១១ នៃក្រម បុគ្គលិកណាម្នាក់ របស់

គណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជា ដែលបានចូលរួមនៅក្នុងការត្រួតពិនិត្យដូប៉ា (មិនមែនកម្មវិធីអប់រំ ឬស្តារនីតិសម្បទាដែលប្រឆាំងដូប៉ា ដែលត្រូវបានអនុញ្ញាតទេ) ត្រូវចុះហត្ថលេខាលើ សេចក្តីថ្លែងការណ៍មួយដែលផ្តល់ដោយគណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជា ដោយបញ្ជាក់ថាពួកគេ មិនត្រូវបានព្យួរសិទ្ធិបណ្តោះអាសន្ន ឬមិនកំពុងអនុវត្តរយៈពេលនៃការព្យួរសិទ្ធិ ហើយនឹងមិនបានចូលរួមដោយផ្ទាល់ ឬដោយចេតនាក្នុងការប្រព្រឹត្តិណាមួយក្នុងរយៈពេល ៦(ប្រាំមួយ)ឆ្នាំ ចុងក្រោយ ដែលអាចជាការបំពានលើវិធានប្រឆាំងដូប៉ា ប្រសិនបើវិធានដែលអនុលោមតាមក្រមត្រូវបានអនុវត្តចំពោះពួកគេ។

ប្រការ២០៖ តួនាទី និងការទទួលខុសបន្ថែមត្រូវរបស់អត្តពលិក

២០.១ ត្រូវមានចំណេះដឹង និងគោរពតាមវិធានប្រឆាំងដូប៉ាទាំងនេះ។

២០.២ ត្រូវមានវត្តមានសម្រាប់ការប្រមូលសំណាកគ្រប់ពេល។

២០.៣ ត្រូវទទួលខុសត្រូវក្នុងបរិបទនៃការប្រឆាំងដូប៉ាចំពោះអ្វីដែលពួកគេបានលេបចូល និងប្រើប្រាស់។

២០.៤ ត្រូវជូនដំណឹងដល់បុគ្គលិកពេទ្យអំពីកាតព្វកិច្ចរបស់ពួកគេ ក្នុងការមិនប្រើសារធាតុហាមឃាត់ និងវិធីសាស្ត្រហាមឃាត់ និងក្នុងការទទួលខុសត្រូវដើម្បីធ្វើឱ្យប្រាកដថា ការព្យាបាលណាមួយមិនត្រូវបំពានវិធានប្រឆាំងដូប៉ាទេ។

២០.៥ ត្រូវបង្ហាញដល់គណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជា និងសហព័ន្ធកីឡាអន្តរជាតិរបស់ពួកគេនូវសេចក្តីសម្រេចណាមួយដោយស្ថាប័នមិនមែនជាស្ថាប័នហត្ថលេខី ដែលរកឃើញថា អត្តពលិកបានប្រព្រឹត្តការបំពានវិធានប្រឆាំងដូប៉ា ក្នុងរយៈពេល ១០(ដប់)ឆ្នាំ កន្លងមក។

២០.៦ ត្រូវសហការជាមួយអង្គការប្រឆាំងដូប៉ាដែលស៊ើបអង្កេតការបំពានវិធានប្រឆាំងដូប៉ា។

ការខកខានរបស់អត្តពលិកណាម្នាក់ ក្នុងការផ្តល់កិច្ចសហការជាមួយអង្គការប្រឆាំងដូប៉ា ក្នុងការស៊ើបអង្កេតការបំពានវិធានដូប៉ាអាចបណ្តាលឱ្យមានការចោទប្រកាន់ពីការប្រព្រឹត្តិកំហុស នៅក្រោមវិធានរបស់គណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជា។

២០.៧ ត្រូវបង្ហាញពីអត្តសញ្ញាណរបស់ បុគ្គលិកគាំពារអត្តពលិក របស់ពួកគេ តាមការស្នើសុំរបស់គណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជា ឬសហព័ន្ធកីឡាជាតិ ឬអង្គការប្រឆាំងដូប៉ាផ្សេងទៀត ដែលមានសិទ្ធិអំណាចលើអត្តពលិកនោះ។

២០.៨ ការប្រព្រឹត្តទុច្ចរិតលើមន្ត្រីត្រួតពិនិត្យដូប៉ា ឬបុគ្គលផ្សេងទៀតដែលពាក់ព័ន្ធនឹង ការត្រួតពិនិត្យដូប៉ាដោយអត្តពលិក ដែលមិនមែនជាការធ្វើឱ្យខូចដំណើរការ អាចបណ្តាលឱ្យមានការចោទប្រកាន់ពីការប្រព្រឹត្តខុសនៅក្រោមវិធានរបស់គណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជា។

ប្រការ២១៖ តួនាទី និងការទទួលខុសត្រូវបន្ថែមរបស់បុគ្គលិកគាំពារអត្តពលិក

២១.១ ត្រូវមានចំណេះដឹង និងគោរពតាមវិធានប្រឆាំងដូប៉ាទាំងនេះ។

២១.២ ត្រូវសហការជាមួយកម្មវិធីធ្វើតេស្តអត្តពលិក។

២១.៣ ត្រូវប្រើប្រាស់ឥទ្ធិពលរបស់ពួកគេទៅលើគុណតម្លៃ និងអាកប្បកិរិយារបស់អត្តពលិក ដើម្បីលើកកម្ពស់

ឥរិយាបថប្រឆាំងដូប៉ា។

២១.៤ ត្រូវបង្ហាញដល់គណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជា និងសហព័ន្ធកីឡាអន្តរជាតិរបស់ពួកគេនូវសេចក្តីសម្រេចណាមួយដោយស្ថាប័នមិនមែនជាស្ថាប័នហត្ថលេខី ថាពួកគេបានបំពានវិធានប្រឆាំងដូប៉ាក្នុងរយៈពេល ១០(ដប់)ឆ្នាំ កន្លងមក។

២១.៥ ត្រូវសហការជាមួយអង្គការប្រឆាំងដូប៉ា ដែលស៊ើបអង្កេតការបំពានវិធានប្រឆាំងដូប៉ា។

ការខកខានរបស់បុគ្គលិកគាំពារអត្តពលិកណាមួយ ក្នុងការផ្តល់កិច្ចសហការពេញលេញ ជាមួយអង្គការប្រឆាំដូប៉ាក្នុងការស៊ើបអង្កេតការបំពានវិធានប្រឆាំងដូប៉ា អាចបណ្តាលឱ្យមានការចោទប្រកាន់ពីការប្រព្រឹត្តិខុសនៅក្រោមវិធានរបស់គណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជា។

២១.៦ បុគ្គលិកគាំពារអត្តពលិកមិនត្រូវប្រើប្រាស់ ឬកាន់កាប់នូវសារជាតុហាមឃាត់ ឬវិធីសាស្ត្រហាមឃាត់ណាមួយ ដោយគ្មានយុត្តិកម្មត្រឹមត្រូវឡើយ។

ការប្រើប្រាស់ ឬកាន់កាប់ណាមួយអាចបណ្តាលឱ្យមានការចោទប្រកាន់ពីការប្រព្រឹត្តិខុស ក្រោមវិធានរបស់គណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជា។

២១.៧ ការប្រព្រឹត្តិទុច្ចរិតលើមន្ត្រីត្រួតពិនិត្យសារជាតុដូប៉ា ឬបុគ្គលផ្សេងទៀត ដែលពាក់ព័ន្ធនឹងការត្រួតពិនិត្យសារជាតុដូប៉ាដោយអត្តពលិក ដែលមិនមែនជាការធ្វើឱ្យខូចដំណើរការ អាចបណ្តាលឱ្យមានការចោទប្រកាន់ពីការប្រព្រឹត្តិខុស នៅក្រោមវិធានរបស់គណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជា។

ប្រការ២២៖ មុខងារ និងការទទួលខុសត្រូវបន្ថែមរបស់បុគ្គលផ្សេងទៀត ដែលស្ថិតក្រោមវិធានប្រឆាំងដូប៉ាទាំងនេះ

២២.១ ត្រូវមានចំណេះដឹង និងគោរពតាមវិធានប្រឆាំងដូប៉ាទាំងនេះ។

២២.២ ត្រូវបង្ហាញដល់គណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជា និងសហព័ន្ធកីឡាអន្តរជាតិរបស់ពួកគេនូវសេចក្តីសម្រេចណាមួយដោយស្ថាប័នមិនមែនជាស្ថាប័នហត្ថលេខី ដែលរកឃើញថាអត្តពលិកបានប្រព្រឹត្តការបំពានវិធានប្រឆាំងដូប៉ាក្នុងរយៈពេល ១០(ដប់)ឆ្នាំ កន្លងមក។

២២.៣ ត្រូវសហការជាមួយអង្គការប្រឆាំងដូប៉ាដែលស៊ើបអង្កេតការបំពានវិធានប្រឆាំងដូប៉ា។

ការខកខានដោយបុគ្គលផ្សេងទៀត ដែលស្ថិតក្រោមវិធានប្រឆាំងដូប៉ាក្នុងការផ្តល់កិច្ចសហការពេញលេញជាមួយអង្គការប្រឆាំងដូប៉ា ក្នុងការស៊ើបអង្កេតអំពីការបំពានវិធានប្រឆាំងដូប៉ា អាចបណ្តាលឱ្យមានការចោទប្រកាន់ពីការប្រព្រឹត្តិខុស នៅក្រោមវិធានរបស់គណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជា។

២២.៤ មិនត្រូវប្រើ ឬកាន់កាប់នូវសារជាតុហាមឃាត់ ឬវិធីសាស្ត្រហាមឃាត់ណាមួយ ដោយគ្មានយុត្តិកម្មត្រឹមត្រូវឡើយ។

២២.៥ ការប្រព្រឹត្តិទុច្ចរិតលើមន្ត្រីត្រួតពិនិត្យសារជាតុដូប៉ា ឬបុគ្គលផ្សេងទៀត ដែលពាក់ព័ន្ធនឹងការត្រួតពិនិត្យដូប៉ាដោយអត្តពលិក ដែលមិនមែនជាការធ្វើឱ្យខូចដំណើរការ អាចបណ្តាលឱ្យមានការចោទប្រកាន់ពីការប្រព្រឹត្តខុស នៅក្រោមវិធានរបស់គណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជា។

ប្រការ២៣៖ ការបកស្រាយក្រម

២៣.១ អត្ថបទផ្លូវការនៃក្រម នឹងត្រូវបានរក្សាទុកដោយទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក ហើយនឹងត្រូវបោះពុម្ពផ្សាយជាភាសាអង់គ្លេស និងបារាំង។ ក្នុងករណីមានភាពខុសគ្នាណាមួយរវាងអត្ថបទជាភាសាអង់គ្លេស និងភាសាបារាំង ត្រូវយកភាសាអង់គ្លេសជាគោល។

២៣.២ មតិយោបល់ដែលផ្តល់សេចក្តីអធិប្បាយលើបទប្បញ្ញត្តិផ្សេងៗនៃក្រម ត្រូវយកមកប្រើដើម្បីបកស្រាយក្រម។

២៣.៣ ក្រមត្រូវបានបកស្រាយជាអត្ថបទឯករាជ្យ និងស្វយ័ត ហើយមិនយោងទៅលើច្បាប់ ឬលក្ខន្តិកៈដែលមានស្រាប់របស់ស្ថាប័នហត្ថលេខី ឬរដ្ឋាភិបាលនោះទេ។

២៣.៤ ចំណងជើងដែលប្រើសម្រាប់ផ្នែក និងប្រការផ្សេងៗនៃក្រម គឺសម្រាប់តែភាពងាយស្រួលយល់ប៉ុណ្ណោះ ហើយមិនត្រូវចាត់ទុកថាជាផ្នែកនៃខ្លឹមសាររបស់ក្រម ឬប៉ះពាល់ដល់ភាសាតាមរបៀបណាមួយ នៃបទប្បញ្ញត្តិដែលចំណងជើងសំដៅលើនោះទេ។

២៣.៥ នៅពេលដែលពាក្យ "ថ្ងៃ" ត្រូវបានប្រើប្រាស់ក្នុងក្រម ឬស្តង់ដារអន្តរជាតិ វាមានន័យថាជាថ្ងៃប្រតិទិន លើកលែងតែមានការបញ្ជាក់ផ្សេងពីនេះ។

២៣.៦ ក្រមនឹងមិនត្រូវអនុវត្តចំពោះបញ្ហាដែលមិនទាន់សម្រេចក្នុងលក្ខណៈប្រតិសកម្មមុនកាលបរិច្ឆេទដែលក្រមត្រូវបានទទួលយកដោយស្ថាប័នហត្ថលេខី និងអនុវត្តក្នុងវិធានរបស់ខ្លួនឡើយ។ ទោះយ៉ាងណាក៏ដោយ ការបំពានវិធានប្រឆាំងដូប៉ាមុនការទទួលយកក្រម នឹងបន្តរាប់ជា "ការបំពានលើកទី១" ឬ "ការបំពានលើកទី២" ក្នុងគោលបំណងកំណត់ការដាក់ទណ្ឌកម្មតាមប្រការ ១០ ចំពោះការបំពានក្រោយការទទួលយកក្រម។

២៣.៧ គោលបំណង វិសាលភាព និងការរៀបចំកម្មវិធីប្រឆាំងដូប៉ាពិភពលោក និងក្រម និងឧបសម្ព័ន្ធ និយមន័យ និងឧបសម្ព័ន្ធ ឧទាហរណ៍នៃការអនុវត្តប្រការ ១០ ត្រូវចាត់ទុកជាផ្នែកសំខាន់នៃក្រមនេះ។

## ប្រការ២៤៖ អវសានបញ្ញត្តិ

២៤.១ នៅពេលដែលពាក្យ "ថ្ងៃ" ត្រូវបានប្រើនៅក្នុងវិធានប្រឆាំងដូប៉ា វាមានន័យថាជាថ្ងៃប្រតិទិន លើកលែងតែមានការបញ្ជាក់ផ្សេងពីនេះ។

២៤.២ វិធានប្រឆាំងដូប៉ាទាំងនេះនឹងត្រូវបានបកស្រាយថាជាអត្ថបទឯករាជ្យ និងស្វយ័ត និងមិនយោងទៅលើច្បាប់ ឬលក្ខន្តិកៈដែលមានស្រាប់ទេ។

២៤.៣ វិធានប្រឆាំងដូប៉ាត្រូវបានអនុវត្តស្របតាមបទប្បញ្ញត្តិជាធរមាននៃក្រម និងបទដ្ឋានអន្តរជាតិ ហើយត្រូវបានបកស្រាយតាមរបៀបដែលមានសង្គតភាពនឹងបទប្បញ្ញត្តិជាធរមាននៃក្រម និងស្តង់ដារអន្តរជាតិ។ ក្រម និងស្តង់ដារអន្តរជាតិ ត្រូវបានចាត់ទុកជាផ្នែកសំខាន់នៃវិធានប្រឆាំងដូប៉ា ហើយត្រូវយកជាគោលក្នុងករណីមានភាពមិនត្រូវគ្នាណាមួយ។

២៤.៤ សេចក្តីផ្តើម និងឧបសម្ព័ន្ធ ត្រូវបានចាត់ទុកថាជាផ្នែកសំខាន់នៃវិធានប្រឆាំងដូប៉ានេះ។

២៤.៥ មតិយោបល់ដែលផ្តល់សេចក្តីអធិប្បាយលើបទប្បញ្ញត្តិផ្សេងៗនៃក្រម ត្រូវបានដាក់បញ្ចូល ជាផ្នែកយោងនៅក្នុងវិធានប្រឆាំងដូប៉ា ហើយត្រូវបានចាត់ទុកថាបានចែងពេញលេញ ហើយនឹងត្រូវប្រើដើម្បីបកស្រាយវិធានប្រឆាំងដូប៉ាទាំងនេះ។

២៤.៦ វិធានប្រឆាំងដូប៉ាំងទាំងនេះ នឹងចូលជាធរមាននៅថ្ងៃទី១ ខែមករា ឆ្នាំ ២០២១ "កាលបរិច្ឆេទចូលជាធរមាន"។ វិធានទាំងនេះជំនួសវិធានរបស់គណៈកម្មាធិការប្រឆាំងដូប៉ាំងកម្ពុជា ដែលបានចូលជាធរមាននៅថ្ងៃទី១ ខែមករា ឆ្នាំ ២០១៥ ។

២៤.៧ វិធានប្រឆាំងដូប៉ាំងទាំងនេះមិនត្រូវអនុវត្តតាមលក្ខណៈប្រតិសកម្មចំពោះបញ្ហាដែលមិនទាន់សម្រេចមុនកាលបរិច្ឆេទចូលជាធរមានឡើយ។ ប៉ុន្តែ ៖

២៤.៧.១ ការបំពានវិធានប្រឆាំងដូប៉ាំង ដែលធ្វើឡើងមុនកាលបរិច្ឆេទចូលជាធរមាននឹងត្រូវរាប់ថាជា "ការបំពានលើកទី១" ឬ "ការបំពានលើកទី២" ក្នុងគោលបំណងកំណត់ការដាក់ទណ្ឌកម្មតាមប្រការ ១០ ចំពោះការបំពានដែលកើតឡើងក្រោយពីកាលបរិច្ឆេទចូលជាធរមាន។

២៤.៧.២ រាល់ករណីបំពានវិធានប្រឆាំងដូប៉ាំងដែលនៅបន្តដំណើរការនៅកាលបរិច្ឆេទចូលជាធរមាន និងករណីបំពានវិធានប្រឆាំងដូប៉ាំងណាមួយដែលត្រូវបានចោទក្រោយ កាលបរិច្ឆេទចូលជាធរមាន ដោយផ្អែកលើការបំពានវិធានប្រឆាំងដូប៉ាំង ដែលបានកើតឡើងមុនកាលបរិច្ឆេទចូលជាធរមានត្រូវបានគ្រប់គ្រងដោយវិធានប្រឆាំងដូប៉ាំងឯករាជ្យ ដែលចូលជាធរមាននៅពេលមានការចោទប្រកាន់ថាមានការបំពានលើវិធានប្រឆាំងដូប៉ាំង ហើយមិនមែនគ្រប់តាមវិធានប្រឆាំងដូប៉ាំងដែលមានចែងនៅក្នុងវិធានប្រឆាំងដូប៉ាំងនេះឡើយ លើកលែងតែក្រុមប្រឹក្សាជំនុំជម្រះករណីនេះកំណត់គោលការណ៍ "អនុគ្រោះ" ដែលត្រូវអនុវត្តក្រោមកាលៈទេសៈនៃករណីនេះ។ សម្រាប់គោលបំណងទាំងនេះ រយៈពេលប្រតិសកម្មនៃការបំពានពីអតីតកាលអាចត្រូវបានពិចារណាសម្រាប់គោលបំណងនៃការបំពានច្រើនដង ក្រោមប្រការ ១០.៩.៤ និងអាជ្ញាយុកាល ដូចដែលមានចែងក្នុងប្រការ ១៦ គឺជាវិធាននីតិវិធី មិនមែនជាវិធានឯករាជ្យទេ ហើយគួរត្រូវបានអនុវត្តលក្ខណៈប្រតិសកម្ម រួមជាមួយវិធាននីតិវិធីផ្សេងទៀតទាំងអស់នៅក្នុងវិធានប្រឆាំងដូប៉ាំងនេះ (ប៉ុន្តែ ក្នុងលក្ខខណ្ឌដែលថាប្រការ ១៦ ត្រូវបានអនុវត្តលក្ខណៈប្រតិសកម្ម ប្រសិនបើច្បាប់អាជ្ញាយុកាលមិនទាន់ផុតកំណត់តាមកាលបរិច្ឆេទចូលជាធរមានទេនោះ)។

២៤.៧.៣ រាល់ការខកខានមិនបានអនុវត្តប្រការ ២.៤ ស្តីពីការផ្តល់ព័ត៌មានអំពីទីសំចត (មិនថាការបំពេញឯកសារ ឬការខកខានក្នុងការធ្វើតេស្តតាមលក្ខខណ្ឌដែលបានកំណត់ក្នុង ស្តង់ដារអន្តរជាតិស្តីពីការដោះស្រាយវិវាទដូប៉ាំងទេ) មុនកាលបរិច្ឆេទចូលជាធរមាននឹងត្រូវបានអនុវត្តបន្ត និងអាចផ្អែកលើបាន មុនពេលវាផុតកំណត់ ដោយអនុលោមទៅតាមស្តង់ដារអន្តរជាតិស្តីពីការដោះស្រាយវិវាទដូប៉ាំង ប៉ុន្តែវាត្រូវបានចាត់ទុកថាបានផុតកំណត់ក្នុងរយៈពេល ១២(ដប់ពីរ)ខែ ក្រោយការខកខាននោះបានកើតឡើង។

២៤.៧.៤ ទាក់ទងទៅនឹងករណីដែលសេចក្តីសម្រេចចុងក្រោយរកឃើញថា មានការបំពានវិធានប្រឆាំងដូប៉ាំងមុនកាលបរិច្ឆេទចូលជាធរមាន ប៉ុន្តែអត្តពលិក ឬបុគ្គលផ្សេងទៀត កំពុងអនុវត្តរយៈពេលនៃការព្យួរសិទ្ធិ ត្រឹមកាលបរិច្ឆេទចូលជាធរមាន អត្តពលិក ឬបុគ្គលផ្សេងទៀតអាចស្នើសុំទៅគណៈកម្មាធិការប្រឆាំងដូប៉ាំងកម្ពុជា ឬអង្គការប្រឆាំងដូប៉ាំងផ្សេងទៀត ដែលមានទំនួលខុសត្រូវក្នុងការដោះស្រាយវិវាទដូប៉ាំង ចំពោះការបំពានវិធានប្រឆាំងដូប៉ាំង ដើម្បីឱ្យពិចារណាបន្ថយបន្ថយរយៈពេលនៃការព្យួរសិទ្ធិក្រោមវិធានប្រឆាំងដូប៉ាំងទាំងនេះ។ ពាក្យសុំបែបនេះត្រូវធ្វើមុនពេលផុតកំណត់រយៈពេលនៃការព្យួរសិទ្ធិ។ សេចក្តីសម្រេចនោះអាចត្រូវបានប្តឹងជំទាស់ដោយអនុលោមតាមប្រការ ១៣.២។ វិធានប្រឆាំងដូប៉ាំងទាំងនេះមិនត្រូវអនុវត្តចំពោះករណីណាដែលសេចក្តីសម្រេចចុងក្រោយរក ឃើញថាមានការបំពានវិធានប្រឆាំងដូប៉ាំង ហើយរយៈពេលនៃការព្យួរសិទ្ធិបានផុតកំណត់នោះទេ។

២៤.៧.៥ ដើម្បីវាយតម្លៃរយៈពេលនៃការព្យួរសិទ្ធិចំពោះការបំពានជាលើកទី២ តាមប្រការ ១០.៩.១ ក្នុងករណីដែលទណ្ឌកម្មចំពោះការបំពានលើកទី១ ត្រូវបានកំណត់ដោយផ្អែកលើវិធានជាធរមាន មុនកាលបរិច្ឆេទ

ចូលជាធរមាន ត្រូវបានអនុវត្តរយៈពេលនៃការព្យួរសិទ្ធិដែលត្រូវបានវាយតម្លៃចំពោះការបំពានលើកទី១ ក្នុងករណីដែលវិធានប្រឆាំងដូប៉ាំងនេះត្រូវបានអនុវត្ត។

២៤.៧.៦ ការផ្លាស់ប្តូរបញ្ជីហាមឃាត់ និងឯកសារបច្ចេកទេសទាក់ទងទៅនឹងសារធាតុ ឬវិធីសាស្ត្រដែលមាននៅក្នុងបញ្ជីហាមឃាត់ មិនត្រូវអនុវត្តតាមលក្ខណៈប្រតិសកម្មទេ លើកលែងតែមានការបញ្ជាក់ផ្សេងពីនេះ។ ទោះយ៉ាងណាក៏ដោយ ករណីលើកលែងនៅពេលដែលសារធាតុហាមឃាត់ ឬវិធីសាស្ត្រហាមឃាត់ ត្រូវបានដកចេញពីបញ្ជីហាមឃាត់ អត្តពលិក ឬបុគ្គលផ្សេងទៀត ដែលកំពុងអនុវត្តរយៈពេលព្យួរសិទ្ធិ ក្នុងករណីសារធាតុហាមឃាត់ ឬវិធីសាស្ត្រហាមឃាត់ពីមុន អាចអនុវត្តចំពោះគណៈកម្មាធិការប្រឆាំងដូប៉ាំកម្ពុជា ឬអង្គភាពប្រឆាំងដូប៉ាំផ្សេងទៀត ដែលមានការទទួលខុសត្រូវលើការដោះស្រាយវិវាទដូប៉ា ចំពោះការបំពានវិធានប្រឆាំងដូប៉ា ដើម្បីពិចារណាពីកាត់បន្ថយរយៈពេលនៃការព្យួរសិទ្ធិ សម្រាប់ការដកសារធាតុ ឬវិធីសាស្ត្រ នោះចេញពីបញ្ជីហាមឃាត់ ។

# ឧបសម្ព័ន្ធ ៖ និយមន័យ

**ប្រព័ន្ធគ្រប់គ្រងរដ្ឋបាលប្រឆាំងដូប៉ា៖** គឺជាឧបករណ៍គ្រប់គ្រងទិន្នន័យលើអ៊ីនធឺណិត សម្រាប់ការបញ្ចូល ការរក្សាការ ចែករំលែក និងការរាយការណ៍ទិន្នន័យ ដែលត្រូវបានបង្កើតឡើងដើម្បីជួយភាគីពាក់ព័ន្ធ និងទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក ក្នុងប្រតិបត្តិការប្រឆាំងដូប៉ាដោយអនុលោមតាមច្បាប់ការពារទិន្នន័យ។

**ការផ្តល់សារធាតុដូប៉ា៖** ការផ្តល់ ការផ្គត់ផ្គង់ ការត្រួតពិនិត្យ ការសម្របសម្រួល ឬការចូលរួមក្នុងការប្រើប្រាស់ ឬការប៉ុនប៉ងប្រើប្រាស់ ដោយបុគ្គល ម្នាក់ទៀតនៃសារធាតុ ហាមឃាត់ ឬវិធីសាស្ត្រហាមឃាត់។ ទោះយ៉ាងណាក៏ដោយ និយមន័យនេះនឹងមិនរាប់បញ្ចូលសកម្មភាពពិតប្រាកដរបស់បុគ្គលិកវេជ្ជសាស្ត្រលើសារធាតុហាមឃាត់ ឬវិធីសាស្ត្រហាមឃាត់ដែល ត្រូវបានប្រើសម្រាប់គោលបំណងព្យាបាលពិតប្រាកដ និងស្របច្បាប់ ឬយុត្តិកម្មដែលអាចទទួលយកបានផ្សេងទៀត និងមិនរាប់បញ្ចូលសកម្មភាពដែលពាក់ព័ន្ធនឹង សារធាតុហាមឃាត់ ដែលមិនត្រូវបានហាមឃាត់នៅក្នុង ការធ្វើតេស្តក្រៅការប្រកួតឡើយ លុះត្រាតែកាលៈទេសៈទាំងមូលបង្ហាញថា សារធាតុហាមឃាត់ បែបនេះមិនមែនត្រូវបានប្រើក្នុងគោលបំណងព្យាបាលពិតប្រាកដ និងស្របច្បាប់ ឬមានគោលបំណងដើម្បីបង្កើនសមត្ថភាពកីឡា។

**លទ្ធផលវិភាគវិជ្ជមាន៖** របាយការណ៍ពីមន្ទីរពិសោធន៍ដែលទទួលស្គាល់ដោយ ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក ឬមន្ទីរពិសោធន៍ដែលត្រូវបានអនុម័តដោយ ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោកផ្សេងទៀត ដែលស្របនឹងស្តង់ដារអន្តរជាតិស្តីពីមន្ទីរពិសោធន៍ បង្ហាញថានៅក្នុងសំណាកមានវត្តមាននៃសារធាតុហាមឃាត់ ឬសារធាតុមេតាប៉ូលីស ឬសារធាតុបិទបាំង ឬភស្តុតាងនៃការប្រើប្រាស់វិធីសាស្ត្រហាមឃាត់ណាមួយ ។

**លទ្ធផលប្រវត្តិជីវសាស្ត្រមិនល្អ៖** របាយការណ៍ដែលកំណត់ថាជាការរកឃើញប្រវត្តិជីវសាស្ត្រមិនល្អដូចដែលបានពិពណ៌នានៅក្នុងស្តង់ដារអន្តរជាតិជាធរមាន ។

**ស្ថានទម្ងន់ទោស៖** ស្ថានភាពដែលពាក់ព័ន្ធនឹង ឬសកម្មភាពរបស់ អត្តពលិក ឬបុគ្គលផ្សេងទៀតដែលអាចបង្ហាញហេតុផលអំពីការព្យួរសិទ្ធិ មិនត្រឹមត្រូវដែលមានទម្ងន់ធ្ងន់ជាង ការដាក់ទណ្ឌកម្មស្តង់ដារ។ កាលៈទេសៈ និងសកម្មភាពបែបនេះរួមបញ្ចូលទាំង៖ អត្តពលិក ឬបុគ្គលផ្សេងទៀតដែលបានប្រើប្រាស់ឬកាន់កាប់សារធាតុហាមឃាត់ច្រើនមុខ ឬវិធីសាស្ត្រហាមឃាត់ផ្សេងៗគ្នា ប្រើប្រាស់ ឬកាន់កាប់សារធាតុហាមឃាត់ ឬវិធីសាស្ត្រហាមឃាត់ច្រើនដង ឬបានប្រព្រឹត្តិបំពានវិធានប្រឆាំងដូប៉ាច្រើនដង ឬបុគ្គលធម្មតាទំនងជាទទួលបាន ផលពីការបង្កើនសមត្ថភាពកីឡាដោយបំពានវិធានប្រឆាំង ដូប៉ាលើសពីរយៈពេលនៃការអនុវត្តការព្យួរសិទ្ធិ ឬអត្តពលិក ឬបុគ្គលដែលពាក់ព័ន្ធនឹងការប្រព្រឹត្តបែបបោកបញ្ឆោតឬរារាំងដើម្បីជៀសវាងការរកឃើញ ឬការវិនិច្ឆ័យចំពោះការបំពានវិធានប្រឆាំងដូប៉ា ឬអត្តពលិក ឬបុគ្គលផ្សេងទៀត ដែលពាក់ព័ន្ធនឹង ការធ្វើឱ្យខូចដំណើរការ ក្នុងអំឡុងពេលនៃការដោះស្រាយវិវាទដូប៉ា។ ដើម្បីជៀសវាងការសង្ស័យ ឧទាហរណ៍នៃកាលៈទេសៈនិងការប្រព្រឹត្តដែលបានពិពណ៌នានៅក្នុងឯកសារនេះ មិនរួមបញ្ចូលកាលៈទេសៈទាំងអស់

ទេ ហើយកាលៈទេសៈ ឬការប្រព្រឹត្តស្រដៀងគ្នាផ្សេងទៀតក៏អាចជាហេតុផលនៃការដាក់ទណ្ឌកម្មដោយព្យួរសិទ្ធិរយៈពេលវែងផងដែរ។

សកម្មភាពប្រឆាំងដូប៉ា៖ ការអប់រំ និងព័ត៌មានស្តីពីការប្រឆាំងដូប៉ា ផែនការបែងចែកការធ្វើតេស្ត បញ្ជីឈ្មោះធ្វើតេស្ត ការគ្រប់គ្រងប្រវត្តិជីវសាស្ត្រអត្តពលិក ការធ្វើតេស្ត ការរៀបចំការវិភាគសំណាក ការប្រមូលព័ត៌មាន និងការស៊ើបអង្កេត ដំណើរការនៃការអនុវត្តការលើកលែងឱ្យប្រើប្រាស់ថ្នាំព្យាបាល ការដោះស្រាយវិវាទដូប៉ា ការពិនិត្យតាមដាន និងការពង្រឹងអនុលោមភាពនៃការអនុវត្តទណ្ឌកម្ម ដែលបានកំណត់ និងសកម្មភាពផ្សេងទៀតពាក់ព័ន្ធនឹងការប្រឆាំងដូប៉ា ដែលអនុវត្តដោយ ឬក្នុងនាមអង្គការប្រឆាំងដូប៉ា ដូចមានចែងក្នុង ក្រម និង/ឬស្តង់ដារអន្តរជាតិ។

អង្គការប្រឆាំងដូប៉ា៖ ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក ឬស្ថាប័នហត្ថលេខីដែលទទួលខុសត្រូវចំពោះការទទួលយកវិធានដើម្បីផ្តួចផ្តើមអនុវត្ត ឬពង្រឹងការអនុវត្តផ្នែកមួយនៃដំណើរការត្រួតពិនិត្យដូប៉ា។ នេះរួមបញ្ចូលទាំងគណៈកម្មាធិការអូឡាំពិកអន្តរជាតិគណៈកម្មាធិការប៉ារ៉ាឡាំពិកអន្តរជាតិ ស្ថាប័នរៀបចំព្រឹត្តិការណ៍កីឡាធំៗផ្សេងទៀតដែលធ្វើតេស្តសម្រាប់ព្រឹត្តិការណ៍កីឡា សហព័ន្ធកីឡាអន្តរជាតិ និងអង្គការប្រឆាំងដូប៉ាជាតិ។

អត្តពលិក៖ បុគ្គលណាម្នាក់ដែលចូលរួមប្រកួតកីឡានៅកម្រិតអន្តរជាតិ (ដូចដែលបានកំណត់ដោយសហព័ន្ធកីឡាអន្តរជាតិនីមួយៗ) ឬកម្រិតជាតិ (ដូចដែលបានកំណត់ដោយ អង្គការប្រឆាំងដូប៉ាជាតិនីមួយៗ)។ អង្គការប្រឆាំងដូប៉ា មានឆន្ទានុសិទ្ធិក្នុងការអនុវត្តវិធានប្រឆាំងដូប៉ា លើអត្តពលិកដែលមិនមែនជាអត្តពលិកកម្រិតអន្តរជាតិ ហើយក៏មិនមែនជាអត្តពលិកកម្រិតជាតិ ដើម្បីឱ្យត្រូវតាមនិយមន័យ "អត្តពលិក"។ ទាក់ទងនឹងអត្តពលិកដែលមិនមែនជាអត្តពលិកកម្រិតអន្តរជាតិ ឬអត្តពលិកកម្រិតជាតិ អង្គការប្រឆាំងដូប៉ាអាចជ្រើសរើស៖ ធ្វើតេស្តមានកំណត់ ឬមិនធ្វើតេស្តទាល់តែសោះ វិភាគសំណាកក្នុងកម្រិតតិចជាងបញ្ជីពេញលេញនៃសារធាតុហាមឃាត់ ទាមទារព័ត៌មានអំពីទីសំចតតិចតួច ឬមិនទាមទារ ឬមិនទាមទារការលើកលែងឱ្យប្រើប្រាស់ថ្នាំព្យាបាលជាមុន។ ទោះយ៉ាងណាក៏ដោយ ប្រសិនបើមានការបំពានវិធានប្រឆាំងដូប៉ាតាមប្រការ ២.១ ប្រការ ២.៣ ឬប្រការ ២.៥ ដោយអត្តពលិកណាម្នាក់ក្រោមដែនសមត្ថកិច្ចរបស់ខ្លួន អង្គការប្រឆាំងដូប៉ាអាចសម្រេចប្រើសិទ្ធិអំណាចរបស់ខ្លួនក្នុងការធ្វើតេស្តលើអត្តពលិកនោះ ដែលចូលរួមប្រកួតនៅកម្រិតក្រោមកម្រិតអន្តរជាតិ ឬកម្រិតជាតិនោះ ទណ្ឌកម្មដែលមានចែងនៅក្នុងក្រមនេះ ត្រូវបានអនុវត្ត។ សម្រាប់គោលបំណងនៃប្រការ ២.៨ និងប្រការ ២.៩ និងសម្រាប់គោលបំណងប្រឆាំងដូប៉ា និងការអប់រំបុគ្គលណាម្នាក់ដែលចូលរួមប្រកួតក្រោមស្ថាប័នហត្ថលេខី រដ្ឋាភិបាល ឬអង្គការកីឡាដទៃទៀតដែលទទួលយកក្រមនេះ គឺជាអត្តពលិក ។

ប្រវត្តិជីវសាស្ត្រអត្តពលិក៖ កម្មវិធី និងវិធីសាស្ត្រនៃការប្រមូល និងបញ្ចូលទិន្នន័យ ដូចដែលបានពិពណ៌នានៅក្នុងស្តង់ដារអន្តរជាតិស្តីពីការធ្វើតេស្ត និងការស៊ើបអង្កេត និងស្តង់ដារអន្តរជាតិស្តីពីមន្ទីរពិសោធន៍។

បុគ្គលិកគាំពារអត្តពលិក៖ គ្រូបង្វឹក គ្រូបណ្តុះបណ្តាល អ្នកគ្រប់គ្រង ភ្នាក់ងារ បុគ្គលិក មន្ត្រី បុគ្គលិកពេទ្យ បុគ្គលិកជំនួយវេជ្ជសាស្ត្រ ឪពុកឬម្តាយ ឬបុគ្គលណាមួយផ្សេងទៀត ដែលព្យាបាល ឬជួយដល់អត្តពលិក ដែលចូលរួមនៅក្នុងការប្រកួត ឬដែលត្រៀមរៀបចំសម្រាប់ការប្រកួត។

ការប៉ុនប៉ង៖ ការចូលរួមដោយចេតនាក្នុងការប្រព្រឹត្ត ដែលបង្កើតបានជាជំហានសំខាន់មួយ ក្នុងការប្រព្រឹត្តដែលបានគ្រោងទុក ដើម្បីឈានដល់ការបំពានវិធានប្រឆាំងដូប៉ា។ ប៉ុន្តែក្នុងលក្ខខណ្ឌដែលថា គ្មានការបំពានវិធានប្រឆាំងដូប៉ាណាមួយ ដែលផ្អែកទាំងស្រុងលើការប៉ុនប៉ងប្រព្រឹត្តការបំពាននោះទេ ប្រសិនបើបុគ្គលនោះលះបង់ចោលការប៉ុនប៉ង មុនពេលវាត្រូវបានរកឃើញដោយភាគីទីបី ដែលមិនពាក់ព័ន្ធនៅក្នុងការប៉ុនប៉ងនោះ។

លទ្ធផលមិនធម្មតា៖ របាយការណ៍ពីមន្ទីរពិសោធន៍ដែល ទទួលស្គាល់ដោយទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក ឬមន្ទីរពិសោធន៍ដែលអនុម័តដោយ ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក ដែលទាមទារឱ្យមានការស៊ើបអង្កេតបន្ថែម ដូចដែលចែងក្នុង ស្តង់ដារអន្តរជាតិស្តីពីមន្ទីរពិសោធន៍ ឬឯកសារបច្ចេកទេសដែលពាក់ព័ន្ធ មុនពេលនៃការសម្រេចលើលទ្ធផលវិភាគវិជ្ជមាន ។

ការរកឃើញប្រវត្តិជីវសាស្ត្រមិនល្អ៖ របាយការណ៍ដែលកំណត់ថាជាការរកឃើញប្រវត្តិជីវសាស្ត្រមិនល្អ ដូចដែលបានពិពណ៌នានៅក្នុងស្តង់ដារអន្តរជាតិជាធរមាន ។

មជ្ឈតកម្មកីឡា៖ តុលាការអាជ្ញាកណ្តាលផ្នែកកីឡា។

ក្រុម៖ ក្រុមប្រឆាំងដូប៉ាពិភពលោក។

ការប្រកួតកីឡា៖ ការប្រណាំងប្រជែង ការប្រកួត កីឡាតែមួយ ឬការប្រឡងប្រជែងកីឡាតែមួយ។ ឧទាហរណ៍៖ កីឡាបាល់បោះ ឬការប្រកួតផ្តាច់ព្រ័ត្រនៃការរត់ប្រណាំងកីឡាអូឡាំពិកចម្ងាយ ១០០ ម៉ែត្រក្នុងវិញ្ញាសាអត្តពលកម្ម។ សម្រាប់ការកួតកីឡាតាមវគ្គ និងការប្រកួតកីឡាដទៃទៀត ដែលរង្វាន់ត្រូវបានផ្តល់ជូនជារៀងរាល់ថ្ងៃ ឬផ្អែកលើមូលដ្ឋាន បណ្តោះអាសន្ន ភាពខុសគ្នារវាង ការប្រកួត និងព្រឹត្តិការណ៍កីឡា នឹងត្រូវបានចែងក្នុងវិធានជាធរមានរបស់សហព័ន្ធកីឡាអន្តរជាតិនោះ។

ទណ្ឌកម្មចំពោះការបំពានវិធានប្រឆាំងដូប៉ា ("ទណ្ឌកម្ម")៖ ការបំពានវិធានប្រឆាំងដូប៉ារបស់អត្តពលិក ឬ បុគ្គលផ្សេងទៀត អាចបណ្តាលឱ្យមានលទ្ធផលមួយ ឬច្រើនដូចខាងក្រោម៖ (ក) ការបដិសេធលទ្ធផលប្រកួត មានន័យថា លទ្ធផលរបស់អត្តពលិកក្នុងការប្រកួត ឬព្រឹត្តិការណ៍កីឡា ជាក់លាក់ណាមួយត្រូវអសុពលភាព និងត្រូវទទួលទណ្ឌកម្មនានា រួមទាំងការដកមេដាយ ពិន្ទុ និងរង្វាន់មកវិញ (ខ) ការព្យួរសិទ្ធិ មានន័យថាអត្តពលិក ឬបុគ្គលផ្សេងទៀតត្រូវបានហាមឃាត់ដោយសារការបំពានវិធានប្រឆាំងដូប៉ា ក្នុងរយៈពេលជាក់លាក់មួយ ពីការចូលរួមក្នុង ការប្រកួតណាមួយ ឬសកម្មភាពណាមួយ ឬមូលនិធិ ដូចដែលមានចែងក្នុងប្រការ ១០.១៤ (គ) ការព្យួរសិទ្ធិបណ្តោះអាសន្ន មានន័យថាអត្តពលិក ឬបុគ្គលផ្សេងទៀតត្រូវបានហាម

ឃាត់ជាបណ្ដោះអាសន្នពីការចូលរួមក្នុងការប្រកួតណាមួយ ឬសកម្មភាពណាមួយ មុនពេលមានសេចក្ដីសម្រេចចុងក្រោយនៅក្នុងសវនាការ ដែលត្រូវប្រព្រឹត្តទៅតាមប្រការ ៨ (ឃ) ទណ្ឌកម្មហិរញ្ញវត្ថុ មានន័យថាការដាក់ទណ្ឌកម្មហិរញ្ញវត្ថុ ដែលបានកំណត់សម្រាប់ការបំពានវិធានប្រឆាំងដូប៉ា ឬដើម្បីស្តារការចំណាយដែលពាក់ព័ន្ធនឹងការបំពានវិធានប្រឆាំងដូប៉ា និង(ង) ការផ្សព្វផ្សាយជាសាធារណៈ មានន័យថាការផ្សព្វផ្សាយ ឬចែកចាយព័ត៌មានដល់សាធារណជនទូទៅ ឬជនដែលក្រៅពីបុគ្គលទាំងឡាយដែលមានសិទ្ធិទទួលបានការជូនដំណឹងជាមុនស្របតាមប្រការ១៤។កីឡាជាក្រុមក៏អាចជាកម្មវត្ថុនៃទណ្ឌកម្មផងដែរ ដូចមានចែងក្នុងប្រការ ១១ ។

**ផលិតផលមិនស្មោះត្រង់៖** ជាផលិតផលដែលមានសារធាតុហាមឃាត់ ដែលមិនត្រូវបានបង្ហាញនៅលើស្លាកផលិតផល ឬនៅក្នុងព័ត៌មានដែលអាចរកបានលើបណ្តាញអ៊ីធឺណិត។

**កំពុងកម្រិតនៃសេចក្ដីសម្រេច៖** តម្លៃនៃលទ្ធផលសម្រាប់កម្រិតកំណត់នៃសារធាតុនៅក្នុងសំណាកមួយ ដែលលើសកម្រិតលទ្ធផលវិភាគវិជ្ជមាន ដូចដែលបានកំណត់នៅក្នុងស្តង់ដារអន្តរជាតិស្តីពីមន្ទីរពិសោធន៍។

**ភាគីទីបីដែលទទួលសិទ្ធិ ៖** បុគ្គលណាម្នាក់ដែលគណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជា ផ្ទេរសិទ្ធិលើទិដ្ឋភាពណាមួយនៃកម្មវិធីត្រួតពិនិត្យសារធាតុដូប៉ា ឬកម្មវិធីអប់រំប្រឆាំងដូប៉ា ទាំងភាគីទី៣ ឬអង្គការប្រឆាំងដូប៉ា ផ្សេងទៀតដែលធ្វើការប្រមូលសំណាក ឬផ្តល់សេវាកម្ម ត្រួតពិនិត្យសារធាតុដូប៉ាផ្សេងទៀត ឬផ្តល់កម្មវិធីអប់រំប្រឆាំងដូប៉ា សម្រាប់គណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជា ឬបុគ្គលដែលបម្រើការជាអ្នកម៉ៅការឯករាជ្យ ដែលផ្តល់សេវាគ្រប់គ្រងសារធាតុដូប៉ាសម្រាប់គណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជា (ឧទាហរណ៍៖ មន្ត្រីត្រួតពិនិត្យសារធាតុដូប៉ាដែលមិនមែនជាបុគ្គលិក ឬអ្នកសង្កេតតាមដាន) និយមន័យនេះមិនរាប់បញ្ចូលមជ្ឈតកម្មកីឡាទេ។

**ដកសិទ្ធិ ៖** សូមមើល ទណ្ឌកម្មចំពោះការបំពានវិធានប្រឆាំងដូប៉ាខាងលើ។

**ការគ្រប់គ្រងសារធាតុដូប៉ា៖** រាល់ជំហាន និងដំណើរការនៃផែនការបែងចែកការធ្វើតេស្តរហូតដល់ការសម្រេចចុងក្រោយលើបណ្តឹងជំទាស់ណាមួយ និងការពង្រឹងការអនុវត្តទណ្ឌកម្ម រួមទាំងជំហាន និងដំណើរការទាំងអស់ដែលស្ថិតក្នុងចន្លោះពេលនោះ រាប់បញ្ចូលទាំងការធ្វើតេស្ត ការស៊ើបអង្កេត ព័ត៌មានអំពីទីសំចត ការលើកលែងឱ្យប្រើប្រាស់ថ្នាំព្យាបាល ការប្រមូលសំណាក និងការគ្រប់គ្រងការវិភាគរបស់មន្ទីរពិសោធន៍ ការដោះស្រាយវិវាទដូប៉ា និងការស៊ើបអង្កេត ឬកិច្ចដំណើរការទាក់ទងទៅនឹងការបំពានប្រការ ១០.១៤ (ស្ថានភាពក្នុងកំឡុងពេលនៃការព្យួរសិទ្ធិ ឬការព្យួរបណ្តោះអាសន្ន )។

**ការអប់រំ៖** ដំណើរការនៃការរៀនសូត្រដើម្បីពង្រឹងគុណតម្លៃនិងអភិវឌ្ឍឥរិយាបថដែលជំរុញនិងការពារស្មារតីកីឡា និងទប់ស្កាត់ការប្រើប្រាស់ដូប៉ាដោយចេតនា និងដោយអចេតនា។

**ព្រឹត្តិការណ៍កីឡា៖** ការប្រកួតកីឡាណាមួយ ដែលធ្វើឡើងរួមគ្នាក្រោមស្ថាប័នគ្រប់គ្រងព្រឹត្តិការណ៍

ប្រកួតកីឡាតែមួយ (ឧទាហរណ៍៖ ការប្រកួតកីឡាអូឡាំពិក ការប្រកួតជើងឯកពិភពលោកនៃសហព័ន្ធកីឡាអន្តរជាតិ ឬព្រឹត្តិការកីឡា)។

**កំឡុងពេលព្រឹត្តិការណ៍៖** ពេលដែលនៅចន្លោះរវាងការចាប់ផ្តើម និងចុងបញ្ចប់នៃព្រឹត្តិការណ៍កីឡាដូចដែលត្រូវបានកំណត់ដោយស្ថាប័នគ្រប់គ្រងព្រឹត្តិការណ៍កីឡា។

**ទីកន្លែងព្រឹត្តិការណ៍៖** ទីកន្លែងទាំងឡាយណាដែលត្រូវបានកំណត់ដោយស្ថាប័នគ្រប់គ្រងព្រឹត្តិការណ៍ប្រកួតកីឡា។

**កំហុស៖** កំហុសគឺបំពានណាមួយលើកាតព្វកិច្ច ឬការខ្វះការយកចិត្តទុកដាក់សមរម្យទៅនឹងស្ថានភាពជាក់លាក់មួយ។ កត្តាដែលត្រូវយកមកពិចារណាក្នុងការវាយតម្លៃកម្រិតកំហុសរបស់អត្តពលិក ឬបុគ្គលផ្សេងទៀត រួមមានដូចជា បទពិសោធផ្ទាល់ខ្លួនរបស់អត្តពលិក ឬបុគ្គល ផ្សេងទៀត ថាតើអត្តពលិក ឬបុគ្គលផ្សេងទៀតគឺបុគ្គលដែលត្រូវបានការពារឬទេ ការពិចារណាពិសេសនានាដូចជាការរងរបួស កម្រិតនៃហានិភ័យដែលគួរយល់ដឹងដោយ អត្តពលិក និងកម្រិតនៃការយកចិត្តទុកដាក់ និងការស៊ើបអង្កេត ដែលបានអនុវត្តដោយអត្តពលិក ទាក់ទងទៅនឹងអ្វីដែលគួរត្រូវបានគិតថាជាកម្រិតនៃហានិភ័យ។ កាលៈទេសៈក្នុងការវាយតម្លៃកម្រិតកំហុសរបស់អត្តពលិក ឬបុគ្គលផ្សេងទៀត ដែលត្រូវបានពិចារណាត្រូវតែជាក់លាក់ និងពាក់ព័ន្ធ ដើម្បីពន្យល់អត្តពលិក ឬបុគ្គលផ្សេងទៀតពីការអនុវត្តប្រាសចាកពីស្តង់ដារឥរិយាបទដែលបានរំពឹងទុក។ ដូច្នេះឧទាហរណ៍ អត្តពលិកម្នាក់ នឹងបាត់បង់ឱកាសក្នុងការរកប្រាក់បានច្រើនក្នុងអំឡុងពេលនៃការព្យួរសិទ្ធិ ឬអត្តពលិកនៅសល់ពេលខ្លីក្នុងអាជីព ឬពេលវេលានៃប្រតិទិនប្រកួត នឹងមិនមែនជាកត្តាពាក់ព័ន្ធដែលត្រូវពិចារណា ក្នុងការបន្ធូរបន្ថយរយៈពេលនៃការព្យួរសិទ្ធិ តាមប្រការ ១០.៦.១ ឬ ប្រការ ១០.៦.២ នោះទេ។

**ទណ្ឌកម្មហិរញ្ញវត្ថុ៖** សូមមើល ទណ្ឌកម្មចំពោះការបំពានវិធានប្រឆាំងដូប៉ាខាងលើ។

**ក្នុងការប្រកួត៖** រយៈពេលដែលគិតចាប់ពីម៉ោង ១១:៥៩ នាទីនៅថ្ងៃមុនការប្រកួត ដែលអត្តពលិក គ្រោងនឹងចូលរួម រហូតដល់ការបញ្ចប់ការប្រកួតនោះ និងដំណើរការប្រមូលសំណាកទាក់ទងនឹងការប្រកួតនោះ ។ ទោះយ៉ាងណាក៏ដោយ ក្នុងករណីដែលថាទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក អនុម័តសម្រាប់កីឡាជាក់លាក់ណាមួយ និយមន័យជំនួស ប្រសិនបើសហព័ន្ធកីឡាអន្តរជាតិផ្តល់នូវយុត្តិកម្មសមហេតុផលថានិយមន័យផ្សេងពីនោះមានភាពចាំបាច់សម្រាប់ការប្រកួតរបស់ខ្លួន ក្រោយពេលមានការអនុម័តបែបនោះពីទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក និយមន័យជំនួសនឹងត្រូវបានអនុវត្តដោយ ស្ថាប័នរៀបចំព្រឹត្តិការណ៍កីឡាធំៗទាំងអស់សម្រាប់ការប្រកួតជាក់លាក់នោះ។

**កម្មវិធីអ្នកសង្កេតការណ៍ឯករាជ្យ៖** ក្រុមអ្នកសង្កេតការណ៍ និង/ឬសវនករ ក្រោមការគ្រប់គ្រងរបស់ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោកដែលសង្កេតការ និងផ្តល់ការណែនាំស្តីពីដំណើរការត្រួតពិនិត្យដូប៉ាមុន ឬក្នុងព្រឹត្តិការណ៍ជាក់លាក់ណាមួយ និងរាយការណ៍អំពីការសង្កេតរបស់ពួកគេ ដែលជាផ្នែកមួយនៃកម្មវិធីពិនិត្យតាមដានដោយអនុលោមភាពរបស់

ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក។

**កីឡាឯកត្តជន៖** កីឡាណាមួយដែលមិនមែនកីឡាជាក្រុម។

**ការព្យួរសិទ្ធិ៖** សូមមើលទណ្ឌកម្មចំពោះការបំពានវិធានប្រឆាំងដូប៉ាខាងលើ។

**ឯករាជ្យភាពស្ថាប័ន៖** ក្រុមប្រឹក្សាជំនុំជម្រះលើបណ្តឹងជំទាស់ ត្រូវមានឯករាជ្យភាពពេញលេញផ្នែកស្ថាប័នពីអង្គការប្រឆាំង ដូប៉ាដែលទទួលខុសត្រូវក្នុងការដោះស្រាយវិវាទដូប៉ា។ ដូច្នេះ ស្ថាប័នទាំងនេះមិនត្រូវស្ថិតក្រោមការគ្រប់គ្រងរដ្ឋបាល មិនត្រូវពាក់ព័ន្ធ ឬស្ថិតក្រោមគ្រប់គ្រងរបស់អង្គការប្រឆាំងដូប៉ា ដែលទទួលខុសត្រូវលើការដោះស្រាយវិវាទដូប៉ាឡើយ។

**ព្រឹត្តិការណ៍កីឡាអន្តរជាតិ ៖** ជាព្រឹត្តិការណ៍កីឡា ឬការប្រកួតកីឡាណាមួយ ដែលគណៈកម្មាធិការអូឡាំពិកអន្តរជាតិ គណៈកម្មាធិការប៉ារ៉ាឡាំពិកអន្តរជាតិ សហព័ន្ធកីឡាអន្តរជាតិ ស្ថាប័នរៀបចំព្រឹត្តិការណ៍កីឡាធំៗ ឬស្ថាប័នរៀបចំកីឡាអន្តរជាតិផ្សេងទៀតជាស្ថាប័នគ្រប់គ្រងព្រឹត្តិការណ៍ប្រកួតកីឡានោះ ឬតែងតាំងមន្ត្រីបច្ចេកទេសសម្រាប់ព្រឹត្តិការណ៍កីឡានោះ។

**អត្តពលិកកម្រិតអន្តរជាតិ៖** អត្តពលិក ដែលចូលរួមប្រកួតកីឡានៅកម្រិតអន្តរជាតិ ដូចដែលបានកំណត់ដោយសហព័ន្ធកីឡាអន្តរជាតិនីមួយៗ ស្របតាមស្តង់ដារអន្តរជាតិស្តីពីការធ្វើតេស្ត និងការស៊ើបអង្កេត។

**ស្តង់ដារអន្តរជាតិ៖** ស្តង់ដារមួយដែលត្រូវបានអនុម័តដោយ ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក ដើម្បីគាំទ្រក្រមនេះ ។ ការអនុលោមតាមស្តង់ដារអន្តរជាតិ (មិនមែនស្តង់ដារ ឬការអនុវត្តន៍ ឬនីតិវិធីជំនួសផ្សេងទៀត) គឺគ្រប់គ្រាន់ដើម្បីសន្និដ្ឋានថានីតិវិធីដែលមានចែងក្នុងស្តង់ដារអន្តរជាតិ ត្រូវបានអនុវត្តត្រឹមត្រូវ។ ស្តង់ដារអន្តរជាតិត្រូវរាប់បញ្ចូលទាំងឯកសារបច្ចេកទេស ដែលត្រូវបានចេញដោយអនុលោមតាមស្តង់ដារអន្តរជាតិនោះ។

**ស្ថាប័នរៀបចំព្រឹត្តិការណ៍កីឡាធំៗ៖** សមាគមប្រចាំទ្វីបនៃគណៈកម្មាធិការជាតិអូឡាំពិក និងអង្គការពហុកីឡាអន្តរជាតិដទៃទៀត ដែលមានតួនាទីជាស្ថាប័នគ្រប់គ្រងព្រឹត្តិការណ៍ប្រកួតកីឡាប្រចាំទ្វីប តំបន់ ឬព្រឹត្តិការណ៍កីឡាអន្តរជាតិ ផ្សេងទៀត។

**សារធាតុបិទបាំង៖** ជាសមាសធាតុ ក្រុមនៃសមាសធាតុ ឬកត្តាជីវសាស្ត្រដែលបង្ហាញពីការប្រើប្រាស់សារធាតុហាមឃាត់ ឬវិធីសាស្ត្រហាមឃាត់។

**សារធាតុមេតាប៉ូលីស៖** សារធាតុណាមួយដែលផលិតដោយដំណើរការផ្លាស់ប្តូរជីវសាស្ត្រ។

**កម្រិតនៃការរាយការណ៍អប្បបរមា៖** កំហាប់ប៉ាន់ស្មាននៃសារធាតុហាមឃាត់ ឬសារធាតុមេតាប៉ូលីស ឬសារធាតុបិទបាំងនៅក្នុងសំណាកក្រោមកម្រិត ដែលមន្ទីរពិសោធន៍ដែលទទួលស្គាល់ដោយទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក មិនគួររាយការណ៍ថាសំណាកនោះមានលទ្ធផលវិភាគវិជ្ជមានទេ។

**អនិតិជន៖** ជាបុគ្គលណាម្នាក់ ដែលមិនទាន់ឈានដល់អាយុ ១៨(ដប់ប្រាំបី)ឆ្នាំ។

| | |
|---|---|
| អង្គការប្រឆាំងដូប៉ា៖ | ជាអង្គភាពដែលត្រូវបានកំណត់ដោយប្រទេសនីមួយៗថា ជាស្ថាប័នមានសិទ្ធិអំណាច និងទំនួលខុសត្រូវចម្បងក្នុងការអនុម័ត និងអនុវត្តវិធានប្រឆាំងដូប៉ា ដឹកនាំការប្រមូលសំណាក ការដោះស្រាយវិវាទដូប៉ា និងការប្រព្រឹត្តទៅនូវសវនាការកម្រិតជាតិ។ ប្រសិនបើការកំណត់នេះមិនត្រូវបានធ្វើឡើងដោយអាជ្ញាធរសាធារណៈដែលមានសមត្ថកិច្ចទេ អង្គភាពនេះនឹងត្រូវជាគណៈកម្មាធិការជាតិអូឡាំពិករបស់ប្រទេស ឬស្ថាប័នដែលគណៈកម្មាធិការនេះចាត់តាំង។ នៅប្រទេសកម្ពុជា អង្គការជាតិប្រឆាំងដូប៉ា គឺគណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជា។ |
| ព្រឹត្តិការណ៍កីឡាជាតិ ៖ | ព្រឹត្តិការណ៍កីឡា ឬការប្រកួតណាមួយ ដែលពាក់ព័ន្ធនឹង អត្តពលិកកម្រិតអន្តរជាតិ ឬកម្រិតជាតិ ដែលមិនមែនជាព្រឹត្តិការណ៍កីឡាអន្តរជាតិ ។ |
| សហព័ន្ធកីឡាជាតិ៖ | អង្គភាពជាតិ ឬតំបន់ណាមួយនៅក្នុងប្រទេសកម្ពុជាដែលជាសមាជិក ឬត្រូវបានទទួលស្គាល់ដោយសហព័ន្ធកីឡាអន្តរជាតិថា ជាអង្គភាពគ្រប់គ្រងកីឡារបស់សហព័ន្ធកីឡាអន្តរជាតិនៅក្នុងប្រទេស ឬតំបន់ ។ |
| អត្តពលិកកម្រិតជាតិ៖ | អត្តពលិក ដែលចូលរួមប្រកួតកីឡានៅថ្នាក់ជាតិ ដូចដែលបានកំណត់ដោយស្ថាប័នប្រឆាំងដូប៉ាជាតិនីមួយៗ ស្របតាមស្តង់ដារអន្តរជាតិស្តីពីការធ្វើតេស្ត និងស៊ើបអង្កេត។ នៅប្រទេសកម្ពុជា អត្តពលិកកម្រិតជាតិ ត្រូវបានកំណត់ដូចមានចែងនៅក្នុងសេចក្តីណែនាំអំពីវិធានប្រឆាំងដូប៉ា (ផ្នែកស្តីពីវិសាលភាព នៃវិធានប្រឆាំងដូប៉ា )។ |
| គណៈកម្មាធិការជាតិអូឡាំពិក៖ | អង្គការដែលទទួលស្គាល់ដោយគណៈកម្មាធិការអូឡាំពិកអន្តរជាតិ។ ពាក្យថា គណៈកម្មាធិការជាតិអូឡាំពិក ក៏ត្រូវបញ្ចូលសហព័ន្ធកីឡាជាតិនៅក្នុងប្រទេសទាំងនោះ ដែលសហព័ន្ធកីឡាជាតិត្រូវអនុវត្តការទទួលខុសត្រូវធម្មតារបស់គណៈកម្មាធិការជាតិអូឡាំពិក ក្នុងកិច្ចការប្រឆាំងដូប៉ា។ នៅប្រទេសកម្ពុជា គណៈកម្មាធិការជាតិអូឡាំពិក គឺគណៈកម្មាធិការជាតិអូឡាំពិកកម្ពុជា។ |
| គ្មានកំហុស ឬការធ្វេសប្រហែស ៖ | អត្តពលិក ឬបុគ្គលផ្សេងទៀតដែលបាន បង្ហាញថា ខ្លួនមិនបានដឹង ឬសង្ស័យ ហើយក្នុងហេតុផលសមស្រប មិនអាចដឹង ឬសង្ស័យ ទោះដោយការប្រុងប្រយ័ត្នខ្ពស់បំផុតក៏ដោយ ថាខ្លួនបានប្រើប្រាស់ ឬត្រូវបានផ្តល់ឱ្យសារធាតុហាមឃាត់ ឬវិធីសាស្ត្រហាមឃាត់ ឬមិនបានដឹងថាបានបំពានលើវិធានប្រឆាំងដូប៉ា។ លើកលែងតែក្នុងករណីបុគ្គលដែលត្រូវបានការពារ ឬអត្តពលិកកម្សាន្ត ចំពោះការបំពានលើប្រការ ២.១ អត្តពលិក ក៏ត្រូវបង្ហាញផងដែរនូវរបៀបដែលសារធាតុហាមឃាត់ចូលក្នុងប្រព័ន្ធរាងកាយរបស់អត្តពលិកនោះ។ |
| គ្មានកំហុសធ្ងន់ធ្ងរ ឬការធ្វេសប្រហែស៖ | អត្តពលិក ឬ បុគ្គលផ្សេងទៀតដែលបានបង្ហាញថាកំហុស ឬការធ្វេសប្រហែស នៅពេលពិនិត្យមើលជារួមនៃកាលៈទេសៈ ហើយពិចារណាលើលក្ខណៈវិនិច្ឆ័យសម្រាប់ភាពគ្មានកំហុសធ្ងន់ធ្ងរ ឬការធ្វេសប្រហែសនោះ មិនធ្ងន់ធ្ងរទាក់ទងទៅនឹងការបំពានវិធានប្រឆាំងដូប៉ា។ លើកលែងតែក្នុងករណីបុគ្គលដែលត្រូវបានការពារ ឬអត្តពលិកកម្សាន្ត ចំពោះការបំពានលើប្រការ ២.១ អត្តពលិកក៏ត្រូវបង្ហាញផងដែរនូវរបៀបដែលសារធាតុហាមឃាត់ ចូលក្នុងប្រព័ន្ធរាងកាយរបស់អត្តពលិក |

នោះ។

ឯករាជ្យភាពផ្នែកប្រតិបត្តិការ៖ មានន័យថា (១) សមាជិកក្រុមប្រឹក្សាភិបាល បុគ្គលិក សមាជិកគណៈកម្មការទីប្រឹក្សា និងមន្ត្រីនៃអង្គការប្រឆាំងដូប៉ា ដែលមានទំនួលខុសត្រូវក្នុងការដោះស្រាយវិវាទដូប៉ា ឬស្ថាប័នបុត្រសម្ព័ន្ធរបស់ខ្លួន (ឧទាហរណ៍៖សហព័ន្ធ ឬសហភាពដែលជាសមាជិក) ក៏ដូចជាបុគ្គលដែលពាក់ព័ន្ធនៅក្នុងការស៊ើបអង្កេត និងក្នុងការធ្វើបុរេវិនិច្ឆ័យលើបញ្ហានោះ មិនអាចត្រូវបានតែងតាំងជាសមាជិក និង/ឬស្មៀន (ក្នុងករណីដែលស្មៀនបែបនេះពាក់ព័ន្ធនឹងដំណើរការពិចារណា និង/ឬការព្រាងសេចក្តីសម្រេចណាមួយ) នៃក្រុមប្រឹក្សាជំនុំជម្រះរបស់ អង្គការប្រឆាំងដូប៉ា ការទទួលខុសត្រូវចំពោះការដោះស្រាយវិវាទដូប៉ា និង(២)ក្រុមប្រឹក្សាជំនុំជម្រះគឺជាស្ថាប័នមានមូលដ្ឋានសមស្របក្នុងការដំណើរការសវនាការ និងការធ្វើសេចក្តីសម្រេចដោយគ្មានការជ្រៀតជ្រែកពីអង្គការប្រឆាំងដូប៉ា ឬភាគីទីពណាមួយឡើយ។ គោលបំណងគឺដើម្បីធានាថាសមាជិកនៃក្រុមប្រឹក្សាជំនុំជម្រះ ឬបុគ្គលនានាដែលពាក់ព័ន្ធនឹងសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាជំនុំជម្រះមិនចូលរួមក្នុងការស៊ើបអង្កេត ឬការធ្វើសេចក្តីសម្រេចក្នុងការបន្តរឿងក្តីទេ។

ក្រៅការប្រកួត៖ រយៈពេលណាមួយដែលមិនមែននៅក្នុងការប្រកួត។

អ្នកចូលរួម៖ អត្តពលិក ឬអ្នកគាំពារអត្តពលិក ។

បុគ្គល៖ ជារូបវន្តបុគ្គល ឬអង្គការណាមួយ ឬអង្គភាពផ្សេងទៀត។

ការកាន់កាប់៖ ការកាន់កាប់ជាក់ស្តែង និងជារូបវន្ត ឬការកាន់កាប់ជាក់ស្តែងតែមិនជារូបវន្ត (ដែលនឹងត្រូវបានរកឃើញតែក្នុងករណី ដែលបុគ្គលនោះមានការគ្រប់គ្រងផ្តាច់មុខ ឬមានបំណងគ្រប់គ្រងលើសារធាតុហាមឃាត់ ឬវិធីសាស្ត្រហាមឃាត់ ឬបរិវេណដែលមានសារធាតុហាមឃាត់ ឬវិធីសាស្ត្រហាមឃាត់) ក្នុងលក្ខខណ្ឌដែលថាប្រសិនបើបុគ្គលនោះ មិនមានការគ្រប់គ្រងផ្តាច់មុខលើសារធាតុហាមឃាត់ ឬវិធីសាស្ត្រហាមឃាត់ ឬបរិវេណដែលមានសារធាតុហាមឃាត់ ឬវិធីសាស្ត្រហាមឃាត់នោះទេ ការកាន់កាប់ជាក់ស្តែងតែមិនជារូបវន្ត អាចត្រូវបានរកឃើញ លុះត្រាតែបុគ្គលនោះបានដឹងអំពីវត្តមាននៃសារធាតុហាមឃាត់ ឬវិធីសាស្ត្រហាមឃាត់ និងមានបំណងធ្វើការគ្រប់គ្រងលើវា។ ក្នុងលក្ខខណ្ឌដែលថា គ្មានការបំពានវិធានប្រឆាំងដូប៉ាណាមួយ ដែលផ្អែកលើតែការកាន់កាប់មួយមុខនោះទេ ប្រសិនបើមុនពេលទទួលបានការជូនដំណឹងអំពីការប្រព្រឹត្តបំពានវិធានប្រឆាំងដូប៉ាប្រភេទណាមួយ បុគ្គលនោះបានចាត់វិធានការជាក់ស្តែងដែលបង្ហាញថាបុគ្គលនោះ មិនដែលមានបំណងកាន់កាប់ និងបានប្រកាសបោះបង់ការកាន់កាប់នោះច្បាស់លាស់ទៅអង្គការប្រឆាំងដូប៉ា។ ទោះជាមានអ្វីផ្ទុយពីនិយមន័យនេះក៏ដោយការទិញ (រួមបញ្ចូលទាំងតាមមធ្យោបាយអេឡិចត្រូនិក ឬមធ្យោបាយផ្សេងទៀត) នៃសារធាតុហាមឃាត់ ឬវិធីសាស្ត្រហាមឃាត់ ត្រូវបានចាត់ទុកថាជាការកាន់កាប់ របស់បុគ្គលដែលធ្វើការទិញនោះ។

បញ្ជីហាមឃាត់ ៖ បញ្ជីដែលសម្គាល់នូវសារធាតុហាមឃាត់ និង វិធីសាស្ត្រហាមឃាត់ ។

| | |
|---|---|
| វិធីសាស្ត្រហាមឃាត់៖ | វិធីសាស្ត្រណាមួយដែលត្រូវបានពិពណ៌នានៅក្នុងបញ្ជីហាមឃាត់ ។ |
| សារធាតុហាមឃាត់៖ | សារធាតុណាមួយ ឬប្រភេទណាមួយនៃសារធាតុដែលត្រូវបានពិពណ៌នានៅក្នុងបញ្ជីហាមឃាត់ ។ |
| បុគ្គលដែលត្រូវបានការពារ៖ | អត្តពលិក ឬបន្តបុគ្គលផ្សេងទៀតដែលនៅពេលមានការបំពានវិធានប្រឆាំងដូប៉ាៈ (i) មិនទាន់ដល់អាយុ ១៦ (ដប់ប្រាំមួយ) ឆ្នាំ (ii) មិនទាន់ដល់អាយុ ១៨(ដប់ប្រាំបី)ឆ្នាំ និងមិនត្រូវបានដាក់បញ្ចូលនៅក្នុង បញ្ជីធ្វើតេស្តណាមួយ ហើយមិនដែលចូលរួមប្រកួតក្នុង ព្រឹត្តិការណ៍កីឡាអន្តរជាតិ នៅក្នុងប្រភេទកីឡាបើកចំហ ឬ (iii) សម្រាប់ហេតុផលផ្សេងក្រៅពីអាយុ ត្រូវបានកំណត់ថាខ្វះសមត្ថភាពផ្នែកច្បាប់ ក្រោមច្បាប់ជាតិជាធរមាន។ |
| សវនាការបណ្តោះអាសន្ន៖ | សម្រាប់គោលបំណងនៃប្រការ ៧.៤.៣ សវនាការបន្ទាន់ដែលធ្វើឡើងមុនពេលបើកសវនការ ក្រោមប្រការ ៨ ដែលផ្តល់ការ ជូនដំណឹងដល់អត្តពលិក និងឱកាសសម្រាប់ផ្តល់ហេតុផល ទាំងក្នុងទម្រង់ជាលាយលក្ខណ៍អក្សរ ឬផ្ទាល់មាត់។ |
| ការព្យួរសិទ្ធិបណ្តោះអាសន្ន៖ | សូមមើលទណ្ឌកម្មនៃការបំពានវិធានប្រឆាំងដូប៉ាខាងលើ។ |
| បង្ហាញជាសាធារណៈ៖ | សូមមើលទណ្ឌកម្មចំពោះការបំពានវិធានប្រឆាំងដូប៉ាខាងលើ។ |
| អត្តពលិកកម្សាន្ត៖ | នៅប្រទេសកម្ពុជាអត្តពលិកកំសាន្តត្រូវបានកំណត់និយមន័យ ដូចមានចែងនៅក្នុងសេចក្តីណែនាំអំពីវិធានប្រឆាំងដូប៉ា (ផ្នែកស្តីពីវិសាលភាពនៃវិធានប្រឆាំងដូប៉ា)។ |
| អង្គភាពប្រឆាំងដូប៉ាប្រចាំតំបន់៖ | អង្គភាពប្រចាំតំបន់ដែលកំណត់ ដោយប្រទេសជាសមាជិកដើម្បីឱ្យសម្របសម្រួល និងគ្រប់គ្រងតំបន់ជាក់លាក់នៃសិទ្ធិនៃកម្មវិធីប្រឆាំងដូប៉ាជាតិរបស់ពួកគេ ដែលអាចរាប់បញ្ចូលទាំងការអនុម័ត និងការអនុវត្តវិធានប្រឆាំងដូប៉ា ការធ្វើផែនការ និងការប្រមូលសំណាក ការដោះស្រាយវិវាទដូប៉ា ការពិនិត្យឡើងវិញនៃការលើកលែងឱ្យប្រើប្រាស់ថ្នាំព្យាបាល ការធ្វើសវនាការ និងការអនុវត្តកម្មវិធីអប់រំ នៅថ្នាក់តំបន់។ |
| បញ្ជីឈ្មោះធ្វើតេស្ត៖ | បញ្ជីឈ្មោះអត្តពលិកដែលមានអាទិភាពខ្ពស់បំផុត ត្រូវបានបង្កើតឡើងដាច់ដោយឡែកនៅកម្រិតអន្តរជាតិដោយសហព័ន្ធកីឡាអន្តរជាតិ និងនៅថ្នាក់ជាតិដោយអង្គការជាតិប្រឆាំងដូប៉ា ដែលជាកម្មវត្ថុនៃការធ្វើតេស្តក្នុងការប្រកួត និងក្រៅការប្រកួតជាក់លាក់ ដែលជាផ្នែកមួយនៃផែនការបែងចែកការធ្វើតេស្ត របស់សហព័ន្ធកីឡាអន្តរជាតិ ឬអង្គការប្រឆាំងដូប៉ា ដូច្នេះហើយចាំបាច់ត្រូវផ្តល់ព័ត៌មានអំពីទីសំចត ដូចដែលមានចែងក្នុងប្រការ ៥.៥ នៃក្រម និងស្តង់ដារអន្តរជាតិស្តីពីការធ្វើតេស្ត និងស៊ើបអង្កេត។ នៅប្រទេសកម្ពុជា បញ្ជីឈ្មោះធ្វើតេស្តរបស់គណៈកម្មាធិការប្រឆាំងដូប៉ាកម្ពុជាត្រូវបានកំណត់ ដូចមានចែងក្នុងប្រការ ៥.៥ នៃវិធានប្រឆាំងដូប៉ា។ |
| ការដោះស្រាយវិវាទដូប៉ា៖ | ដំណើរការដែលរួមបញ្ចូលទាំងរយៈពេលកំណត់ ចាប់ពីការជូនដំណឹងដូចមានចែងក្នុងប្រការ ៥ នៃស្តង់ដារអន្តរជាតិស្តីពីការដោះស្រាយវិវាទដូប៉ា ឬក្នុងករណីជាក់លាក់ |

មួយចំនួន (ឧទាហរណ៍៖ លទ្ធផលមិនធម្មតា ប្រវត្តិជីវសាស្ត្រអត្តពលិក ការខកខានក្នុងការផ្តល់ព័ត៌មានអំពីទីសំចត) ជំហានមុនការជូនដំណឹងបែបនេះ ដូចដែលមានចែងក្នុងប្រការ ៥ នៃស្តង់ដារអន្តរជាតិស្តីពីការដោះស្រាយវិវាទដូប៉ា រហូតដល់ការចោទប្រកាន់ និង សេចក្តីសម្រេចចុងក្រោយលើករណីនោះ រួមទាំងការបញ្ចប់ដំណើរការសវនាការនៃរឿងក្តីដំបូង ឬបណ្តឹងជំទាស់ (ប្រសិនបើបណ្តឹងជំទាស់ត្រូវបានដាក់) ។

| | |
|---|---|
| សំណាក ឬគំរូ៖ | សម្ភារៈជីវៈសាស្ត្រណាមួយដែលត្រូវបានប្រមូលសម្រាប់គោលបំណងនៃការត្រួតពិនិត្យសារធាតុដូប៉ា ។ |
| ស្ថាប័នហត្ថលេខី៖ | អង្គភាពទាំងឡាយដែលទទួលយកក្រមនេះ ហើយយល់ព្រមអនុវត្តក្រម ដូចមានចែងក្នុងប្រការ ២៣ នៃក្រម ។ |
| វិធីសាស្ត្រជាក់លាក់៖ | សូមមើលប្រការ ៤.២.២ ។ |
| សារធាតុជាក់លាក់៖ | សូមមើលប្រការ ៤.២.២ ។ |
| ការទទួលខុសត្រូវតឹងរឹង៖ | វិធានដែលចែងថានៅក្រោមប្រការ ២.១ និងប្រការ ២.២ វាមិនចាំបាច់ដែលថាចេតនា កំហុសការធ្វេសប្រហែស ឬការប្រើប្រាស់ដោយមានការយល់ដឹងរបស់អត្តពលិក ត្រូវបានបង្ហាញដោយអង្គការប្រឆាំងដូប៉ា ក្នុងគោលបំណងបង្កើតបទបំពានវិធានប្រឆាំងដូប៉ា។ |
| សារធាតុបំពាន៖ | សូមមើលប្រការ ៤.២.៣ ។ |
| ជំនួយសំខាន់៖ | សម្រាប់គោលបំណងនៃប្រការ ១០.៧.១ បុគ្គលដែលផ្តល់ជំនួយសំខាន់ ត្រូវតែ៖ (១) បង្ហាញពេញលេញនៅក្នុងសេចក្តីប្រកាសជាលាយលក្ខណ៍អក្សរ ដែលបានចុះហត្ថលេខា ឬការសម្ភាសន៍ដែលត្រូវបានថតទុក នូវរាល់ព័ត៌មានទាំងអស់ដែលគាត់មាន ទាក់ទងនឹងការបំពានវិធានប្រឆាំងដូប៉ា ឬដំណើរការផ្សេងទៀត ដូចមានចែងក្នុងប្រការ ១០.៧.១.១ និង (២) សហការពេញលេញជាមួយការស៊ើបអង្កេត និងការវិនិច្ឆ័យករណី ឬបញ្ហាណាមួយដែលពាក់ព័ន្ធនឹងព័ត៌មាននោះ រួមមានដូចជាការបង្ហាញសក្ខីកម្មនៅឯសវនាការ ប្រសិនបើមានការស្នើពីអង្គការប្រឆាំងដូប៉ា ឬក្រុមប្រឹក្សាជំនុំជម្រះ។ លើសពីនេះទៀត ព័ត៌មានដែលបានផ្តល់ត្រូវតែមានភាពអាចជឿទុកចិត្តបាន ហើយត្រូវតែមានផ្នែកសំខាន់នៃករណី ឬនីតិវិធីដែលត្រូវបានផ្តួចផ្តើម ឬបើគ្មានករណី ឬដំណើរការនីតិវិធីណាមួយដែលត្រូវបានផ្តួចផ្តើមឡើងទេ ត្រូវមានមូលដ្ឋានគ្រប់គ្រាន់ដែលអាចនាំឱ្យមានករណី ឬដំណើរការនីតិវិធីករណី។ |
| ការធ្វើឱ្យខូចដំណើរការ៖ | ការប្រព្រឹត្តដោយចេតនាដែលធ្វើឱ្យខូចដល់ដំណើរការ ត្រួតពិនិត្យសារធាតុដូប៉ា ប៉ុន្តែមិនត្រូវបានរាប់បញ្ចូលក្នុងនិយមន័យនៃវិធីសាស្ត្រហាមឃាត់។ ការធ្វើឱ្យខូចដំណើរការ រួមបញ្ចូលទាំងការផ្តល់ ឬទទួលសំណូកដើម្បីអនុវត្ត ឬមិនអនុវត្តសកម្មភាពណាមួយ ការរារាំងដល់ការប្រមូលសំណាក ការធ្វើឱ្យប៉ះពាល់ ឬធ្វើឱ្យមិនអាចវិភាគបាននូវសំណាក ការក្លែងបន្លំឯកសារដែលបានបញ្ជូនទៅអង្គការ |

ប្រឆាំងដូប៉ា ឬគណៈកម្មាធិការលើកលែងឱ្យប្រើប្រាស់ថ្នាំព្យាបាល ឬក្រុមប្រឹក្សាជំនុំជម្រះ ការផ្តល់សក្ខីកម្មមិនពិតពីសាក្សី ការប្រព្រឹត្តនូវការក្លែងបន្លំណាមួយលើអង្គការប្រឆាំងដូប៉ា ឬក្រុមប្រឹក្សាជំនុំជម្រះ ដើម្បីមានឥទ្ធិពលលើការដោះស្រាយវិវាទដូប៉ា ឬការដាក់ទណ្ឌកម្ម និងការជ្រៀតជ្រែកដោយចេតនា ឬការប៉ុនប៉ងជ្រៀតជ្រែកណាមួយដែលពាក់ព័ន្ធនឹងផ្នែកណាមួយនៃការត្រួតពិនិត្យដូប៉ា ។

ការធ្វើតេស្តគោលដៅ៖ ការជ្រើសរើសអត្តពលិកជាក់លាក់សម្រាប់ការធ្វើតេស្ត ដោយផ្អែកលើលក្ខណៈវិនិច្ឆ័យ ដូចដែលមានចែងក្នុងស្តង់ដារអន្តរជាតិស្តីពីការធ្វើតេស្ត និងការស៊ើបអង្កេត។

កីឡាជាក្រុម៖ កីឡាមួយដែលការជំនួសកីឡាករត្រូវបានអនុញ្ញាតក្នុងពេលប្រកួត ។

ឯកសារបច្ចេកទេស៖ ឯកសារណាមួយដែលត្រូវបានទទួលយកទៅអនុវត្ត និងផ្សព្វផ្សាយដោយទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោកនៅពេលណាមួយ ដែលមានលក្ខខណ្ឌតម្រូវបច្ចេកទេសចាំបាច់លើប្រធានបទប្រឆាំងដូប៉ាជាក់លាក់ ដូចមានចែងក្នុងស្តង់ដារអន្តរជាតិ។

ការធ្វើតេស្ត៖ ផ្នែកខ្លះនៃដំណើរការត្រួតពិនិត្យសារធាតុដូប៉ារួមមានផែនការបែងចែកការធ្វើតេស្ត ការប្រមូលសំណាក ការគ្រប់គ្រងសំណាក និងការដឹកជញ្ជូនសំណាកទៅមន្ទីរពិសោធន៍ជាដើម។

ការលើកលែងឱ្យប្រើជាប្រាស់ថ្នាំព្យាបាល (TUE)៖ ការលើកលែងឱ្យប្រើប្រាស់ថ្នាំព្យាបាល អនុញ្ញាតឱ្យអត្តពលិក ដែលមានលក្ខខណ្ឌវេជ្ជសាស្ត្រជាក់លាក់ ប្រើសារធាតុហាមឃាត់ ឬវិធីសាស្ត្រហាមឃាត់ ប៉ុន្តែលុះត្រាតែលក្ខខណ្ឌ ដូចដែលមានចែងក្នុងប្រការ ៤.៤ និង ស្តង់ដារអន្តរជាតិស្តីពីការលើកលែងការប្រើប្រាស់ថ្នាំព្យាបាល ត្រូវបានបំពេញប៉ុណ្ណោះ។

ការជួញដូរ៖ ការលក់ ការផ្តល់ឱ្យ ការដឹកជញ្ជូន ការផ្ញើ ការប្រគល់ ឬការចែកចាយ (ឬការកាន់កាប់សម្រាប់គោលបំណងបែបនោះ) នូវសារធាតុហាមឃាត់ ឬវិធីសាស្ត្រហាមឃាត់ (ទាំងតាមមធ្យោបាយផ្ទាល់ ឬតាមមធ្យោបាយអេឡិចត្រូនិក ឬមធ្យោបាយណាមួយផ្សេងទៀត) ដោយអត្តពលិក បុគ្គលិកគាំទ្រអត្តពលិក ឬបុគ្គលផ្សេងទៀតដែលស្ថិតក្រោមសិទ្ធិអំណាចរបស់អង្គភាពប្រឆាំងដូប៉ា ទៅឱ្យភាគីទីពណាមួយក្នុងលក្ខខណ្ឌដែលថានិយមន័យនេះ មិនត្រូវរាប់បញ្ចូលសកម្មភាពរបស់បុគ្គលិកវេជ្ជសាស្ត្រដែលប្រើប្រាស់សារធាតុហាមឃាត់ សម្រាប់គោលបំណងព្យាបាលពិតប្រាកដ និងស្របច្បាប់ ឬយុត្តិកម្មផ្សេងទៀតដែលអាចទទួលយកបាន និងមិនរាប់បញ្ចូលសកម្មភាពដែលពាក់ព័ន្ធនឹងសារធាតុហាមឃាត់ ដែលមិនត្រូវបានហាមឃាត់នៅក្នុងការធ្វើតេស្តក្រៅការប្រកួតទេ លុះត្រាតែកាលៈទេសៈទាំងមូលបង្ហាញថាសារធាតុហាមឃាត់បែបនេះ មិនត្រូវបានបម្រុងទុកសម្រាប់គោលបំណងព្យាបាលពិតប្រាកដ និងស្របច្បាប់ ឬមានគោលបំណងដើម្បីបង្កើនសមត្ថភាពកីឡា។

អនុសញ្ញារបស់អង្គការយូណេស្កូ៖ អនុសញ្ញាអន្តរជាតិប្រឆាំងដូប៉ាក្នុងវិស័យកីឡា ដែលត្រូវបានអនុម័តនៅក្នុងសម័យប្រជុំលើកទី ៣៣ នៃសន្និសីទទូទៅរបស់អង្គការយូណេស្កូ នៅថ្ងៃទី ១៩ ខែតុលា ឆ្នាំ២០០៥ រួមទាំងវិសោធនកម្មណាមួយ និងទាំងអស់ដែលត្រូវបានអនុម័តដោយរដ្ឋភាគីនៃអនុសញ្ញានេះ និងសន្និសីទរបស់រដ្ឋភាគីនៃអនុសញ្ញាអន្តរជាតិប្រឆាំងដូប៉ាក្នុងវិស័យកីឡា។

| | |
|---|---|
| ការប្រើប្រាស់៖ | ការប្រើប្រាស់ ការអនុវត្ត ការលេបចូល ការចាក់បញ្ចូល ឬការស្រូបចូលដោយប្រើមធ្យោបាយណាមួយ នៃសារធាតុហាមឃាត់ ឬវិធីសាស្ត្រហាមឃាត់ ។ |
| ទីភ្នាក់ងារប្រឆាំងដូប៉ាពិភពលោក៖ | ស្ថាប័នប្រឆាំងដូប៉ាពិភពលោក។ |
| កិច្ចព្រមព្រៀងរក្សាសិទ្ធិភាគី ៖ | សម្រាប់គោលបំណងនៃប្រការ ១០.៧.១.១ និងប្រការ ១០.៨.២ កិច្ចព្រមព្រៀងជាលាយលក្ខណ៍អក្សររវាង អង្គការប្រឆាំងដូប៉ា និងអត្តពលិក ឬបុគ្គលផ្សេងទៀតដែលអនុញ្ញាតឱ្យអត្តពលិក ឬបុគ្គលផ្សេងទៀតផ្តល់ព័ត៌មានដល់អង្គការប្រឆាំងដូប៉ា ក្នុងរយៈពេលកំណត់ច្បាស់លាស់ ជាមួយនឹងការយល់ដឹងថា ប្រសិនបើកិច្ចព្រមព្រៀងស្តីពីជំនួយសំខាន់ ឬកិច្ចព្រមព្រៀងដំណោះស្រាយរឿងក្តីមិនត្រូវបានបញ្ចប់ទេនោះ ព័ត៌មានដែលផ្តល់ដោយអត្តពលិក ឬបុគ្គលផ្សេងទៀតនៅក្នុងបរិបទជាក់លាក់នេះ មិនអាចត្រូវបានប្រើប្រាស់ដោយ អង្គការប្រឆាំងដូប៉ា ប្រឆាំងនឹងអត្តពលិក ឬបុគ្គលផ្សេងទៀតឡើយ នៅក្នុងការដោះស្រាយវិវាទដូប៉ា ណាមួយដែលស្ថិតក្រោមក្រមនេះ ហើយព័ត៌មានដែលផ្តល់ដោយ អង្គការប្រឆាំងដូប៉ា ក្នុងបរិបទជាក់លាក់នេះមិនអាចត្រូវបានប្រើដោយអត្តពលិក ឬបុគ្គលផ្សេងទៀតប្រឆាំងនឹងអង្គការប្រឆាំងដូប៉ា នៅក្នុងនីតិវិធីដោះស្រាយវិវាទដូប៉ាណាមួយឡើយនៅក្រោមក្រមនេះ។ កិច្ចព្រមព្រៀងបែបនេះមិនត្រូវហាមឃាត់អង្គភាពប្រឆាំងដូប៉ា អត្តពលិក ឬបុគ្គលផ្សេងទៀតពី ការប្រើប្រាស់ព័ត៌មាន ឬភស្តុតាងដែលប្រមូលបានពីប្រភពណាមួយ ក្រៅពីក្នុងកំឡុងពេលជាក់លាក់ដែលបានកំណត់ក្នុងកិច្ចព្រមព្រៀងឡើយ។ |